# រាជរដ្ឋាភិបាលកម្ពុជា

## គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

# ផែនការអនុវត្ត
# រយៈពេលប្រាំឆ្នាំ ដំណាក់កាលទី២ (២០២៦ - ២០៣០)
# នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ
# នៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី២ (២០២១ - ២០៣០)

ឆ្នាំ២០២៦

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ទីស្តីការគណៈរដ្ឋមន្ត្រី**
លេខ: ៣៣៤ សជណ.មឃ

ថ្ងៃ ចន្ទ ៦រោច ខែផល្គុន ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ៩ ខែមីនា ឆ្នាំ២០២៦

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**សូមជម្រាបជូន**
**ឯកឧត្តមអភិសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន**
**គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ**

**កម្មវត្ថុ** ៖ ករណីគោរពរាយការណ៍អំពីវឌ្ឍនភាពនៃការអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងស្នើសុំពិនិត្យនិងសម្រេចលើផែនការអនុវត្ត៥ឆ្នាំ ដំណាក់កាលទី២ (២០២៦-២០៣០) នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

**យោង** ៖- លិខិតលេខ០២៣ របក/គ.ជ.អ.ប. ចុះថ្ងៃទី២ ខែមីនា ឆ្នាំ២០២៦ របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- លិខិតលេខ០២៣ ខន/០២៦ សជណ ចុះថ្ងៃទី៤ ខែមីនា ឆ្នាំ២០២៦ របស់ខុទ្ទកាល័យសម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ចំណារដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០២៦។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រីសូមជម្រាបជូនឯកឧត្តមអភិសន្តិបណ្ឌិតមេត្តាជ្រាបថា រាជរដ្ឋាភិបាលឯកភាពលើរបាយការណ៍អំពីវឌ្ឍនភាពនៃការអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ និងផែនការអនុវត្តរយៈពេល៥ឆ្នាំ ដំណាក់កាលទី២ (២០២៦-២០៣០) នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី២ (២០២១-២០៣០)។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមអភិសន្តិបណ្ឌិតមេត្តាជ្រាបនិងចាត់ចែងអនុវត្ត។

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ**

**កែន សត្ថា**

**ចម្លងជូន៖**
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
- រដ្ឋបាលរាជធានី ខេត្ត
- ឯកសារ កាលប្បវត្តិ

# អារម្ភកថា

ផែនការអនុវត្ត៥ឆ្នាំដំណាក់កាលទី២ (**ផអ៥ទី២**) គឺជាផែនការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដំណាក់កាលទី២ (**កជទី២**) ពីឆ្នាំ២០២៦ ដល់ឆ្នាំ២០៣០ បន្ទាប់ពីផែនការអនុវត្តរយៈពេល៥ឆ្នាំដំណាក់កាលទី១ (**ផអ៥ទី១**) ត្រូវបានអនុវត្តបញ្ចប់ដោយជោគជ័យពីឆ្នាំ២០២១ដល់ឆ្នាំ២០២៥។ **ផអ៥ទី២** នេះបានរៀបចំឡើងដោយផ្អែកតាមផែនទីតម្រង់ទិសនៃ**កជទី២** និងផ្អែកលើសមិទ្ធផលដែលសម្រេចបាន និងបញ្ហាប្រឈមជាគន្លឹះដែលបានជួបប្រទះក្នុងអំឡុងពេលនៃការអនុវត្ត **ផអ៥ទី១** ព្រមទាំងផ្អែកតាមកម្មវិធីនយោបាយ យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ វិធានការណ៍គន្លឹះជាអាទិភាព គោលនយោបាយ និងយុទ្ធសាស្ត្រថ្មីៗដែលបានដាក់ចេញដោយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរាជរដ្ឋាភិបាលអាណត្តិទី៧នៃរដ្ឋសភា។

ផែនការអនុវត្ត៥ឆ្នាំដំណាក់កាលទី២ ត្រូវបានដំណើរការរៀបចំដោយមានការសិក្សាស្រាវជ្រាវ វាយតម្លៃ ពិនិត្យ ពិភាក្សា និងពិគ្រោះយោបល់ជាច្រើនលើកច្រើនសារទាំងក្នុងកម្រិតក្រុមការងារបច្ចេកទេស សិក្ខាសាលាពិគ្រោះយោបល់យ៉ាងទំលំទូលាយជាមួយតំណាងក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានា ព្រមទាំងបានពិភាក្សាពិគ្រោះយោបល់ជាមួយថ្នាក់ដឹកនាំនៃកម្មវិធីកំណែទម្រង់គន្លឹះ ដើម្បីប្រមូលធាតុចូល ការគាំទ្រផ្នែកនយោបាយ និងអនុសាសន៍ទម្រង់ទិសលើសកម្មភាពជាអាទិភាពចាំបាច់នានា និងបានដាក់ឆ្លងការពិនិត្យ ពិភាក្សា និងទទួលបានការឯកភាពក្នុងកិច្ចប្រជុំលើកទី២៥របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.) នាថ្ងៃទី២៧ ខែមករា ឆ្នាំ២០២៦។ **ផអ៥ទី២** ក៏ត្រូវបានគោរពដាក់ជូន**សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី** ពិនិត្យ សម្រេច នាថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២៦។

**ផែនការអនុវត្ត៥ឆ្នាំដំណាក់កាលទី២** បានកំណត់សកម្មភាពជាអាទិភាពដែលក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរួមគ្នាពង្រឹងភាពម្ចាស់ការ និងការទទួលខុសត្រូវលើការជំរុញ និងពង្រឹងការអនុវត្ត ដើម្បីធានាឱ្យសម្រេចបាននូវចក្ខុវិស័យ គោលបំណង គោលដៅ សមិទ្ធផលរំពឹងទុកដែលបានកំណត់ក្នុងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដំណាក់កាលទី២ សំដៅចូលរួមចំណែកសម្រេចនូវគោលបំណងនៃយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១របស់រាជរដ្ឋាភិបាលអាណត្តិទី៧ នៃរដ្ឋសភា។

ក្នុងនាម គ.ជ.អ.ប. ខ្ញុំសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះមគ្គុទេសក៍ដឹកនាំ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រី** និងការបន្តដឹកនាំរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលបានផ្តល់នូវគោលការណ៍ដឹកនាំ និងតម្រង់ទិសជាប្រចាំអំពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន ឆ្លើយតបទៅនឹងតម្រូវការជាអាទិភាព

នានានៅមូលដ្ឋាន និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ ជាមួយគ្នានេះ ខ្ញុំសូមគោរពថ្លែងអំណរគុណចំពោះ **សម្តេចក្រឡាហោម ស ខេង អតីតឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប.** ដែលបានដឹកនាំសម្របសម្រួល អនុវត្តកំណែទម្រង់ទម្រង់វិមជ្ឈការ និងវិសហមជ្ឈការឱ្យមានដំណើរការទៅប្រកបដោយលទ្ធផលជាវិជ្ជមានជាច្រើនស្របតាមគោលនយោបាយកំណែទម្រង់ច្បាប់រៀបចំអង្គការ និងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិរបស់រាជរដ្ឋាភិបាល។

ក្នុងនាមរាជរដ្ឋាភិបាល និងក្នុងនាម គ.ជ.អ.ប. ខ្ញុំសូមថ្លែងអំណរគុណ និងវាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល វិស័យឯកជន និងសាធារណៈជនដែលបានផ្តល់ការគាំទ្រ និងចូលរួមអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការតាមដំណាក់កាលនីមួយៗ ក្នុងរយៈពេលកន្លងមកឱ្យសម្រេចលទ្ធផលប្រកបដោយផ្លែផ្កា និងមានការវិវឌ្ឍកាន់តែស៊ីជម្រៅរហូតមកដល់ពេលនេះ។

ខ្ញុំសង្ឃឹមជឿជាក់យ៉ាងមុតមាំថា ថ្នាក់ដឹកនាំ មន្ត្រីរាជការនៃក្រសួង ស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល វិស័យឯកជន និងសាធារណជននឹងបន្តសហការគ្នាផ្តល់ការគាំទ្រ និងចូលរួមកាន់តែសកម្មបន្ថែមទៀតក្នុងការអនុវត្ត "**ផែនការអនុវត្ត៥ឆ្នាំដំណាក់កាលទី២**" នេះឱ្យទទួលបានជោគជ័យថ្មីៗបន្ថែមទៀត ដើម្បីឧត្តមប្រយោជន៍ជាតិ និងប្រជាជនកម្ពុជាគ្រប់រូប។

*ថ្ងៃ អង្គារ ១៤កើត ខែ ផល្គុន ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩*

*រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ២០២៦*

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**និងជាប្រធាន គ.ជ.អ.ប.**

**អភិសន្តិបណ្ឌិត ស សុខា**

# មាតិកា


អារម្ភកថា .......... i

មាតិកា .......... iii

ជំពូកទី១  ទិដ្ឋភាពទូទៅ .......... 1

១. សេចក្តីផ្តើម .......... 1

២. ចក្ខុវិស័យ គោលបំណង គោលដៅនៃ ផអ៥ទី២ .......... 7

២.១. ចក្ខុវិស័យ .......... 7

២.២. គោលបំណង .......... 7

២.៣. គោលដៅ .......... 7

៣. សមាសភាគ និងលទ្ធផលរំពឹងទុក .......... 8

៤. យុទ្ធសាស្ត្រនៃការអនុវត្ត .......... 16

ជំពូកទី២  សមាសភាគនានានៃផែនការអនុវត្តរយៈពេលប្រាំឆ្នាំ ដំណាក់កាលទី២ .......... 18

១. សមាសភាគទី១៖ ការដឹកនាំ និងការសម្របសម្រួលការងារកំណែទម្រង់ .......... 20

១.១. សនិទានភាព .......... 20

១.២. សមិទ្ធផលរំពឹងទុក .......... 21

១.៣. លទ្ធផលរំពឹងទុក .......... 21

២. សមាសភាគទី២៖ រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ .......... 42

២.១. សនិទានភាព .......... 42

២.១. សមិទ្ធផលរំពឹងទុក .......... 44

២.៣. លទ្ធផលរំពឹងទុកនៃ ផអ៥ទី២ .......... 44

៣. សមាសភាគទី៣៖ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស .......... 64

៣.១. សនិទានភាព .......... 64

៣.២. សមិទ្ធផលរំពឹងទុក .......... 65

៣.៣. លទ្ធផលរំពឹងទុកនៃ ផអ៥ទី២ .......... 66

៤. សមាសភាគទី៤៖ វិមជ្ឈការហិរញ្ញវត្ថុ និងប្រព័ន្ធផែនការនិងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ .......... 88

៤.១. សនិទានភាព .......... 88

៤.២. សមិទ្ធផលរំពឹងទុក .......... 90

៤.៣. លទ្ធផលរំពឹងទុក ....................................................................................................90
៥ សមាសភាគទី៥÷ ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន ...................................119
៥.១. សនិទានភាព ..........................................................................................................119
៥.២. សមិទ្ធផលរំពឹងទុក ..................................................................................................119
៥.៣. លទ្ធផលរំពឹងទុក ....................................................................................................121
ជំពូកទី៣  ការគ្រប់គ្រង និងការអនុវត្ត ផអ៥ទី២...................................................................142
១. ក្របខ័ណ្ឌសម្រាប់ការគ្រប់គ្រង និងការអនុវត្ត.......................................................................142
២. ការត្រួតពិនិត្យ និងការវាយតម្លៃ ផអ៥ទី២..........................................................................143
២.១. ការត្រួតពិនិត្យ និងការរៀបចំរបាយការណ៍ការអនុវត្ត ផអ៥ទី២ ...........................................143
២.២. ការវាយតម្លៃនៃការអនុវត្ត ផអ៥ទី២ ...............................................................................144
២.៣.   ផែនការសកម្មភាព និងថវិកាសម្រាប់ការត្រួតពិនិត្យ និងវាយតម្លៃ.......................................146
៣. ការគ្រប់គ្រងហានិភ័យ ......................................................................................................146
ជំពូកទី៤ ផែនការចំណាយនៃផែនការអនុវត្តរយៈពេលប្រាំឆ្នាំ ដំណាក់កាលទី២ .......................153
៤.១. ការប៉ាន់ស្មានចំណាយសម្រាប់ ផអ៥ទី២...........................................................................153
៤.២. ការផ្តល់ហិរញ្ញប្បទានសម្រាប់ ផអ៥ទី២ ...........................................................................154
ជំពូកទី ៥  សេចក្តីសន្និដ្ឋាន ..............................................................................................156

# ជំពូកទី១
# និដ្ឋភាពទូទៅ

## ១. សេចក្តីផ្តើម

ផែនការអនុវត្តរយៈពេល៥ឆ្នាំដំណាក់កាលទី២ (ផអ៥ទី២) គឺជាផែនការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដំណាក់កាលទី២ (កជទី២) ពីឆ្នាំ២០២៦ដល់ឆ្នាំ២០៣០ បន្ទាប់ពីផែនការអនុវត្តរយៈពេល៥ឆ្នាំដំណាក់កាលទី១ (ផអ៥ទី១) ត្រូវបានអនុវត្តដោយជោគជ័យពីឆ្នាំ២០២១ដល់ឆ្នាំ២០២៥។ ផអ៥ទី២នេះ បានរៀបចំឡើងដោយផ្អែកលើសមិទ្ធផលនៃ ផអ៥ទី១ កម្មវិធីនយោបាយ យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ វិធានការគន្លឹះ និងផែនការយុទ្ធសាស្ត្រនានាដែលបានដាក់ឱ្យអនុវត្តដោយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា។

ក្នុងអំឡុងពេលនៃការអនុវត្ត ផអ៥ទី១ ពីឆ្នាំ២០២១ដល់ឆ្នាំ២០២៥ ទោះបីកម្ពុជាបានជួបវិបត្តិនៃការរីករាលដាលជំងឺកូវីដ-១៩ក៏ដោយ ក៏ក្រោមការដឹកនាំរបស់ គ.ជ.អ.ប. ដែលមានការចូលរួមពីក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងភាគីពាក់ព័ន្ធនានាបានជំរុញឱ្យការអនុវត្ត ផអ៥ទី១ ទទួលបានលទ្ធផលផ្លែផ្កាគួរជាទីមោទនៈ ដែលក្នុងនោះសកម្មភាពជាអាទិភាពចំនួន **៩០**ស្មើនឹង**៨០%** នៃសកម្មភាពជាអាទិភាពសរុបចំនួន**១១២** និងសូចនាករចំនួន**១២៧** ស្មើនឹង**៧៧%** នៃសូចនាករសរុបចំនួន**១៦៥**ត្រូវបានអនុវត្ត។ សមិទ្ធផលសំខាន់ៗដែលបានសម្រេចក្នុងអំឡុងពេលនៃ ផអ៥ទី១ រួមមានសង្ខេបដូចខាងក្រោម៖

ការដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ៖ គ.ជ.អ.ប. បានរៀបចំកិច្ចប្រជុំតាមការកំណត់ដើម្បីត្រួតពិនិត្យលើវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្តកម្មវិធីកំណែទម្រង់ ព្រមទាំងបានពិនិត្យពិភាក្សាលើឯកសារគោលនយោបាយ ច្បាប់ លិខិតបទដ្ឋានគតិយុត្តប្រមាណជាង២៥០ឯកសារដែលពាក់ព័ន្ធនឹងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ ក្រសួង ស្ថាប័ននៅថ្នាក់ជាតិចំនួន២២ និងរដ្ឋបាលថ្នាក់ក្រោមជាតិទូទាំងប្រទេសបានចូលរួមរៀបចំ និងអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ គ.ជ.អ.ប. ដែលជាផែនការអនុវត្តប្រចាំឆ្នាំនៃ ផអ៥ទី១ ដោយបានវិភាជថវិការបស់ស្ថាប័នសាមីនីមួយៗគាំទ្រដល់ការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំទាំងនេះដែលមានចំនួនសរុបជាមធ្យមពី **៥-៦ លានដុល្លារអាមេរិក**ក្នុងមួយឆ្នាំៗ។

ផ្អែកតាមគំនិតផ្តួចផ្តើម និងការណែនាំតម្រង់ទិសរបស់ **សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** គ.ជ.អ.ប. បានដឹកនាំរៀបចំវេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្រោមប្រធានបទ "**កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីចូលរួមសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០**" ប្រកបដោយជោគជ័យនាថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៥ ដោយមានអ្នកចូលរួមផ្ទាល់ប្រមាណ

**ជាង១.៤០០នាក់** និងអ្នកចូលរួមតាមប្រព័ន្ធអនឡាញប្រមាណជាង**១០.០០០នាក់**។ វេទិកានេះ គឺជាព្រឹត្តិការណ៍ដ៏សំខាន់មួយនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការដែលបានរៀបចំឡើងក្នុងបំណងរួមគ្នាវាយតម្លៃវឌ្ឍនភាព បញ្ហាប្រឈម និងតម្រង់ទិសផ្នែកគោលនយោបាយ ព្រមទាំងសម្រួចការរៀបចំ និងការអនុវត្តកំណែទម្រង់នេះឱ្យកាន់តែស៊ីជម្រៅ និងកាន់តែមានប្រសិទ្ធភាពក្នុងការចូលរួមចំណែកអនុវត្តកម្មវិធីនយោបាយ វិធានការគន្លឹះ និងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១របស់រាជរដ្ឋាភិបាលអាណត្តិទី៧។

លេខាធិការដ្ឋាន គ.ជ.អ.ប. បានដើរតួនាទីជាសេនាធិការជូន គ.ជ.អ.ប. យ៉ាងសកម្មក្នុងការដឹកនាំគ្រប់គ្រងការងារប្រចាំថ្ងៃ ការសម្របសម្រួលជាមួយក្រសួង ស្ថាប័ននៅថ្នាក់ជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលក្នុងការកៀរគរការចូលរួម និងការគាំទ្រដល់ការអនុវត្តជអ៥ទី១។ ទន្ទឹមគ្នានេះ លេខាធិការដ្ឋាន គ.ជ.អ.ប. ក៏បានសម្របសម្រួល ជំរុញ និងពង្រឹងកិច្ចសហប្រតិបត្តិការរវាងកម្មវិធីកំណែទម្រង់គន្លឹះនានា រួមមានកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ កម្មវិធីកែទម្រង់ច្បាប់ កម្មវិធីកែទម្រង់ប្រព័ន្ធយុត្តិធម៌ ដើម្បីធានាឱ្យការរៀបចំ និងការអនុវត្តកម្មវិធីកំណែទម្រង់គន្លឹះទាំងនេះមានភាពស៊ីសង្វាក់ ប្រទាក់ក្រឡាគ្នា និងបំពេញឱ្យគ្នាទៅវិញទៅមក។

**ការពង្រឹងការអភិវឌ្ឍស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ៖** ក្រុមប្រឹក្សា គណៈអភិបាល និងមន្ត្រីរដ្ឋបាលក្រុង ស្រុក ខណ្ឌបានខិតខំបំពេញការងារតាមមុខងារ និងរចនាសម្ព័ន្ធថ្មីរបស់ខ្លួនដែលបានរៀបចំឡើងវិញនាដើមឆ្នាំ២០២០ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។ មុខងារអប់រំ យុវជន និងកីឡាដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌក៏ត្រូវបានគ្រប់គ្រង និងចាត់ចែងប្រកបដោយការទទួលខុសត្រូវខ្ពស់ស្របតាមគោលការណ៍ នីតិវិធី និងស្តង់ដាដែលបានកំណត់ ដែលប្រការនេះបានជំរុញឱ្យការផ្តល់សេវាអប់រំនៅតាមគ្រឹះស្ថានសិក្សាស្ថិតក្រោមដែនសមត្ថកិច្ចរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗមានដំណើរការកាន់តែល្អប្រសើរ។

ក្រុមប្រឹក្សា និងគណៈអភិបាលរាជធានី ខេត្តបានផ្តោតការយកចិត្តទុកដាក់ និងការទទួលខុសត្រូវខ្ពស់ក្នុងការជំរុញ ការគាំទ្រ ការតាមដាន និងការត្រួតពិនិត្យជាប្រចាំលើការផ្តល់សេវាសុខាភិបាលនៅតាមមន្ទីរពេទ្យ និងមណ្ឌលសុខភាព តាមរយៈកិច្ចប្រជុំក្រុមប្រឹក្សាប្រចាំខែ និងការចុះត្រួតពិនិត្យជាក់ស្តែង។ ប្រការនេះ បានរួមចំណែកធ្វើឱ្យមានការប្រែប្រួលជាវិជ្ជមានទាំងគុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសុខាភិបាលនៅតាមមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព។ មណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែកបានរៀបចំឱ្យមានបុគ្គលិកប្រចាំការ២៤ម៉ោងក្នុង១ថ្ងៃ និងបុគ្គលិកសុខាភិបាលមានភាពរួសរាយរាក់ទាក់ និងមានក្រមសីលធម៌វិជ្ជាជីវៈក្នុងការបំពេញតួនាទីភារកិច្ចរបស់ខ្លួន ដោយបានធ្វើឱ្យប្រជាពលរដ្ឋកាន់តែមានជំនឿជឿជាក់ និងមកទទួលយកសេវានៅមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែកកាន់តែច្រើនឡើង។

លេខាធិការដ្ឋាន គ.ជ.អ.ប. បានដឹកនាំក្រុមការងារបច្ចេកទេសអន្តរក្រសួងក្នុងការសិក្សា ស្វែងយល់អំពីមេរៀន បទពិសោធន៍ពីបណ្តាប្រទេសនានាទាំងក្នុងតំបន់ និងក្រៅតំបន់ ព្រមទាំងបានចុះសិក្សាអំពីស្ថានភាពជាក់ស្តែងនៅតាមរដ្ឋបាលថ្នាក់ក្រោមជាតិមួយចំនួន ដើម្បីមានមូលដ្ឋានក្នុងការកំណត់ជម្រើសសមស្របនានាសម្រាប់ការកែលម្អរចនាសម្ព័ន្ធ និងប្រព័ន្ធអភិបាលរដ្ឋបាលរាជធានីឱ្យក្លាយទៅជារដ្ឋបាលទីក្រុងមេត្រូប៉ូលីតែន រដ្ឋបាលខេត្តឱ្យក្លាយទៅជារដ្ឋបាលតំបន់ និងរដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ឱ្យក្លាយទៅជារដ្ឋបាលមូលដ្ឋានជួរមុខប្រកបដោយភាពធន់ រឹងមាំ និងស្អាតស្អំក្នុងការផ្តល់សេវាសាធារណៈ ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន បម្រើផលប្រយោជន៍ជូនប្រជាពលរដ្ឋឱ្យកាន់តែមានប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព បរិយាបន្ន និងសមធម៌សង្គម។

ការផ្តល់សេវារដ្ឋបាលតាមយន្តការច្រកចេញចូលតែមួយនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ក៏បានពង្រឹង និងកែលម្អនូវនីតិវិធីផ្តល់សេវាឱ្យកាន់តែមានលក្ខណៈងាយស្រួល និងឆាប់រហ័ស។ រដ្ឋបាលធានី ខេត្ត និងរដ្ឋបាលក្រុង ស្រុក ខណ្ឌមួយចំនួនបានធ្វើទំនើបកម្មប្រព័ន្ធផ្តល់សេវារដ្ឋបាល និងការទូទាត់សេវារដ្ឋបាលក្នុងវិស័យមួយចំនួនតាមប្រព័ន្ធអនឡាញ។ ការអង្កេតអភិបាលកិច្ចក្នុងឆ្នាំ២០២៥ បានបង្ហាញឱ្យឃើញថា សន្ទស្សន៍នៃភាពពេញចិត្តរបស់ប្រជាពលរដ្ឋចំពោះការផ្តល់សេវារដ្ឋបាលតាមយន្តការច្រកចេញចូលតែមួយមានតម្លៃ០,៦៩ គឺស្ថិតក្នុងចំណាត់ថ្នាក់ល្អបង្គួរ។

ការងារគណនេយ្យភាពសង្គមត្រូវបានពង្រីក និងអនុវត្តក្នុងឃុំ សង្កាត់គោលដៅចំនួន៩៤% នៃចំនួនឃុំ សង្កាត់សរុបទូទាំងប្រទេស ដើម្បីបង្កលក្ខណៈងាយស្រួលជូនប្រជាពលរដ្ឋក្នុងការទទួលបាននូវព័ត៌មាន និងចូលរួមតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការបំពេញការងារ និងការផ្តល់សេវារបស់អង្គភាពផ្តល់សេវានៅតាមមូលដ្ឋាន។ ការងារគណនេយ្យភាពសង្គមនេះ ក៏បានចាប់ផ្តើមពង្រីកអនុវត្តនៅថ្នាក់រដ្ឋបាលក្រុង ស្រុកជាបណ្តើរៗផងដែរ។ លទ្ធផលនៃការវាយតម្លៃចុងឆ្នាំ២០២៤ បានបង្ហាញឱ្យដឹងថា៩២%នៃប្រជាពលរដ្ឋបានពេញចិត្ត និងបានចូលរួមយ៉ាងសកម្មក្នុងការលើកកម្ពស់ការបំពេញការងារ ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានដែលផ្តល់ដោយអង្គភាពផ្តល់សេវាទាំង៣ គឺរដ្ឋបាលឃុំ សង្កាត់ មណ្ឌលសុខភាព និងសាលាបឋមសិក្សា។

ការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ៖ រដ្ឋបាលថ្នាក់ក្រោមជាតិបានបន្តពង្រឹងការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់បុគ្គលិករបស់ខ្លួនស្របតាមសិទ្ធិអំណាច និងការទទួលខុសត្រូវដែលបានកំណត់ក្នុងលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។ សេចក្តីណែនាំស្តីពីគោលការណ៍ និងនីតិវិធីគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ បណ្តុះបណ្តាល និងដាក់ឱ្យអនុវត្តដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។

អនុក្រឹត្យស្តីពីការកំណត់មុខតំណែងវិជ្ជាជីវៈ និងការពិពណ៌នាមុខតំណែងក្នុងរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត ដើម្បីឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌមានមូលដ្ឋានក្នុងការរៀបចំផែនការបុគ្គលិកឱ្យឆ្លើយតបទៅនឹងតម្រូវការបុគ្គលិកជាក់ស្តែងពិតប្រាកដ ការជ្រើសរើស

បុគ្គលិកបានត្រឹមត្រូវតាមជំនាញវិជ្ជាជីវៈដែលត្រូវការ ការរៀបចំលក្ខខណ្ឌការងារបុគ្គលិកឱ្យស្របទៅនឹងជំនាញវិជ្ជាជីវៈរបស់បុគ្គលិកម្នាក់ៗ និងការអភិវឌ្ឍធនធានមនុស្សឱ្យត្រូវតាមជំនាញវិជ្ជាជីវៈដែលត្រូវការជាក់ស្តែងនៅតាមរដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗ។

ទន្ទឹមគ្នានេះ អនុក្រឹត្យស្តីពីគោលការណ៍ និងនីតិវិធីតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់មុខតំណែងនាយកគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងនាយកគ្រឹះស្ថានបឋមសិក្សាសាធារណៈ ព្រមទាំងនិយាមនីតិវិធីប្រតិបត្តិសម្រាប់ការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់មុខតំណែងនាយកគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងនាយកគ្រឹះស្ថានបឋមសិក្សាសាធារណៈត្រូវបានរៀបចំ និងផ្សព្វផ្សាយដាក់ឱ្យអនុវត្តនៅដើមឆ្នាំ២០២៥។

គិតមកដល់ពេលនេះ បុគ្គលិកដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិមានចំនួនប្រមាណជាង **១០០.០០០នាក់** ក្នុងនោះ បុគ្គលិករដ្ឋបាលចំនួនប្រមាណ **៧.០០០នាក់** បុគ្គលិកអប់រំ/គ្រូបង្រៀនជាង **៧០.០០០នាក់** បុគ្គលិកជំនាញតាមវិស័យនានាប្រមាណ **១០.០០០នាក់** និងបុគ្គលិកសុខាភិបាល/គ្រូពេទ្យចំនួនប្រមាណជាង **២០.០០០នាក់**។

ជារៀងរាល់ឆ្នាំ រដ្ឋបាលរាជធានី ខេត្តបានរៀបចំ និងអនុវត្តផែនការអភិវឌ្ឍន៍សមត្ថភាពសម្រាប់បុគ្គលិករបស់ខ្លួន និងបុគ្គលិករដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ផ្អែកលើការវាយតម្លៃអំពីតម្រូវការអភិវឌ្ឍសមត្ថភាពដែលជាមធ្យមរដ្ឋបាលរាធានី ខេត្តបានអនុវត្តសកម្មភាពអភិវឌ្ឍសមត្ថភាពចំនួនជាង**២០០វគ្គ**ក្នុងមួយឆ្នាំដោយមានសិក្ខាកាមចូលរួមចំនួនជាង**៦.៧០០នាក់**។ សាលាជាតិរដ្ឋបាលមូលដ្ឋាន ក៏បានដំណើរការយ៉ាងសកម្ម ដោយមានកិច្ចសហការជាមួយក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធនានាក្នុងការផ្តល់សេវាអភិវឌ្ឍសមត្ថភាពជូនដល់ក្រុមប្រឹក្សា និងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ដែលជាមធ្យមសាលាបានរៀបចំការបណ្តុះបណ្តាលដល់រដ្ឋបាលថ្នាក់ក្រោមជាតិចំនួន**៣៥វគ្គ**ក្នុងមួយឆ្នាំ ដែលមានសិក្ខាមចំនួនជាង**១.៥០០នាក់**។

ទាំងក្រុមប្រឹក្សា និងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិមានការយល់ដឹងយ៉ាងទូលំទូលាយអំពីសមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម។ រាល់ការតែងតាំង ឬផ្លាស់ប្តូរមុខតំណែនានាតែងតែមានការប្រឹក្សាយោបល់ និងការចូលរួមពីតំណាងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ និងអភិបាលរងជាស្ត្រីក្នុងការពិចារណា និងគិតគូរពីបេក្ខភាពជាស្ត្រី។ ផ្អែកតាមទិន្នន័យឆ្នាំ២០២៥ អាត្រាបុគ្គលិកជាស្ត្រីកាន់មុខតំណែងគ្រប់គ្រងនៅថ្នាក់ក្រុង ស្រុក ខណ្ឌមានចំនួន**២៣%** និងថ្នាក់រាជធានី ខេត្តមានចំនួន**៣៣%**។

***ការងារវិមជ្ឈការហិរញ្ញវត្ថុ និងប្រព័ន្ធផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ៖*** រាជរដ្ឋាភិបាលបានបង្កើនថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិជារៀងរាល់ឆ្នាំ។ ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងឆ្នាំ២០២១មានចំនួនសរុបប្រមាណ***៨៥៩លានដុល្លារអាមេរិក*** បានកើនឡើងដល់ចំនួនប្រមាណ***១.៧៩១លានដុល្លារអាមេរិក*** នៅក្នុងឆ្នាំ២០២៥។ ក្របខ័ណ្ឌពេលវេលានៃការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល និងក្របខ័ណ្ឌពេលវេលា

នៃការរៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានកែលម្អឱ្យមានភាពស៊ីសង្វាក់គ្នា ដោយបានធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិអាចប្រើប្រាស់ថវិកាប្រចាំឆ្នាំរបស់ខ្លួនសម្រាប់អនុវត្តគម្រោង និងសកម្មភាពជាអាទិភាពនានាដែលបានកំណត់នៅក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិលបានទាន់ពេលវេលា។

ធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌសម្រាប់អនុវត្តមុខងារអប់រំ ត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌសម្រាប់អនុវត្តមុខងារសុខាភិបាល ត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលរាជធានី ខេត្ត តាមពេលវេលាដែលបានកំណត់ និងបានប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពស្របតាមលក្ខខណ្ឌដែលបានកំណត់។

រដ្ឋបាលថ្នាក់ក្រោមជាតិទាំង៣កម្រិត បានប្រើប្រាស់ថវិការបស់ខ្លួនកាន់តែច្រើនសម្រាប់ការផ្តល់សេវាសង្គម និងអនាម័យបរិស្ថាន ដើម្បីជួយដល់ក្រុមគ្រួសារក្រីក្រ និងជនងាយរងគ្រោះ ដើម្បីលើកកម្ពស់ការប្រើប្រាស់ធនធានសាធារណៈប្រកបដោយបរិយាបន្ន និងសមធម៌សង្គម។

ជាមួយគ្នានេះ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ (SARMIS) ក៏បានរៀបចំ និងដាក់ឱ្យប្រើប្រាស់ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាឱ្យការគ្រប់គ្រងធនធានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋរបស់រដ្ឋបាលថ្នាក់ក្រោមជាតិកាន់តែមានប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។

**ការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន៖** រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗបានខិតខំជំរុញ និងពង្រឹងការការគ្រប់គ្រង និងការអនុវត្តមុខងារជាកាតព្វកិច្ច និងមុខងារជម្រើសដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពនានារបស់ប្រជាពលរដ្ឋ។ សេចក្តីណែនាំបច្ចេកទេសសម្រាប់អនុវត្តមុខងារតាមវិស័យនានាដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត។

ការផ្តល់សេវារដ្ឋបាលតាមយន្តការច្រកចេញចូលតែមួយនៅរដ្ឋបាលថ្នាក់ក្រោមជាតិទាំង៣កម្រិត បានបន្តដំណើរយ៉ាងរលូន ព្រមទាំងបានធ្វើទំនើបកម្មជាបណ្តើរៗ ដើម្បីធានាឱ្យការផ្តល់សេវារដ្ឋបាលដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗកាន់តែមានភាពងាយស្រួល មានប្រសិទ្ធភាព តម្លាភាព និងទទួលបានការពេញចិត្តពីប្រជាពលរដ្ឋ។ ផ្អែកតាមលទ្ធផលនៃការអង្កេតអភិបាលកិច្ចឆ្នាំ២០២៥ បានបង្ហាញឱ្យឃើញថាសន្ទស្សន៍នៃភាពពេញចិត្តរបស់ប្រជាពលរដ្ឋចំពោះការផ្តល់សេវារដ្ឋបាលតាមច្រកចេញចូលតែមួយទទួលបាន០,៦៩ពិន្ទុ ស្ថិតក្នុងចំណាត់ថ្នាក់បង្គួរ។

ក្នុងក្របខ័ណ្ឌនៃការអនុវត្តមុខងារជាជម្រើស រដ្ឋបាលថ្នាក់ក្រោមជាតិទាំង៣កម្រិតបានខិតខំប្រើប្រាស់ថវិការបស់ខ្លួន និងថវិកាដែលកៀរគរបានពីប្រភពស្របច្បាប់ផ្សេងទៀតក្នុងការរៀបចំ និងអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធ គម្រោងសេវាសង្គម និងអនាម័យបរិស្ថាន បានជាមធ្យមប្រមាណជាង**២.៦០០គម្រោង**ក្នុងមួយឆ្នាំៗ ដើម្បីដោះស្រាយបញ្ហាប្រឈម និងឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពនានារបស់ប្រជាពលរដ្ឋ និងសហគមន៍នៅតាមមូលដ្ឋាន។

ទោះបីការអនុវត្តផអ៥ទី១ពីឆ្នាំ២០២១ដល់ឆ្នាំ២០២៥ ទទួលបានសមិទ្ធផលជាច្រើនក៏ដោយ ក៏នៅមានបញ្ហាប្រឈមជាគន្លឹះ និងសកម្មភាពជាអាទិភាព និងចាំបាច់មួយចំនួនដែលត្រូវបន្តដោះស្រាយ និងអនុវត្តក្នុងអំឡុងពេលនៃផអ៥ទី២ ជាអាទិ៍៖

- ការតាមដាន ការត្រួតពិនិត្យ និងការគាំទ្រពីក្រសួង ស្ថាប័នថ្នាក់ជាតិទៅលើការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ការគាំទ្របច្ចេកទេសពីរដ្ឋបាលរាជធានី ខេត្តទៅដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ និងការគាំទ្របច្ចេកទេសពីរដ្ឋបាលក្រុង ស្រុកទៅដល់រដ្ឋបាលឃុំ សង្កាត់នៅមានភាពទន់ខ្សោយដែលទាមទារឱ្យមានការជំរុញ និងការពង្រឹងបន្ថែម
- ភាពចាំបាច់ដែលត្រូវបន្តពិនិត្យ និងរៀបចំឡើងវិញនូវរចនាសម្ព័ន្ធ ប្រព័ន្ធអភិបាលកិច្ច និងមុខងាររបស់រដ្ឋបាលរាជធានី ខេត្តឱ្យស្របទៅនឹងគោលការណ៍នៃរដ្ឋបាលឯកភាពដូចដែលបានកំណត់ក្នុងច្បាប់រៀបចំអង្គការស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីធានាឱ្យក្រុមប្រឹក្សារាជធានី ខេត្តអាចម្ចាស់ការក្នុងការគ្រប់គ្រង និងការចាត់ចែងមុខងារ និងធនធាន ព្រមទាំងមានសមត្ថភាពក្នុងការដឹកនាំ និងសម្របសម្រួលប្រកបដោយប្រសិទ្ធភាពនូវសកម្មភាពផ្តល់សេវា និងការអភិវឌ្ឍនានា សំដៅឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន
- រដ្ឋបាលថ្នាក់ក្រោមជាតិបាន និងកំពុងជួបប្រទះបញ្ហាខ្វះធនធានមនុស្ស ទាំងចំនួន និងជំនាញវិជ្ជាជីវៈ ដែលបញ្ហានេះទាមទារឱ្យមានការដោះស្រាយក្នុងលក្ខណៈជាប្រព័ន្ធច្បាស់លាស់មួយ
- ភាពចាំបាច់ក្នុងការគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិរៀបចំផែនការរៀបចំដែនដី ប្លង់គោលប្រើប្រាស់ដី ផែនការប្រើប្រាស់ដី ដើម្បីលើកកម្ពស់ការរៀបចំនគរូបនីយកម្ម និងការអភិវឌ្ឍតាមវិស័យនានា ដែលធានាឱ្យការប្រើប្រាស់ធនធានដែលជាសក្តានុពលនៅតាមរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗប្រកបដោយសុវត្ថិភាពផ្នែកបរិស្ថាន សោភ័ណភាព ផាសុកភាព មានរបៀបរៀបរយ មានភាពទាក់ទាញដល់វិនិយោគិន និងមាននិរន្តរភាពនៃការអភិវឌ្ឍ។

ក្រៅពីបញ្ហាប្រឈមជាគន្លឹះដែលត្រូវបន្តដោះស្រាយ ការរៀបចំ ផអ៥ទី២ បានផ្តោតលើការសិក្សាវាយតម្លៃ និងវិភាគស្ថានភាពផ្នែកសេដ្ឋកិច្ច នគរូបនីយកម្ម បច្ចេកវិទ្យា និងហានិភ័យនានាដែលកើតចេញពីវិបត្តិជាសាកល និងជម្លោះព្រំប្រទល់កម្ពុជា-ថៃ ដើម្បីមានមូលដ្ឋានកាន់តែច្បាស់លាស់ក្នុងការរៀបចំ ផអ៥ទី២ ឱ្យឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង និងមានលក្ខណៈគ្រប់ជ្រុងជ្រោយស្របតាម កជទី២ គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ច្បាប់រៀបចំអង្គការ យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ និងវិធានការគន្លឹះនានារបស់រាជរដ្ឋាភិបាល។

ក្នុងការវាយតម្លៃ និងវិភាគស្ថានភាពទាំងនេះ ក្រៅពីការសិក្សាស្រាវជ្រាវលើឯកសារពាក់ព័ន្ធនានា លេខាធិការដ្ឋាន គ.ជ.អ.ប. បានពិគ្រោះយោបល់ជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិដែលជាប្រតិបត្តិករផ្ទាល់នៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធដែលជាតួអង្គរៀបចំ

គោលនយោបាយ ច្បាប់និងលិខិតបទដ្ឋានគតិយុត្ត កំណត់ស្តង់ដាសេវា គាំទ្របច្ចេកទេស និងតាមដាន ត្រួតពិនិត្យនីត្យានុកូលភាពលើការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ជាមួយដៃគូអភិវឌ្ឍន៍ និង អង្គការសង្គមស៊ីវិលពាក់ព័ន្ធនានាដែលជាស្ថាប័នមិនមែនរដ្ឋ មានតួនាទីសំខាន់ក្នុងការគាំទ្រហិរញ្ញប្បទាន ជំនួយបច្ចេកទេស និងការចូលរួមអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។

ជារួម ផអ៥ទី២ ត្រូវបានបែងចែកជា៥ជំពូកធំៗ រួមមាន ជំពូកទី១៖ អំពីទិដ្ឋភាពទូទៅដែល បរិយាយអំពីសេចក្តីផ្តើម ចក្ខុវិស័យ គោលបំណង គោលដៅ សេចក្តីសង្ខេបអំពីសមាសភាគ លទ្ធផល រំពឹងទុក ក្របខ័ណ្ឌលទ្ធផល និងយុទ្ធសាស្ត្រនៃការអនុវត្ត ផអ៥ទី២។ ជំពូកទី២៖ អំពីសមាសភាគនានា នៃ ផអ៥ទី២ ដែលរៀបរាប់លម្អិតអំពីសមាសភាគទាំង៥ ដោយសមាសភាគនីមួយៗបែងចែកជា៤ផ្នែក រួមមាន សនិទានភាព សមិទ្ធផលរំពឹងទុក លទ្ធផលរំពឹងទុក និងថវិកាប៉ាន់ស្មាន។ ជំពូកទី៣៖ អំពីការ គ្រប់គ្រង និងការអនុវត្ត ផអ៥ទី២ ដែលពិពណ៌នាអំពីក្របខ័ណ្ឌសម្រាប់ការគ្រប់គ្រង ការអនុវត្ត ការ ត្រួតពិនិត្យ និងការវាយតម្លៃ និងការគ្រប់គ្រងហានិភ័យ។ ជំពូកទី៤៖ អំពីផែនការចំណាយនៃ ផអ៥ទី២ ដែលរៀបរាប់អំពីការប៉ាន់ស្មានចំណាយ និងការផ្តល់ហិរញ្ញប្បទានសម្រាប់គាំទ្រ ផអ៥ទី២។ ជំពូកទី៥៖ អំពីសេចក្តីសន្និដ្ឋានដែលគូសបញ្ជាក់អំពីកត្តាសំខាន់ៗ ដើម្បីធានាការសម្រេចបានដោយជោគជ័យនៃ គោលដៅរបស់ កជទី២ ក្នុងរយៈពេល៥ឆ្នាំ។

## ២. ចក្ខុវិស័យ គោលបំណង គោលដៅនៃ ផអ៥ទី២

### ២.១. ចក្ខុវិស័យ

ផអ៥ទី១ និងផអ៥ទី២ ត្រូវបានរៀបចំឡើងដើម្បីសម្រេចបាននូវចក្ខុវិស័យរបស់ កជទី២ គឺ **"ប្រជាពលរដ្ឋទទួលបានផលប្រយោជន៍ពីសេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានដែលផ្តល់ដោយ រដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយបរិយាបន្ន និងសមធម៌សង្គម ដើម្បីរួមចំណែកសម្រេចគោលបំណង ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមជាតិ និងប្រែក្លាយប្រទេសកម្ពុជាឱ្យទៅជាប្រទេសដែលមានចំណូលមធ្យម កម្រិតខ្ពស់នៅឆ្នាំ២០៣០"**។

### ២.២. គោលបំណង

ក្នុងការរួមចំណែកសម្រេចបាននូវចក្ខុវិស័យនេះ គោលបំណងរបស់ ផអ៥ទី២ គឺបន្ត និងពង្រឹង **"ការលើកកម្ពស់ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានស្របតាមគោលការណ៍នៃការអភិវឌ្ឍ តាមបែបប្រជាធិបតេយ្យ ដើម្បីធានាលើកកម្ពស់បរិយាបន្ន សមធម៌សង្គម និងយុត្តិធម៌ក្នុងការរួមចំណែក លុបបំបាត់ភាពក្រីក្រ និងលើកកម្ពស់គុណភាពជីវិតរបស់ប្រជាជនឱ្យកាន់តែប្រសើរឡើង"**។

### ២.៣. គោលដៅ

ដើម្បីធានាការសម្រេចបាននូវគោលបំណងខាងលើ គោលដៅនៃ ផអ៥ទី២ គឺ **"រដ្ឋបាលថ្នាក់ក្រោម ជាតិមានសិទ្ធិអំណាច ស្វ័យភាព សមត្ថភាព និងលទ្ធភាពសមស្របសម្រាប់អនុវត្តមុខងារក្នុងការផ្តល់សេវា សាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន"**។

ការសម្រេចបាននូវគោលដៅនេះ ចាំបាច់ត្រូវមានការពិនិត្យ និងកែសម្រួលរចនាសម្ព័ន្ធ ប្រព័ន្ធ មុខងារ សិទ្ធិអំណាច និងធនធានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យស្របទៅតាមចរិតលក្ខណៈនៃប្រភេទរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ដូចជារដ្ឋបាលតំបន់ទីក្រុង ឬតំបន់ជនបទជាដើម។ ទន្ទឹមនេះ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរៀបចំឱ្យមានលក្ខណៈទំនើប និងប្រសិទ្ធភាពក្នុងការកសាងផែនការ ការគ្រប់គ្រងហិរញ្ញវត្ថុនិងលទ្ធកម្ម ការគ្រប់គ្រងធនធានមនុស្ស ហើយបុគ្គលិកត្រូវមានសមត្ថភាព និងជំនាញវិជ្ជាជីវៈសមស្រប ដើម្បីដំណើរការប្រព័ន្ធទាំងនេះ។

បន្ថែមលើនេះ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរៀបចំផែនការ និងថវិកាដែលឆ្លុះបញ្ចាំងពីតម្រូវការ និងអាទិភាពនានានៅតាមមូលដ្ឋាននីមួយៗ តាមរយៈការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ អង្គការសង្គមស៊ីវិល និងវិស័យឯកជននានា។ ជាមួយគ្នានេះ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវទទួលបាននូវសិទ្ធិអំណាចសមស្របក្នុងការធ្វើការសម្រេចនានាពាក់ព័ន្ធនឹងការប្រើប្រាស់ថវិការបស់ខ្លួន។ ទន្ទឹមនេះ សមត្ថភាព និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពង្រឹង ដើម្បីធានាគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះប្រជាពលរដ្ឋ។

## ៣. សមាសភាគ និងលទ្ធផលរំពឹងទុក

ផអ៥ទី២ ត្រូវបានរៀបចំ និងបែងចែកជាសមាសភាគសំខាន់ៗចំនួន០៥ គឺ ៖

**សមាសភាគទី១** ៖ ការដឹកនាំ និងការសម្របសម្រួលការងារកំណែទម្រង់

**សមាសភាគទី២** ៖ រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ

**សមាសភាគទី៣** ៖ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស

**សមាសភាគទី៤** ៖ វិមជ្ឈការហិរញ្ញវត្ថុ និងប្រព័ន្ធផែនការនិងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

**សមាសភាគទី៥** ៖ ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន។

សមាសភាគនីមួយៗរួមមានសមិទ្ធផល លទ្ធផលរំពឹងទុក សកម្មភាពជាអាទិភាព សូចនាករ និងចំណុចដៅជាក់លាក់ដែលត្រូវអនុវត្ត ដើម្បីធានាការសម្រេចបាននូវគោលដៅនៃ ផអ៥ទី២។

សមាសភាគទាំង៥មានលក្ខណៈជាប្រទាក់ក្រឡាគ្នា ពោលគឺភាពជោគជ័យនៃការអនុវត្តសមាសភាគណាមួយ អាស្រ័យលើការអនុវត្តសមាសភាគទាំង៤ផ្សេងទៀត។ ជាមួយគ្នានេះ ពុំមានស្ថាប័នអនុវត្តណាមួយដែលទទួលខុសត្រូវចំពោះសមាសភាគជាក់លាក់ណាមួយនោះឡើយ។ ផ្ទុយទៅវិញ ស្ថាប័នអនុវត្តអាចទទួលខុសត្រូវលើការអនុវត្តលទ្ធផល និងសកម្មភាពមួយចំនួននៅក្នុងសមាសភាគណាមួយ និងស្ថាប័នអនុវត្តមួយចំនួនអាចទទួលខុសត្រូវលើការអនុវត្តសកម្មភាពនៃសមាសភាគច្រើនជាងមួយ។

តារាងខាងក្រោមបង្ហាញអំពីក្របខ័ណ្ឌលទ្ធផលនៃ ផអ៥ទី២ រួមបញ្ចូលសូចនាករ និងចំណុចដៅនៃលទ្ធផលរំពឹងទុក តាមសមាសភាគនីមួយៗ។

## តារាងក្របខណ្ឌលទ្ធផលនៃ ផអ៥ទី២

| កូដ | ក្របខណ្ឌលទ្ធផលនៃ ផអ៥ទី២ | សូចនាករ និងចំណុចដៅ | | |
|---|---|---|---|---|
| | | សូចនាករ | ដើមគ្រាឆ្នាំ២០២៥ | ចុងគ្រាឆ្នាំ២០៣០ |
| | ចក្ខុវិស័យ ៖<br>**ប្រជាពលរដ្ឋទទួលបានផលប្រយោជន៍ពីសេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានដែលផ្តល់ដោយរដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយបរិយាបន្ន និងសមធម៌សង្គម ដើម្បីរួមចំណែកសម្រេចគោលបំណងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមជាតិ និងប្រែក្លាយប្រទេសកម្ពុជាឱ្យទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០** | | | |
| | គោលបំណង ៖<br>ការលើកកម្ពស់ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានស្របតាមគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ដើម្បីធានាលើកកម្ពស់បរិយាបន្ន សមធម៌សង្គម និងយុត្តិធម៌ក្នុងការរួមចំណែកលុបបំបាត់ភាពក្រីក្រ និងលើកកម្ពស់គុណភាពជីវិតរបស់ប្រជាជនឱ្យកាន់តែប្រសើរឡើង | – សន្ទស្សន៍អភិបាលកិច្ច | – ០,៦៤ | – ០,៧៤ |
| | គោលដៅ ៖<br>រដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិអំណាច ស្វ័យភាព សមត្ថភាព និងលទ្ធភាពសមស្របសម្រាប់អនុវត្តមុខងារក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន | – សន្ទស្សន៍សេវា<br>– សន្ទស្សន៍សមត្ថភាព | – ០,៦៩<br>– ០,៧៥ | – ០,៧៩<br>– ០,៨៥ |
| **សមាសភាគទី១÷ ការដឹកនាំ និងការសម្របសម្រួលការងារកំណែទម្រង់** | | | | |
| | សមិទ្ធផលរំពឹងទុក៖<br>ការដឹកនាំ សម្របសម្រួល និងគាំទ្រដល់ការងារកំណែទម្រង់នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិត្រូវបានពង្រឹង ដើម្បីលើកកម្ពស់ភាពជាម្ចាស់ និងការទទួលខុសត្រូវនៅក្នុងការរៀបចំ និងអនុវត្តកម្មវិធីកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព | | | |
| ១.១. | លទ្ធផលរំពឹងទុកទី១៖<br>យន្តការដឹកនាំកំណែទម្រង់ត្រូវបានពង្រឹងទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីធានាដល់ការដឹកនាំ សម្របសម្រួល និងអនុវត្ត ផអ៥ទី២ ឱ្យមានប្រសិទ្ធភាព សំដៅរួម | – ចំនួនលិខិតបទដ្ឋានដែលពិនិត្យ និងដាក់ចេញ<br>– ទំហំថវិកាសម្រាប់សកម្មភាពស្នូល | – ៥<br><br>– ៦លានដុល្លារ | – ៥/ឆ្នាំ<br><br>– ៦លានដុល្លារ/ឆ្នាំ |

| កូដ | ក្របខ័ណ្ឌលទ្ធផលនៃ ផអវ៥ទី២ | សូចនាករ និងចំណុចដៅ | | |
|---|---|---|---|---|
| | | សូចនាករ | ដើមគ្រាឆ្នាំ២០២៥ | ចុងគ្រាឆ្នាំ២០៣០ |
| | ចំណែកអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ និងវិធានការគន្លឹះនានារបស់រាជរដ្ឋាភិបាល | | | |
| ១.២. | លទ្ធផលរំពឹងទុកទី២៖<br>កំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិត្រូវបានផ្សព្វផ្សាយ ដើម្បីបង្កើនការយល់ដឹង និងការគាំទ្រយ៉ាងទូលំទូលាយពីក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានា | – តម្លៃសន្ទស្សន៍ចំណេះដឹងអំពីកំណែទម្រង់របស់រាជរដ្ឋាភិបាល | – ០,៦១ | – ០,៧១ |
| ១.៣. | លទ្ធផលរំពឹងទុកទី៣៖<br>ផែនការអនុវត្តរយៈពេល៥ឆ្នាំ ដំណាក់កាលទី២ ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ | – ភាគរយនៃសូចនាករលទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាពរំពឹងទុកដែលបានសម្រេច | – ៨០% | – ១០០% |
| ១.៤. | លទ្ធផលរំពឹងទុកទី៤៖<br>រចនាសម្ព័ន្ធ និងមុខងាររបស់ក្រសួង ស្ថាប័ននៅថ្នាក់ជាតិត្រូវបានពិនិត្យ និងកែសម្រួលស្របតាមការវិវឌ្ឍនៃកំណែទម្រង់ ដើម្បីពង្រឹងការដឹកនាំ ការសម្របសម្រួល និងការគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិ | – សន្ទស្សន៍ការណែនាំ និងការគាំទ្របច្ចេកទេសពីថ្នាក់ជាតិ | – ០,៨៨ | – ០,៩៥ |
| ១.៥. | លទ្ធផលរំពឹងទុកទី៥៖<br>សមាគមជាតិក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពង្រឹង ដើម្បីបម្រើឱ្យផលប្រយោជន៍ និងអភិវឌ្ឍសមត្ថភាពរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ | – សន្ទស្សន៍ពាក់ព័ន្ធនឹងសារៈសំខាន់ និងប្រសិទ្ធភាពនៃការអនុវត្តការងាររបស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ | – ០,៧៧ | – ០,៨៧ |
| **សមាសភាគទី២៖ រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ** | | | | |
| | សមិទ្ធផលរំពឹងទុក៖<br>ស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានបន្តរៀបចំ និងពង្រឹងឱ្យធន់មាំ ខ្លាំង ឆ្លាតវៃ និងស្អាតស្អំ ស្របតាមគោលការណ៍រដ្ឋបាលឯកភាព គោលការណ៍អភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងស្របទៅតាមចរិតលក្ខណៈនៃរដ្ឋបាលទីក្រុងមេត្រូប៉ូលីតែន រដ្ឋបាលតំបន់ រដ្ឋបាលមូលដ្ឋាន និងទីក្រុងឆ្លាតវៃ | | | |

| កូដ | ក្របខ័ណ្ឌលទ្ធផលនៃ ផអប៥ទី២ | សូចនាករ និងចំណុចដៅ | | |
|---|---|---|---|---|
| | | សូចនាករ | ដើមគ្រាឆ្នាំ២០២៥ | ចុងគ្រាឆ្នាំ២០៣០ |
| ២.១. | លទ្ធផលរំពឹងទុកទី១៖<br>រចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពង្រឹង និងសិក្សាកែសម្រួលស្របតាមចរិតលក្ខណៈនៃរដ្ឋបាលថ្នាក់ក្រោមជាតិ និងសក្ដានុពលរបស់រដ្ឋបាលនីមួយៗ និងគោលការណ៍នៃរដ្ឋបាលឯកភាព | – ការរៀបចំបង្កើតរដ្ឋបាលមេត្រូប៉ូលីតែន និងរដ្ឋបាលតំបន់ | – កំពុងសិក្សា | – ដំណើរការ |
| ២.២. | លទ្ធផលរំពឹងទុកទី២៖<br>ប្រព័ន្ធ និងមុខងារការគ្រប់គ្រងដីធ្លី និងនគរូបនីយកម្មនៅថ្នាក់ក្រោមជាតិត្រូវបានពង្រឹង | – ផែនការរៀបចំដែនដី<br>– ប្លង់គោលប្រើប្រាស់ដី | – ៣<br>– ២៨១ | – ២៤<br>– ៨៧០ |
| ២.៣. | លទ្ធផលរំពឹងទុកទី៣៖<br>ការដឹកនាំ ទំនាក់ទំនងការងារ និងគណនេយ្យភាពរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពង្រឹង | – សន្ទស្សន៍ការឆ្លើយតប<br>– សន្ទស្សន៍ការបំពេញការងារ<br>– សន្ទស្សន៍តម្លាភាព<br>– សន្ទស្សន៍គណនេយ្យភាព | – ០,៦៧<br>– ០,៧៤<br>– ០,៦២<br>– ០,៥៤ | – ០,៧៧<br>– ០,៨៤<br>– ០,៧២<br>– ០,៦៤ |
| ២.៤. | លទ្ធផលរំពឹងទុកទី៤៖<br>យន្តការចូលរួមរបស់ប្រជាពលរដ្ឋត្រូវបានលើកកម្ពស់ ដើម្បីបង្កើនជំនឿទុកចិត្តរបស់ប្រជាពលរដ្ឋមកលើរដ្ឋបាលថ្នាក់ក្រោមជាតិ | – សន្ទស្សន៍ការចូលរួមរបស់ប្រជាពលរដ្ឋ | – ០,៥៨ | – ០,៧៥ |
| ២.៥. | លទ្ធផលរំពឹងទុកទី៥៖<br>ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានធ្វើទំនើបកម្មតាមរយៈការរៀបចំ និងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធឌីជីថល | – សន្ទស្សន៍ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល (អង្កេតសមត្ថភាព) | – ០,៦២ | – ០,៧២ |
| ២.៦. | លទ្ធផលរំពឹងទុកទី៦៖<br>យន្តការ និងប្រព័ន្ធតាមដាន ត្រួតពិនិត្យនិងវាយតម្លៃលើការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ កែសម្រួល និងដាក់ឱ្យអនុវត្ត | – សន្ទស្សន៍ការត្រួតពិនិត្យ និងវាយតម្លៃផ្ទៃក្នុង<br>– សន្ទស្សន៍អធិការកិច្ច/សវនកម្មផ្ទៃក្រៅ | – ០,៧៦<br>– ០,៧៥ | – ០,៨០<br>– ០,៨០ |

| កូដ | ក្របខ័ណ្ឌលទ្ធផលនៃ ផអ៥ទី២ | សូចនាករ និងចំណុចដៅ | | |
|---|---|---|---|---|
| | | សូចនាករ | ដើមគ្រាឆ្នាំ២០២៥ | ចុងគ្រាឆ្នាំ២០៣០ |
| **សមាសភាគទី៣÷ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស** | | | | |
| | សមិទ្ធផលរំពឹងទុក៖<br>រដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិជ្រើសរើស គ្រប់គ្រង ចាត់ចែង និងប្រើប្រាស់បុគ្គលិកផ្អែកលើទំហំការងារនិងលទ្ធភាពហិរញ្ញវត្ថុរបស់ខ្លួន និងមានបុគ្គលិកប្រកបដោយសមត្ថភាព ឆន្ទៈម្ចាស់ការ ភក្តីភាព និងមនសិការជំនាញវិជ្ជាជីវៈស្របតាមតួនាទី ភារកិច្ច និងការទទួលខុសត្រូវដែលបានកំណត់ | | | |
| ៣.១. | លទ្ធផលរំពឹងទុកទី១៖<br>សិទ្ធិអំណាច និងការទទួលខុសត្រូវក្នុងការគ្រប់គ្រងបុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពង្រឹងដោយមានការគិតគូរដល់ការលើកកម្ពស់សមភាពយេនឌ័រ | – សន្ទស្សន៍ការគ្រប់គ្រងបុគ្គលិក<br>– %ស្ត្រីកាន់មុខតំណែងគ្រប់គ្រង | – ០,៨២<br>– ២៣% (ក្រុង ស្រុក ខណ្ឌ) ៣៣% (រាជធានី ខេត្ត) | – ០,៩០<br>– ៣០% (ក្រុង ស្រុក ខណ្ឌ) ៣៧% (រាជធានី ខេត្ត) |
| ៣.២. | លទ្ធផលរំពឹងទុកទី២៖<br>ប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្មត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត | – សន្ទស្សន៍ការគ្រប់គ្រងបុគ្គលិក | – ០,៨២ | – ០,៩០ |
| ៣.៣. | លទ្ធផលរំពឹងទុកទី៣៖<br>សមត្ថភាពក្រុមប្រឹក្សា និងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានលើកកម្ពស់ | – សន្ទស្សន៍ការអភិវឌ្ឍសមត្ថភាព | – ០,៦៨ | – ០,៧៥ |
| ៣.៤. | លទ្ធផលរំពឹងទុកទី៤៖<br>ស្ថាប័ន/អង្គភាពអភិវឌ្ឍន៍សមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពង្រឹង | – សន្ទស្សន៍ចំណេះដឹងបច្ចេកទេស និងជំនាញរបស់បុគ្គលិក | – ០,៦៥ | – ០,៧៥ |
| **សមាសភាគទី៤÷ វិមជ្ឈការហិរញ្ញវត្ថុ និងប្រព័ន្ធផែនការនិងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ** | | | | |
| | សមិទ្ធផលរំពឹងទុក៖<br>រដ្ឋបាលថ្នាក់ក្រោមជាតិមានធនធានថវិកាដែលអាចព្យាករណ៍បាន និងមានទំហំសមស្របទៅនឹងមុខងារ និងអាទិភាពគោលនយោបាយជាតិ ហើយត្រូវបានវិភាជសម្រាប់ការប្រើប្រាស់ប្រកបដោយភាពបត់បែនក្នុងការឆ្លើយតបទៅនឹងតម្រូវការនានា ដូចមានកំណត់នៅក្នុងផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគ និងផែនការយុទ្ធសាស្ត្រថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | | | |

| កូដ | ក្របខ័ណ្ឌលទ្ធផលនៃ ផអ៥ទី២ | សូចនាករ និងចំណុចដៅ | | |
|---|---|---|---|---|
| | | សូចនាករ | ដើមគ្រាឆ្នាំ២០២៥ | ចុងគ្រាឆ្នាំ២០៣០ |
| ៤.១. | លទ្ធផលរំពឹងទុកទី១៖<br>កិច្ចដំណើរការកសាងផែនការត្រូវបានពង្រឹង កែលម្អ និងបន្សុីគ្នាជាមួយនឹងការរៀបចំគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | – សន្ទស្សន៍ការឆ្លើយតប<br>– សន្ទស្សន៍ពាក់ព័ន្ធនឹងផែនការ និងថវិកា | – ០,៦៧<br>– ០,៩១ | – ០,៧៧<br>– ០,៩៥ |
| ៤.២. | លទ្ធផលរំពឹងទុកទី២៖<br>ភាពជាម្ចាស់ និងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រងចាត់ចែង និងប្រើប្រាស់ធនធានហិរញ្ញវត្ថុត្រូវបានពង្រឹង | – សន្ទស្សន៍ការអនុវត្តថវិកា | – ០,៨១ | – ០,៨៥ |
| ៤.៣. | លទ្ធផលរំពឹងទុកទី៣៖<br>ចំណូលមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានបង្កើន | – ភាគរយនៃចំណូលមូលដ្ឋានរដ្ឋបាលថ្នាក់ក្រោមជាតិ | – ៩% | – ១១% |
| ៤.៤. | លទ្ធផលរំពឹងទុកទី៤៖<br>ទ្រព្យសម្បត្តិរដ្ឋត្រូវបានផ្ទេរ និងពង្រឹងការគ្រប់គ្រងដោយរដ្ឋបាលថ្នាក់ក្រោមជាតិ | – សន្ទស្សន៍ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ | – ០,៨៤ | – ០,៩៥ |
| ៤.៥. | លទ្ធផលរំពឹងទុកទី៥៖<br>មូលនិធិគ្មានភ្ជាប់លក្ខខណ្ឌត្រូវបានបង្កើន និងវិភាជទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិតាមរូបមន្ត និងលក្ខណៈវិនិច្ឆ័យប្រកបដោយសមធម៌ | – សន្ទស្សន៍ធនធានសម្រាប់មុខងារជាជម្រើស | – ០,៧៥ | – ០,៨៥ |
| ៤.៦. | លទ្ធផលរំពឹងទុកទី៦៖<br>មូលនិធិមានភ្ជាប់លក្ខខណ្ឌត្រូវបានផ្ទេរ និងគ្រប់គ្រងដោយរដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព | – សន្ទស្សន៍ធនធានសម្រាប់មុខងារជាកាតព្វកិច្ច | – ០,៦៧ | – ០,៧៥ |

| កូដ | ក្របខណ្ឌលទ្ធផលនៃ ផអវ៥ទី២ | សូចនាករ និងចំណុចដៅ | | |
|---|---|---|---|---|
| | | សូចនាករ | ដើមគ្រាឆ្នាំ២០២៥ | ចុងគ្រាឆ្នាំ២០៣០ |
| ៤.៧. | លទ្ធផលរំពឹងទុកទី៧៖<br>ក្របខ័ណ្ឌសម្រាប់ផ្តល់ហិរញ្ញប្បទានការវិនិយោគសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពង្រឹង និងកែលម្អ | – លិខិតបទដ្ឋានសម្រាប់គ្រប់គ្រងការវិនិយោគសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | – គ្មាន | – អនុវត្ត |
| ៤.៨. | លទ្ធផលរំពឹងទុកទី៨៖<br>ក្របខ័ណ្ឌភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងវិស័យឯកជនត្រូវបានបង្កើត និងដាក់ឱ្យអនុវត្ត | – លិខិតបទដ្ឋានសម្រាប់ភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិបានបង្កើត | – គ្មាន | – អនុវត្ត |
| **សមាសភាគទី៥៖ ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន** | | | | |
| | សមិទ្ធផលរំពឹងទុក៖<br>រដ្ឋបាលថ្នាក់ក្រោមជាតិមានយន្តការ នីតិវិធី និងស្តង់ដាសម្រាប់ផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋឱ្យកាន់តែមានប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព បរិយាបន្ន និងសមធម៌សង្គម | | | |
| ៥.១. | លទ្ធផលរំពឹងទុកទី១៖<br>ការគ្រប់គ្រង និងការអនុវត្តមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវាសាធារណៈត្រូវបានពង្រឹងឱ្យកាន់តែមានប្រសិទ្ធភាព | – ប្រជាពលរដ្ឋពេញចិត្តនឹងការផ្តល់សេវាសាធារណៈជាទូទៅ | – 0,៦១ | – 0,៧១ |
| ៥.២. | លទ្ធផលរំពឹងទុកទី២៖<br>យន្តការច្រកចេញចូលតែមួយនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានធ្វើទំនើបកម្ម ពង្រឹង និងពង្រីកការអនុវត្ត | – ប្រជាពលរដ្ឋពេញចិត្តនឹងការផ្តល់សេវារដ្ឋបាល | – 0,៦៩ | – 0,៧៥ |
| ៥.៣. | លទ្ធផលរំពឹងទុកទី៣៖<br>ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានប្រកបដោយចីរភាពនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងការអភិវឌ្ឍតាមតំបន់ជាប់ព្រំដែនត្រូវបានជំរុញ និងលើកកម្ពស់ | – GDP សម្រាប់មនុស្សម្នាក់នៃរាជធានីខេត្ត | – តាកែវ $១.៨១៥ (២០២៤)<br>– កំពង់ស្ពឺ $១.៩៨៤ (២០២៣) | – កើនឡើង |

| កូដ | ក្របខ័ណ្ឌលទ្ធផលនៃ ផអវ៥ទី២ | សូចនាករ និងចំណុចដៅ | | |
|---|---|---|---|---|
| | | សូចនាករ | ដើមគ្រាឆ្នាំ២០២៥ | ចុងគ្រាឆ្នាំ២០៣០ |
| | | | – ព្រះសីហនុ ៥.៥៧៩ (២០២៥)<br>– .......... | |
| ៥.៤. | លទ្ធផលរំពឹងទុកទី៤៖<br>ភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រងហានិភ័យពីគ្រោះមហន្តរាយ ជំងឺឆ្លងកាចសាហាវនានា និងកិច្ចគាំពារសង្គមត្រូវបានបញ្ជ្រាបទៅក្នុងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | – សន្ទស្សន៍ភាពធន់ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ | – ០,៤៣ | – ០,៩០ |

## ៤. យុទ្ធសាស្ត្រនៃការអនុវត្ត

កំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ តម្រូវឱ្យមានការចូលរួមយ៉ាងសកម្មពីគ្រប់ស្ថាប័នពាក់ព័ន្ធទាំងអស់របស់រាជរដ្ឋាភិបាល ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងលើកទឹកចិត្តឱ្យមានការចូលរួមពីអង្គការសង្គមស៊ីវិល វិស័យឯកជន ប្រជាពលរដ្ឋ និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធនានា។

គ.ជ.អ.ប. គឺជាស្ថាប័នដឹកនាំ គ្រប់គ្រង និងសម្របសម្រួលការអនុវត្ត ផអ៥ទី២។ គ.ជ.អ.ប. ពិនិត្យ ពិភាក្សានិងអនុម័តលើឯកសារសំខាន់ៗរួមមាន ផែនការអនុវត្តតាមដំណាក់កាលនីមួយៗ ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់កម្មវិធីជាតិ របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ ព្រមទាំងពិនិត្យ ពិភាក្សា និងអនុម័តលើឯកសារគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត និងឯកសារណែនាំសំខាន់ៗដែលត្រូវបានរៀបចំក្នុងក្របខ័ណ្ឌនៃ កជទី២។ គ.ជ.អ.ប. ត្រូវធានានូវការសម្របសម្រួលយ៉ាងជិតស្និទ្ធរវាងស្ថាប័នអនុវត្តនានានៃ កជទី២ ជាមួយនឹងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ កម្មវិធីកែទម្រង់ច្បាប់ កម្មវិធីកែទម្រង់ប្រព័ន្ធយុត្តិធម៌ និងកម្មវិធីកំណែទម្រង់តាមវិស័យផ្សេងៗទៀត។

កជទី២ ត្រូវអនុវត្តដោយក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់ថ្នាក់ ព្រមទាំងមានការចូលរួមគាំទ្រ និង/ឬអនុវត្តដោយដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល វិស័យឯកជន និងអ្នកពាក់ព័ន្ធនានា។ ក្រសួង ស្ថាប័នដែលទទួលខុសត្រូវពាក់ព័ន្ធនឹងការងារអន្តរស្ថាប័ន រួមមានដូចជា ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមុខងារសាធារណៈ ក្រសួងផែនការ និងក្រសួងកិច្ចការនារី ដែលមានតួនាទីយ៉ាងសំខាន់ក្នុងការអនុវត្ត ផអ៥ទី២។

ផអ៥ទី២ គឺជាផែនការអនុវត្តដំណាក់កាលទី២ នៃកជទី២ សម្រាប់រយៈពេល០៥ឆ្នាំ ចាប់ពីឆ្នាំ២០២៦ ដល់ឆ្នាំ២០៣០។ ផអ៥ទី២នេះ នឹងកំណត់ជាក់លាក់អំពីស្ថាប័នទទួលខុសត្រូវអនុវត្តទៅតាមសកម្មភាពជាអាទិភាពនីមួយៗ។ ស្ថាប័នទទួលខុសត្រូវអនុវត្តនីមួយៗត្រូវធានាថា លទ្ធផលរំពឹងទុក និងសកម្មភាពអាទិភាពពាក់ព័ន្ធនានានៃសមាសភាគនីមួយៗរបស់ ផអ៥ទី២ ព្រមទាំងកិច្ចការអន្តរវិស័យដែលពាក់ព័ន្ធនឹងការលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម និងការគ្រប់គ្រងការកាត់បន្ថយភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានាដែលបានកំណត់ក្នុង កជទី២នេះ នឹងត្រូវបានដាក់បញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រថវិកា ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ក្រសួង ស្ថាប័នសាមីនីមួយៗ។ ការអនុវត្ត ផអ៥ទី២ នៅតាមស្ថាប័ននីមួយៗត្រូវដឹកនាំដោយគណៈកម្មាធិការដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការដែលមានរដ្ឋមន្ត្រី ឬប្រធានស្ថាប័នជាប្រធាន។ រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុកត្រូវដឹកនាំ និងគ្រប់គ្រងដោយគណៈកម្មាធិការដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការដែលមានអភិបាលជាប្រធាន។

លេខាធិការដ្ឋាន គ.ជ.អ.ប. ក៏ជាស្ថាប័នអនុវត្ត ផអ៥ទី២ផងដែរ។ ក្រៅពីនេះ លេខាធិការដ្ឋាន គ.ជ.អ.ប. មានតួនាទីជាសេនាធិការរបស់ គ.ជ.អ.ប. និងទទួលខុសត្រូវជួយ គ.ជ.អ.ប. ក្នុងការដឹកនាំ និងសម្របសម្រួលការគ្រប់គ្រង និងការអនុវត្ត ផអ៥ទី២ ជាប្រចាំ រួមមាន ៖

- បូកសរុប និងរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ (ផ.ស.ថ.) របស់ គ.ជ.អ.ប.
- សម្របសម្រួល និងគាំទ្រការអនុវត្តសកម្មភាពរបស់ស្ថាប័នអនុវត្ត
- តាមដាន ត្រួតពិនិត្យលើការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ គ.ជ.អ.ប.
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើលទ្ធផលរំពឹងទុកដែលបានកំណត់ក្នុង ផអ៥ទី២ និងក្របខ័ណ្ឌលទ្ធផលនៃកជទី២
- លើកកម្ពស់ការផ្សព្វផ្សាយ ការយល់ដឹង និងការគាំទ្រចំពោះកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិក្នុងចំណោមស្ថាប័នរដ្ឋ ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល ស្ថាប័នឯកជន ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានា
- កៀរគរ គ្រប់គ្រង និងសម្របសម្រួលមូលនិធិគាំទ្រជំនួយបច្ចេកទេសសម្រាប់ការអនុវត្តគម្រោង/កម្មវិធីនានាដែលពាក់ព័ន្ធនឹងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- បំពេញកិច្ចការផ្សេងៗទៀតតាមការណែនាំពី គ.ជ.អ.ប.។

# ជំពូកទី២

## សមាសភាគនានានៃផែនការអនុវត្តរយៈពេលប្រាំឆ្នាំ ដំណាក់កាលទី២

ជំពូកនេះ គឺជាជំពូកមួយដ៏សំខាន់នៃឯកសារ ផអ៥ទី២។ ជារួម ផអ៥ទី២ នឹងរក្សាសមាសភាគជាយុទ្ធសាស្ត្រចំនួន៥ ដូចសមាសភាគទាំង៥ នៃកជទី២ដែរ រួមមាន៖

**សមាសភាគទី១ ៖ ការដឹកនាំ និងការសម្របសម្រួលការងារកំណែទម្រង់** ផ្ដោតលើការបន្តពង្រឹងយន្តការដឹកនាំ សម្របសម្រួលការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សំដៅលើកកម្ពស់ភាពជាម្ចាស់ និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការរៀបចំ និងអនុវត្តសកម្មភាពជាអាទិភាពនានានៃកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការឱ្យកាន់តែមានប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។

**សមាសភាគទី២ ៖ រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ** ផ្ដោតលើការបន្តពិនិត្យ និងការកែសម្រួលមុខងារ រចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង ធនធាន និងសិទ្ធិអំណាចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យស្របតាមចរិតលក្ខណៈជារដ្ឋបាលនៃតំបន់ទីក្រុងធំ រដ្ឋបាលនៃតំបន់ទីប្រជុំជន និងរដ្ឋបាលនៃតំបន់ជនបទ ការរៀបចំផែនការរៀបចំដែនដី ប្លង់គោលប្រើប្រាស់ដី ផែនការប្រើប្រាស់ដី ការជំរុញការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការផ្តល់សេវា និងការប្រាស្រ័យទាក់ទងសាធារណៈ ព្រមទាំងដើម្បីធានាដល់ការឆ្លើយតបទៅនឹងការវិវឌ្ឍយ៉ាងឆាប់រហ័សនៃសកម្មភាពសេដ្ឋកិច្ចនគរូបនីយកម្ម បច្ចេកវិទ្យាព័ត៌មានវិទ្យា និន្នាការបម្លាស់ទីរបស់ប្រជាពលរដ្ឋមកកាន់ទីប្រជុំជន ការកើនឡើងនៃតម្រូវការសេវាសង្គម និងតម្រូវការនៃការកាត់បន្ថយហានិភ័យនានាដែលបង្កឡើងដោយគ្រោះធម្មជាតិ ការប្រែប្រួលអាកាសធាតុ និងវិបត្តិជាសកល។

**សមាសភាគទី៣ ៖ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស** ផ្ដោតលើការជំរុញ និងពង្រឹងការអនុវត្តសិទ្ធិអំណាច និងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការជ្រើសរើស ការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់បុគ្គលិករបស់ខ្លួន ផ្អែកលើទំហំការងារ ការធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានបុគ្គលិកប្រកបដោយឆន្ទៈម្ចាស់ការ ភក្តីភាព និងមនសិការជំនាញវិជ្ជាជីវៈ ស្របតាមតួនាទី ការទទួលខុសត្រូវរបស់ខ្លួន ព្រមទាំងទទួលបានការអភិវឌ្ឍសមត្ថភាព និងជំនាញវិជ្ជាជីវៈជាប្រចាំ។

**សមាសភាគទី៤ ៖ វិមជ្ឈការហិរញ្ញវត្ថុ និងប្រព័ន្ធផែនការនិងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ** ផ្ដោតលើការបន្តរៀបចំឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានធនធានថវិកាដែលអាចព្យាករណ៍បាន និងមានទំហំសមស្រប ព្រមទាំងអាចវិភាជធនធានទាំងនោះប្រកបដោយភាពបត់បែនសម្រាប់ការប្រើប្រាស់លើការអនុវត្តមុខងារ និងកិច្ចការអាទិភាពនានា ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋដែលបានកំណត់ក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យបានទាន់ពេល និងប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។

**សមាសភាគទី៤ ៖ ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន** ផ្តោតលើការបន្តធ្វើទំនើបកម្មយន្តការ និងនីតិវិធីផ្តល់សេវា ការអភិវឌ្ឍមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ឆ្លើយតបទៅនឹងតម្រូវការចាំបាច់របស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព បរិយាបន្ន និងសមធម៌សង្គម។

ក្រៅពីសមាសភាគទាំង៥ខាងលើ ផអ៥ទី២ ក៏ផ្តោតលើកិច្ចការអន្តរវិស័យសំខាន់ចំនួន០៣ គឺ៖

- ការលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម
- ការកាត់បន្ថយភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ និងហានិភ័យនៃគ្រោះមហន្តរាយ
- អភិបាលកិច្ចឌីជីថល។

## ១. សមាសភាគទី១៖ ការដឹកនាំ និងការសម្របសម្រួលការងារកំណែទម្រង់

### ១.១. សន្ទិទានភាព

កម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ គឺជាកំណែទម្រង់ផ្នែកអភិបាលកិច្ចដ៏សំខាន់ និងមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធជាមួយនឹងកំណែទម្រង់ជាគន្លឹះផ្សេងៗទៀតរបស់រាជរដ្ឋាភិបាល រួមមានកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ កម្មវិធីកែទម្រង់ច្បាប់ និងកម្មវិធីកែទម្រង់ប្រព័ន្ធយុត្តិធម៌។ អាស្រ័យហេតុនេះ កម្មវិធីកំណែទម្រង់ទាំងនេះត្រូវអនុវត្តដោយមានការសម្របសម្រួល គាំទ្រ និងសហការជាមួយគ្នា ព្រមទាំងត្រូវសហការជាមួយកម្មវិធីកំណែទម្រង់តាមវិស័យនានា ដូចជាកំណែទម្រង់វិស័យអប់រំ កំណែទម្រង់វិស័យសុខាភិបាល និងកំណែទម្រង់វិស័យផ្សេងទៀត។

ការអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការស្ថិតនៅក្រោមការដឹកនាំ និងការសម្របសម្រួលរបស់ គ.ជ.អ.ប.។ នៅតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ការអនុវត្តកម្មវិធីកំណែទម្រង់នេះស្ថិតនៅក្រោមការដឹកនាំ និងការសម្របសម្រួលរបស់ គ.ដ.វ.វ. ដែលត្រូវបានបង្កើតឡើងស្របតាមសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលលេខ០២ សណន ដែលបានដាក់ចេញក្នុងឆ្នាំ២០១៨។

ផ្អែកតាមលទ្ធផលនៃការវាយតម្លៃពាក់កណ្ដាលអាណត្តិនៃ កជទី២ ឬការវាយតម្លៃបញ្ចប់ ផអ៥ទី១ (២០២១-២០២៥) បានបង្ហាញថា ការអនុវត្ត កជទី២ សម្រេចបានលទ្ធផលជាច្រើន ដូចជារដ្ឋបាលថ្នាក់ក្រោមជាតិ មន្ទីរ អង្គភាព អង្គការសង្គមស៊ីវិល និងភាគីពាក់ព័ន្ធនានាយល់កាន់តែច្បាស់អំពីការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ជាពិសេសជាមួយការផ្ទេរមុខងារ សិទ្ធិអំណាច ធនធានមនុស្ស ធនធានហិរញ្ញវត្ថុ និងការលើកកម្ពស់ការផ្តល់សេវារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ការលើកកម្ពស់សមភាពយេនឌ័រ ការងារគណនេយ្យភាពសង្គម។ល។ ក្រោមការសម្របសម្រួលរបស់ គ.ជ.អ.ប. រាជរដ្ឋាភិបាល/ក្រសួង ស្ថាប័ននានាបានរៀបចំ និងដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្តចំនួនជាង**២៥០** ពាក់ព័ន្ធទៅនឹងការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារ ធនធានហិរញ្ញវត្ថុ ធនធានមនុស្ស គោលការណ៍និងនីតិវិធីបំពេញការងារ ការសម្រុះសម្រួលការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ព្រមទាំងការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ល។ ទន្ទឹមនេះ គ.ជ.អ.ប. ក្នុងនាមជាសេនាធិការរបស់រាជរដ្ឋាភិបាលក៏បានសម្របសម្រួលរៀបចំវេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិលើកទី១ (២០២១-២០២៤) ស្តីពី "កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការដើម្បីចូលរួមសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០" ក្នុងគោលបំណងពិគ្រោះពិភាក្សា និងរួមគ្នាវាយតម្លៃលើវឌ្ឍនភាព និងបញ្ហាប្រឈមជាគន្លឹះ ដើម្បីធានាឱ្យរាជរដ្ឋាភិបាលមានមូលដ្ឋានកាន់តែច្បាស់ និងជាក់លាក់ក្នុងការកំណត់ និងដាក់ចេញការតម្រង់ទិសផ្នែកគោលនយោបាយសម្រាប់សម្រួចការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការឱ្យកាន់តែមានប្រសិទ្ធភាព។ សមាគមជាតិក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិបាននិងកំពុងបំពេញតួនាទី និងភារកិច្ចរបស់យ៉ាងសកម្ម ដើម្បីលើកកម្ពស់ការយល់ដឹង និងអភិវឌ្ឍសមត្ថភាព

ដល់សមាជិករបស់ខ្លួន។ ជាមួយគ្នានេះ គ.ជ.អ.ប. ក៏បានសម្របសម្រួល កៀរគរការគាំទ្របច្ចេក ទេស និងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលពាក់ព័ន្ធនានាដល់ការអនុវត្ត កជទី២ ផងដែរ។

ទន្ទឹមនឹងសមិទ្ធផលខាងលើ ការវាយតម្លៃពាក់កណ្តាលអាណត្តិនៃ កជទី២ ក៏បានរកឃើញនូវភាពអសកម្ម/ចំណុចខ្វះខាតមួយចំនួនដែលត្រូវបន្តយកចិត្តទុកដាក់ជំរុញ និងពង្រឹងការអនុវត្ត កជទី២ ពីឆ្នាំ២០២៦ដល់ឆ្នាំ២០៣០ ដែលរួមមានដូចជា (១). ការពង្រឹងកិច្ចប្រជុំជាទៀងទាត់របស់យន្តការ គ.ជ.វ.វ. ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីដឹកនាំ សម្របសម្រួលដល់ការរៀបចំ និងការអនុវត្តផែនការសកម្មភាព និងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការងារវិមជ្ឈការ និងវិសហមជ្ឈការក្នុងក្របខ័ណ្ឌសមត្ថកិច្ចរបស់ខ្លួន (២). ការបង្កើនការយល់ដឹងអំពី កជទី២ (៣). ការពង្រឹងការតាមដានត្រួតពិនិត្យលើការអនុវត្ត ផ.ស.ថ. ប្រចាំឆ្នាំ រួមទាំងប្រព័ន្ធទិន្នន័យស្តីពីការរៀបចំ និងការតាមដានការអនុវត្ត ផ.ស.ថ. (៤). ការជំរុញការផ្សព្វផ្សាយ និងការបង្កើនការយល់ដឹងដល់សមាជិកក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធអំពីបេសកកម្ម និងតួនាទី ភារកិច្ចរបស់សមាគមជាតិក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ និង(៥). ការធានាដល់សង្គតិភាពនៃការរៀបចំគោលនយោបាយ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត ផែនការយុទ្ធសាស្ត្រតាមវិស័យនីមួយៗជាមួយនឹងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ។

### ១.២. សមិទ្ធផលរំពឹងទុក

សមិទ្ធផលរំពឹងទុកនៃការដឹកនាំ និងការសម្របសម្រួលការងារកំណែទម្រង់ គឺ "**ការដឹកនាំ សម្របសម្រួល និងគាំទ្រដល់ការងារកំណែទម្រង់នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិត្រូវបានពង្រឹង ដើម្បីលើកកម្ពស់ភាពជាម្ចាស់ និងការទទួលខុសត្រូវនៅក្នុងការរៀបចំ និងអនុវត្តកម្មវិធីកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព**"។

### ១.៣. លទ្ធផលរំពឹងទុក

ដើម្បីសម្រេចបាននូវសមិទ្ធផលរំពឹងទុកខាងលើ សមាសភាគទី១ បានកំណត់នូវលទ្ធផលរំពឹងទុកចំនួន០៥ រួមមាន ៖

លទ្ធផលរំពឹងទុកទី១ ៖ យន្តការដឹកនាំកំណែទម្រង់ត្រូវបានពង្រឹងទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីធានាដល់ការដឹកនាំ សម្របសម្រួល និងអនុវត្ត ផអ៥ទី២ ឱ្យមានប្រសិទ្ធភាព សំដៅរួមចំណែកអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ និងវិធានការគន្លឹះនានារបស់រាជរដ្ឋាភិបាល

លទ្ធផលរំពឹងទុកទី២ ៖ កំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិត្រូវបានផ្សព្វផ្សាយដើម្បីបង្កើនការយល់ដឹង និងការគាំទ្រយ៉ាងទូលំទូលាយពីក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានា

លទ្ធផលរំពឹងទុកទី៣ ៖ ផែនការអនុវត្តរយៈពេល៥ឆ្នាំ ដំណាក់កាលទី២ ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ

លទ្ធផលរំពឹងទុកទី៤ ៖ រចនាសម្ព័ន្ធ និងមុខងាររបស់ក្រសួង ស្ថាប័ននៅថ្នាក់ជាតិត្រូវបានពិនិត្យ និងកែសម្រួលស្របតាមការវិវឌ្ឍនៃកំណែទម្រង់ ដើម្បីពង្រឹងការដឹកនាំ ការសម្របសម្រួល និងការគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិ

លទ្ធផលរំពឹងទុកទី៥ ៖ សមាគមជាតិក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពង្រឹង ដើម្បីបម្រើឱ្យផលប្រយោជន៍ និងអភិវឌ្ឍសមត្ថភាពរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ។

សកម្មភាពជាអាទិភាពដែលត្រូវអនុវត្ត ដើម្បីសម្រេចបានលទ្ធផលរំពឹងទុកនីមួយៗ រួមបញ្ចូលសូចនាករ និងចំណុចដៅសម្រាប់វាស់វែងការសម្រេចបាននូវសកម្មភាពជាអាទិភាពទាំងនេះ មានបរិយាយតាមលទ្ធផលរំពឹងទុកខាងក្រោម ៖

### លទ្ធផលរំពឹងទុក ១.១.៖ យន្តការដឹកនាំកំណែទម្រង់ត្រូវបានពង្រឹងទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីធានាដល់ការដឹកនាំ សម្របសម្រួល និងអនុវត្ត ផអ៥ទី២ ឱ្យមានប្រសិទ្ធភាព សំដៅរួមចំណែកអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ និងវិធានការគន្លឹះនានារបស់រាជរដ្ឋាភិបាល

ការអនុវត្ត ផអ៥ទី២ ស្ថិតក្រោមការដឹកនាំ និងការសម្របសម្រួលរបស់ គ.ជ.អ.ប. ដោយមានអនុគណៈកម្មាធិការនានានៃ គ.ជ.អ.ប. ជួយផ្តល់មតិយោបល់ជូន គ.ជ.អ.ប. លើការងារសំខាន់ៗពាក់ព័ន្ធនឹងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងមានលេខាធិការដ្ឋាន គ.ជ.អ.ប. ជាសេនាធិការក្នុងការគ្រប់គ្រង ការសម្របសម្រួល និងការអនុវត្តកិច្ចការនេះប្រចាំថ្ងៃ។ ការលើកកម្ពស់ការដឹកនាំ និងការសម្របសម្រួលរបស់ គ.ជ.អ.ប. អនុគណៈកម្មាធិការនានា និងការពង្រឹងសមត្ថភាព និងការទទួលខុសត្រូវរបស់លេខាធិការដ្ឋាន គ.ជ.អ.ប. គឺជាកិច្ចការស្នូលដែលចាំបាច់ត្រូវបន្តអនុវត្តនៅក្នុងអំឡុងពេលនៃ ផអ៥ទី២។ ទន្ទឹមនេះ ការអនុវត្ត ផអ៥ទី២ ត្រូវសម្របសម្រួល និងសហការជិតស្និទ្ធជាមួយកម្មវិធីកំណែទម្រង់គន្លឹះនានារបស់រាជរដ្ឋាភិបាល និងកម្មវិធីកំណែទម្រង់តាមវិស័យ រួមបញ្ចូលការលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម។

នៅតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ការអនុវត្ត ផអ៥ទី២ ស្ថិតក្រោមការដឹកនាំ និងការសម្របសម្រួលរបស់ គ.ដ.វ.វ.។ ការវាយតម្លៃពាក់កណ្តាលអាណត្តិនៃ កជទី២ បង្ហាញថា គ.ដ.វ.វ. បំពេញតួនាទី និងភារកិច្ចរបស់ខ្លួនមិនទាន់បានពេញលេញទៅតាមតួនាទី ភារកិច្ច និងរបៀបរបបការងារដែលបានកំណត់។ ទន្ទឹមនេះ រដ្ឋបាលថ្នាក់ក្រោមជាតិមួយចំនួនពុំទាន់យល់ដឹងច្បាស់លាស់អំពីយន្តការ និងតួនាទី ភារកិច្ចរបស់ គ.ដ.វ.វ. នៅឡើយ។ អាស្រ័យហេតុនេះ ក្នុងអំឡុងពេលនៃ ផអ៥ទី២ ការ

បំពេញតួនាទី ភារកិច្ចរបស់ គ.ដ.វ.វ. ចាំបាច់ត្រូវធ្វើការពង្រឹង ដើម្បីលើកកម្ពស់ការដឹកនាំ និងសម្របសម្រួល កជទី២ នៅតាមស្ថាប័ននីមួយៗឱ្យកាន់តែមានប្រសិទ្ធភាព។

ដើម្បីសម្រេចបានលទ្ធផលរំពឹងទុកនេះ សកម្មភាពជាអាទិភាពដែលត្រូវអនុវត្តមានចំនួន០៤ ដូចមានរៀបរាប់ខាងក្រោម ៖

**សកម្មភាពអាទិភាព ១.១.១៖ ការពង្រឹងយន្តការដឹកនាំសម្របសម្រួលកម្មវិធីកំណែទម្រង់នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ**

សកម្មភាពនេះ ផ្តោតលើការពង្រឹងយន្តការដឹកនាំ និងសម្របសម្រួលកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលរួមមាន គ.ជ.អ.ប. អនុគណៈកម្មាធិការនៃ គ.ជ.អ.ប. គ.ដ.វ.វ. និងលេខាធិការដ្ឋាន គ.ជ.អ.ប. ដើម្បីធានាដល់ការរៀបចំគោលនយោបាយ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត កម្មវិធី និងផែនការពាក់ព័ន្ធនឹងកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិឱ្យស្របតាមតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ស្ថាប័ននីមួយៗប្រកបដោយប្រសិទ្ធភាពដោយមានការគិតគូរដល់ការលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម។ ដើម្បីធានាឱ្យមានសង្គតិភាពនៃការរៀបចំគោលនយោបាយ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត ផែនការយុទ្ធសាស្ត្រតាមវិស័យនីមួយៗជាមួយនឹងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ព្រមទាំងកម្មវិធីជាតិចាំបាច់ត្រូវមានការពិគ្រោះយោបល់ ឬការពិនិត្យ និងអនុម័តដោយ គ.ជ.អ.ប.។

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពជាអាទិភាពនេះរួមមាន ៖

- រៀបចំកិច្ចប្រជុំ គ.ជ.អ.ប. ឱ្យបានទៀងទាត់ ដើម្បីពិនិត្យ ផ្តល់យោបល់ និងអនុម័តលើសេចក្តីព្រាងគោលនយោបាយ ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា កម្មវិធី និងផែនការ ព្រមទាំងត្រួតពិនិត្យវឌ្ឍនភាព និងដោះស្រាយបញ្ហាប្រឈមនានានៃការអនុវត្តការងារកំណែទម្រង់
- ពង្រឹងការអនុវត្តតួនាទី និងភារកិច្ចរបស់អនុគណៈកម្មាធិការ គ.ជ.អ.ប. ក្នុងការពិនិត្យ និងផ្តល់យោបល់ជូន គ.ជ.អ.ប. ពាក់ព័ន្ធនឹងការរៀបចំរចនាសម្ព័ន្ធ មុខងារ ធនធានមនុស្ស ហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ ផែនការ និងកិច្ចការចាំបាច់ផ្សេងៗទៀតពាក់ព័ន្ធនឹងកំណែទម្រង់
- ពង្រឹងការអនុវត្តតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ គ.ដ.វ.វ. របស់ក្រសួង ស្ថាប័ននីមួយៗ ដើម្បីធានាដល់ការចូលរួមអនុវត្តការងារកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងក្របខ័ណ្ឌសមត្ថកិច្ចនៃក្រសួង ស្ថាប័ននីមួយៗ ព្រមទាំងធានាដល់សង្គតិភាពនៃការរៀបចំគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ផែនការយុទ្ធសាស្ត្រតាមវិស័យនីមួយៗ ជាមួយនឹងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ
- ពិនិត្យមើលឡើងវិញនូវយន្តការ គ.ដ.វ.វ. នៅថ្នាក់ក្រោមជាតិ និងពង្រឹងតួនាទី ភារកិច្ច និងរបៀបរបបធ្វើការងាររបស់ គ.ដ.វ.វ. នៅថ្នាក់ក្រោមជាតិ ដើម្បីធានាដល់ការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការឱ្យមានប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព

- ពង្រឹងការអនុវត្តតួនាទី ភារកិច្ច និងរបៀបរបបការងារ ព្រមទាំងការអភិវឌ្ឍសមត្ថភាព លេខាធិការដ្ឋាន គ.ជ.អ.ប. ដើម្បីបំពេញតួនាទីជាសេនាធិការជូន គ.ជ.អ.ប. ក្នុងការគ្រប់គ្រង សម្របសម្រួល និងអនុវត្ត កជទី២
- ពិនិត្យ និងកែសម្រួលសៀវភៅណែនាំស្តីពីនីតិវិធីប្រតិបត្តិរបស់ គ.ជ.អ.ប.។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ គ.ជ.អ.ប. អនុគណៈកម្មាធិការ គ.ជ.អ.ប. គ.ដ.វ.វ. និងលេខាធិការដ្ឋាន គ.ជ.អ.ប.

**ស្ថាប័នចូលរួមអនុវត្ត** ៖ ក្រសួង ស្ថាប័នជាសមាជិក គ.ជ.អ.ប.

**តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ១.១.១.**

| ល.រ. | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | ការរៀបចំកិច្ចប្រជុំ គ.ជ.អ.ប. | ២ | ២ | ២ | ២ | ២ | ២ |
| ២ | ការរៀបចំកិច្ចប្រជុំ គ.ដ.វ.វ. របស់ក្រសួង ស្ថាប័ន | ១២ | ១២ | ១២ | ១២ | ១២ | ១២ |
| ៣ | ការរៀបចំកិច្ចប្រជុំ គ.ដ.វ.វ. របស់រដ្ឋបាលរាជធានី ខេត្ត | ១២ | ១២ | ១២ | ១២ | ១២ | ១២ |
| ៤ | សេចក្តីព្រាងគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ផែនការ និងរបាយការណ៍នានាដែលបានរៀបចំ ដើម្បីដាក់ជូន គ.ជ.អ.ប. ពិនិត្យ និងអនុម័ត | ៥ | ៥* | ៥* | ៥* | ៥* | ៥* |
| ៥ | ការរៀបចំ និងដាក់ចេញលិខិតបទដ្ឋានស្តីពីការកែសម្រួល គ.ដ.វ.វ. ថ្នាក់ក្រោមជាតិ | | អនុម័ត | | | | |
| ៦ | ពិនិត្យ និងកែសម្រួលសៀវភៅណែនាំស្តីពីនីតិវិធីប្រតិបត្តិរបស់ គ.ជ.អ.ប. | | អនុម័ត | | | | |

*សម្គាល់ ៖ (១). ផែនការសកម្មភាព និងថវិកាប្រចាំរបស់ គ.ជ.អ.ប. (២). របាយការណ៍វឌ្ឍនភាពប្រចាំឆមាសរបស់ គ.ជ.អ.ប. (៣). របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំរបស់ គ.ជ.អ.ប. (៤). លិខិតបទដ្ឋានគតិយុត្តផ្សេងៗ និង (៥). របាយការណ៍សិក្សាផ្សេងៗ

## សកម្មភាពអាទិភាព ១.១.២.៖ ការពង្រឹងកិច្ចសហប្រតិបត្តិការរវាងកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការជាមួយកម្មវិធីកំណែទម្រង់គន្លឹះនានា

សកម្មភាពនេះ ផ្តោតលើការពង្រឹងកិច្ចសហប្រតិបត្តិការរវាងកម្មវិធីកែទម្រង់អភិបាលកិច្ចនានារបស់រាជរដ្ឋាភិបាល រួមមាន កម្មវិធីកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ កម្មវិធីកែទម្រង់ច្បាប់ និងកម្មវិធីកែទម្រង់ប្រព័ន្ធយុត្តិធម៌ ដើម្បីធានាសង្គតិភាព ភាពប្រទាក់ក្រឡាគ្នា និងការគាំទ្រគ្នាទៅវិញទៅមក សំដៅលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្ត និងការគ្រប់គ្រងកម្មវិធីកំណែទម្រង់គន្លឹះទាំងនេះ។

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពជាអាទិភាពនេះរួមមាន ៖

- រៀបចំកិច្ចប្រជុំប្តូរវេនប្រចាំត្រីមាសរបស់លេខាធិការដ្ឋាននៃកម្មវិធីកែទម្រង់គន្លឹះនានា
- រៀបចំ និងអនុវត្តផែនការសកម្មភាពរួមប្រចាំឆ្នាំនៃកម្មវិធីកែទម្រង់គន្លឹះនានា
- រៀបចំកិច្ចប្រជុំប្រចាំឆ្នាំរវាងកំណែទម្រង់គន្លឹះទាំង៥។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ លេខាធិការដ្ឋាននៃកម្មវិធីកែទម្រង់គន្លឹះនានា

**ស្ថាប័នចូលរួមអនុវត្ត** ៖ ក្រសួង ស្ថាប័នជាសមាជិកនៃគណៈកម្មាធិការដឹកនាំកម្មវិធីកែទម្រង់គន្លឹះ

**តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ១.១.២.**

| ល.រ. | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | ការរៀបចំកិច្ចប្រជុំប្ដូរវេនប្រចាំត្រីមាស | ២ | ៤ | ៤ | ៤ | ៤ | ៤ |
| ២ | ការរៀបចំផែនការសកម្មភាពរួមប្រចាំឆ្នាំនៃកំណែទម្រង់គន្លឹះនានា | ១ | ១ | ១ | ១ | ១ | ១ |
| ៣ | ការរៀបចំកិច្ចប្រជុំប្រចាំឆ្នាំនៃកំណែទម្រង់គន្លឹះ | ១ | ១ | ១ | ១ | ១ | ១ |

**សកម្មភាពអាទិភាព ១.១.៣.៖ ការរៀបចំវេទិកា ព្រឹត្តិការណ៍នានា និងការចែករំលែកមេរៀនបទពិសោធន៍ ដើម្បីលើកកម្ពស់ការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ**

សកម្មភាពនេះ ផ្ដោតលើការរៀបចំឱ្យមានវេទិកា និងព្រឹត្តិការណ៍នានាសម្រាប់ការពិភាក្សា ការពិគ្រោះយោបល់រវាងរាជរដ្ឋាភិបាល ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងអ្នកពាក់ព័ន្ធនានា ដើម្បីរួមគ្នាវាយតម្លៃអំពីវឌ្ឍនភាពនៃការអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ការកំណត់នូវបញ្ហាប្រឈមជាគន្លឹះនានា និងការដាក់ចេញនូវវិធានការដោះស្រាយ និងការតម្រង់ទិសផ្នែកគោលនយោបាយដើម្បីសម្រួចការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងការចូលរួមអនុវត្តយុទ្ធសាស្ត្របញ្ចកោណ និងគោលនយោបាយគន្លឹះនានារបស់រាជរដ្ឋាភិបាលសំដៅសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០។ ទន្ទឹមនេះ សកម្មភាពនេះក៏មានគោលបំណងក្នុងការពង្រឹងសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការចងក្រង ការចែករំលែកមេរៀន និងបទពិសោធន៍នានាក្នុងចំណោមរដ្ឋបាលថ្នាក់ក្រោមជាតិ អំពីការដឹកនាំ ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារ និងធនធានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពជាអាទិភាពនេះរួមមាន ៖

- រៀបចំវេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិស្ដីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីចូលរួមសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០
- រៀបចំសន្និបាតឃុំ សង្កាត់តាមអាណត្តិនីមួយៗ ដើម្បីវាយតម្លៃលទ្ធផលការងាររបស់រដ្ឋបាលឃុំ សង្កាត់ និងការដាក់ចេញគោលនយោបាយអភិវឌ្ឍឃុំ សង្កាត់តាមអាណត្តិនីមួយៗ
- រៀបចំព្រឹត្តិការណ៍ផ្សេងទៀតតាមការចាំបាច់ ដើម្បីផ្សព្វផ្សាយ ឆ្លុះបញ្ចាំងអំពីវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្តកំណែទម្រង់ ការចែករំលែកបទពិសោធន៍ និងការពិភាក្សា ពិគ្រោះយោបល់នានា
- រៀបចំចងក្រង និងចែករំលែកមេរៀន បទពិសោធន៍ និងគំនិតផ្តួចផ្តើមនានាស្តីពីការដឹកនាំ ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារ និងធនធានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ លេខាធិការដ្ឋាន គ.ជ.អ.ប. និងក្រសួងមហាផ្ទៃ

**ស្ថាប័នចូលរួមអនុវត្ត** ៖ ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល

**តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ១.១.៣.**

| ល.រ. | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | ការរៀបចំវេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ | ១ | | | ១ | | |
| ២ | ការរៀបចំសន្និបាតឃុំ សង្កាត់ | | ១ | | | | |
| ៣ | ការចងក្រងមេរៀន បទពិសោធន៍ និងគំនិតផ្តួចផ្តើមនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | | ៣ | ៣ | ៣ | ៣ | ៣ |

## សកម្មភាពអាទិភាព ១.១.៤.៖ ការពង្រឹងយន្តការលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គមនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

សកម្មភាពនេះផ្តោតលើការលើកកម្ពស់ការយកចិត្តទុកដាក់ និងការឆ្លើយតបទៅនឹងបញ្ហា និងតម្រូវការនានារបស់ស្ត្រី យុវជន កុមារ និងក្រុមជនងាយរងគ្រោះនានានៅក្នុងការអនុវត្ត ជអ៥ទី២ ជាពិសេសក្នុងការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋានដោយរដ្ឋបាលថ្នាក់ក្រោមជាតិស្របតាមគោលនយោបាយ ផែនការយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល និងផែនការយុទ្ធសាស្ត្ររបស់ គ.ជ.អ.ប. ស្តីពីការលើកកម្ពស់សមភាពយេនឌ័រសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

ក្រុមការងារយេនឌ័រដែលត្រូវបានបង្កើតឡើងក្នុងក្របខ័ណ្ឌនៃ គ.ជ.អ.ប. នឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តួចផ្តើមសិក្សា លើកយោបល់ ព្រមទាំងតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តគោលនយោបាយសមភាពយេនឌ័រ ដែលត្រូវបានអនុវត្តដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពជាអាទិភាពនេះរួមមាន ៖

- ពង្រឹងសមត្ថភាព និងការបំពេញតួនាទី ភារកិច្ចរបស់ក្រុមការងារយេនឌ័រនៃ គ.ជ.អ.ប. សម្រាប់គាំទ្រការអនុវត្ត ជអ៥ទី២
- ពង្រឹងសមត្ថភាព និងការអនុវត្តតួនាទី ភារកិច្ចនៃយន្តការទទួលបន្ទុកការងារយេនឌ័រនៅតាមរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គមក្នុងដំណើរការនៃការរៀបចំ និងអនុវត្តគោលនយោបាយ លិខិតបទដ្ឋានគតិយុត្តនានា ផែនការ ថវិកា បុគ្គលិក ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន
- សិក្សា និងរៀបចំលិខិតបទដ្ឋាន ឬឯកសារបច្ចេកទេសសម្រាប់អនុវត្តគោលនយោបាយយេនឌ័រ ព្រមទាំងតាមដាន និងត្រួតពិនិត្យលើការអនុវត្តគោលនយោបាយយេនឌ័រ
- រៀបចំសវនកម្មយេនឌ័រ។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ លេខាធិការដ្ឋាន គ.ជ.អ.ប. ក្រសួងមហាផ្ទៃ និងក្រសួងកិច្ចការនារី

**ស្ថាប័នចូលរួមអនុវត្ត** ៖ ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលនានា

**តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ១.១.៤.**

| ល.រ. | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | ការរៀបចំកិច្ចប្រជុំក្រុមការងារយេនឌ័រនៃ គ.ជ.អ.ប. | | ៤ | ៤ | ៤ | ៤ | ៤ |
| ២ | ការរៀបចំកិច្ចប្រជុំ គ.ក.ស.ក. រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និង គ.ក.ន.ក. ឃុំ សង្កាត់នីមួយៗ | ១២ | ១២ | ១២ | ១២ | ១២ | ១២ |
| ៣ | ការរៀបចំសវនកម្មយេនឌ័រ | ២ | | ១ | | | ១ |

**លទ្ធផលរំពឹងទុក ១.២.៖ កំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិត្រូវបានផ្សព្វផ្សាយ ដើម្បីបង្កើនការយល់ដឹង និងការគាំទ្រយ៉ាងទូលំទូលាយពីក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានា**

ការយល់ដឹងបានទូលំទូលាយរបស់ភាគីពាក់ព័ន្ធអំពី កជទី២/ផអ៥ទី២ និងគោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការពិតជាមានសារៈសំខាន់ក្នុងការធានាដល់ការចូលរួម ការគាំទ្រក្នុងការរៀបចំ និងការអនុវត្ត ផអ៥ទី២ និង ផ.ស.ថ. ប្រចាំឆ្នាំរបស់ គ.ជ.អ.ប. ឱ្យសម្រេចបាននូវចក្ខុវិស័យ គោលបំណង គោលដៅ សមិទ្ធផល និងលទ្ធផលរំពឹងទុករបស់ ផអ៥ទី២ នៃកជទី២ ជាពិសេសគឺការយល់ដឹងទូលំទូលាយរបស់ប្រជាពលរដ្ឋអំពីមុខងារ តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន ដើម្បីលើកកម្ពស់សិទ្ធិអំណាចក្នុងការចូលរួម ការតាមដាន និងការត្រួតពិនិត្យរបស់ប្រជាពលរដ្ឋលើការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

ក្នុងអំឡុង កជទី១ គ.ជ.អ.ប. បានរៀបចំ និងដាក់ចេញនូវយុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទងសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងបានផ្សព្វផ្សាយយ៉ាងទូលំទូលាយតាមរយៈមធ្យោបាយផ្សេងៗដល់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងភាគីពាក់ព័ន្ធនានា។ ដោយឡែក សម្រាប់ កជទី២ ក៏ចាំបាច់ត្រូវពិនិត្យ និងកែលម្អនូវយុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទងឱ្យស្របទៅតាមនៃការវិវត្តនៃកំណែទម្រង់ និងបច្ចេកវិទ្យាឌីជីថល ដើម្បីលើកកម្ពស់ការផ្សព្វផ្សាយអំពី កជទី២/ផអ៥ទី២ និងគោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការឱ្យបានទូលំទូលាយ និងបញ្ជ្រាបការយល់ដឹងដល់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ សាធារណជន និងអ្នកពាក់ព័ន្ធនានា។

ដើម្បីសម្រេចបានលទ្ធផលរំពឹងទុកនេះ សកម្មភាពជាអាទិភាពដែលត្រូវអនុវត្តមានចំនួន**០២** ដូចមានរៀបរាប់ខាងក្រោម ៖

## សកម្មភាពអាទិភាព ១.២.១.៖ ការកែលម្អ និងអនុវត្តយុទ្ធសាស្ត្រប្រាស្រ័យទាក់ទងស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

សកម្មភាពនេះ ផ្តោតលើការរៀបចំបញ្ចប់ អនុម័ត និងដាក់ឱ្យអនុវត្តនូវយុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទងសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលបានពិនិត្យ និងកែលម្អក្នុងអំឡុង ផអ៥ទី១។ យុទ្ធសាស្ត្រនេះ នឹងត្រូវធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់ក្រុមគោលដៅពាក់ព័ន្ធនានា រួមមាន ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល វិស័យឯកជន ប្រជាពលរដ្ឋ និងភាគីពាក់ព័ន្ធនានា សំដៅលើកកម្ពស់ការយល់ដឹង និងការចូលរួមក្នុងការអនុវត្តកម្មវិធីកំណែទម្រង់នេះ។

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពជាអាទិភាពនេះរួមមាន ៖

- រៀបចំបញ្ចប់ និងអនុម័តយុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទងសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដោយមានការគិតគូរដល់ការលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម
- រៀបចំ និងផ្សព្វផ្សាយយុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទងសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដែលបានអនុម័ត ដោយខិតខំកៀរគរការចូលរួម និងកិច្ចសហការជាមួយក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ វិស័យឯកជន/គ្រឹះស្ថានអប់រំ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងភាគីពាក់ព័ន្ធផ្សេងៗទៀតដល់ក្រុមគោលដៅពាក់ព័ន្ធនានាតាមមធ្យោបាយ និងឧបករណ៍ផ្សេងៗ
- រៀបចំ និងផ្សព្វផ្សាយកញ្ចប់ព័ត៌មានអំពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ កជទី២/ផអ៥ទី២ រួមបញ្ចូលការលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម និងឯកសារពាក់ព័ន្ធផ្សេងទៀត
- ពង្រឹងសមត្ថភាពមន្ត្រីទទួលបន្ទុកការងារប្រាស្រ័យទាក់ទង និងផ្សព្វផ្សាយព័ត៌មានទាំងនៅថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិអំពីការរៀបចំ និងការផ្សព្វផ្សាយព័ត៌មាន
- ពង្រឹង កែលម្អ និងធ្វើឱ្យមានលក្ខណៈទំនើបនូវហេដ្ឋារចនាសម្ព័ន្ធ ប្រព័ន្ធ ឧបករណ៍ និងសម្ភារនានាសម្រាប់ការផ្សព្វផ្សាយតាមប្រព័ន្ធឌីជីថល។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ លេខាធិការដ្ឋាន គ.ជ.អ.ប.

**ស្ថាប័នចូលរួមអនុវត្ត** ៖ ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងភាគីពាក់ព័ន្ធផ្សេងទៀត

### តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ១.២.១.

| ល.រ | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | ការអនុម័ត និងដាក់ឱ្យអនុវត្តនូវយុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទងសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិប | សេចក្តីព្រាង | អនុម័ត | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | គេយ្យនៅថ្នាក់ក្រោមជាតិ | | | | | | |
| ២ | ការរៀបចំកញ្ចប់ព័ត៌មានអំពីកំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ កជទី២/ផអ៥ទី២ និងឯកសារពាក់ព័ន្ធផ្សេងទៀត | | រៀបចំ | អនុវត្ត | អនុវត្ត | អនុវត្ត | អនុវត្ត |
| ៣ | ចំនួនឯកសារព័ត៌មានអំពីការងារកំណែទម្រង់ដែលបានផ្សព្វផ្សាយ | ១០ | ១០ | ១០ | ១០ | ១០ | ១០ |
| ៤ | ចំនួនវេទិកា ឬកម្មវិធីផ្សព្វផ្សាយអំពីកម្មវិធីកំណែទម្រង់ដែលបានអនុវត្តត្រូវបានផ្សព្វផ្សាយ | ៥ | ៥ | ៥ | ៥ | ៥ | ៥ |
| ៥ | ចំនួនអ្នកចូលទស្សនាប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរបស់ គ.ជ.អ.ប. ប្រចាំឆ្នាំមានការកើនឡើង (១). បណ្ណាល័យអេឡិចត្រូនិច (២). គេហទំព័រ គ.ជ.អ.ប. (៣). Facebook Page (៤). YouTube channel | ១). ១២លាន<br>២). ៦៤០.០០០<br>៣). ៤២.០០០<br>៤). ២.៥០០ | កើនឡើង | កើនឡើង | កើនឡើង | កើនឡើង | កើនឡើង |

## សកម្មភាពអាទិភាព ១.២.២.៖ ការត្រួតពិនិត្យ និងវាយតម្លៃយុទ្ធសាស្ត្រប្រាស្រ័យទាក់ទងស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

សកម្មភាពនេះ ផ្តោតទៅលើការត្រួតពិនិត្យ និងការគាំទ្រជាប្រចាំលើការរៀបចំ និងការអនុវត្តសកម្មភាពផ្សព្វផ្សាយនានាទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិអំពីកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ជាពិសេស កជទី២/ផអ៥ទី២ សំដៅលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តសកម្មភាពផ្សព្វផ្សាយទាំងនោះ។ ទន្ទឹមនេះ នៅក្នុងឆ្នាំ២០២៩ នឹងត្រូវអនុវត្តការវាយតម្លៃ ឬការអង្កេតនានា ដើម្បីវាស់វែងអំពីសមិទ្ធផលនៃការអនុវត្តយុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទង។

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពជាអាទិភាពនេះរួមមាន ៖

- ត្រួតពិនិត្យ និងគាំទ្រជាប្រចាំលើការរៀបចំ និងការអនុវត្តសកម្មភាពផ្សព្វផ្សាយនានាទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិអំពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ជាពិសេសការផ្សព្វផ្សាយព័ត៌មានអំពី កជទី២/ផអ៥ទី២
- រៀបចំការវាយតម្លៃ ឬការអង្កេត ដើម្បីវាស់វែងអំពីការផ្លាស់ប្តូរនូវការយល់ដឹង ឥរិយាបថ និងអាកប្បកិរិយារបស់ក្រុមជនគោលដៅនានា។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ លេខាធិការដ្ឋាន គ.ជ.អ.ប.

**ស្ថាប័នចូលរួមអនុវត្ត** ៖ ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ វិស័យឯកជន ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងភាគីពាក់ព័ន្ធផ្សេងទៀត

### តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ១.២.២.

| ល.រ. | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | ការវាយតម្លៃ ឬការអង្កេត ដើម្បីវាស់វែងលទ្ធផលនៃការប្រាស្រ័យទាក់ទង | | | | | ១ | |

## លទ្ធផលរំពឹងទុក ១.៣.៖ ផែនការអនុវត្តរយៈពេល៥ឆ្នាំ ដំណាក់កាលទី២ ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ

ផែនការអនុវត្ត៥ឆ្នាំ ដំណាក់កាលទី២ នៃកជទី២ គឺជាដំណាក់កាលចុងក្រោយ និងជាដំណាក់កាលមួយដ៏មានសារៈសំខាន់ក្នុងការសម្រេចគោលដៅ និងគោលបំណងរបស់ កជទី២ និងឈានទៅសម្រេចបាននូវចក្ខុវិស័យរបស់ កជទី២ "**ប្រជាពលរដ្ឋទទួលបានផលប្រយោជន៍ពីសេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានប្រកបដោយបរិយាបន្ន និងសមធម៌សង្គម**"។

ដើម្បីធានាការសម្រេចបាននូវគោលដៅ គោលបំណង សមិទ្ធផល និងលទ្ធផលរំពឹងទុកនៃ ផអ៥ទី២ ចាំបាច់ត្រូវរៀបចំ និងអនុវត្តប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនូវផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំដែលត្រូវរៀបចំឡើងដោយមានការពិគ្រោះយោបល់ឱ្យបានទូលំទូលាយ និងការចូលរួមអនុវត្តពីក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល វិស័យឯកជន និងអ្នកពាក់ព័ន្ធនានា។ ក្នុងន័យនេះ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាពនៃ ផ.ស.ថ. ប្រចាំឆ្នាំនីមួយៗ ត្រូវរៀបចំឱ្យមានភាពច្បាស់លាស់តាមគោលការណ៍ SMART (**ត្រូវមានលក្ខណៈជាក់លាក់ អាចវាស់វែងបាន អាចសម្រេចបាន មានភាពពាក់ព័ន្ធនឹងតម្រូវការជាក់ស្តែង និងមានពេលវេលាសម្រាប់អនុវត្តជាក់លាក់**)។ ជាមួយគ្នានេះ ក៏ចាំបាច់ត្រូវមានការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើវឌ្ឍនភាពនៃការអនុវត្ត ផ.ស.ថ. ប្រចាំឆ្នាំ និងការវាយតម្លៃ កជទី២ នៅឆ្នាំ២០៣០ ដើម្បីជាមូលដ្ឋានសម្រាប់ការគិតគូរការរៀបចំកម្មវិធីជាតិដំណាក់កាលបន្ទាប់។

ដើម្បីសម្រេចបានលទ្ធផលរំពឹងទុកនេះ សកម្មភាពជាអាទិភាពដែលត្រូវអនុវត្តមានចំនួន០៤ ដូចមានរៀបរាប់ខាងក្រោម ៖

### សកម្មភាពអាទិភាព ១.៣.១.៖ ការផ្សព្វផ្សាយ និងការអនុវត្តផែនការអនុវត្ត៥ឆ្នាំ ដំណាក់កាលទី២ (២០២៦-២០៣០)

សកម្មភាពនេះ ផ្តោតលើការផ្សព្វផ្សាយដាក់ឱ្យអនុវត្តនូវផែនការអនុវត្ត៥ឆ្នាំ ដំណាក់កាលទី២ (២០២៦-២០៣០) ដល់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល វិស័យឯកជន និងអ្នកពាក់ព័ន្ធនានា។

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពជាអាទិភាពនេះរួមមាន ៖

- រៀបចំសិក្ខាសាលាផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្ត ផអ៥ទី២
- បោះពុម្ព និងផ្សព្វផ្សាយឯកសារ ផអ៥ទី២។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ លេខាធិការដ្ឋាន គ.ជ.អ.ប.

**ស្ថាប័នចូលរួមអនុវត្ត** ៖ ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលពាក់ព័ន្ធ

**តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ១.៣.១.**

| ល.រ. | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | ពិធីប្រកាសផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្តជាផ្លូវការនូវផអ៥ទី២ | | ១ | | | | |
| ២ | សិក្ខាសាលា/កិច្ចប្រជុំ/វេទិកាផ្សព្វផ្សាយ ផអ៥ទី២ | | ៣ | ៣ | ៣ | ៣ | ៣ |

## សកម្មភាពអាទិភាព ១.៣.២៖ ការរៀបចំ និងអនុវត្ត ផ.ស.ថ. ប្រចាំឆ្នាំរបស់ គ.ជ.អ.ប. ប្រកបដោយប្រសិទ្ធភាព

សកម្មភាពនេះ ផ្តោតលើការរៀបចំ និងការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ គ.ជ.អ.ប. ដោយដាក់បញ្ចូលនូវសកម្មភាព និងថវិការបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ និងគម្រោង/កម្មវិធីដាច់ដោយឡែកនានាដែលគាំទ្រ ផ.ស.ថ. ប្រចាំឆ្នាំ។ គ.ជ.អ.ប. ត្រូវធានាឱ្យមានការពិគ្រោះយោបល់ឱ្យបានទូលំទូលាយពីក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល វិស័យឯកជន និងអ្នកពាក់ព័ន្ធនានាក្នុងដំណើរការរៀបចំ ផ.ស.ថ. ប្រចាំឆ្នាំនីមួយៗ។ ផ.ស.ថ. ប្រចាំឆ្នាំរបស់ គ.ជ.អ.ប. ត្រូវបានពិនិត្យ និងអនុម័តដោយ គ.ជ.អ.ប.។

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពជាអាទិភាពនេះរួមមាន ៖

- ពិនិត្យមើលឡើងវិញនូវគោលការណ៍ណែនាំស្តីពីការរៀបចំ ផ.ស.ថ. ប្រចាំឆ្នាំរបស់ គ.ជ.អ.ប. ការរៀបចំសេចក្តីសម្រេចរួមរវាង គ.ជ.អ.ប. និងក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងផ្សព្វផ្សាយអនុវត្ត
- រៀបចំ និងអនុវត្ត ផ.ស.ថ. ប្រចាំឆ្នាំរបស់ គ.ជ.អ.ប.
- រៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំឆមាស និងប្រចាំឆ្នាំស្តីពីការអនុវត្ត ផ.ស.ថ. ជូន គ.ជ.អ.ប. និងរាជរដ្ឋាភិបាល។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ លេខាធិការដ្ឋាន គ.ជ.អ.ប.

**ស្ថាប័នចូលរួមអនុវត្ត** ៖ ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងភាគីពាក់ព័ន្ធផ្សេងទៀត

**តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ១.៣.២.**

| ល.រ. | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | ផ.ស.ថ. ប្រចាំឆ្នាំរបស់ គ.ជ.អ.ប. ដែលបានអនុម័តដោយ គ.ជ.អ.ប. | ១ | ១ | ១ | ១ | ១ | ១ |
| ២ | របាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំស្តីពីការអនុវត្ត ផ.ស.ថ ដែលបានអនុម័តដោយ គ.ជ.អ.ប. | ២ | ២ | ២ | ២ | ២ | ២ |

| ល.រ. | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ៣ | របាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការដែលបានដាក់ជូនប្រមុខរាជរដ្ឋាភិបាល | ១ | ២ | ២ | ២ | ២ | ២ |
| ៤ | គោលការណ៍ណែនាំស្តីពីការរៀបចំ ផ.ស.ថ. ប្រចាំឆ្នាំរបស់ គ.ជ.អ.ប. ដែលបានអនុម័ត | | អនុម័ត | | | | |

## សកម្មភាពអាទិភាព ១.៣.៣.៖ ការលើកកម្ពស់កិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលក្នុងការដឹកនាំ សម្របសម្រួល និងអនុវត្ត ជអ៥ទី២

សកម្មភាពនេះ ផ្តោតលើការលើកកម្ពស់កិច្ចសហការ ការចូលរួម និងការគាំទ្ររបស់ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលនានាក្នុងដំណើរការរៀបចំ និងអនុវត្ត ផ.ស.ថ. ប្រចាំឆ្នាំនៃ ជអ៥ទី២ (ទាំងការគាំទ្រទៅលើសកម្មភាពស្នូលនៃ ជអ៥ទី២/ផ.ស.ថ. ប្រចាំឆ្នាំរបស់ គ.ជ.អ.ប. និងការគាំទ្រទៅលើការរៀបចំ និងការអនុវត្តគម្រោង/កម្មវិធីដាច់ដោយឡែក)។ ទន្ទឹមនេះ គ.ជ.អ.ប. ក៏ត្រូវធានាឱ្យមានការចូលរួមពិគ្រោះយោបល់ពីដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលនានាក្នុងដំណើរការរៀបចំគោលនយោបាយ និងលិខិតបទដ្ឋាននានាពាក់ព័ន្ធនឹងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពជាអាទិភាពនេះរួមមាន ៖

- រៀបចំកិច្ចប្រជុំសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលនានាក្នុងការរៀបចំ ការអនុវត្ត និងការគ្រប់គ្រង ផ.ស.ថ. ព្រមទាំងការរៀបចំគោលនយោបាយ និងលិខិតបទដ្ឋានពាក់ព័ន្ធនានា
- រៀបចំកិច្ចប្រជុំជាទៀងទាត់ជាមួយនឹងអង្គការសង្គមស៊ីវិល
- សិក្សា រៀបចំគម្រោង/កម្មវិធីនានាដែលគាំទ្រដោយដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល
- ពង្រឹងការអនុវត្តសវនកម្មផ្ទៃក្នុងលើគម្រោង/កម្មវិធីដែលគាំទ្រដោយដៃគូអភិវឌ្ឍន៍ស្របតាមគោលការណ៍ និងនីតិវិធីដែលបានកំណត់
- សម្របសម្រួល និងគាំទ្រការអនុវត្តសវនកម្មផ្ទៃក្រៅលើគម្រោង/កម្មវិធីដាច់ដោយឡែកនានា។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ លេខាធិការដ្ឋាន គ.ជ.អ.ប. និងក្រសួងមហាផ្ទៃ

**ស្ថាប័នចូលរួមអនុវត្ត** ៖ ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងភាគីពាក់ព័ន្ធនានា

### តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ១.៣.៣.

| ល.រ. | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | កិច្ចប្រជុំក្រុមការងារបច្ចេកទេសស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(TWG-SNDD) | ១ | ១ | ១ | ១ | ១ | ១ |
| ២ | កិច្ចប្រជុំជាមួយនឹងអង្គការសង្គមស៊ីវិល | ១ | ១ | ១ | ១ | ១ | ១ |

## សកម្មភាពអាទិភាព ១.៣.៤៖ ការត្រួតពិនិត្យ និងការវាយតម្លៃលើការអនុវត្ត ផអ៥ទី២

សកម្មភាពនេះ ផ្តោតលើការលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្ត ផ.ស.ថ. និងគម្រោង/កម្មវិធីដាក់ដោយឡែកនានា តាមរយៈការពង្រឹងការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃ រួមបញ្ចូលការអនុវត្តសវនកម្មផ្ទៃក្នុង និងសវនកម្មពីខាងក្រៅជាប្រចាំលើការអនុវត្ត ផ.ស.ថ. របស់ គ.ជ.អ.ប. និង ផ.ស.ថ. របស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំង ផ.ស.ថ. របស់គម្រោង/កម្មវិធីដាក់ដោយឡែកនានាដែលអនុវត្ត និងគ្រប់គ្រងដោយលេខាធិការដ្ឋាន គ.ជ.អ.ប.។

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពជាអាទិភាពនេះរួមមាន ៖

- ពិនិត្យមើលឡើងវិញលើសៀវភៅណែនាំស្តីពីការធ្វើសវនកម្មផ្ទៃក្នុងរបស់លេខាធិការដ្ឋាន គ.ជ.អ.ប.
- ដាក់ឱ្យអនុវត្តនូវប្រព័ន្ធទិន្នន័យស្តីពីការរៀបចំ និងការគ្រប់គ្រង ផ.ស.ថ. របស់ គ.ជ.អ.ប.
- រៀបចំកិច្ចប្រជុំប្រចាំឆមាសជាមួយស្ថាប័នអនុវត្តនានា ដើម្បីពិនិត្យវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្ត ផ.ស.ថ.
- រៀបចំកិច្ចប្រជុំប្រចាំត្រីមាសជាមួយគម្រោង/កម្មវិធីដាក់ដោយឡែកនានា ដើម្បីពិនិត្យវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្ត ផ.ស.ថ. ឬកិច្ចព្រមព្រៀង
- រៀបចំការអង្កេតអភិបាលកិច្ច
- រៀបចំការអង្កេតវាយតម្លៃសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ
- សិក្សាវាយតម្លៃទៅលើការអនុវត្តច្បាប់រៀបចំអង្គការ ពាក់ព័ន្ធនឹងការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់
- រៀបចំការវាយតម្លៃចុងបញ្ចប់នៃ កជទី២
- រៀបចំតាក់តែងកម្មវិធីជាតិ និងផែនការអនុវត្តដំណាក់កាលបន្ទាប់។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ លេខាធិការដ្ឋាន គ.ជ.អ.ប. និងក្រសួងមហាផ្ទៃ

**ស្ថាប័នចូលរួមអនុវត្ត** ៖ ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងគម្រោង/កម្មវិធីនានា

### តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ១.៣.៤

| ល.រ. | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | សៀវភៅណែនាំស្តីពីការធ្វើសវនកម្មផ្ទៃក្នុងរបស់លេខាធិការដ្ឋាន គ.ជ.អ.ប. | | អនុម័ត | | | | |
| ២ | ប្រព័ន្ធទិន្នន័យស្តីពីការរៀបចំ ផ.ស.ថ. | រៀបចំ | អនុវត្ត | | | | |
| ៣ | របាយការណ៍វាយតម្លៃចុងបញ្ចប់ កជទី២ | | | | | | ១ |
| ៤ | របាយការណ៍វាយតម្លៃច្បាប់រៀបចំអង្គការ | | | | ១ | | |
| ៥ | របាយការណ៍អង្កេតអភិបាលកិច្ច | ១ | | | | ១ | |
| ៦ | របាយការណ៍អង្កេតសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ | ១ | | | | ១ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៧ | កម្មវិធីជាតិ ដំណាក់កាលបន្ទាប់ | | | | | | ១ |
| ៨ | ផែនការអនុវត្តកម្មវិធីជាតិដំណាក់កាលបន្ទាប់ | | | | | | ១ |

### លទ្ធផលរំពឹងទុក ១.៤៖ រចនាសម្ព័ន្ធ និងមុខងាររបស់ក្រសួង ស្ថាប័ននៅថ្នាក់ជាតិត្រូវបានពិនិត្យ និងកែសម្រួលស្របតាមការវិវឌ្ឍនៃកំណែទម្រង់ ដើម្បីពង្រឹងការដឹកនាំ ការសម្របសម្រួល និងការគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិ

ក្នុងក្របខ័ណ្ឌនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីលើកកម្ពស់ប្រសិទ្ធភាព និងគុណភាពនៃការផ្តល់សេវាសាធារណៈឱ្យកាន់តែឆាប់រហ័ស និងឆ្លើយតបទាន់ពេលវេលា និងចំគោលដៅជូនប្រជាពលរដ្ឋ រាជរដ្ឋាភិបាល/ក្រសួង ស្ថាប័នក្នុងវិស័យអាទិភាពនានាបានផ្ទេរមុខងារ និងធនធានជាជំហានៗតាមដំណាក់កាលនីមួយៗទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារទាំងនោះ ក្នុងនោះរួមមាន មុខងារគ្រប់គ្រងនិងផ្តល់សេវាសុខាភិបាល និងមុខងារគ្រប់គ្រងមណ្ឌលថែទាំកុមាររដ្ឋត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ព្រមទាំងមុខងារចំនួន៥៥ នៃវិស័យសំខាន់ៗចំនួន២០ ត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ។ ទន្ទឹមនេះ មុខងារផ្តល់សេវារដ្ឋបាលប្រមាណ ៨០០ប្រភេទសេវាក្នុងវិស័យចំនួន១៤ក៏ត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលត្រូវផ្តល់ជូនប្រជាពលរដ្ឋតាមយន្តការច្រកចេញចូលតែមួយ។

ផ្អែកលើការផ្ទេរមុខងារទាំងនេះ ក្រសួង ស្ថាប័នផ្ទេរមុខងារចាំបាច់ត្រូវពិនិត្យ និងកែសម្រួលរចនាសម្ព័ន្ធ និងមុខងាររបស់ខ្លួនឡើងវិញ ព្រមទាំងកំណត់ឱ្យបានច្បាស់នូវតួនាទី ភារកិច្ចរបស់ក្រសួង ស្ថាប័ននីមួយៗ ដើម្បីទទួលខុសត្រូវក្នុងការរៀបចំគោលនយោបាយ ស្តង់ដាសេវា បទដ្ឋានបច្ចេកទេស ការគាំទ្រ ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃលើការបំពេញមុខងារដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយប្រសិទ្ធភាព ក៏ដូចជាការពង្រឹងគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះក្រសួង ស្ថាប័នថ្នាក់ជាតិ។

ទន្ទឹមនេះ ក៏ចាំបាច់ត្រូវពង្រឹងតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ក្រសួងមហាផ្ទៃ (អគ្គនាយកដ្ឋានរដ្ឋបាល សាលាជាតិរដ្ឋបាលមូលដ្ឋាន អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង អគ្គនាយកដ្ឋានឌីជីថលនិងផ្សព្វផ្សាយអប់រំ អគ្គនាយកដ្ឋានគ្រប់គ្រងធនធានមនុស្ស និងអគ្គនាយកដ្ឋានពាក់ព័ន្ធផ្សេងទៀត) ក្នុងការដឹកនាំ ការសម្របសម្រួលជាមួយក្រសួង ស្ថាប័ននានាក្នុងការគាំទ្រ (ធនធានមនុស្ស ហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ បច្ចេកទេស ការអភិវឌ្ឍសមត្ថភាព...) និងការតាមដាន ការត្រួតពិនិត្យនិងការវាយតម្លៃដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាដល់ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារ និងធនធានដែលបានផ្ទេរឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យកាន់តែមានប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព បរិយាបន្ន និងសមធម៌។

ដើម្បីសម្រេចបានលទ្ធផលរំពឹងទុកនេះ សកម្មភាពជាអាទិភាពដែលត្រូវអនុវត្តមានចំនួន០២ ដូចមានរៀបរាប់ខាងក្រោម ៖

## សកម្មភាពអាទិភាព ១.៤.១.៖ ការកែសម្រួលរចនាសម្ព័ន្ធនៃក្រសួង ស្ថាប័នពាក់ព័ន្ធនានា ដើម្បីគាំទ្ររដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវា

សកម្មភាពនេះ ផ្តោតលើការពិនិត្យ និងកែសម្រួលរចនាសម្ព័ន្ធ ប្រព័ន្ធ មុខងារ និងសិទ្ធិអំណាចរបស់ក្រសួង ស្ថាប័ននានាដែលបានផ្ទេរមុខងាររបស់ខ្លួនទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ សំដៅលើកកម្ពស់ការអនុវត្តតួនាទី ភារកិច្ចរបស់ក្រសួង ស្ថាប័នទាំងនោះក្នុងការរៀបចំគោលនយោបាយ ការតាមដាន ការត្រួតពិនិត្យ ការវាយតម្លៃ រួមទាំងការធ្វើអធិការកិច្ចនិងសវនកម្ម ការអភិវឌ្ឍសមត្ថភាព និងការគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយប្រសិទ្ធភាពខ្ពស់។

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពជាអាទិភាពនេះរួមមាន ៖

- ពិនិត្យ និងកែសម្រួលរចនាសម្ព័ន្ធ ប្រព័ន្ធ មុខងារ និងសិទ្ធិអំណាចរបស់ក្រសួង ស្ថាប័នស្របតាមសេចក្តីណែនាំលេខ០១ របស់រាជរដ្ឋាភិបាលស្តីពីការពិនិត្យឡើងវិញ និងការវិភាគមុខងារ និងរចនាសម្ព័ន្ធក្រសួង ស្ថាប័នដែលបានដាក់ចេញនៅខែឧសភា ឆ្នាំ២០២៤
- វិភាគ និងពិនិត្យមើលឡើងវិញនូវមុខងារ និងធនធានចាំបាច់នានារបស់ក្រសួង ស្ថាប័នដែលត្រូវផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ ក្រសួងមុខងារសាធារណៈ លេខាធិការដ្ឋាន គ.ជ.អ.ប. និងក្រសួង ស្ថាប័នផ្ទេរមុខងារពាក់ព័ន្ធ

**ស្ថាប័នចូលរួមអនុវត្ត** ៖ ក្រសួង ស្ថាប័នពាក់ព័ន្ធ

**តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ១.៤.១.**

| ល.រ. | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | ចំនួនក្រសួងបានពិនិត្យមើលឡើងវិញនូវមុខងារដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ | ១៥ | ១៦ | ១៨ | ២០ | ២២ | ២២ |

## សកម្មភាពអាទិភាព ១.៤.២.៖ ការពង្រឹងតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ក្រសួងមហាផ្ទៃ

សកម្មភាពនេះ ផ្តោតលើការពិនិត្យមើលឡើងវិញ ការវិភាគ និងការកែសម្រួលរចនាសម្ព័ន្ធ ប្រព័ន្ធ តួនាទី ភារកិច្ចរបស់អគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងមហាផ្ទៃ ដើម្បីកំណត់ឡើងវិញនូវរចនាសម្ព័ន្ធ តួនាទី ភារកិច្ចរបស់អង្គភាពនេះឱ្យបានច្បាស់លាស់ និងជាក់លាក់សម្រាប់ទទួលខុសត្រូវក្នុងការដឹកនាំ សម្របសម្រួល និងគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយប្រសិទ្ធភាព និងគណនេយ្យភាព។ កិច្ចការនេះ ត្រូវអនុវត្តស្របតាមសេចក្តីណែនាំលេខ០១ របស់រាជរដ្ឋាភិបាលស្តីពីការពិនិត្យឡើងវិញ និងការវិភាគមុខងារ និងរចនាសម្ព័ន្ធក្រសួង ស្ថាប័នដែលបានដាក់ចេញនៅខែឧសភា ឆ្នាំ២០២៤។

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពជាអាទិភាពនេះរួមមាន ៖

- សិក្សា និងវិភាគអំពីរចនាសម្ព័ន្ធ មុខងាររបស់ក្រសួងមហាផ្ទៃក្នុងការដឹកនាំ និងការគ្រប់គ្រងរដ្ឋបាលដែនដីគ្រប់ថ្នាក់ស្របតាមច្បាប់រៀបចំអង្គការ
- សិក្សាអំពីមេរៀន និងបទពិសោធន៍ពីបណ្ដាប្រទេសនានាក្នុងតំបន់ និងប្រទេសផ្សេងទៀត អំពីតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ស្ថាប័នទទួលបន្ទុកក្នុងការដឹកនាំ ការសម្របសម្រួល និងការគាំទ្ររដ្ឋបាលថ្នាក់ក្រោមជាតិ
- ពង្រឹងការទទួលខុសត្រូវ គាំទ្រ និងអភិវឌ្ឍសមត្ថភាពអង្គភាពពាក់ព័ន្ធនានានៃក្រសួងមហាផ្ទៃ។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ ក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប.

**ស្ថាប័នចូលរួមអនុវត្ត** ៖ ក្រសួង ស្ថាប័នពាក់ព័ន្ធ

**តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ១.៤.២.**

| ល.រ | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | ការរៀបចំរចនាសម្ព័ន្ធនិងមុខងាររបស់ក្រសួងមហាផ្ទៃត្រូវបានរៀបចំឡើងវិញ | | ១ | | | | |
| ២ | របាយការណ៍សិក្សាអំពីតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ស្ថាប័នទទួលបន្ទុកក្នុងការដឹកនាំ សម្របសម្រួល និងគាំទ្ររដ្ឋបាលថ្នាក់ក្រោមជាតិ | | | ១ | | | |

**លទ្ធផលរំពឹងទុក ១.៥.៖ សមាគមជាតិក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពង្រឹង ដើម្បីបម្រើឱ្យផលប្រយោជន៍ និងអភិវឌ្ឍសមត្ថភាពរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ**

ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិបាននិងកំពុងបំពេញតួនាទី ភារកិច្ចយ៉ាងសំខាន់ក្នុងការដឹកនាំរដ្ឋបាលថ្នាក់ក្រោមជាតិស្របតាមគោលការណ៍នៃរដ្ឋបាលឯកភាព។ ក្នុងគោលបំណងគាំទ្រក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិបំពេញតួនាទី ភារកិច្ចនេះប្រកបដោយប្រសិទ្ធភាព សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ (សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត និងសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន) ត្រូវបានបង្កើតឡើង ដើម្បីតំណាងឱ្យសំឡេង ការការពារផលប្រយោជន៍ និងសិទ្ធិស្របច្បាប់របស់ក្រុមប្រឹក្សា ព្រមទាំងការអភិវឌ្ឍសមត្ថភាពដល់សមាជិករបស់ខ្លួន។

ក្នុងអំឡុង កជទី១ សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិបានបំពេញតួនាទី ភារកិច្ចយ៉ាងសកម្មក្នុងការអភិវឌ្ឍសមត្ថភាពសមាគម និងសមាជិករបស់ខ្លួន រួមទាំងការបង្កើតយន្តការនានានៅថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពក្នុងការដឹកនាំរបស់ក្រុមប្រឹក្សា និងរួមចំណែកក្នុងការរៀបចំ និងការដាក់ចេញនូវគោលនយោបាយ និងលិខិតបទដ្ឋាននានាដែលពាក់ព័ន្ធនឹងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ទោះជាយ៉ាងណាក៏ដោយ លទ្ធផលនៃការវាយតម្លៃ កជទី១ និងការវាយតម្លៃពាក់កណ្ដាលអាណត្តិនៃ កជទី២ បានបង្ហាញថា ចំណេះដឹង សមត្ថភាព និងសិទ្ធិអំណាច

របស់ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិក្នុងការអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួននៅតែជាបញ្ហាដែលត្រូវបន្តពង្រឹង និងដោះស្រាយក្នុង ផអ៥ទី២។

ដើម្បីសម្រេចបានលទ្ធផលរំពឹងទុកនេះ សកម្មភាពជាអាទិភាពដែលត្រូវអនុវត្តមានចំនួន០៤ ដូចមានរៀបរាប់ខាងក្រោម ៖

**សកម្មភាពអាទិភាព ១.៥.១.៖ ការពង្រឹងសមត្ថភាពសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត**

សកម្មភាពនេះ ផ្តោតលើការពង្រឹងសមត្ថភាពថ្នាក់ដឹកនាំ ក្រុមប្រឹក្សាជាតិ និងគណៈកម្មាធិការប្រតិបត្តិជាតិនៃសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត ដើម្បីបម្រើផលប្រយោជន៍ ការពារសិទ្ធិ សំឡេង និងអភិវឌ្ឍសមត្ថភាពរបស់សមាជិកសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត សំដៅលើកកម្ពស់ការបំពេញតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សារាជធានី ខេត្តក្នុងការបំពេញតួនាទីជាតំណាង និងបម្រើផលប្រយោជន៍ជូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពជាអាទិភាពនេះ រួមមាន ៖

- រៀបចំមហាសន្និបាតសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត ដើម្បីឆ្លុះបញ្ចាំងពីសមិទ្ធផល បញ្ហាប្រឈម និងលើកទិសដៅការងារនៅអាណត្តិបន្តទៀត ព្រមទាំងជ្រើសរើសថ្នាក់ដឹកនាំក្រុមប្រឹក្សាជាតិ និងគណៈកម្មាធិការប្រតិបត្តិជាតិនៃសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត សម្រាប់អាណត្តិបន្ទាប់
- រៀបចំកិច្ចប្រជុំក្រុមប្រឹក្សាជាតិប្រចាំឆ្នាំ ដើម្បីបូកសរុបសមិទ្ធផលការងារ និងលើកទិសដៅការងារសម្រាប់ឆ្នាំបន្ទាប់
- រៀបចំកិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិជាតិប្រចាំឆមាស និងប្រចាំឆ្នាំ ដើម្បីត្រួតពិនិត្យវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្តការងាររបស់សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត
- រៀបចំកិច្ចប្រជុំប្រចាំឆមាសរវាងថ្នាក់ដឹកនាំសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត និងប្រធានក្រុមប្រឹក្សារាជធានី ខេត្ត ដើម្បីពិភាក្សាអំពីបញ្ហាប្រឈម និងតម្រូវការរបស់ក្រុមប្រឹក្សារាជធានី ខេត្ត
- រៀបចំកិច្ចប្រជុំគណៈកម្មការនានា ដើម្បីលើកយោបល់ជូនថ្នាក់ដឹកនាំសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត ពិនិត្យ និងសម្រេច
- ពង្រឹងកិច្ចសហការ គណនេយ្យភាព និងការគាំទ្រក្រុមប្រឹក្សារាជធានី ខេត្តក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ពង្រឹងការសម្របសម្រួល កិច្ចសហការ និងការចូលរួមជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប. និងក្រសួង ស្ថាប័នពាក់ព័ន្ធនានាក្នុងការរៀបចំគោលនយោបាយ និងលិខិតបទដ្ឋាននានា ដែលពាក់ព័ន្ធនឹងផលប្រយោជន៍របស់ក្រុមប្រឹក្សារាជធានី ខេត្ត និងប្រជាពលរដ្ឋ

– លើកកម្ពស់ការសម្របសម្រួល និងកិច្ចសហការជាមួយក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលនានាក្នុងការគាំទ្រ និងអភិវឌ្ឍសមត្ថភាពរបស់សមាជិកនៃសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត/អគ្គលេខាធិការដ្ឋានសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ

**ស្ថាប័នចូលរួមអនុវត្ត** ៖ ក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ និងសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន

**តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ១.៥.១.**

| ល.រ | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | កិច្ចប្រជុំក្រុមប្រឹក្សាជាតិរបស់សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត | ១ | ១ | ១ | ១ | ១ | ១ |
| ២ | កិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិនៃសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត | ១ | ២ | ២ | ២ | ២ | ២ |
| ៣ | កិច្ចប្រជុំរវាងថ្នាក់ដឹកនាំសមាគម និងប្រធានក្រុមប្រឹក្សារាជធានី ខេត្ត | ១ | ២ | ២ | ២ | ២ | ២ |
| ៤ | មហាសន្និបាតសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត | | | | | ១ | |
| ៥ | ចំនួនសកម្មភាពនៃកិច្ចសហការ និងការគាំទ្រក្រុមប្រឹក្សារាជធានី ខេត្ត | | ៤ | ៤ | ៤ | ៤ | ៤ |

## សកម្មភាពអាទិភាព ១.៥.២.៖ ការពង្រឹងសមត្ថភាពសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន

សកម្មភាពនេះ ផ្តោតលើការពង្រឹងសមត្ថភាពថ្នាក់ដឹកនាំ ក្រុមប្រឹក្សាជាតិ និងគណៈកម្មាធិការប្រតិបត្តិជាតិនៃសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន ដើម្បីបម្រើផលប្រយោជន៍ ការពារសិទ្ធិ សំឡេង និងអភិវឌ្ឍសមត្ថភាពរបស់សម្ព័ន្ធភាពជាតិ សំដៅលើកកម្ពស់ការបំពេញតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ក្នុងការបំពេញតួនាទីជាតំណាង និងបម្រើផលប្រយោជន៍ជូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពជាអាទិភាពនេះរួមមាន ៖

– រៀបចំមហាសន្និបាតសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន ដើម្បីឆ្លុះបញ្ចាំងពីសមិទ្ធផលដែលបានសម្រេច បញ្ហាប្រឈម និងលើកទិសដៅការងារនៅអាណត្តិបន្តទៀត ព្រមទាំងជ្រើសរើសថ្នាក់ដឹកនាំ ក្រុមប្រឹក្សាជាតិ និងគណៈកម្មាធិការប្រតិបត្តិជាតិនៃសម្ព័ន្ធភាពជាតិសម្រាប់អាណត្តិបន្ទាប់

– រៀបចំកិច្ចប្រជុំក្រុមប្រឹក្សាជាតិនៃសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋានប្រចាំឆ្នាំ ដើម្បីបូកសរុបសមិទ្ធផលការងារ និងលើកទិសដៅការងារសម្រាប់ឆ្នាំបន្ទាប់

- រៀបចំកិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិជាតិ ដើម្បីត្រួតពិនិត្យវឌ្ឍនភាព និងបញ្ហាប្រឈម នៃការអនុវត្តការងាររបស់សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន
- លើកកម្ពស់ការសម្របសម្រួល និងកិច្ចសហការជាមួយសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត
- ពង្រឹងការសម្របសម្រួល កិច្ចសហការ និងការចូលរួមជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប. និង ក្រសួង ស្ថាប័នពាក់ព័ន្ធនានាក្នុងការរៀបចំគោលនយោបាយ និងលិខិតបទដ្ឋាននានាដែល ពាក់ព័ន្ធនឹងផលប្រយោជន៍របស់សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន និងប្រជាពលរដ្ឋ
- លើកកម្ពស់ការសម្របសម្រួល និងកិច្ចសហការជាមួយក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ និង អង្គការសង្គមស៊ីវិលនានាក្នុងការគាំទ្រ និងអភិវឌ្ឍសមត្ថភាពរបស់សមាជិកនៃសម្ព័ន្ធភាពជាតិ ក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត ៖** សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន/អគ្គលេខាធិការដ្ឋានសមាគម ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ

**ស្ថាប័នចូលរួមអនុវត្ត ៖** ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ សមាគមជាតិ ក្រុមប្រឹក្សាថ្នាក់ មូលដ្ឋាន ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល

**តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ១.៥.២.**

| ល.រ | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | កិច្ចប្រជុំក្រុមប្រឹក្សាជាតិ របស់សម្ព័ន្ធភាពជាតិ | ១ | ១ | ១ | ១ | ១ | ១ |
| ២ | កិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិនៃសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន | ១ | ២ | ២ | ២ | ២ | ២ |
| ៣ | មហាសន្និបាតសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន | | | | | ១ | |
| ៤ | ចំនួនសកម្មភាពផ្សព្វផ្សាយ និងអភិវឌ្ឍសមត្ថភាពដល់សមាជិកសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន | | ៣ | ៣ | ៣ | ៣ | ៣ |

**សកម្មភាពអាទិភាព ១.៥.៣.៖ ការពង្រឹងសមត្ថភាពអគ្គលេខាធិការដ្ឋានសមាគមក្រុមប្រឹក្សារដ្ឋបាល ថ្នាក់ក្រោមជាតិ**

អគ្គលេខាធិការដ្ឋានសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិបំពេញតួនាទីជាសេនាធិការជូន សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត និងសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន។

សកម្មភាពនេះ ផ្តោតលើការពង្រឹងសមត្ថភាពអគ្គលេខាធិការដ្ឋានសមាគមក្រុមប្រឹក្សារដ្ឋបាល ថ្នាក់ក្រោមជាតិក្នុងការបំពេញតួនាទី ភារកិច្ចប្រចាំថ្ងៃរបស់ខ្លួន ដើម្បីជួយសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត និងសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋានប្រកបដោយប្រសិទ្ធភាព។

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពជាអាទិភាពនេះរួមមាន ៖

- រៀបចំផែនការរយៈពេលមធ្យម និងរយៈពេលវែងរបស់សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត និងសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន
- រៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត និងសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន ដើម្បីដាក់ជូនថ្នាក់ដឹកនាំពិនិត្យ និងអនុម័ត
- ជួយសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត និងសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន ក្នុងការរៀបចំ និងអនុវត្តគម្រោង/កម្មវិធីនានាដែលគាំទ្រមូលនិធិដោយដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលនានា
- ជួយសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត និងសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន ក្នុងការរៀបចំមហាសន្និបាត កិច្ចប្រជុំនានា
- ជួយសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត និងសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន ក្នុងការសម្របសម្រួល និងសហការជាមួយក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលនានា
- ជួយសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត និងសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន ក្នុងការរៀបចំ និងដាក់ចេញនូវលិខិតបទដ្ឋាននានា
- សម្របសម្រួល សហការ និងរៀបចំសកម្មភាពអភិវឌ្ឍន៍សមត្ថភាពដល់បុគ្គលិករបស់ខ្លួន។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ អគ្គលេខាធិការដ្ឋានសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ

**ស្ថាប័នចូលរួមអនុវត្ត** ៖ សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន និងក្រសួង ស្ថាប័ន

**តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ១.៥.៣.**

| ល.រ | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | ផែនការរយៈពេលមធ្យម និងរយៈពេលវែងរបស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ | | | ២ | | | ២ |
| ២ | ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ | | ២ | ២ | ២ | ២ | ២ |
| ៣ | សកម្មភាពអភិវឌ្ឍន៍សមត្ថភាពអគ្គលេខាធិការដ្ឋាន | | ៣ | ៣ | ៣ | ៣ | ៣ |

## សកម្មភាពអាទិភាព ១.៥.៤.៖ ការពង្រឹងសមត្ថភាពសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ដែលជាសមាជិកនៃសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន

រចនាសម្ព័ន្ធនៃសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន រួមបញ្ចូលសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់នៅតាមរាជធានី ខេត្ត និងសាខាថ្នាក់ក្រុង ស្រុក ខណ្ឌនៃសមាគមក្រុមប្រឹក្សា ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់នៅតាមរាជធានី ខេត្តត្រូវបានបង្កើតឡើងក្នុងគោលបំណងជួយគាំទ្រសម្ព័ន្ធភាព

ជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋានក្នុងការលើកកម្ពស់ប្រសិទ្ធភាពនៃការបម្រើផលប្រយោជន៍ជូនសមាជិករបស់ខ្លួន និងជូនប្រជាពលរដ្ឋ។

សកម្មភាពនេះ ផ្តោតលើការពង្រឹងសមត្ថភាពរចនាសម្ព័ន្ធនៃសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន ដើម្បីបំពេញតួនាទី ភារកិច្ចរបស់ខ្លួនក្នុងការបម្រើផលប្រយោជន៍ជូនសមាជិករបស់ខ្លួន និងប្រជាពលរដ្ឋ ព្រមទាំងការសម្របសម្រួល និងសហការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលនានាប្រកបដោយប្រសិទ្ធភាព។

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពជាអាទិភាពនេះរួមមាន ៖

- រៀបចំ និងអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់សមាគមក្រុមប្រឹក្សា ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
- រៀបចំកិច្ចប្រជុំជាទៀងទាត់របស់រចនាសម្ព័ន្ធនៅតាមថ្នាក់រដ្ឋបាលនីមួយៗ
- រៀបចំសកម្មភាពអភិវឌ្ឍសមត្ថភាពដល់សមាជិករបស់ខ្លួនដោយសម្របសម្រួល និងសហការជិតស្និទ្ធជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងភាគីពាក់ព័ន្ធ
- ចុះតាមដាន និងផ្តល់ការគាំទ្រជាប្រចាំដល់សមាជិកក្រុមប្រឹក្សាក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ សមាគមក្រុមប្រឹក្សា ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់នៃសម្ព័ន្ធភាពក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន

**ស្ថាប័នចូលរួមអនុវត្ត** ៖ ក្រសួង ស្ថាប័ន និងសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ

**តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ១.៥.៤.**

| ល.រ | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់សមាគមថ្នាក់រាជធានី ខេត្ត | | ២៥ | ២៥ | ២៥ | ២៥ | ២៥ |
| ២ | ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់សាខាថ្នាក់ក្រុង ស្រុក ខណ្ឌ | | ២០៨ | ២០៨ | ២០៨ | ២០៨ | ២០៨ |
| ៣ | កិច្ចប្រជុំរបស់សមាគមថ្នាក់រាជធានី ខេត្ត | | ៤ | ៤ | ៤ | ៤ | ៤ |
| ៤ | កិច្ចប្រជុំរបស់សាខាថ្នាក់ក្រុង ស្រុក ខណ្ឌ | | ៤ | ៤ | ៤ | ៤ | ៤ |
| ៥ | សកម្មភាពផ្សព្វផ្សាយ និងអភិវឌ្ឍសមត្ថភាពដល់សមាជិកសមាគមតាមរាជធានី ខេត្តនីមួយៗ | | ៣ | ៣ | ៣ | ៣ | ៣ |

## ២. សមាសភាគទី២៖ រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ

### ២.១. សនិទានភាព

រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលសាធារណៈរឹងមាំ ស្អាតស្អំ និងឆ្លាតវៃដែលធានាដល់ការអនុវត្តការងារប្រកបដោយប្រសិទ្ធភាព គឺជាកត្តាដ៏សំខាន់ក្នុងការចូលរួមចំណែកធ្វើឱ្យសម្រេចបានចក្ខុវិស័យរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍកម្ពុជាឱ្យក្លាយទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។

អាស្រ័យហេតុនេះ ការកែលម្អ និងការធ្វើទំនើបកម្មរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលសាធារណៈដែលធានាដល់ការលើកកម្ពស់សមត្ថភាពស្ថាប័ន ពង្រឹងភាពស្អាតស្អំក្នុងរដ្ឋបាលសាធារណៈ បង្កើនប្រសិទ្ធភាព និងនវានុវត្តន៍ក្នុងការបំពេញការងារ និងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ គឺជាកិច្ចការដ៏សំខាន់ដែលត្រូវផ្តល់អាទិភាពក្នុងអំឡុងពេលនៃ កជទី២។ ទន្ទឹមនឹងនេះ កជទី២ បង្ហាញពីភាពចាំបាច់ក្នុងការកំណត់ឱ្យបានច្បាស់លាស់នូវមុខងារ និងការទទួលខុសត្រូវរបស់រដ្ឋបាលតាមថ្នាក់នីមួយៗ ដើម្បីជៀសវាងនូវភាពមិនច្បាស់លាស់ និងភាពត្រួតស៊ីគ្នានៃមុខងារ និងការទទួលខុសត្រូវក្នុងចំណោមរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្រៅពីនេះ ដើម្បីធានាដល់ការអនុវត្តមុខងារ និងការផ្តល់សេវាសាធារណៈប្រកបដោយគុណភាពជូនប្រជាពលរដ្ឋ ចាំបាច់ក៏ត្រូវបង្កបរិយាកាសឱ្យបានសមស្របក្នុងការលើកកម្ពស់គំនិតផ្តួចផ្តើមដ៏ទូលំទូលាយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅក្នុងកិច្ចដំណើរការពង្រឹងស្ថាប័នអនុវត្តមុខងារ និងការផ្តល់សេវាដោយប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទំនើប។

ដំណើរការនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ រហូតមកដល់ពេលនេះទទួលបាននូវលទ្ធផលជាច្រើនគួរជាទីមោទនៈ។ ក្នុងនោះ រចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាល សិទ្ធិអំណាច និងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំឡើងវិញ និងបន្តកែសម្រួលជាជំហានៗ ដើម្បីឱ្យស្របទៅតាមគោលការណ៍នៃរដ្ឋបាលឯកភាព និងគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។ ជាក់ស្តែង រចនាសម្ព័ន្ធគ្រប់គ្រង មុខងារ និងសិទ្ធិអំណាចរបស់រដ្ឋបាលឃុំ សង្កាត់ ត្រូវបានរៀបចំទៅតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ដែលអនុម័តក្នុងឆ្នាំ២០០១ ហើយរចនាសម្ព័ន្ធរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌត្រូវបានរៀបចំទៅតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលអនុម័តក្នុងឆ្នាំ២០០៨។ លើសពីនេះទៀត រចនាសម្ព័ន្ធ និងមុខងាររដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវបានរៀបចំកែសម្រួលឡើងវិញ តាមរយៈអនុក្រឹត្យលេខ១៨២ លេខ១៨៣ និងលេខ១៨៤ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក ខណ្ឌ នាឆ្នាំ២០១៩ និងលិខិតបទដ្ឋានគតិយុត្តជាច្រើនទៀត។ រចនាសម្ព័ន្ធប្រព័ន្ធគ្រប់គ្រងរដ្ឋបាល សិទ្ធិអំណាច និងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ ឡើងជាជំហានៗ តាមដំណាក់កាលនីមួយៗ ស្របតាមអភិក្រម **"ធ្វើផង រៀនសូត្រដកស្រង់បទពិសោធន៍ផង និងកែលម្អផង"**។

ជាមួយគ្នានេះ មុខងារក្នុងវិស័យអាទិភាពក៏ត្រូវបានផ្ទេរជាបន្តបន្ទាប់តាមបែបផែននៃការធ្វើប្រតិភូកម្ម (វិសហមជ្ឈការ) និងបែបផែននៃការប្រគល់ (វិមជ្ឈការ) ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ និងត្រូវបានពង្រឹងការអនុវត្តនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ លើសពីនេះទៀត នីតិវិធីបំពេញការងារ យន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ និងយន្តការលើកកម្ពស់គណនេយ្យភាពចំពោះប្រជាពលរដ្ឋ និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការជាមួយអង្គការសង្គមស៊ីវិល និងសហគមន៍មូលដ្ឋានក៏ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តនៅរដ្ឋបាលថ្នាក់ក្រោមជាតិជាបណ្តើរៗផងដែរ។

តាមរយៈ គ.ជ.អ.ប. រាជរដ្ឋាភិបាលបានធ្វើការសិក្សាជាបន្តបន្ទាប់សម្រាប់ផ្តល់ជាភស្តុតាង បទពិសោធន៍ មេរៀនល្អៗ និងបញ្ហាប្រឈមក្នុងការអនុវត្តកិច្ចការពង្រឹងស្ថាប័ន បែងចែក និងអនុវត្តមុខងារ និងការធ្វើទំនើបកម្មរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្នុងគោលបំណងដើម្បីរៀបចំស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យកាន់តែមានភាពធន់មាំ មានសមត្ថភាព និងមានលទ្ធភាពសមស្របសម្រាប់ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានកាន់តែល្អប្រសើរ គ.ជ.អ.ប. ក្នុងនាមជាសេនាធិការជូនរាជរដ្ឋាភិបាល បាននិងកំពុងរៀបចំឱ្យមានការសិក្សាវាយតម្លៃ និងប្រមូលចងក្រងនូវមេរៀន និងបទពិសោធន៍នៃការអនុវត្តជាក់ស្តែងពីបណ្តាប្រទេសមួយចំនួនទាំងក្នុងតំបន់ និងក្រៅតំបន់ ដើម្បីជាមូលដ្ឋានក្នុងការវិភាគ និងពិចារណាអំពីជម្រើសសមស្របនានាសម្រាប់ការរៀបចំ និងកែលម្អរដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

អាស្រ័យហេតុនេះ ជអ៥ទី២ នឹងត្រូវបន្តគិតគូរលើ៖

- ពង្រឹង និងរៀបចំស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យធន់មាំ ខ្លាំង ឆ្លាតវៃ និងស្អាតស្អំក្នុងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន និងការផ្តល់សេវាសាធារណៈនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ស្របតាមគោលការណ៍រដ្ឋបាលឯកភាព គោលការណ៍អភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងស្របទៅតាមចរិតលក្ខណៈនៃរដ្ឋបាលទីក្រុងម៉េត្រូប៉ូលីតែន រដ្ឋបាលតំបន់ រដ្ឋបាលមូលដ្ឋាន (ទីប្រជុំជន និងតំបន់ជនបទ) និងការរៀបចំទីក្រុងឆ្លាតវៃ
- រៀបចំឱ្យមានផែនការរៀបចំដែនដី និងប្លង់គោលប្រើប្រាស់ដីធ្លីនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានទស្សនវិស័យ និងផែនការច្បាស់លាស់សម្រាប់ប្រើប្រាស់ដីធ្លីក្នុងការអភិវឌ្ឍ ការសាងសង់លំនៅដ្ឋាន ការរៀបចំទីក្រុង ទីប្រជុំជន តំបន់ឧស្សាហកម្ម ការធ្វើកសិកម្ម សួនច្បារសាធារណៈជាដើម ប្រកបដោយចីរភាព
- ពង្រឹងការអនុវត្តតួនាទី សិទ្ធិអំណាច ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាដល់ការអនុវត្តតួនាទី ភារកិច្ច និងមុខងារប្រកបដោយភាពម្ចាស់ការ និងមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល ក្រសួង ស្ថាប័ន និងចំពោះប្រជាពលរដ្ឋ តាមរយៈការចូលរួមរបស់ប្រជាពលរដ្ឋ កម្មវិធីគណនេយ្យភាពសង្គម ការិយាល័យប្រជាពលរដ្ឋ គណនេយ្យភាពផ្ទៃក្នុង និងអន្តររដ្ឋបាល

- បន្តជំរុញ និងលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការធ្វើសេចក្ដីសម្រេចចិត្តរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ការចូលរួមអនុវត្ត ការតាមដាន ការត្រួតពិនិត្យ ការវាយតម្លៃ និងការផ្ដល់យោបល់ត្រឡប់ ដើម្បីធានាដល់ការលើកកម្ពស់ប្រសិទ្ធភាពនៃការបំពេញការងារ ការផ្ដល់សេវា និងការអភិវឌ្ឍមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ សំដៅធានាដល់លើកកម្ពស់ការជឿទុកចិត្តរបស់ប្រជាពលរដ្ឋមកលើរដ្ឋបាលថ្នាក់ក្រោមជាតិ
- ពង្រឹងកិច្ចសហប្រតិបត្តិការរវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងវិស័យឯកជន តាមរយៈការរៀបចំឱ្យមានក្របខ័ណ្ឌស្ដីពីកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល វិស័យឯកជន និងរវាងរដ្ឋបាលថ្នាក់ក្រោមជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិផ្សេងទៀត និងកិច្ចសហប្រតិបត្តិការទីក្រុងសម្ព័ន្ធមេត្រី
- ធ្វើបច្ចុប្បន្នភាពទៅលើយុទ្ធសាស្ត្រស្ដីពីអភិបាលកិច្ចតាមប្រព័ន្ធអេឡិចត្រូនិច ការរៀបចំប្រព័ន្ធគ្រប់គ្រងតាមបច្ចេកវិទ្យាឌីជីថលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ (រួមមាន ប្រព័ន្ធទិន្នន័យ ប្រព័ន្ធតាមដាន ត្រួតពិនិត្យនិងវាយតម្លៃ ប្រព័ន្ធស្ទង់មតិប្រជាពលរដ្ឋអំពីការផ្ដល់សេវា ប្រព័ន្ធផ្ដល់ព័ត៌មាន និងប្រព័ន្ធទទួលនិងសម្រុះសម្រួលដោះស្រាយបណ្ដឹងនិងសំណើសំណូមពររបស់ប្រជាពលរដ្ឋ និងប្រព័ន្ធគ្រប់គ្រងផ្សេងៗទៀត) និងការធ្វើសន្ទានកម្មប្រព័ន្ធគ្រប់គ្រងបច្ចេកវិទ្យាឌីជីថល (រួមមាន ប្រព័ន្ធគ្រប់គ្រងទិន្នន័យ ប្រព័ន្ធផ្សព្វផ្សាយ...) របស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានស្រាប់ឱ្យស្ថិតនៅក្នុងប្រព័ន្ធគ្រប់គ្រងមេតែមួយ ដើម្បីធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិអាចប្រើប្រាស់ស្តង់ដា API (Application Programming Interface) តែមួយសម្រាប់ការគ្រប់គ្រងកិច្ចការរដ្ឋបាល និងការផ្ដល់សេវាសាធារណៈ
- សិក្សាអំពីជម្រើសនៃការធ្វើសុខដុមនីយកម្មយន្តការអធិការកិច្ច សវនកម្មរបស់ក្រសួង ស្ថាប័នថ្នាក់ជាតិទៅលើការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាឱ្យកិច្ចដំណើរការនៃការធ្វើអធិការកិច្ច និងសវនកម្មរបស់ក្រសួង ស្ថាប័នអាចប្រព្រឹត្តទៅរួមគ្នា និងមិនត្រួតស៊ីគ្នា។

### ២.១. សមិទ្ធផលរំពឹងទុក

សមិទ្ធផលរំពឹងទុកនៃសមាសភាគនេះគឺ **"ស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានបន្តរៀបចំ និងពង្រឹងឱ្យធន់មាំ ខ្លាំង ឆ្លាតវៃ និងស្អាតស្អំ ស្របតាមគោលការណ៍រដ្ឋបាលឯកភាព គោលការណ៍អភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងស្របទៅតាមចរិតលក្ខណៈនៃរដ្ឋបាលទីក្រុងម៉េត្រូប៉ូលីតែន រដ្ឋបាលតំបន់ រដ្ឋបាលមូលដ្ឋាន និងទីក្រុងឆ្លាតវៃ"។**

### ២.៣. លទ្ធផលរំពឹងទុកនៃ ផអ៥ទី២

ផ្អែកលើភាពជោគជ័យ បទពិសោធន៍ និងបញ្ហាប្រឈមក្នុងការអនុវត្ត៥ឆ្នាំកន្លងមក សមាសភាគទី២ នៃ ផអ៥ទី២ មានលទ្ធផលរំពឹងទុកចំនួន០៦ ធៀបនឹងលទ្ធផលរំពឹងទុកចំនួន០៨ ដែលបានអនុវត្តក្នុងដំណាក់កាល ផអ៥ទី១។ លទ្ធផលរំពឹងទុកដើមចំនួន០៤ ត្រូវបានដាក់បញ្ចូលគ្នា ដោយសារសកម្មភាព

អាទិភាពមួយចំនួនពាក់ព័ន្ធគ្នាខ្លាំង និងមួយចំនួនទៀតត្រូវបានអនុវត្តរួចហើយ។ លទ្ធផលរំពឹងទុកដែលដាក់បញ្ចូលគ្នាផ្តោតសំខាន់លើការសិក្សា ការរៀបចំឡើងវិញរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងាររបស់រដ្ឋបាលខេត្តឱ្យក្លាយជារដ្ឋបាលតំបន់ និងរាជធានីភ្នំពេញឱ្យក្លាយជារដ្ឋបាលទីក្រុងម៉េត្រូប៉ូលីតែន សំដៅឆ្លើយតបនឹងការប្រែប្រួល និងស្ថានភាពជាក់ស្តែងខាងផ្នែកនគរូបនីយកម្ម សេដ្ឋកិច្ច-សង្គម ប្រជាសាស្ត្រ ភូមិសាស្ត្រ បច្ចេកវិទ្យា និងការប្រែប្រួលអាកាសធាតុ។ ការពិនិត្យឡើងវិញ និងពិចារណាលើការកែសម្រួលនេះ សំដៅពង្រឹងតួនាទី ក៏ដូចជាស័ក្តិសិទ្ធិភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានក្នុងនាមជាតំណាងរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន និងរាជរដ្ឋាភិបាល។

សកម្មភាពអាទិភាពសំខាន់ៗក្នុងលទ្ធផលរំពឹងទុកដើម ក៏ត្រូវដាក់បញ្ចូលក្នុងលទ្ធផលរំពឹងទុកថ្មីតាមជាក់ស្តែង ដើម្បីសម្រេចបានតាមលទ្ធផលដែលរំពឹងទុកក្នុង កជទី២។ ចំណែកលទ្ធផលរំពឹងទុកផ្សេងទៀត មានការប្រែប្រួលខ្លះ ទាំងខ្លឹមសារ ទាំងសកម្មភាពអាទិភាព ដើម្បីធ្វើយ៉ាងណាឱ្យឆ្លើយតបទៅនឹងលទ្ធផលដែលទទួលបានពីការអនុវត្ត៥ឆ្នាំកន្លងមក ការប្រែប្រួលខាងគោលនយោបាយជាតិជាបន្តបន្ទាប់ និងការចូលរួមជាមតិយោបល់ និងបទពិសោធន៍ពីភាគីពាក់ព័ន្ធក្នុងដំណាក់កាលប្រមូលធាតុចូល។ លើសពីនេះ សមាសភាគទី២នេះក៏បានដាក់បញ្ចូលលទ្ធផលរំពឹងទុកថ្មីមួយសម្រាប់អនុវត្តក្នុង ជអ៥ទី២ ស្តីពីប្រព័ន្ធ និងមុខងារការគ្រប់គ្រងដីធ្លី និងនគរូបនីយកម្មនៅថ្នាក់ក្រោមជាតិ។

ដើម្បីសម្រេចបាននូវសមិទ្ធផលរំពឹងទុកខាងលើ សមាសភាគទី២ បានកំណត់នូវលទ្ធផលរំពឹងទុកចំនួន០៦ និងសកម្មភាពអាទិភាពចំនួន១៨ រួមមាន ៖

លទ្ធផលរំពឹងទុកទី១ ៖ រចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពង្រឹង និងសិក្សាកែសម្រួលស្របតាមចរិតលក្ខណៈនៃរដ្ឋបាលថ្នាក់ក្រោមជាតិ និងសក្តានុពលរបស់រដ្ឋបាលនីមួយៗ និងគោលការណ៍នៃរដ្ឋបាលឯកភាព

លទ្ធផលរំពឹងទុកទី២ ៖ ប្រព័ន្ធ និងមុខងារការគ្រប់គ្រងដីធ្លី និងនគរូបនីយកម្មនៅថ្នាក់ក្រោមជាតិត្រូវបានពង្រឹង

លទ្ធផលរំពឹងទុកទី៣ ៖ ការដឹកនាំ ទំនាក់ទំនងការងារ និងគណនេយ្យភាពរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពង្រឹង

លទ្ធផលរំពឹងទុកទី៤ ៖ យន្តការចូលរួមរបស់ប្រជាពលរដ្ឋត្រូវបានលើកកម្ពស់ ដើម្បីបង្កើនជំនឿទុកចិត្តរបស់ប្រជាពលរដ្ឋមកលើរដ្ឋបាលថ្នាក់ក្រោមជាតិ

លទ្ធផលរំពឹងទុកទី៥ ៖ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានធ្វើទំនើបកម្មតាមរយៈការរៀបចំ និងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធឌីជីថល

លទ្ធផលរំពឹងទុកទី៦ ៖ យន្តការ និងប្រព័ន្ធតាមដាន ត្រួតពិនិត្យនិងវាយតម្លៃលើការបំពេញការងារ របស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ កែសម្រួល និងដាក់ឱ្យអនុវត្ត។

សកម្មភាពជាអាទិភាពដែលត្រូវអនុវត្ត ដើម្បីសម្រេចបានលទ្ធផលរំពឹងទុកនីមួយៗ រួមបញ្ចូលសូចនាករ និងចំណុចដៅសម្រាប់វាស់វែងការសម្រេចបាននូវសកម្មភាពជាអាទិភាពទាំងនេះ មានបរិយាយតាមលទ្ធផលរំពឹងទុកខាងក្រោម ៖

### លទ្ធផលរំពឹងទុកទី ២.១.៖ រចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពង្រឹង និងសិក្សាកែសម្រួលស្របតាមចរិតលក្ខណៈនៃរដ្ឋបាលថ្នាក់ក្រោមជាតិ និងសក្ដានុពលរបស់រដ្ឋបាលនីមួយៗ និងគោលការណ៍នៃរដ្ឋបាលឯកតាព

ផ្អែកតាមច្បាប់រៀបចំអង្គការ រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗមានតួនាទី ភារកិច្ច និងការទទួលខុសត្រូវក្នុងការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន ឆ្លើយតបទៅនឹងតម្រូវការ សំណើ សំណូមពរ និងដោះស្រាយបញ្ហាប្រឈមនានាជូនប្រជាពលរដ្ឋនៅមូលដ្ឋាន។ នៅក្នុងការអនុវត្ត កជទី១ កន្លងមកនេះ ក្រោមការដឹកនាំ និងសម្របសម្រួលរបស់ គ.ជ.អ.ប. រាជរដ្ឋាភិបាលក៏បានរៀបចំឡើងវិញនូវរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិស្របទៅតាមច្បាប់រៀបចំអង្គការ និងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ។ ទោះបីយ៉ាងនេះក្តី តាមរយៈការវាយតម្លៃពាក់កណ្តាលអាណត្តិនៃ កជទី២ បានបង្ហាញឱ្យឃើញថា រចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិគឺជាកិច្ចការចាំបាច់ដែលត្រូវបន្តពង្រឹងការអនុវត្ត និងត្រូវពិនិត្យមើលឡើងវិញនៅក្នុង ផអ៥ទី២ ដើម្បីធានាដល់ការលើកកម្ពស់ប្រសិទ្ធភាពនៃស្ថាប័ន ការបែងចែកសិទ្ធិអំណាច និងការទទួលខុសត្រូវឱ្យបានច្បាស់លាស់រវាងរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ និងក្នុងចំណោមរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ព្រមទាំងឆ្លើយតបទៅនឹងការវិវឌ្ឍនៃសេដ្ឋកិច្ច-សង្គម នគរូបនីយកម្ម ភូមិសាស្ត្រ ប្រជាសាស្ត្រ បច្ចេកវិទ្យា និងការប្រែប្រួលអាកាសធាតុ។

ដើម្បីសម្រេចបានលទ្ធផលរំពឹងទុកនេះ សកម្មភាពជាអាទិភាពដែលត្រូវអនុវត្តមានចំនួន០៣ ដូចមានរៀបរាប់ខាងក្រោម ៖

### សកម្មភាពអាទិភាព ២.១.១.៖ ពង្រឹងការអនុវត្តមុខងារ និងរចនាសម្ព័ន្ធបច្ចុប្បន្នរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

សកម្មភាពនេះ ផ្តោតលើការពង្រឹងការអនុវត្តមុខងារ និងរចនាសម្ព័ន្ធរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបានរៀបចំ និងដាក់ឱ្យអនុវត្តក្នុងអំឡុងពេលនៃការអនុវត្ត ផអ៥ទី១។

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពជាអាទិភាពនេះរួមមាន ៖

– ពង្រឹង និងលើកកម្ពស់ប្រសិទ្ធភាពការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់ប្រភេទ ក្នុងការគ្រប់គ្រង ការចាត់ចែងមុខងារ ផែនការ ធនធានហិរញ្ញវត្ថុ កិច្ចលទ្ធកម្ម ទ្រព្យសម្បត្តិ

បុគ្គលិក និងរបៀបរបបការងារ តាមរយៈការគាំទ្របច្ចេកទេស ការអភិវឌ្ឍសមត្ថភាព ការរៀបចំបទដ្ឋានបច្ចេកទេស/ស្តង់ដាសេវា ការតាមដាន ការត្រួតពិនិត្យ និងវាយតម្លៃពីក្រសួង ស្ថាប័នថ្នាក់ជាតិ

- ពង្រឹងតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់រដ្ឋបាលរាជធានី ខេត្តក្នុងការគាំទ្របច្ចេកទេស ការអភិវឌ្ឍសមត្ថភាព ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃលើរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់ក្នុងការដឹកនាំ ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារ ផែនការ ធនធានហិរញ្ញវត្ថុ កិច្ចលទ្ធកម្ម ទ្រព្យសម្បត្តិ បុគ្គលិក និងរបៀបរបបការងារ និងដើម្បីដោះស្រាយបញ្ហាប្រឈមចំពោះមុខនានា
- ពង្រឹងតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់រដ្ឋបាលក្រុង ស្រុកក្នុងការគាំទ្របច្ចេកទេស ការអភិវឌ្ឍសមត្ថភាព ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃលើរដ្ឋបាលឃុំ សង្កាត់ក្នុងការដឹកនាំ ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារ ផែនការ ធនធានហិរញ្ញវត្ថុ កិច្ចលទ្ធកម្ម ទ្រព្យសម្បត្តិ បុគ្គលិក និងរបៀបរបបការងារ និងដើម្បីដោះស្រាយបញ្ហាប្រឈមចំពោះមុខនានា
- សិក្សាលទ្ធភាពនៃការផ្ទេរមុខងារសុខាភិបាលមួយចំនួនពីរដ្ឋបាលរាជធានី ខេត្តទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់ក៏ដូចជាលទ្ធភាពក្នុងការផ្ទេរ និងបង្កើតការិយាល័យសុខាភិបាលនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីផ្តល់សេវាសុខាភិបាលជូនប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព និងគណនេយ្យភាព។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ ក្រសួងមហាផ្ទៃ លេខាធិការដ្ឋាន គ.ជ.អ.ប. និងរដ្ឋបាលថ្នាក់ក្រោមជាតិ
**ស្ថាប័នចូលរួមអនុវត្ត** ៖ ក្រសួង ស្ថាប័នពាក់ព័ន្ធ

**តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ២.១.១.**

| ល.រ. | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | ការសិក្សាអំពីការផ្ទេរមុខងារសុខាភិបាលទៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ | | បានសិក្សា | | | | |
| ២ | ភាគរយនៃមុខងារដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌមានសេចក្តីណែនាំបច្ចេកទេសសម្រាប់អនុវត្ត | | ១០០% | | | | |

## សកម្មភាពអាទិភាព ២.១.២.៖ ការពិនិត្យ និងការកែសម្រួលរចនាសម្ព័ន្ធ និងមុខងាររបស់រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់

សកម្មភាពនេះ ផ្តោតលើការពិនិត្យមើលឡើងវិញនូវរចនាសម្ព័ន្ធ និងមុខងាររបស់រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ឱ្យស្របទៅតាមចរិតលក្ខណៈជាទីក្រុង ទីប្រជុំជននិងតំបន់ជនបទ និងស្របទៅតាមភូមិសាស្ត្រ ប្រជាសាស្ត្រ និងសក្តានុពលផ្នែកសេដ្ឋកិច្ច-សង្គមរបស់រដ្ឋបាលនីមួយៗ ដើម្បី

ពង្រឹងរដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ជារដ្ឋបាលមូលដ្ឋានជួរមុខក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន។

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពជាអាទិភាពនេះរួមមាន ៖

- សិក្សា និងវាយតម្លៃទៅលើរចនាសម្ព័ន្ធ និងមុខងាររបស់រដ្ឋបាលក្រុង ស្រុក ដើម្បីរៀបចំរដ្ឋបាលទាំងនេះឱ្យមានលក្ខណៈសមស្របទៅតាមទំហំ(ធំ មធ្យម តូច ដោយផ្អែកលើស្ថានភាពភូមិសាស្ត្រ និងប្រជាសាស្ត្រ) និងប្រភេទនៃរដ្ឋបាល (ទីក្រុង/ទីប្រជុំជន និងតំបន់ជនបទ)
- កំណត់លក្ខណៈវិនិច្ឆ័យសម្រាប់កំណត់ក្រុង ស្រុកមានទំហំធំ មធ្យម និងតូច
- កំណត់លក្ខណៈវិនិច្ឆ័យសម្រាប់ការរៀបចំជារដ្ឋបាលក្រុង និងជារដ្ឋបាលសង្កាត់
- រៀបចំទីក្រុងឆ្លាតវៃ។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ ក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប.

**ស្ថាប័នចូលរួមអនុវត្ត** ៖ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ

**តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ២.១.២.**

| ល.រ | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | របាយការណ៍សិក្សាលើរចនាសម្ព័ន្ធ និងមុខងាររបស់រដ្ឋបាលក្រុង ស្រុក | | ១ | | | | |
| ២ | លក្ខណៈវិនិច្ឆ័យសម្រាប់កំណត់ក្រុង ស្រុកមានទំហំធំ មធ្យម និងតូច | | ១ | | | | |
| ៣ | លក្ខណៈវិនិច្ឆ័យសម្រាប់ការរៀបចំជារដ្ឋបាលក្រុង និងជារដ្ឋបាលសង្កាត់ | | ១ | | | | |

**សកម្មភាពអាទិភាព ២.១.៣.៖ ការសិក្សាជម្រើសសម្រាប់កែសម្រួលរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងាររបស់រដ្ឋបាលរាជធានីភ្នំពេញឱ្យក្លាយជារដ្ឋបាលក្រុងមេត្រូប៉ូលីតែន និងរដ្ឋបាលខេត្តឱ្យក្លាយជារដ្ឋបាលតំបន់**

ក្នុង ផអ៥ទី១ គ.ជ.អ.ប. បានដឹកនាំសម្របសម្រួលការសិក្សា ប្រមូល ចងក្រងមេរៀន បទពិសោធន៍ពីបណ្តាប្រទេសមួយចំនួនទាំងក្នុង និងក្រៅតំបន់អំពីការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងាររបស់រដ្ឋបាលម៉េត្រូប៉ូលីតែន និងរដ្ឋបាលតំបន់ ព្រមទាំងបានចុះសិក្សាវាយតម្លៃអំពីស្ថានភាពជាក់ស្តែងនៃការអនុវត្តមុខងារ និងរចនាសម្ព័ន្ធរបស់រដ្ឋបាលខេត្តចំនួន២ ក្រុងចំនួន២ និងស្រុកចំនួន២។ ក្នុង ផអ៥ទី២ ចាំបាច់ត្រូវបន្តការសិក្សានេះឱ្យស៊ីជម្រៅ និងឱ្យបានទូលំទូលាយបន្ថែមទៀត។

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពជាអាទិភាពនេះរួមមាន ៖

- បន្តការសិក្សា និងរៀបចំរបាយការណ៍ស្តីពីលទ្ធផលនៃការសិក្សាអំពីរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងាររបស់រដ្ឋបាលរាជធានី ខេត្ត

- កំណត់ជម្រើសនានាសម្រាប់កែសម្រួលរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងាររដ្ឋបាលរាជធានីភ្នំពេញដែលមានចរិតលក្ខណៈជារដ្ឋបាលក្រុងមេត្រូប៉ូលីតែន ដោយផ្អែកលើលទ្ធផលនៃការសិក្សាសម្រាប់ដាក់ជូន គ.ជ.អ.ប. និងរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច
- កំណត់ជម្រើសនានាសម្រាប់កែសម្រួលរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងាររដ្ឋបាលខេត្តដែលមានចរិតលក្ខណៈជារដ្ឋបាលតំបន់ ដោយផ្អែកលើលទ្ធផលនៃការសិក្សាសម្រាប់ដាក់ជូន គ.ជ.អ.ប. និងរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច
- រៀបចំសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត ដើម្បីកែសម្រួលរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងាររដ្ឋបាលរាជធានីភ្នំពេញឱ្យមានចរិតលក្ខណៈជារដ្ឋបាលមេត្រូប៉ូលីតែន
- រៀបចំសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត ដើម្បីកែសម្រួលរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងាររបស់រដ្ឋបាលខេត្តឱ្យមានចរិតលក្ខណៈជារដ្ឋបាលតំបន់។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ ក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប.

**ស្ថាប័នចូលរួមអនុវត្ត** ៖ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ

**តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ២.១.៣.**

| ល.រ | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | របាយការណ៍ស្តីពីលទ្ធផលនៃការសិក្សាអំពីរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងាររបស់រដ្ឋបាលរាជធានី ខេត្ត | កំពុងសិក្សា | ១ | | | | |
| ២ | លិខិតបទដ្ឋានគតិយុត្តស្តីពីការរៀបចំរដ្ឋបាលរាជធានីភ្នំពេញទៅជារដ្ឋបាលដែលមានចរិតលក្ខណៈជារដ្ឋបាលមេត្រូប៉ូលីតែន | | | សេចក្តីព្រាង | សេចក្តីព្រាង | អនុម័ត | |
| ៣ | លិខិតបទដ្ឋានគតិយុត្តស្តីពីការរៀបចំរដ្ឋបាលខេត្តឱ្យទៅជារដ្ឋបាលដែលមានចរិតលក្ខណៈជារដ្ឋបាលតំបន់ | | | សេចក្តីព្រាង | សេចក្តីព្រាង | អនុម័ត | |

### លទ្ធផលរំពឹងទុកទី ២.២.៖ ប្រព័ន្ធ និងមុខងារការគ្រប់គ្រងដីធ្លី និងនគរូបនីយកម្មនៅថ្នាក់ក្រោមជាតិត្រូវបានពង្រឹង

រដ្ឋបាលថ្នាក់ក្រោមជាតិបានដើរតួនាទីយ៉ាងសំខាន់ក្នុងការឆ្លើយតបនឹងតម្រូវការអភិវឌ្ឍរបស់ប្រជាពលរដ្ឋនៅមូលដ្ឋានស្របតាមក្របខ័ណ្ឌគោលនយោបាយ និងបទប្បញ្ញត្តិផ្សេងៗដែលបានដាក់ចេញដោយរាជរដ្ឋាភិបាល។ ក្នុងន័យនេះ ការគ្រប់គ្រង និងការប្រើប្រាស់ដីធ្លីនៅមូលដ្ឋានជាកត្តាកំណត់នៃការអភិវឌ្ឍសេដ្ឋកិច្ចលក្ខណៈជាយុទ្ធសាស្ត្រ។

ក្នុងន័យនេះ ផែនការរៀបចំដែនដី ប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីនៅរដ្ឋបាលថ្នាក់ក្រោមជាតិគឺជាផែនទីបង្ហាញផ្លូវសម្រាប់ការអភិវឌ្ឍមូលដ្ឋានរបស់ខ្លួន តាមរយៈការកំណត់ពីតំបន់នៃការប្រើប្រាស់ដីធ្លី និងហេដ្ឋារចនាសម្ព័ន្ធចាំបាច់ផ្សេងៗ រួមទាំងការកំណត់តំបន់លំនៅដ្ឋាន តំបន់ពាណិជ្ជកម្ម និងឧស្សាហកម្ម តំបន់ទីប្រជុំជន តំបន់កសិកម្ម ទ្រព្យសម្បត្តិរដ្ឋ តំបន់រក្សាការពារ សួនច្បារសាធារណៈ ជាដើម។

ដូច្នេះ ជាការចាំបាច់ដែលរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវមានសមត្ថភាព និងលទ្ធភាពក្នុងការកសាង និងធ្វើបច្ចុប្បន្នភាពផែនការរៀបចំដែនដី ប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីឱ្យបានទៀងទាត់ សម្រាប់ការប្រើប្រាស់ដីធ្លី ព្រមទាំងមានយន្តការ និងផែនការសម្រាប់អនុវត្តផែនការប្រើប្រាស់ដីនេះ ដើម្បីឱ្យសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមនៅក្នុងមូលដ្ឋានរបស់ខ្លួន។

បច្ចុប្បន្ននេះ រដ្ឋបាលថ្នាក់ក្រោមជាតិមួយចំនួនបានរៀបចំផែនការរៀបចំដែនដី ប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីរបស់ខ្លួនរួចហើយ រួមមាន ប្លង់គោលប្រើប្រាស់ដីរាជធានីភ្នំពេញ ផែនការរៀបចំដែនដីខេត្តចំនួន៣ ប្លង់គោលប្រើប្រាស់ដីក្រុង ស្រុក ខណ្ឌចំនួន២៥ និងផែនការប្រើប្រាស់ដីឃុំ សង្កាត់ចំនួន២៥៥។ រដ្ឋបាលថ្នាក់ក្រោមជាតិមួយចំនួនទៀតនៅមិនទាន់បានរៀបចំឱ្យមានផែនការរៀបចំដែនដី ប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីរបស់ខ្លួននៅឡើយ ដែលចាំបាច់ត្រូវរៀបចំក្នុង ផអ៥ទី២ នេះ។ រដ្ឋបាលថ្នាក់ក្រោមជាតិដែលមានផែនការរៀបចំដែនដី ប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីរួចហើយ ក៏នៅពុំទាន់បានប្រើប្រាស់ឱ្យបានដិតដល់ និងពុំបានធ្វើបច្ចុប្បន្នភាពតាមការជាក់ស្តែង ដើម្បីឆ្លើយតបនឹងការប្រែប្រួលនៃសេដ្ឋកិច្ច-សង្គម ប្រជាសាស្ត្រ ការរីកចម្រើននគរូបនីយកម្ម ស្ថានភាពភូមិសាស្ត្រ និងសម្បត្តិធម្មជាតិរបស់ខ្លួន ក៏ដូចជាហានិភ័យធម្មជាតិ និងអាកាសធាតុ។

ដើម្បីសម្រេចបានលទ្ធផលរំពឹងទុកនេះ សកម្មភាពជាអាទិភាពដែលត្រូវអនុវត្ត មានចំនួន០២ ដូចមានរៀបរាប់ខាងក្រោម ៖

**សកម្មភាពអាទិភាព ២.២.១.៖ ការពង្រឹងយន្តការរៀបចំដែនដី និងនគរូបនីយកម្មនៅថ្នាក់ក្រោមជាតិ**

សកម្មភាពនេះ ផ្តោតទៅលើការពង្រឹងយន្តការរៀបចំដែនដី និងនគរូបនីយកម្មនៅរដ្ឋបាលថ្នាក់ក្រោមជាតិ សំដៅធានាដល់ការរៀបចំ និងអនុវត្តឱ្យបានពេញលេញនូវផែនការរៀបចំដែនដី ប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីក្នុងដែនដីក្នុងដែនសមត្ថកិច្ចរបស់ខ្លួនដោយអនុវត្តតាមនិយាមដែលមានចែងជាធរមាន។

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពជាអាទិភាពនេះរួមមាន ៖

- ពង្រឹងការអនុវត្តតួនាទីភារកិច្ចរបស់គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មនៅថ្នាក់រាជធានី ខេត្ត និងថ្នាក់ក្រុង ស្រុក ខណ្ឌ និងពង្រឹងទំនាក់ទំនងការងារ និងកិច្ចសហប្រតិបត្តិការរវាងគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មនៅថ្នាក់រាជធានី ខេត្ត និងថ្នាក់ក្រុង ស្រុក ខណ្ឌ
- អភិវឌ្ឍសមត្ថភាព ផ្តល់ការគាំទ្របច្ចេកទេស ឧបករណ៍ មធ្យោបាយ និងធនធានដល់រដ្ឋបាលថ្នាក់ក្រោមជាតិដែលមានសមត្ថកិច្ចនីមួយៗក្នុងការរៀបចំផែនការរៀបចំដែនដី ប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដី
- រៀបចំផែនការការងារ និងក្របខ័ណ្ឌពេលវេលាសម្រាប់ការរៀបចំ និងអភិវឌ្ឍន៍ផែនការរៀបចំដែនដី ប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដី។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ ក្រសួងមហាផ្ទៃ ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ និង រដ្ឋបាលថ្នាក់ក្រោមជាតិ

**ស្ថាប័នចូលរួមអនុវត្ត** ៖ ក្រសួង ស្ថាប័នពាក់ព័ន្ធ

**តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ២.២.១.**

| ល.រ | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | ភាគរយរដ្ឋបាលរាជធានី ខេត្តដែលមានផែនការការងារ និង ក្របខ័ណ្ឌការងារសម្រាប់រៀបចំ និងអភិវឌ្ឍផែនការរៀបចំដែនដី ប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដី | | ១០០% | | | | |
| ២ | ភាគរយរដ្ឋបាលក្រុង ស្រុក ខណ្ឌដែលមានផែនការការងារ និង ក្របខ័ណ្ឌការងារសម្រាប់រៀបចំ និងអភិវឌ្ឍផែនការរៀបចំដែនដី ប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដី | | ៥០% | ១០០% | | | |

## សកម្មភាពអាទិភាព ២.២.២.៖ ការរៀបចំ និងការធ្វើបច្ចុប្បន្នភាពផែនការរៀបចំដែនដី ប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីនៅថ្នាក់ក្រោមជាតិ

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពជាអាទិភាពនេះរួមមាន ៖

- រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗត្រូវរៀបចំ និងធ្វើបច្ចុប្បន្នភាពផែនការរៀបចំដែនដី ប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីសម្រាប់មូលដ្ឋានរបស់ខ្លួនស្របតាមគោលការណ៍ និងនីតិវិធីជាធរមាន
- រដ្ឋបាលថ្នាក់ក្រោមជាតិផ្សព្វផ្សាយផែនការរៀបចំដែនដី ប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីឱ្យបានទូលំទូលាយ ដើម្បីធានាដល់ការចូលរួមអនុវត្តឱ្យមានប្រសិទ្ធភាព។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ ក្រសួងមហាផ្ទៃ ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

**ស្ថាប័នចូលរួមអនុវត្ត** ៖ ក្រសួង ស្ថាប័នពាក់ព័ន្ធ

**តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ២.២.២.**

| ល.រ | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | ចំនួនរដ្ឋបាលរាជធានី ខេត្តដែលមានផែនការរៀបចំដែនដី | ៤ | ១០ | ១៥ | ១៨ | ២២ | ២៥ |
| ២ | ចំនួនរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលមានប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដី | ២៥ | ៥ | ១០ | ១៥ | ២០ | ៣៣ |
| ៣ | ចំនួនរដ្ឋបាលឃុំ សង្កាត់ដែលមានផែនការប្រើប្រាស់ដី | ២៥៥ | ៣០ | ៥០ | ១០០ | ១៦៣ | ១៦៣ |

## លទ្ធផលរំពឹងទុកទី ២.៣.៖ ការដឹកនាំ ទំនាក់ទំនងការងារ និងគណនេយ្យភាពរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពង្រឹង

រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗអាចបំពេញការងាររបស់ខ្លួនប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាពចំពោះប្រជាពលរដ្ឋ និងរាជរដ្ឋាភិបាល លុះត្រាតែក្រុមប្រឹក្សាដែលជានីតិបុគ្គលនៃនីតិសាធារណៈមានសមត្ថភាព សិទ្ធិអំណាច និងការទទួលខុសត្រូវច្បាស់លាស់លើការដឹកនាំ ការធ្វើសេចក្តីសម្រេចចិត្ត ការដាក់ចេញដីកា និងសេចក្តីសម្រេចនានា និងការតាមដាន ការត្រួតពិនិត្យលើការបំពេញការងារនៃរដ្ឋបាលរបស់ខ្លួនស្របតាមច្បាប់រៀបចំអង្គការ។

ដើម្បីសម្រេចបាននូវលទ្ធផលរំពឹងទុកនេះ ផអ៥ទី២ បានគ្រោងឡើងនូវសកម្មភាពអាទិភាពចំនួន **០៣** ដូចខាងក្រោម៖

### សកម្មភាពអាទិភាព ២.៣.១.៖ ការពង្រឹង ការពិនិត្យ និងការកែសម្រួលគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ

គណៈកម្មាធិការរបស់ក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិត្រូវបានបង្កើតមកតាមក្របខ័ណ្ឌច្បាប់ និងបទដ្ឋានគតិយុត្ត ដើម្បីធ្វើជាសេនាធិការក្នុងការផ្តល់ការគាំទ្រដល់ការបំពេញការងាររបស់ក្រុមប្រឹក្សា។ គណៈកម្មាធិការក្រុមប្រឹក្សាដែលត្រូវបានបង្កើតរហូតមកបានបំពេញការងារសំខាន់ៗក្នុងការគាំទ្រក្រុមប្រឹក្សា។ ទន្ទឹមនេះ ក៏មានគណៈកម្មាធិការក្រុមប្រឹក្សាមួយចំនួននៅពុំទាន់បានបំពេញការងារសកម្មនៅឡើយដែលទាមទារឱ្យមានការយកចិត្តទុកដាក់ក្នុងការពង្រឹងសមត្ថភាព និងធ្វើការកែសម្រួល ដើម្បីឆ្លើយតបនឹងការប្រែប្រួលនៃតម្រូវការជាក់ស្តែងនៅមូលដ្ឋាន និងយុទ្ធសាស្ត្រអភិវឌ្ឍន៍នៅថ្នាក់ជាតិ។

ដូច្នេះ គណៈកម្មាធិការទាំងនេះ ចាំបាច់ត្រូវពិនិត្យឡើងវិញ កែសម្រួល និងឬបង្កើតថ្មី ដើម្បីធានាឱ្យបាននូវការផ្តល់ការគាំទ្រដល់ក្រុមប្រឹក្សាក្នុងបំពេញតួនាទី ភារកិច្ចរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព និងគណនេយ្យភាពចំពោះប្រជាពលរដ្ឋ។

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពជាអាទិភាពនេះរួមមាន ៖

- ពង្រឹងសមត្ថភាពរបស់គណៈកម្មាធិការនានាដែលបានបង្កើតឡើង ដើម្បីបំពេញតួនាទីក្នុងការផ្តល់យោបល់ជូនក្រុមប្រឹក្សារបស់ខ្លួន
- សិក្សា និងវាយតម្លៃឡើងវិញអំពីគណៈកម្មាធិការនានាដែលបានបង្កើតឡើង ដើម្បីមានមូលដ្ឋានក្នុងការគាំទ្រ ពង្រឹងការទទួលខុសត្រូវ និងពិនិត្យ កែសម្រួល។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ ក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប.

**ស្ថាប័នចូលរួមអនុវត្ត** ៖ ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ

### តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ២.៣.១.

| ល.រ | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | របាយការណ៍សិក្សាវាយតម្លៃអំពីគណៈកម្មាធិការនានាដែលបានបង្កើតឡើង | | | ១ | | | |

## សកម្មភាពអាទិភាព ២.៣.២.៖ ការពង្រឹងលេខាធិការដ្ឋានក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ

កន្លងមក ទោះបីរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានបង្កើតអង្គភាពឱ្យទទួលបន្ទុកជាលេខាធិការដ្ឋានក៏ពិតមែន តែការបំពេញការងាររបស់អង្គភាពនេះនៅថ្នាក់ក្រុង ស្រុក ខណ្ឌនៅពុំទាន់ដំណើរការបានល្អនៅឡើយ ដោយសារបញ្ហាសមត្ថភាព ធនធានមនុស្ស និងការទទួលខុសត្រូវ។ ហេតុដូច្នេះ ផែនការ៥ឆ្នាំទៅមុខចាំបាច់ត្រូវផ្តោតលើការពង្រឹងលេខាធិការដ្ឋាននេះ ដើម្បីឱ្យការបំពេញការងារមានប្រសិទ្ធភាពកាន់តែខ្លាំងឡើងថែមទៀត។

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពជាអាទិភាពនេះរួមមាន ៖

- ពង្រឹងសមត្ថភាពមន្ត្រីនៃលេខាធិការដ្ឋានក្រុមប្រឹក្សា
- ពិនិត្យមើលឡើងវិញ និងរៀបចំឱ្យមានបុគ្គលិកសមស្របសម្រាប់ការងារលេខាធិការដ្ឋានក្រុមប្រឹក្សា
- ពង្រឹងការទទួលខុសត្រូវរបស់លេខាធិការដ្ឋានក្រុមប្រឹក្សាស្របតាមតួនាទី ភារកិច្ចដែលបានកំណត់។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ ក្រសួងមហាផ្ទៃ

**ស្ថាប័នចូលរួមអនុវត្ត** ៖ ក្រសួង ស្ថាប័ន និងសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ

### តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ២.៣.២.

| ល.រ | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | ភាគរយនៃលេខាធិការក្រុមប្រឹក្សារដ្ឋបាលក្រុង ស្រុក ខណ្ឌ ទទួលបានការបណ្តុះបណ្តាល | | ៥០% | ១០០% | | | |

## សកម្មភាពអាទិភាព ២.៣.៣.៖ ការពង្រឹងទំនាក់ទំនងការងារ និងគណនេយ្យភាពរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិចំពោះប្រជាពលរដ្ឋ

ការពង្រឹងទំនាក់ទំនង និងគណនេយ្យភាពរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិចំពោះប្រជាពលរដ្ឋ គឺជាកិច្ចការដ៏មានសារៈសំខាន់ និងចាំបាច់។

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពជាអាទិភាពនេះរួមមាន ៖

– ពង្រឹងទំនាក់ទំនងរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិជាមួយប្រជាពលរដ្ឋ តាមរយៈការរៀបចំវេទិកាសាធារណៈនានា និងការចុះជួបប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋដោយផ្ទាល់ ក៏ដូចជាការប្រើប្រាស់នូវបណ្តាញផ្សព្វផ្សាយព័ត៌មាននានា ដើម្បីធានាដល់ការផ្តល់ព័ត៌មានជូនប្រជាពលរដ្ឋអំពីការបំពេញការងាររបស់ខ្លួន និងទទួលបាននូវសំណើ សំណូមពរនានារបស់ប្រជាពលរដ្ឋ ជាពិសេសស្ត្រី កុមារ និងក្រុមជនងាយរងគ្រោះផ្សេងទៀត

– ការពង្រឹងគណនេយ្យភាពរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិចំពោះប្រជាពលរដ្ឋ តាមរយៈ (១). ការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋក្នុងការរៀបចំគោលនយោបាយផែនការអភិវឌ្ឍន៍ ការរៀបចំគម្រោង និងការធ្វើសេចក្តីសម្រេចចិត្តនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (២). ការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន ដើម្បីដោះស្រាយ និងឆ្លើយតបទៅនឹងតម្រូវការ និងសំណើ សំណូមពររបស់ប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព ព្រមទាំងបែងចែកផលប្រយោជន៍ជូនប្រជាពលរដ្ឋប្រកបដោយបរិយាបន្ន និងសមធម៌សង្គម និង(៣). ការលើកកម្ពស់សិទ្ធិអំណាចប្រជាពលរដ្ឋក្នុងការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃលើការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការរៀបចំឱ្យមានយន្តការនៃការតាមដាន ត្រួតពិនិត្យរបស់ប្រជាពលរដ្ឋ ដើម្បីធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិបំពេញការងារប្រកបដោយប្រសិទ្ធភាព តម្លាភាព និងសមធម៌។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ រដ្ឋបាលថ្នាក់ក្រោមជាតិ
**ស្ថាប័នគាំទ្រអនុវត្ត** ៖ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអង្គការសង្គមស៊ីវិលនានា

**តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ២.៣.៣.**

| ល.រ | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | ភាគរយរដ្ឋបាលរាជធានី ខេត្តដែលបានរៀបចំវេទិកាប្រចាំឆ្នាំតាមពេលវេលាកំណត់ | | ១០០% | ១០០% | ១០០% | ១០០% | ១០០% |
| ២ | ភាគរយរដ្ឋបាលក្រុង ស្រុក ខណ្ឌដែលបានរៀបចំវេទិកាប្រចាំឆ្នាំតាមពេលវេលាកំណត់ | | ១០០% | ១០០% | ១០០% | ១០០% | ១០០% |

### លទ្ធផលរំពឹងទុកទី ២.៤៖ យន្តការចូលរួមរបស់ប្រជាពលរដ្ឋត្រូវបានលើកកម្ពស់ ដើម្បីបង្កើនជំនឿទុកចិត្តរបស់ប្រជាពលរដ្ឋមកលើរដ្ឋបាលថ្នាក់ក្រោមជាតិ

យន្តការចូលរួមរបស់ប្រជាពលរដ្ឋចាំបាច់ត្រូវពង្រឹង ដើម្បីលើកកម្ពស់ជំនឿទុកចិត្តរបស់ប្រជាពលរដ្ឋមកលើរដ្ឋបាលថ្នាក់ក្រោមជាតិ។ បច្ចុប្បន្ន យន្តការផ្សេងៗត្រូវបានអនុវត្ត ដើម្បីពង្រឹងការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការសម្រេចចិត្តរបស់រដ្ឋបាលមូលដ្ឋាន ដូចជា ការកសាងផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគ ការរៀបចំវិកាប្រចាំឆ្នាំ និងយន្តការគណនេយ្យភាពសង្គម ជាដើម។ យន្តការទាំងនេះ

ជាជំហានសំខាន់ឆ្ពោះទៅការពង្រឹងដំណើរការនៃការសម្រេចចិត្តប្រកបដោយបរិយាបន្ន តម្លាភាព ការឆ្លើយតប និងសមធម៌នៅថ្នាក់ក្រោមជាតិ។

ទោះជាយ៉ាងនេះក៏ដោយ យន្តការទាំងនេះនៅពុំទាន់បានធ្វើបច្ចុប្បន្នភាពនូវឧបករណ៍ និងវិធីសាស្ត្រឱ្យមានប្រសិទ្ធភាពល្អនៅឡើយ ដែលជាកត្តានាំឱ្យបាត់បង់ឱកាសក្នុងការពង្រឹងការសម្រេចចិត្តប្រកបដោយការចូលរួមនៅថ្នាក់ក្រោមជាតិ។ ដូចគ្នានេះដែរ ការផ្តល់ព័ត៌មានច្បាស់លាស់ក៏មានសារៈសំខាន់សម្រាប់ការផ្តល់អំណាចដល់ប្រជាពលរដ្ឋ និងភាគីពាក់ព័ន្ធក្នុងការចូលរួមលើកកម្ពស់ប្រសិទ្ធភាពនៃការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ លើសពីនេះ ការសម្រុះសម្រួលដោះស្រាយបណ្តឹងតវ៉ារបស់ប្រជាពលរដ្ឋពាក់ព័ន្ធនឹងការផ្តល់សេវាឱ្យបានទាន់ពេលវេលា និងប្រកបដោយការឆ្លើយតប ដែលជាការចូលរួមចំណែកធានាដល់ការលើកកម្ពស់ជំនឿទុកចិត្ត និងការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការនៃការសម្រេចចិត្តថ្នាក់ក្រោមជាតិ ក៏ចាំបាច់ត្រូវបន្តពង្រឹងផងដែរ។

ដើម្បីសម្រេចបាននូវលទ្ធផលរំពឹងទុកនេះ ផអ៥ទី២ បានគ្រោងឡើងនូវសកម្មភាពអាទិភាពចំនួន០៤ ដូចខាងក្រោម៖

### សកម្មភាពអាទិភាព ២.៤.១.៖ ការពង្រឹងយន្តការផ្តល់ព័ត៌មានជូនប្រជាពលរដ្ឋ

សកម្មភាពនេះ ផ្តោតទៅលើការពង្រឹងគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ចំពោះប្រជាពលរដ្ឋ តាមរយៈការលើកកម្ពស់ការផ្សព្វផ្សាយព័ត៌មានជូនប្រជាពលរដ្ឋឱ្យបានទូលំទូលាយប្រកបដោយគុណភាព និងតម្លាភាពអំពីសេចក្តីសម្រេចចិត្តនានា ការប្រើប្រាស់ធនធាន ការផ្តល់សេវាសាធារណៈ ការអភិវឌ្ឍមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងព័ត៌មានចាំបាច់ផ្សេងទៀតដែលពាក់ព័ន្ធនឹងសិទ្ធិកាតព្វកិច្ច/ករណីកិច្ច និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋតាមគ្រប់មធ្យោបាយផ្តល់ព័ត៌មាន។

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពជាអាទិភាពនេះរួមមាន ៖

- រៀបចំឱ្យមានអង្គភាពទទួលខុសត្រូវជាក់លាក់នៅរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ និងពង្រឹងសមត្ថភាព និងការទទួលខុសត្រូវសម្រាប់ការផ្តល់ព័ត៌មានជូនប្រជាពលរដ្ឋ
- គាំទ្ររដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗក្នុងការរៀបចំ និងអនុវត្តយុទ្ធសាស្ត្រស្តីពីការផ្សព្វផ្សាយព័ត៌មានជូនប្រជាពលរដ្ឋ តាមរយៈការបង្កើត ឬធ្វើបច្ចុប្បន្នភាពគេហទំព័រ និងបណ្តាញសង្គម។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ ក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប.

**ស្ថាប័នចូលរួមអនុវត្ត** ៖ ក្រសួងពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គការសង្គមស៊ីវិល

**តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ២.៤.១.**

| ល.រ | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | ភាគរយរដ្ឋបាលរាជធានី ខេត្តមាន (១).គេហទំព័រ (២). Facebook (៣). Telegram Channel | ១). ១០០% ២). ៨៨% ៣). ៧២% | ១). ១០០% ២). ១០០% ៣). ១០០% | ១). ១០០% ២). ១០០% ៣). ១០០% | ១). ១០០% ២). ១០០% ៣). ១០០% | ១). ១០០% ២). ១០០% ៣). ១០០% | ១). ១០០% ២). ១០០% ៣). ១០០% |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ២ | ភាគរយរដ្ឋបាលក្រុង ស្រុក ខណ្ឌ មាន (១). គេហទំព័រ (២). Facebook (៣). Telegram Channel | ១). ២,៣%<br>២). ៩២%<br>៣). ២៤% | ១). ១០%<br>២). ១០០%<br>៣). ៥០% | ១). ២០%<br>២). ១០០%<br>៣). ១០០% | ១). ៣០%<br>២). ១០០%<br>៣). ១០០% | ១). ៤០%<br>២). ១០០%<br>៣). ១០០% | ១). ៥០%<br>២). ១០០%<br>៣). ១០០% |
| ៣ | ភាគរយរដ្ឋបាលឃុំ សង្កាត់មាន (១). Facebook (២). Telegram Channel | ១). ៧៨%<br>២). ១៩% | ១). ១០០%<br>២). ១០០% | ១). ១០០%<br>២). ១០០% | ១). ១០០%<br>២). ១០០% | ១). ១០០%<br>២). ១០០% | ១). ១០០%<br>២). ១០០% |

## សកម្មភាពអាទិភាព ២.៤.២៖ ការពង្រឹង និងពង្រីកការងារគណនេយ្យភាពសង្គម

ការងារគណនេយ្យភាពសង្គមបានដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់ព័ត៌មានជូនប្រជាពលរដ្ឋអំពីសេវាសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការតាមដាន និងការវាយតម្លៃ ដើម្បីកែលម្អគុណភាពសេវា។ បច្ចុប្បន្ន ការអនុវត្តការងារនេះនៅមិនទាន់គ្របដណ្តប់នៅរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ទូទាំងប្រទេសនៅឡើយ។ ការងារគណនេយ្យសង្គមត្រូវបានរៀបចំ និងគាំទ្រការអនុវត្តដោយគម្រោង និងកម្មវិធីដែលមានការគាំទ្រដោយដៃគូអភិវឌ្ឍន៍នានា ហើយដំណើរការនៃការអនុវត្តគម្រោង និងកម្មវិធីទាំងនេះនៅពុំទាន់បានបញ្ចូលទៅក្នុងយន្តការស្ថាប័នរបស់រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យបានពេញលេញនៅឡើយ។

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពជាអាទិភាពនេះរួមមាន ៖

- បន្តពង្រឹង និងពង្រីករដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅ (ឃុំ សង្កាត់ និងក្រុង ស្រុក ខណ្ឌ) និងពង្រីកវិសាលភាពនៃសេវាសាធារណៈក្នុងក្របខ័ណ្ឌការងារគណនេយ្យភាពសង្គម
- រៀបចំ និងដាក់ឱ្យអនុវត្តផែនការអនុវត្តន៍គណនេយ្យភាពសង្គមដំណាក់កាលទី៣ និងពង្រឹងតួនាទីរបស់រដ្ឋបាលរាជធានី ខេត្តក្នុងការគាំទ្រសកម្មភាពការងារគណនេយ្យភាពសង្គម
- រៀបចំ និងដាក់ឱ្យអនុវត្តផែនការយុទ្ធសាស្ត្រនិរន្តរភាពគណនេយ្យភាពសង្គមនៅថ្នាក់ឃុំ សង្កាត់។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ លេខាធិការដ្ឋាន គ.ជ.អ.ប.

**ស្ថាប័នចូលរួមអនុវត្ត** ៖ ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល

### តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ២.៤.២.

| ល.រ | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | ភាគរយនៃរដ្ឋបាលឃុំ សង្កាត់ដែលអនុវត្តការងារគណនេយ្យភាពសង្គម | ៩៤% | ១០០% | | | | |
| ២ | ភាគរយនៃរដ្ឋបាលក្រុង ស្រុកដែលអនុវត្តការងារគណនេយ្យភាពសង្គម | ២៦% | ២៦% | ៤០% | ៦០% | ៨០% | ១០០% |
| ៣ | យុទ្ធសាស្ត្រនិរន្តរភាពគណនេយ្យភាពសង្គមនៅឃុំ សង្កាត់ដែលបានអនុម័ត | | ១ | | | | |

## សកម្មភាពអាទិភាព២.៤.៣.៖ ការពង្រឹងយន្តការទទួល និងដោះស្រាយបណ្តឹងក្រៅប្រព័ន្ធតុលាការ និងសំណើ សំណូមពររបស់ប្រជាពលរដ្ឋ

យន្តការទទួល និងដោះស្រាយបណ្តឹងក្រៅប្រព័ន្ធតុលាការ និងសំណើ សំណូមពររបស់ប្រជាពលរដ្ឋ គឺជាមធ្យោបាយដ៏មានសារសំខាន់សម្រាប់បង្កើនជំនឿទុកចិត្តរបស់ប្រជាពលរដ្ឋមកលើការដឹកនាំ ការគ្រប់គ្រង ការចាត់ចែង ការអនុវត្តមុខងារ ការប្រើប្រាស់ធនធាន និងការផ្តល់សេវាសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ តាមរយៈយន្តការនេះ រដ្ឋបាលថ្នាក់ក្រោមជាតិក៏អាចទទួលបាននូវព័ត៌មានត្រឡប់ (ការផ្តល់យោបល់សម្រាប់កែលម្អ ការលើកសរសើរ និងការទិតៀននានា) ដែលជាមូលដ្ឋានសម្រាប់ការពង្រឹង និងការកែលម្អទៅលើការដឹកនាំ ការចាត់ចែង និងការបំពេញការងាររបស់ខ្លួន។

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពជាអាទិភាពនេះរួមមាន ៖

- ពង្រឹងសមត្ថភាព និងការទទួលខុសត្រូវរបស់ការិយាល័យប្រជាពលរដ្ឋ អង្គភាពទទួលបន្ទុកលើការទទួល និងដោះស្រាយបណ្តឹង និងសំណើ សំណូមពររបស់ប្រជាពលរដ្ឋនៅតាមរដ្ឋបាលថ្នាក់ក្រោមជាតិនានា
- រៀបចំ និងកែលម្អនូវនីតិវិធីសម្រាប់ទទួល និងសម្រុះសម្រួលដោះស្រាយបណ្តឹង និងសំណើ សំណូមពររបស់ប្រជាពលរដ្ឋ
- រៀបចំ និងធ្វើបច្ចុប្បន្នភាពកម្មវិធីទទួលបណ្តឹង សំណើសំណូមពរ និងការឆ្លើយតបសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ ក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប.

**ស្ថាប័នចូលរួមអនុវត្ត** ៖ ក្រសួងយុត្តិធម៌ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

### តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ២.៤.៣.

| ល.រ | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | ភាគរយនៃការដោះស្រាយបណ្តឹង សំណើសំណូមពររបស់ប្រជាពលរដ្ឋតាមការិយាល័យប្រជាពលរដ្ឋនៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ | ៨០% | ៨៥% | ៨៥% | ៩០% | ៩០% | ៩០% |
| ២ | ភាគរយនៃការដោះស្រាយបណ្តឹងរបស់ប្រជាពលរដ្ឋតាមអង្គភាពទទួល និងដោះស្រាយបណ្តឹងរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ | | ៨០% | ៨២% | ៨៤% | ៨៦% | ៩០% |
| ៣ | ចំនួនរដ្ឋបាលរាជធានី ខេត្តដែលដាក់ឱ្យប្រើប្រាស់កម្មវិធីទូរស័ព្ទ "មតិយើង" | ១០ | ២៥ | ២៥ | ២៥ | ២៥ | ២៥ |
| ៤ | ភាគរយរដ្ឋបាលក្រុង ស្រុក ខណ្ឌដែលដាក់ឱ្យប្រើប្រាស់កម្មវិធីទូរស័ព្ទ "មតិយើង" | | | ២០ | ៤០ | ៧០ | ១០០% |

## សកម្មភាពអាទិភាព ២.៤.៤៖ ការលើកកម្ពស់ការចូលរួមរបស់អង្គការស៊ីវិលក្នុងដំណើរការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

ការចូលរួមរបស់អង្គការសង្គមស៊ីវិលមានសារៈសំខាន់សម្រាប់ពង្រឹងការចូលរួមរបស់ពលរដ្ឋ និងកៀរគរធនធានសម្រាប់ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន ពិសេសសម្រាប់ឆ្លើយតបនឹងតម្រូវការរបស់ក្រុមជនងាយរងគ្រោះរួមទាំងស្ត្រី កុមារ ជនជាតិភាគតិច ជនចាស់ជរា ជនមានពិការភាពជាដើម។ ដូច្នេះ ការលើកកម្ពស់ការចូលរួមរបស់អង្គការសង្គមស៊ីវិលក្នុងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិគួរទទួលបាននូវការយកចិត្តទុកដាក់ និងអនុវត្តជាទៀងទាត់ក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការមួយប្រកបដោយភាតរភាព និងស្មោះត្រង់។

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពជាអាទិភាពនេះរួមមាន៖

- សិក្សា និងរៀបចំឱ្យមានក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការរវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយនឹងអង្គការសង្គមស៊ីវិល
- រៀបចំកិច្ចប្រជុំជាទៀងទាត់រវាងរដ្ឋបាលរាជធានី ខេត្ត និងអង្គការសង្គមស៊ីវិល ដើម្បីលើកកម្ពស់ការចូលរួម និងការផ្តល់យោបល់របស់អង្គការសង្គមស៊ីវិលក្នុងការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន ព្រមទាំងការផ្សព្វផ្សាយ និងការចែករំលែកព័ត៌មាននានា។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត**៖ រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គការសង្គមស៊ីវិល

**ស្ថាប័នគាំទ្រអនុវត្ត** ៖ ក្រសួងមហាផ្ទៃ ស្ថាប័នពាក់ព័ន្ធ លេខាធិការដ្ឋាន គ.ជ.អ.ប.

### តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ២.៤.៤.

| ល.រ | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | ក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គការសង្គមស៊ីវិលដែលបានរៀបចំ | | សិក្សា | អនុម័ត | | | |
| ២ | ភាគរយរាជធានី ខេត្តរៀបចំកិច្ចប្រជុំជាមួយអង្គការសង្គមស៊ីវិលជាទៀងទាត់ | | ១០០% | ១០០% | ១០០% | ១០០% | ១០០% |

## លទ្ធផលរំពឹងទុកទី ២.៥៖ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានធ្វើទំនើបកម្ម តាមរយៈការរៀបចំ និងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធឌីជីថល

ការធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការទទួលយកបច្ចេកវិទ្យាឌីជីថលមានសារៈសំខាន់សម្រាប់លើកកម្ពស់ប្រសិទ្ធភាព ការសម្រេចចិត្ត ការផ្តល់សេវា និងការអភិវឌ្ឍសេដ្ឋកិច្ច។ ក្នុងន័យនេះ ការធ្វើឌីជីថលនីយកម្មជាការចាំបាច់ ពិសេសលើប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស ប្រព័ន្ធគ្រប់គ្រងធនធានហិរញ្ញវត្ថុ ប្រព័ន្ធគ្រប់គ្រងគម្រោង និងប្រព័ន្ធគ្រប់គ្រងទិន្នន័យផ្សេងទៀត។ ប្រព័ន្ធទាំងអស់នេះ មានតួនាទីសំខាន់សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ក៏ដូចជាក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត

ក្នុងការធ្វើការសម្រេចចិត្ត ការធ្វើផែនការ ការកៀរគរធនធាន និងការសម្របសម្រួលជាមួយភាគីពាក់ព័ន្ធផ្សេងទៀតសម្រាប់ជាប្រយោជន៍ដល់ការផ្តល់សេវា ការវិនិយោគ និងការអភិវឌ្ឍសេដ្ឋកិច្ច ព្រមទាំងការដោះស្រាយគ្រោះមហន្តរាយធម្មជាតិ និងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ។

ការអនុវត្ត៥ឆ្នាំកន្លងមក បានសម្រេចបានសមិទ្ធផលជាច្រើន ដោយដាក់ឱ្យប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងនោះរួមមានប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ជាដើម។ ដូច្នេះ ការប្រើប្រាស់នូវប្រព័ន្ធឌីជីថលទាំងនេះត្រូវធ្វើបន្ត និងពង្រឹងបន្ថែមទៀត ក៏ដូចជាកែលម្អនូវប្រព័ន្ធខ្លះៗផងដែរ សំដៅឆ្លើយតបនឹងស្ថានភាពជាក់ស្តែងនៅមូលដ្ឋាន។

ដើម្បីសម្រេចបានលទ្ធផលរំពឹងទុកនេះ ផអ៥ទី២ បានគ្រោងឡើងនូវសកម្មភាពអាទិភាពចំនួន០២ ដូចខាងក្រោម៖

## សកម្មភាពអាទិភាព ២.៥.១.៖ ការពង្រឹង និងពង្រីកលទ្ធភាពក្នុងការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធបណ្តាញអ៊ីនធឺណិត

រដ្ឋបាលថ្នាក់ក្រោមជាតិបានតភ្ជាប់សេវាអិនធឺណិតជាបន្តបន្ទាប់ ដោយក្នុងនោះរដ្ឋបាលរាជធានី ខេត្តបានតភ្ជាប់ ១០០% រដ្ឋបាលក្រុង ស្រុក ខណ្ឌចំនួនបាន៨៤% និងរដ្ឋបាលឃុំ សង្កាត់បាន៦៧%។ ផអ៥ទី២ បន្តផ្តោតទៅលើការពង្រឹង និងពង្រីកការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធបណ្តាញអិនធឺណិតឱ្យបានដល់តំបន់ជនបទ (ស្រុក និងឃុំ) ដើម្បីធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនៅតំបន់ជនបទទាំងនោះ មានលទ្ធភាពក្នុងការតភ្ជាប់សេវាអិនធឺណិត ដើម្បីរៀបចំរដ្ឋបាលរបស់ខ្លួនឱ្យទៅជារដ្ឋបាលឌីជីថល។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងក្រសួងមហាផ្ទៃ
**ស្ថាប័នចូលរួមអនុវត្ត** ៖ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ

**តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ២.៥.១.**

| ល.រ | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | ភាគរយសាលាក្រុង ស្រុក ខណ្ឌដែលតភ្ជាប់ប្រព័ន្ធអិនធឺណិត* | ៨៤% | ៨៧% | ៩០% | ៩៣% | ៩៦% | ១០០% |
| ២ | ភាគរយសាលាឃុំ សង្កាត់ដែលតភ្ជាប់ប្រព័ន្ធអិនធឺណិត | ៦៧% | ៧៣% | ៧៩% | ៨៥% | ៩៥% | ១០០% |

* បណ្តាញអិនធឺណិតត្រូវបានតភ្ជាប់ ដែលមានវិសាលភាពគ្រប់ដណ្តប់ទៅលើទីប្រជុំជនក្នុងក្រុង ស្រុក ខណ្ឌនីមួយៗ។

## សកម្មភាពអាទិភាព ២.៥.២.៖ ការរៀបចំ និងការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធឌីជីថលទៅក្នុងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពជាអាទិភាពនេះរួមមាន៖

- សិក្សា និងរៀបចំយុទ្ធសាស្ត្រស្តីពីអភិបាលកិច្ចតាមប្រព័ន្ធឌីជីថលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- សិក្សា និងរៀបចំប្រព័ន្ធឌីជីថលសម្រាប់ការប្រាស្រ័យទាក់ទងការងាររដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

- ពង្រឹង កែលម្អ និងពង្រីកប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងការទទួលព័ត៌មានត្រលប់ពីប្រជាពលរដ្ឋតាមប្រព័ន្ធឌីជីថលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- ពង្រឹងការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងបណ្តឹងនិងព័ត៌មានផ្សេងៗរបស់ការិយាល័យប្រជាពលរដ្ឋ
- រៀបចំប្រព័ន្ធឌីជីថលសម្រាប់ការគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ (HRMIS)
- កែលម្អ និងពង្រឹងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ (SARMIS) និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS)
- សិក្សា និងរៀបចំប្រព័ន្ធកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិតាមប្រព័ន្ធឌីជីថល កែលម្អ និងពង្រឹងការអនុវត្តប្រព័ន្ធទិន្នន័យមូលដ្ឋានឃុំ សង្កាត់ (CDB) កែលម្អនិងជំរុញការអនុវត្តប្រព័ន្ធទិន្នន័យអនុវត្តគម្រោងរដ្ឋបាលថ្នាក់ក្រោមជាតិ (PID) កែលម្អនិងពង្រឹងការប្រើប្រាស់ប្រព័ន្ធទិន្នន័យគម្រោងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (SPD) និងពង្រឹងការប្រើប្រាស់កម្មវិធីព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រង និងផ្តល់សេវានៅយន្តការច្រកចេញចូលតែមួយ។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ ក្រសួងមហាផ្ទៃ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងផែនការ ក្រសួងមុខងារសាធារណៈ លេខាធិការដ្ឋាន គ.ជ.អ.ប.

**ស្ថាប័នចូលរួមអនុវត្ត** ៖ រដ្ឋបាលថ្នាក់ក្រោមជាតិ ក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍន៍

**តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ២.៥.២.**

| ល.រ | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | ចំនួនរដ្ឋបាលរាជធានី ខេត្តដែលបានប្រើប្រាស់ប្រព័ន្ធឌីជីថលសម្រាប់ការប្រាស្រ័យទាក់ទងការងាររដ្ឋបាល | | ២ | ១០ | ១៥ | ២០ | ២៥ |
| ២ | ចំនួនរដ្ឋបាលក្រុង ស្រុក ខណ្ឌដែលបានប្រើប្រាស់ប្រព័ន្ធឌីជីថលសម្រាប់ការប្រាស្រ័យទាក់ទងការងាររដ្ឋបាល | | ២ | ២០ | ៣០ | ៥០ | ១០០ |
| ៣ | ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ | | ១ | | | | |
| ៤ | ប្រព័ន្ធ FMIS Portal ជំនាន់ថ្មីដែលបានដាក់ឱ្យប្រើប្រាស់នៅរដ្ឋបាលថ្នាក់ក្រោមជាតិ | ៤៤ ក្រុង ស្រុក ខណ្ឌ | ៥១ ក្រុង ស្រុក | ១១៥ ស្រុក | ៥៥០ឃុំ សង្កាត់ | ៥៥០ឃុំ សង្កាត់ | ៥៥២ឃុំ សង្កាត់ |

## លទ្ធផលរំពឹងទុកទី ២.៦៖ យន្តការ និងប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ កែសម្រួល និងដាក់ឱ្យអនុវត្ត

គិតមកដល់ពេលនេះ សិទ្ធិអំណាច មុខងារតាមវិស័យនានា រួមទាំងធនធានមនុស្ស និងធនធានហិរញ្ញវត្ថុត្រូវបានផ្ទេរជាបណ្តើរៗទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិដោយបានធ្វើឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ

កាន់តែមានលទ្ធភាព និងសមត្ថភាពក្នុងការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន ឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ ដោះស្រាយបញ្ហាប្រឈមនានានៅតាមមូលដ្ឋានបានចំទិសដៅឆាប់រហ័ស និងមានប្រសិទ្ធភាព។

ទោះយ៉ាងនេះក្តី ក្នុងពេលដែលសិទ្ធិអំណាច មុខងារ និងធនធានកាន់តែច្រើនបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ រាជរដ្ឋាភិបាល ក្រសួង ស្ថាប័ននៅថ្នាក់ជាតិក៏ចាំចាច់ត្រូវរៀបចំបង្កើតប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃច្បាស់លាស់មួយ ដើម្បីធានាឱ្យបានថា រដ្ឋបាលថ្នាក់ក្រោមជាតិបានដឹកនាំ គ្រប់គ្រង ចាត់ចែងការអនុវត្តមុខងារ និងការប្រើប្រាស់សិទ្ធិអំណាច និងធនធានដែលបានផ្ទេរឱ្យស្របតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត គោលការណ៍ នីតិវិធី និងស្តង់ដាសេវាដែលបានកំណត់ សំដៅទទួលបានការជឿទុកចិត្តពីរាជរដ្ឋាភិបាល ក្រសួង ស្ថាប័ននៅថ្នាក់ជាតិ ជាពិសេសពីប្រជាពលរដ្ឋ និងសហគមន៍មូលដ្ឋាន។ ជាមួយគ្នានេះ យន្តការ និងប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិក៏ចាំបាច់ត្រូវមានសុខដុមនីយកម្មក្នុងចំណោមយន្តការ និងប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនានា ដើម្បីធានានូវការលើកកម្ពស់ស្វ័យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងកាត់បន្ថយបន្ទុកការងារ និងពេលវេលារបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរងការត្រួតពិនិត្យ និងវាយតម្លៃជាច្រើនពីក្រសួង ស្ថាប័នពាក់ព័ន្ធនានា។ យន្តការ និងប្រព័ន្ធពាក់ព័ន្ធនេះត្រូវបង្កើតឡើងក្នុងគោលបំណងពង្រឹងប្រសិទ្ធភាព និងប្រសិទ្ធផលការងារ ដើម្បីទទួលបាននូវជំនឿទុកចិត្តពីប្រជាពលរដ្ឋ រាជរដ្ឋាភិបាល ក៏ដូចជាភាគីពាក់ព័ន្ធ។

ដើម្បីសម្រេចបានលទ្ធផលរំពឹងទុកនេះ ផអ៥ទី២ បានគ្រោងឡើងនូវសកម្មភាពអាទិភាពចំនួន **០៣** ដូចខាងក្រោម៖

**សកម្មភាពអាទិភាព ២.៦.១.៖ ការរៀបចំ និងការពង្រឹងយន្តការសវនកម្មផ្ទៃក្នុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពជាអាទិភាពនេះរួមមាន៖

- ពង្រឹងការអនុវត្តតួនាទី ភារកិច្ចរបស់ការិយាល័យត្រួតពិនិត្យផ្ទៃក្នុងរបស់រដ្ឋបាលក្រុង ស្រុក តាមរយៈការរៀបចំ និងការបណ្តុះបណ្តាលអំពីគោលការណ៍ និងនីតិវិធីសវនកម្មផ្ទៃក្នុងដល់មន្ត្រីពាក់ព័ន្ធនៃរដ្ឋបាលក្រុង ស្រុក
- រៀបចំបង្កើតអង្គភាពសវនកម្មផ្ទៃក្នុងរបស់រដ្ឋបាលរាជធានី ខេត្ត និងរៀបចំនិងបណ្តុះបណ្តាលអំពីគោលការណ៍ នីតិវិធីសវកម្មផ្ទៃក្នុងដល់មន្ត្រីពាក់ព័ន្ធរបស់រដ្ឋបាលរាជធានី ខេត្ត
- សិក្សាអំពីជម្រើស និងលទ្ធភាពនៃការរៀបចំការធ្វើសវនកម្មផ្ទៃក្នុងសម្រាប់រដ្ឋបាលឃុំ
- គាំទ្រ និងតាមដាន ត្រួតពិនិត្យទៅលើដំណើរការសវនកម្មផ្ទៃក្នុងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ លេខាធិការដ្ឋាន គ.ជ.អ.ប. និងរដ្ឋបាលថ្នាក់ក្រោមជាតិ

**ស្ថាប័នចូលរួមអនុវត្ត** ៖ ក្រសួង ស្ថាប័នពាក់ព័ន្ធ

## តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ២.៦.១.

| ល.រ | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | គោលការណ៍ និងនីតិវិធីសវនកម្មផ្ទៃក្នុងរបស់រដ្ឋបាលក្រុង ស្រុក | សេចក្តីព្រាង | អនុម័ត | | | | |
| ២ | ភាគរយរដ្ឋបាលក្រុង ស្រុកដែលទទួលបានការបណ្តុះបណ្តាលអំពីគោលការណ៍ និងនីតិវិធីសវនកម្មផ្ទៃក្នុង | | ១០០% | | | | |
| ៣ | ចំនួនរដ្ឋបាលរាជធានី ខេត្តដែលដាក់ឱ្យដំណើរការអង្គភាពសវនកម្មផ្ទៃក្នុង | | | ២៥ | | | |
| ៤ | ភាគរយរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុកអនុវត្តសវនកម្មផ្ទៃក្នុង | | | ៥០% | ១០០% | | |

### សកម្មភាពអាទិភាព ២.៦.២.៖ ការរៀបចំលិខិតបទដ្ឋានគតិយុត្ត និងឯកសារណែនាំបច្ចេកទេសសម្រាប់ការបង្កើត និងពង្រឹងយន្តការអធិការកិច្ចលើរដ្ឋបាលថ្នាក់ក្រោមជាតិ

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពជាអាទិភាពនេះរួមមាន៖

- សិក្សាស្រាវជ្រាវលើយន្តការ នីតិវិធី និងបញ្ហាប្រឈមនានានៃការធ្វើអធិការកិច្ចរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធទៅលើការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិនាពេលបច្ចុប្បន្ន។ សកម្មភាពនេះ ត្រូវវិភាគ ប្រមូលចងក្រងមេរៀន និងបទពិសោធន៍អំពីយន្តការអធិការកិច្ចលើការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបាននិងកំពុងអនុវត្តនៅតាមបណ្តាប្រទេសនានា ដើម្បីកំណត់ជម្រើសសមស្របសម្រាប់ការរៀបចំ និងដាក់ឱ្យអនុវត្តនូវយន្តការអធិការកិច្ចលើការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលធានាដល់សុខដុមនីយកម្មនៃយន្តការអធិការកិច្ចតាមវិស័យនានារបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនីមួយៗ។ ការកំណត់នូវជម្រើសនានាត្រូវផ្តោតលើ៖
    - លទ្ធភាពនៃការពង្រឹងប្រព័ន្ធអធិការកិច្ចរបស់ថ្នាក់ជាតិទៅលើរដ្ឋបាលថ្នាក់ក្រោមជាតិស្របតាមគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ និងធានាដល់ការមិនរំខានច្រើនដល់ការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងនាមជារដ្ឋបាលដែលមានស្វ័យភាពស្របតាមការកំណត់ដោយច្បាប់
    - លទ្ធភាពនៃការបង្កើតយន្តការនៅថ្នាក់រាជធានី ខេត្ត ដើម្បីទទួលខុសត្រូវលើការធ្វើអធិការកិច្ចលើការអនុវត្តការងាររបស់រដ្ឋបាលមូលដ្ឋាន (ក្រុង ស្រុក និងឃុំ សង្កាត់)
    - កិច្ចដំណើរការអធិការកិច្ច (វិធីសាស្ត្រ ឧបករណ៍ និងរបាយការណ៍)
    - ការរៀបចំប្រព័ន្ធលើកទឹកចិត្ត និងដាក់ទណ្ឌកម្ម ពិន័យចំពោះរដ្ឋបាលថ្នាក់ក្រោមជាតិផ្អែកតាមលទ្ធផលនៃការអធិការកិច្ច។
- ផ្អែកលើជម្រើសនានាដែលមានការពិគ្រោះយោបល់យ៉ាងទូលំទូលាយជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ចាំបាច់ត្រូវកែសម្រួល ឬរៀបចំលិខិតបទដ្ឋានគតិយុត្តនានាសម្រាប់រៀបចំយន្តការអធិការកិច្ចដែលមានលក្ខណៈជាប្រព័ន្ធមួយ ដែលធានានូវ

សុខដុមនីយកម្មនៃការធ្វើអធិការកិច្ចលើរដ្ឋបាលថ្នាក់ក្រោមជាតិ និងរៀបចំឯកសារណែនាំបច្ចេកទេសលម្អិតសម្រាប់ការធ្វើអធិការកិច្ចនេះ
- ការធ្វើអធិការកិច្ចលើការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមយន្តការ គោលការណ៍ និងនីតិវិធីដែលបានកំណត់។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ ក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប.

**ស្ថាប័នចូលរួមអនុវត្ត** ៖ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ

**តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ២.៦.២.**

| ល.រ | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | សិក្សាពីជម្រើសបង្កើតយន្តការអធិការកិច្ចរួមមួយលើរដ្ឋបាលថ្នាក់ក្រោមជាតិ | | ១ | | | | |
| ២ | លិខិតបទដ្ឋានគតិយុត្ត និងឯកសារណែនាំបច្ចេកទេសសម្រាប់យន្តការអធិការកិច្ចលើរដ្ឋបាលថ្នាក់ក្រោមជាតិ | | | ១ | | | |

### សកម្មភាពអាទិភាព២.៦.៣.៖ បង្កើតប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការដឹកនាំ ការគ្រប់គ្រង ការចាត់ចែងការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

ក្រៅពីកិច្ចការអធិការកិច្ច និងសវនកម្មផ្ទៃក្នុង និងផ្ទៃក្រៅលើការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃប្រចាំឆ្នាំលើការដឹកនាំ គ្រប់គ្រង និងចាត់ចែងការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក៏ជាកិច្ចការដែលមានសារៈសំខាន់ក្នុងការធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់សិទ្ធិអំណាច និងធនធានដែលបានផ្ទេរឱ្យស្របតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត គោលការណ៍ នីតិវិធី និងស្តង់ដាសេវាដែលបានកំណត់ សំដៅទទួលបាននូវការជឿទុកចិត្តពីរាជរដ្ឋាភិបាល ក្រសួង ស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិ ជាពិសេសពីប្រជាពលរដ្ឋ និងសហគមន៍មូលដ្ឋាន។

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពជាអាទិភាពនេះរួមមាន៖
- បង្កើត និងដាក់ឱ្យអនុវត្តប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃប្រចាំឆ្នាំលើការដឹកនាំ គ្រប់គ្រង និងចាត់ចែងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ ក្រសួងមហាផ្ទៃ

**ស្ថាប័នចូលរួមអនុវត្ត** ៖ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ

**តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ២.៦.៣.**

| ល.រ | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | ប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃត្រូវបានរៀបចំ | | ១ | | | | |
| ២ | ភាគរយរដ្ឋបាលថ្នាក់ក្រោមជាតិដែលបានអនុវត្តប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃប្រចាំឆ្នាំ | | | ១០០% | ១០០% | ១០០% | ១០០% |

## ៣. សមាសភាគទី៣៖ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស

### ៣.១. សនិទានភាព

រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តនានាសម្រាប់ការរៀបចំ និងការកែលម្អប្រព័ន្ធគ្រប់គ្រងបុគ្គលិកនៅរដ្ឋបាលថ្នាក់ក្រោមជាតិជាបន្តបន្ទាប់ រួមមាន (១). គោលនយោបាយគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ (២). លក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ (៣). ការធ្វើប្រតិភូកម្មសិទ្ធិអំណាចទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រងបុគ្គលិកដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ (៤). នីតិវិធីនៃការគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ និង(៥). លិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀតជាច្រើន។

បន្ថែមពីនេះទៀត យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា បានកំណត់ក្នុងបញ្ចកោណទី១ គឺ**ការអភិវឌ្ឍមូលធនមនុស្ស** ហើយស្នូលនៃបញ្ចកោណផ្ដោតលើការកែទម្រង់ និងការពង្រឹងអភិបាលកិច្ច និងការធ្វើទំនើបកម្មស្ថាប័នរដ្ឋឱ្យក្លាយជារដ្ឋបាលសាធារណៈទំនើបប្រកបដោយសមត្ថភាពខ្ពស់ ខ្លាំង ឆ្លាតវៃ និងស្អាតស្អំ ព្រមទាំងកំណត់យកអាទិភាពគន្លឹះ៥ គឺ **មនុស្ស ផ្លូវ ទឹក ភ្លើង និងបច្ចេកវិទ្យា**។ មុំទី២នៃស្នូលបញ្ចកោណបានផ្ដោតលើការលើកកម្ពស់សមត្ថភាពធនធានមនុស្ស និងការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តការងារ ហើយគោលនយោបាយចំណុចទី៣នៃមុំទី១ បានផ្ដោតអាទិភាពលើ «**ការពង្រឹងសមត្ថភាពនៃការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការធ្វើប្រតិភូកម្មអំណាច និងការទទួលខុសត្រូវក្នុងការជ្រើសរើស ការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់បុគ្គលិក**»។

ក្នុងកំឡុងពេលអនុវត្ត ផអ៥ទី១ ដោយផ្អែកតាមដំណើរការផ្ទេរមុខងារ និងសិទ្ធិអំណាចតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន រាជរដ្ឋាភិបាល និងក្រសួង ស្ថាប័នថ្នាក់ជាតិបានផ្ទេរបុគ្គលិកទៅឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិសរុបជាង**១០០.០០០នាក់** ក្នុងនោះបុគ្គលិកក្រសួងមហាផ្ទៃចំនួនប្រមាណ**៧.៥០០នាក់** គ្រូបង្រៀនប្រមាណជាង**៧០.០០០នាក់** គ្រូពេទ្យជាង **២០.០០០នាក់** និងបុគ្គលិកជំនាញវិស័យនានាប្រមាណជាង **៧.៥០០នាក់**។ រហូតដល់ពេលនេះ រដ្ឋបាលរាជធានី ខេត្ត មានបុគ្គលិកប្រមាណជាង**២៥.០០០នាក់** និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ មានបុគ្គលិកប្រមាណជាង ៨០.០០០នាក់។

អាស្រ័យហេតុនេះ ផអ៥ទី២ ចាំបាច់ត្រូវបន្តពង្រឹង កែលម្អប្រព័ន្ធគ្រប់គ្រងបុគ្គលិក ការអភិវឌ្ឍសមត្ថភាពបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ និងពង្រឹងស្ថាប័នបណ្ដុះបណ្ដាល ដោយផ្ដោតអាទិភាពលើការពិនិត្យ ការកែសម្រួល ការរៀបចំ និងការពង្រឹងការអនុវត្តគោលនយោបាយ ច្បាប់ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងធនធានមនុស្សដែលក្នុងនោះរួមមាន ការជ្រើសរើស និងការរៀបចំបុគ្គលិកសមស្របតាមតម្រូវការជាក់លាក់ទាំងចំនួនបុគ្គលិក និងជំនាញវិជ្ជាជីវៈ ការវាយតម្លៃផ្អែកលើសមិទ្ធកម្ម ការលើកទឹកចិត្តដល់បុគ្គលិក ការរៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងបុគ្គលិក ការបង្កើន

ចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រង ការរៀបចំក្របខ័ណ្ឌស្តង់ដាសមត្ថភាព ការពង្រឹងគុណភាពកម្មវិធីសិក្សានិងវិធីសាស្ត្របណ្តុះបណ្តាល ការពង្រឹងសមត្ថភាពសាលាជាតិរដ្ឋបាលមូលដ្ឋាន និងទីចាត់ការគ្រប់គ្រងធនធានមនុស្សនៃរដ្ឋបាលរាជធានី ខេត្ត ព្រមទាំងពង្រឹងភាពម្ចាស់ការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការកំណត់អំពីតម្រូវបណ្តុះបណ្តាល ការរៀបចំផែនការអភិវឌ្ឍន៍សមត្ថភាព និងផ្តល់សេវាអភិវឌ្ឍសមត្ថភាពដល់បុគ្គលិករបស់ខ្លួន។

### ៣.២. សមិទ្ធផលរំពឹងទុក

សមិទ្ធផលរំពឹងទុកនៃសមាសភាគទី៣នៃ ផអ៥ទី២ គឺ "**រដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិជ្រើសរើស គ្រប់គ្រង ចាត់ចែង និងប្រើប្រាស់បុគ្គលិកផ្អែកលើទំហំការងារនិងលទ្ធភាពហិរញ្ញវត្ថុរបស់ខ្លួន និងមានបុគ្គលិកប្រកបដោយសមត្ថភាព ឆន្ទៈម្ចាស់ការ ភក្តីភាព និងមនសិការជំនាញវិជ្ជាជីវៈស្របតាមតួនាទីភារកិច្ច និងការទទួលខុសត្រូវដែលបានកំណត់**"។

ដើម្បីសម្រេចបាននូវសមិទ្ធផលខាងលើនេះ ផអ៥ទី២ នឹងបន្តលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងបុគ្គលិក ពង្រឹងសមត្ថភាពបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិឱ្យក្លាយទៅជាមូលធនមនុស្ស និងពង្រឹងអង្គភាពនិងស្ថាប័នបណ្តុះបណ្តាល តាមរយៈការពង្រឹងការទទួលខុសត្រូវពេញលេញរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការជ្រើសរើស ការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់បុគ្គលិករបស់ខ្លួនស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន ពង្រឹងសមត្ថភាពបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការបណ្តុះបណ្តាលប្រកបដោយគុណភាពខ្ពស់ និងពង្រឹងអង្គភាពនិងស្ថាប័នបណ្តុះបណ្តាលឱ្យក្លាយជាគ្រឹះស្ថានបណ្តុះបណ្តាលប្រកបដោយវិជ្ជាជីវៈ។ ក្នុងន័យនេះ រដ្ឋបាលថ្នាក់ក្រោមជាតិនឹងមានបុគ្គលិកក្នុងចំនួនសមស្របមានសមត្ថភាព មានក្រមសីលធម៌ល្អ និងមានជំនាញវិជ្ជាជីវៈច្បាស់លាស់ក្នុងការអនុវត្តតួនាទីភារកិច្ច និងការទទួលខុសត្រូវរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។

អាស្រ័យហេតុនេះ ផអ៥ទី២ នឹងបន្តផ្តោតលើ៖

- ពង្រឹងការគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ និងគាំទ្រដល់ការអនុវត្តសិទ្ធិអំណាចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រងបុគ្គលិក តាមរយៈការរៀបចំ ការពិនិត្យ និងការកែសម្រួលឡើងវិញនូវលិខិតបទដ្ឋានគតិយុត្តមួយចំនួនពាក់ព័ន្ធនឹងការគ្រប់គ្រងបុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដូចជាការរៀបចំនិយាមនីតិវិធីប្រតិបត្តិសម្រាប់ជ្រើសរើសបុគ្គលិកផ្អែកលើកិច្ចព្រមព្រៀងការងារ និងមន្ត្រីរាជការ គោលនយោបាយលើកទឹកចិត្តដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ការកំណត់មុខតំណែងវិជ្ជាជីវៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិជាដើម
- ពង្រឹងប្រសិទ្ធភាពនៃការបំពេញការងាររបស់មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិ រួមមាន វិន័យក្រមសីលធម៌ លក្ខខណ្ឌការងារ ការកំណត់អំពីអង្គមន្ត្រីរាជការស៊ីវិល ដើម្បីធានាដល់ការរៀបចំ ការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់បុគ្គលិកស្របតាមវិជ្ជាជីវៈនីមួយៗ និងការរៀបចំប្រព័ន្ធវាយតម្លៃផ្អែកលើសមិទ្ធកម្មរបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ

- សិក្សាអំពីការកំណត់ពិដានបុគ្គលិកតាមអង្គភាពនីមួយៗនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីចូលរួមចំណែកក្នុងការកាត់បន្ថយបន្ទុកចំណាយបុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ពង្រឹងយន្តការអភិវឌ្ឍន៍សមត្ថភាពនៅថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាដល់ការផ្តល់សេវាអភិវឌ្ឍសមត្ថភាពប្រកបដោយគុណភាព និងជាប្រចាំដល់ក្រុមប្រឹក្សា និងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិទាំងផ្នែករដ្ឋបាល និងជំនាញវិជ្ជាជីវៈក្នុងការអនុវត្តតួនាទី ភារកិច្ច និងមុខងាររបស់ខ្លួន
- គ្រប់គ្រង និងអភិវឌ្ឍសមត្ថភាពក្រុមប្រឹក្សា បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិតាមប្រព័ន្ធឌីជីថល
- ពង្រឹងភាពជាម្ចាស់របស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការកំណត់អំពីតម្រូវបណ្តុះបណ្តាល ការរៀបចំផែនការនិងថវិកាសម្រាប់អភិវឌ្ឍសមត្ថភាព និងផ្តល់ការបណ្តុះបណ្តាលដល់បុគ្គលិករបស់ខ្លួន។

### ៣.៣. លទ្ធផលរំពឹងទុកនៃ ផអ៥ទី២

លទ្ធផលរំពឹងទុកក្នុងសមាសភាគទី៣នៃ ផអ៥ទី២ ត្រូវកែសម្រួលមកនៅត្រឹមចំនួន៤ ប៉ុណ្ណោះ ខណៈដែលលទ្ធផលរំពឹងទុកក្នុងសមាសភាគទី៣នៃ ផអ៥ទី១ និងកជទី២ មានរហូតដល់ចំនួន១០ ដោយហេតុថាលទ្ធផលរំពឹងទុកមួយចំនួនដែលបានកំណត់នៅក្នុង ផអ៥ទី១ និងកជទី២ ត្រូវបានអនុវត្តរួចហើយក្នុងអំឡុង ផអ៥ទី១ និងលទ្ធផលរំពឹងទុកមួយចំនួនទៀតត្រូវបានកែសម្រួលមកជាសកម្មភាពអាទិភាពវិញ ដូច្នេះសមាសភាគទី៣នៃ ផអ៥ទី២នេះ មានតែលទ្ធផលរំពឹងចំនួន០៤ប៉ុណ្ណោះ រួមមានដូចខាងក្រោម៖

លទ្ធផលរំពឹងទុកទី១ ៖ សិទ្ធិអំណាច និងការទទួលខុសត្រូវក្នុងការគ្រប់គ្រងបុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពង្រឹងដោយមានការគិតគូរដល់ការលើកកម្ពស់សមភាពយេនឌ័រ

លទ្ធផលរំពឹងទុកទី២ ៖ ប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្មត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត

លទ្ធផលរំពឹងទុកទី៣ ៖ សមត្ថភាពក្រុមប្រឹក្សា និងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានលើកកម្ពស់

លទ្ធផលរំពឹងទុកទី៤ ៖ ស្ថាប័ន/អង្គភាពអភិវឌ្ឍន៍សមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពង្រឹង។

សកម្មភាពជាអាទិភាពដែលត្រូវអនុវត្ត ដើម្បីសម្រេចបានលទ្ធផលរំពឹងទុកនីមួយៗ រួមបញ្ចូលសូចនាករ និងចំណុចដៅសម្រាប់វាស់វែងការសម្រេចបាននូវសកម្មភាពជាអាទិភាពទាំងនេះ មានបរិយាយតាមលទ្ធផលរំពឹងទុកខាងក្រោម ៖

#### លទ្ធផលរំពឹងទុក ៣.១៖ សិទ្ធិអំណាច និងការទទួលខុសត្រូវក្នុងការគ្រប់គ្រងបុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពង្រឹងដោយមានការគិតគូរដល់ការលើកកម្ពស់សមភាពយេនឌ័រ

កន្លងមកនេះ ដើម្បីធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិអំណាច ការទទួលខុសត្រូវក្នុងការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់បុគ្គលិករបស់ខ្លួនប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព

រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តនានាសម្រាប់ការរៀបចំ និងការកែលម្អប្រព័ន្ធគ្រប់គ្រងបុគ្គលិកនៅរដ្ឋបាលថ្នាក់ក្រោមជាតិជាបន្តបន្ទាប់។ ទោះជាយ៉ាងនេះក្តី ផ្អែកតាមការវិវត្តនៃគោលនយោបាយថ្មីៗ និងកម្មវិធីកំណែទម្រង់គន្លឹះនានារបស់រាជរដ្ឋាភិបាល ដើម្បីពង្រឹងការគ្រប់គ្រង ការចាត់ចែង និងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យកាន់តែល្អប្រសើរស្របតាមសិទ្ធិអំណាចដែលបានប្រគល់ជូន ចាំបាច់ត្រូវមានការរៀបចំនូវលិខិតបទដ្ឋានថ្មីៗមួយចំនួនពាក់ព័ន្ធនឹងការរៀបចំអង្គមន្ត្រីរាជការស៊ីវិល នីតិវិធីប្រតិបត្តិនៃការជ្រើសរើសមន្ត្រីប្រកបដោយគុណាធិបតេយ្យ តម្លាភាព យុត្តិធម៌ បរិយាបន្ន សមធម៌សង្គម គោលនយោបាយលើកទឹកចិត្ត និងការបង្កើនចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិជាដើម។

ដើម្បីសម្រេចបាននូវលទ្ធផលរំពឹងទុកនេះ ផអ៥ទី២ បានគ្រោងឡើងនូវសកម្មភាពអាទិភាពចំនួន **០៥** ដូចខាងក្រោម៖

## សកម្មភាពអាទិភាព ៣.១.១៖ ការពិនិត្យ និងកែសម្រួលអង្គមន្ត្រីរាជការស៊ីវិល

ផ្អែកតាមកិច្ចដំណើរការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ មានមន្ត្រីក្នុងវិស័យជាច្រើនប្រមាណ **១០ម៉ឺននាក់** ត្រូវបានផ្ទេរឱ្យស្ថិតនៅក្រោមរចនាសម្ព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិផ្ទាល់ អាស្រ័យហេតុនេះ ដើម្បីធានាដល់ការដាក់បញ្ចូលនូវមុខតំណែងនៃមន្ត្រីទាំងនេះទៅក្នុងអង្គមន្ត្រីវិជ្ជាជីវៈនីមួយៗឱ្យបានសមស្រប និងដើម្បីធានាដល់ប្រសិទ្ធភាពនៃការគ្រប់គ្រង ការរៀបចំ និងការប្រើប្រាស់មន្ត្រីទៅតាមជំនាញវិជ្ជាជីវៈនីមួយៗ ផអ៥ទី២ នឹងផ្តោតទៅលើ៖

- ពិនិត្យ និងរៀបចំឡើងវិញនូវអង្គមន្ត្រីរាជការនីមួយៗដែលមានការពាក់ព័ន្ធទៅនឹងមុខតំណែងនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដូចជា អង្គសុខាភិបាល អង្គគ្រូបង្រៀន អង្គរដ្ឋបាល និងអង្គបច្ចេកទេសជាដើម ដោយកំណត់ឱ្យបានច្បាស់លាស់អំពីអង្គវិជ្ជាជីវៈ ក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ ស្របតាមឧបនិស្ស័យ និងលក្ខណៈសម្បត្តិនានារបស់មន្ត្រីរាជការសម្រាប់ការជ្រើសរើស និងការតែងតាំងតាមមុខតំណែងនានានៅរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងត្រូវគិតគូរដល់ការលើកទឹកចិត្ត តាមរយៈការរៀបចំកំណត់អំពីក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ឱ្យស័ក្តិសមនឹងមុខតំណែង និងការទទួលខុសត្រូវរបស់មន្ត្រីនៃរដ្ឋបាលថ្នាក់ក្រោមជាតិ
- រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរៀបចំបុគ្គលិកឱ្យស្របទៅតាមការកំណត់តាមអង្គនីមួយៗបន្ទាប់ពីលិខិតបទដ្ឋានគតិយុត្តស្តីពីការរៀបចំអង្គមន្ត្រីរាជការត្រូវបានពិនិត្យ និងអនុម័ត។

***ស្ថាប័នទទួលខុសត្រូវអនុវត្ត*** ៖ ក្រសួងមុខងារសាធារណៈ ក្រសួងមហាផ្ទៃ និងក្រសួងសាមី
***ស្ថាប័នចូលរួមអនុវត្ត*** ៖ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ

**តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ៣.១.១.**

| ល.រ. | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | ព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈនៃអង្គសុខាភិបាល | សេចក្តីព្រាង | អនុម័ត | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ២ | ព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈនៃអង្គគ្រូបង្រៀន | សេចក្តីព្រាង | អនុម័ត | | | | |
| ៣ | ព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈនៃអង្គរដ្ឋបាល | | សេចក្តីព្រាង | អនុម័ត | | | |
| ៤ | ព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈនៃអង្គបច្ចេកទេស | | សេចក្តីព្រាង | អនុម័ត | | | |

**សកម្មភាពអាទិភាព ៣.១.២.៖ ការរៀបចំនិយាមនីតិវិធីប្រតិបត្តិសម្រាប់ការប្រឡងប្រជែងជ្រើសរើសមន្ត្រីក្របខ័ណ្ឌ និងមន្ត្រីផ្អែកលើកិច្ចព្រមព្រៀងការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ**

នាពេលបច្ចុប្បន្ននេះ រដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសរដ្ឋបាលខេត្ត ក្រុង ស្រុកមានបញ្ហាប្រឈម យ៉ាងខ្លាំងអំពីកង្វះបុគ្គលិក ជាពិសេសបុគ្គលិកជំនាញបច្ចេកទេសក្នុងពេលដែលរាជរដ្ឋាភិបាលបានផ្អាកឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិជ្រើសរើសមន្ត្រីថ្មីតាំងពីឆ្នាំ២០២១ រហូតមកដល់បច្ចុប្បន្ន។ បន្ថែមពីនេះទៀត ជារៀងរាល់ឆ្នាំមានមន្ត្រីចូលនិវត្តន៍ជាបន្តបន្ទាប់ដែលធ្វើឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិកាន់តែជួបប្រទះបញ្ហាខ្វះបុគ្គលិកកាន់តែខ្លាំងឡើងៗពីមួយឆ្នាំទៅមួយឆ្នាំ។

ជាក់ស្តែង បុគ្គលិកជំនាញតាមវិស័យ (២០វិស័យ) ដែលបានផ្ទេរក្នុងឆ្នាំ២០២០ មានចំនួន **៧.៥៤៨នាក់** មកដល់ឆ្នាំ២០២៥នេះ បុគ្គលិកទាំងនោះនៅសល់ចំនួន**៥.៦៦៩នាក់** មានការថយចុះចំនួន **១.៨៧៩នាក់** (២៥%)។ ជារួម មន្ត្រីជំនាញស្ទើរគ្រប់វិស័យមានការថយចុះ ដោយសារការចូលនិវត្តន៍ ការផ្ទេរចេញ មរណភាពជាដើម លើកលែងតែវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ដែលមានការកើនឡើងចំនួន**៤៤នាក់**។ ចំនួននេះ នឹងបន្តថយចុះបន្ថែមទៀតនៅឆ្នាំ២០២៦ និងឆ្នាំ២០២៧ខាងមុខ ដែលធ្វើឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមិនអាចអនុវត្តមុខងារ និងធនធានដែលបានផ្ទេរទៅឱ្យ និងម្ចាស់ការគ្រប់គ្រង ចាត់ចែងកិច្ចការចាំបាច់នានានៅមូលដ្ឋានបានល្អប្រសើរ។

បើពិនិត្យមើលចំនួនមន្ត្រីជាមធ្យមសម្រាប់រដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗ (លើកលែងគណៈអភិបាល និងនាយក/នាយករងរដ្ឋបាល និងបុគ្គលិកអប់រំ) មានចំនួន **៣៥រូប**។ បើពិនិត្យមើលចំនួនមន្ត្រីនៅតាមការិយាល័យនីមួយៗ (មន្ត្រីរដ្ឋបាល និងមន្ត្រីជំនាញ) នោះយើងឃើញថា ជាមធ្យមការិយាល័យនីមួយៗ (លើកលែងការិយាល័យអប់រំ យុវជន និងកីឡា) មានមន្ត្រីប្រមាណ**២,៧នាក់ក្នុងមួយការិយាល័យ** (ចន្លោះពី ១នាក់ទៅ ៦នាក់ក្នុងមួយការិយាល័យ ដោយគិតបញ្ចូលទាំងប្រធាន អនុប្រធាន និងមន្ត្រី)។

ដើម្បីធានាបានការជ្រើសរើសមន្ត្រីក្របខ័ណ្ឌ និងមន្ត្រីផ្អែកលើកិច្ចព្រមព្រៀងការងារបន្ថែមនៅរដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយគុណាធិបតេយ្យ តម្លាភាព យុត្តិធម៌ បរិយាបន្ន សមធម៌ គុណសម្បត្តិស័ក្តិសម និងត្រូវអនុវត្តអនុលោមតាមបទប្បញ្ញត្តិជាធរមាន កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពជាអាទិភាពនេះរួមមាន៖

- រៀបចំនិយាម និងនីតិវិធីប្រតិបត្តិសម្រាប់ការប្រឡងប្រជែងជ្រើសរើសមន្ត្រីក្របខ័ណ្ឌ និងមន្ត្រីផ្អែកលើកិច្ចព្រមព្រៀងការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- ផ្សព្វផ្សាយ និងបណ្តុះបណ្តាលដល់រដ្ឋបាលថ្នាក់ក្រោមជាតិអំពីនិយាម និងនីតិវិធីប្រតិបត្តិសម្រាប់ការប្រឡងប្រជែងជ្រើសរើសមន្ត្រី បុគ្គលិករបស់ខ្លួន

- រៀបចំការប្រលងប្រជែងជ្រើសរើសបុគ្គលិកក្របខ័ណ្ឌ និងមន្ត្រីផ្នែកលើកិច្ចព្រមព្រៀងការងារស្របតាមនិយាម និងនីតិវិធីប្រតិបត្តិដែលបានកំណត់ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ ក្រសួងមុខងារសាធារណៈ ក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប.
**ស្ថាប័នចូលរួមអនុវត្ត** ៖ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ

**តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ៣.១.២.**

| ល.រ. | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | និយាមនីតិវិធីប្រតិបត្តិសម្រាប់ការប្រឡងប្រជែងជ្រើសរើសបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិដែលបានអនុម័ត | | ១ | | | | |
| ២ | ភាគរយរដ្ឋបាលក្រុង ស្រុកបានអនុវត្ត | | | ១0% | ៥0% | ៧0% | ១00% |
| ៣ | ភាគរយរដ្ឋបាលរាជធានី ខេត្តបានអនុវត្ត | | | ៥0% | ១00% | | |

## សកម្មភាពអាទិភាព ៣.១.៣.៖ ការរៀបចំគោលនយោបាយលើកទឹកចិត្តបុគ្គលិកនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

បច្ចុប្បន្ននេះ កង្វះធនធានមនុស្សទាំងបរិមាណ និងគុណភាពនៅរដ្ឋបាលថ្នាក់ក្រោមជាតិនៅតែជាបញ្ហាប្រឈមចម្បងនៅឡើយ បើទោះបីជាមុខងារ ធនធាន និងការទទួលខុសត្រូវទាំងក្នុងការអភិវឌ្ឍមូលដ្ឋាន និងការផ្តល់សេវានានាត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិកាន់តែច្រើនឡើងៗក៏ដោយ។ បញ្ហាប្រឈមទាំងនេះ ដោយសារការរៀបចំមុខតំណែង ក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងប្រាក់បំណាច់មុខងារសម្រាប់មុខតំណែងនានានៅរដ្ឋបាលថ្នាក់ក្រោមជាតិពុំទាន់មានការលើកទឹកចិត្តឱ្យបានសមស្រប និងជំរុញឱ្យមានការស្ម័គ្រចិត្តរបស់បុគ្គលិកដែលមានសមត្ថភាព និងចំណេះដឹងខ្ពស់ឱ្យទៅបំពេញការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសនៅថ្នាក់ស្រុកដែលនៅឆ្ងាយពីទីប្រជុំជន និងជួបការលំបាក។ អាស្រ័យហេតុនេះ ដើម្បីទាក់ទាញ និងធានាឱ្យមានបុគ្គលិកដែលមានសមត្ថភាព បទពិសោធន៍ និងជំនាញវិជ្ជាជីវៈសមស្របទៅបំពេញការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ផអ៥ទី២ ចាំបាច់ត្រូវពិនិត្យមើលឡើងវិញ និងរៀបចំឱ្យមានគោលនយោបាយលើកទឹកចិត្តដល់បុគ្គលិកទាំងផ្នែកថវិកា និងមិនមែនថវិកា (មុខតំណែង ក្របខ័ណ្ឌ ឋានន្តរស័ក្តិ ប័ណ្ណសរសើរ មេដាយ ។ល។) សម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាដល់ការផ្តល់សេវាជូនប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព។

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពជាអាទិភាពនេះរួមមាន៖

- សិក្សាអំពីជម្រើសនានាសម្រាប់ផ្តល់ការលើកទឹកចិត្តដល់បុគ្គលិកដែលបម្រើការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- រៀបចំ និងដាក់ឱ្យអនុវត្តគោលនយោបាយលើកទឹកចិត្តដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ លេខាធិការដ្ឋាន គ.ជ.អ.ប. ក្រសួងមហាផ្ទៃ ក្រសួងមុខងារសាធារណៈ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**ស្ថាប័នគាំទ្រអនុវត្ត** ៖ រដ្ឋបាលថ្នាក់ក្រោមជាតិ ក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍន៍

**តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ៣.១.៣.**

| ល.រ. | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | របាយការណ៍សិក្សាអំពីជម្រើសនានាសម្រាប់រៀបចំប្រព័ន្ធលើកទឹកចិត្តបុគ្គលិកនៅរដ្ឋបាលថ្នាក់ក្រោមជាតិ | | សិក្សា | | | | |
| ២ | គោលនយោបាយលើកទឹកចិត្តបុគ្គលិកនៅរដ្ឋបាលថ្នាក់ក្រោមជាតិដែលបានអនុម័ត | | | ១ | | | |

## សកម្មភាពអាទិភាព ៣.១.៤៖ ការរៀបចំ និងដាក់ឱ្យអនុវត្តសេចក្តីណែនាំស្តីពីការបង្កើនចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

គ.ជ.អ.ប. បានដាក់ចេញផែនការយុទ្ធសាស្ត្រស្តីពីការបង្កើនចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ (២០២៤-២០២៨)។ ដើម្បីសម្រេចបានគោលដៅដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រនេះ លេខាធិការដ្ឋាន គ.ជ.អ.ប. ត្រូវសម្របសម្រួល និងសហការជាមួយក្រសួងមហាផ្ទៃ ក្រសួងកិច្ចការនារី និងក្រសួងមុខងារសាធារណៈក្នុងការរៀបចំ និងអនុវត្តកិច្ចការដូចខាងក្រោម៖

- រៀបចំសេចក្តីណែនាំស្តីពីការបង្កើនចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្តនូវសេចក្តីណែនាំនេះ ដើម្បីឱ្យរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌយកចិត្តទុកដាក់ក្នុងការបង្កើនចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រងនៅថ្នាក់ក្រោមជាតិក្នុងគោលដៅបង្កើនការចូលរួមរបស់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិឆ្លើយតបទៅនឹងការលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម
- គាំទ្រ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ដើម្បីជំរុញ និងពង្រឹងការអនុវត្តសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាពខ្ពស់។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ លេខាធិការដ្ឋាន គ.ជ.អ.ប ក្រសួងមហាផ្ទៃ ក្រសួងកិច្ចការនារី និងក្រសួងមុខងារសាធារណៈ

**ស្ថាប័នគាំទ្រអនុវត្ត** ៖ ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងដៃគូអភិវឌ្ឍន៍

**តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ៣.១.៤.**

| ល.រ | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | សេចក្តីណែនាំស្តីពីការបង្កើនចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌដែលបានអនុម័ត | សេចក្តីព្រាង | ១ | | | | |
| ២ | ភាគរយស្ត្រីក្នុងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលរាជធានី ខេត្ត | ៣៣% | ៣៥% | ៣៥,៥% | ៣៦% | ៣៦,៥% | ៣៧% |
| ៣ | ភាគរយស្ត្រីក្នុងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាល ក្រុង ស្រុក ខណ្ឌ | ២៣% | ២៥% | ២៧% | ២៨% | ២៩% | ៣០% |

## សកម្មភាពអាទិភាព ៣.១.៥៖ ការរៀបចំ និងដាក់ឱ្យអនុវត្តសេចក្ដីណែនាំស្ដីពីការបង្កើតបរិយាកាសមេត្រីភាព និងលក្ខខណ្ឌអំណោយផលនៅកន្លែងបំពេញការងារ

គ.ជ.អ.ប. បានដាក់ចេញផែនការយុទ្ធសាស្ត្រស្ដីពីការបង្កើនចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ (២០២៤-២០២៨)។ ដើម្បីសម្រេចបានគោលដៅដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រនេះ ការបង្កើតបរិយាកាសមេត្រីភាព និងលក្ខខណ្ឌអំណោយផលនៅកន្លែងបំពេញការងារសម្រាប់បុគ្គលិកជាស្ត្រីគឺជាការចាំបាច់។

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពជាអាទិភាពនេះរួមមាន៖

- រៀបចំ និងដាក់ឱ្យអនុវត្តសេចក្ដីណែនាំស្ដីពីការបង្កើតបរិយាកាសមេត្រីភាព និងលក្ខខណ្ឌអំណោយផលនៅកន្លែងបំពេញការងារ និងការអនុវត្តតួនាទី ភារកិច្ចរបស់បុគ្គលិកនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិរៀបចំឱ្យមានទីកន្លែងបំពេញការងារដែលមានលក្ខណៈងាយស្រួល និងសុវត្ថិភាពសម្រាប់បុគ្គលិក និងរៀបចំឱ្យមានយន្តការនិងវិធានការក្នុងការទទួល និងដោះស្រាយបណ្ដឹងនានា ដើម្បីធានាដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសបុគ្គលិកជាស្ត្រី ជនមានពិការភាព ជនជាតិដើមភាគតិចអាចអនុវត្តតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព និងស័ក្ដិសិទ្ធិភាព
- គាំទ្រ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ដើម្បីជំរុញ និងពង្រឹងការអនុវត្តសេចក្ដីណែនាំនេះឱ្យមានប្រសិទ្ធភាពខ្ពស់។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ លេខាធិការដ្ឋាន គ.ជ.អ.ប. ក្រសួងមហាផ្ទៃ ក្រសួងកិច្ចការនារី ក្រសួងមុខងារសាធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

**ស្ថាប័នគាំទ្រអនុវត្ត** ៖ ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងដៃគូអភិវឌ្ឍន៍

**តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ៣.១.៥.**

| ល.រ | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | សេចក្ដីណែនាំស្ដីពីការបង្កើតបរិយាកាសមេត្រីភាព និងលក្ខខណ្ឌអំណោយផលនៅកន្លែងបំពេញការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិដែលបានអនុម័ត | សេចក្ដីព្រាង | ១ | | | | |
| ២ | ភាគរយរដ្ឋបាលរាជធានី ខេត្តដែលបានរៀបចំទីកន្លែងបំពេញការងារស្របតាមសេចក្ដីណែនាំ | | | ៥០% | ៧០% | ១០០% | |
| ៣ | ភាគរយរដ្ឋបាលក្រុង ស្រុក ខណ្ឌដែលបានរៀបចំទីកន្លែងបំពេញការងារស្របតាមសេចក្ដីណែនាំ | | | ៣០% | ៦០% | ៩០% | ១០០% |

## លទ្ធផលរំពឹងទុកទី ៣.២៖ ប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្មត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត

ប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម មិនត្រឹមជាឧបករណ៍សម្រាប់វាយតម្លៃក្នុងការបំពេញការងាររបស់បុគ្គលិកប៉ុណ្ណោះទេ ប៉ុន្តែជាឧបករណ៍ដ៏មានសារៈសំខាន់ក្នុងការគ្រប់គ្រង ការអភិវឌ្ឍសមត្ថភាព ការដាក់វិន័យ និងការលើកទឹកចិត្តដល់បុគ្គលិកសំដៅពង្រឹងប្រសិទ្ធភាពនៃការបំពេញការងាររបស់បុគ្គលិក។ ការរៀបចំប្រព័ន្ធគ្រប់គ្រងបុគ្គលិកផ្អែកលើសមិទ្ធកម្ម គឺដើម្បីរៀបចំផែនការសម្រាប់បុគ្គលិកម្នាក់ៗបំពេញការងារសំដៅសម្រេចបានគោលដៅនិងបេសកកម្មរបស់អង្គភាព ពង្រឹងផលិតភាពនិងប្រសិទ្ធភាពការងាររបស់បុគ្គលិក ពង្រឹងទំនាក់ទំនងនិងខ្សែគណនេយ្យភាពឱ្យបានច្បាស់លាស់រវាងអ្នកគ្រប់គ្រងនិងបុគ្គលិក កំណត់ឱ្យបានត្រឹមត្រូវអំពីតម្រូវការអភិវឌ្ឍសមត្ថភាព ផ្តល់យុត្តិធម៌និងតម្លាភាពក្នុងការតែងតាំង ការតម្លើងថ្នាក់ ឋានន្តរស័ក្តិ ការលើកទឹកចិត្តឬការផ្តល់រង្វាន់ ព្រមទាំងជួយស្ថាប័ន/អង្គភាពអាចរៀបចំផែនការយុទ្ធសាស្ត្រគ្រប់គ្រងធនធានមនុស្សបានល្អទៀតផង។

ប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្មត្រូវរៀបចំឱ្យមានសមាសធាតុសំខាន់ៗដូចជាការកំណត់មុខតំណែងវិជ្ជាជីវៈនិងការពិពណ៌នាមុខតំណែងរបស់បុគ្គលិក លក្ខខណ្ឌការងារប្រចាំឆ្នាំសម្រាប់បុគ្គលិកម្នាក់ៗ ការគ្រប់គ្រងវត្តមានបុគ្គលិកប្រចាំថ្ងៃ ការវាយតម្លៃបុគ្គលិកផ្អែកលើសមទ្ធិកម្មប្រចាំឆ្នាំ និងការលើកទឹកចិត្ត។

ដើម្បីសម្រេចបាននូវលទ្ធផលរំពឹងទុកនេះ ផអ៥ទី២ បានគ្រោងឡើងនូវសកម្មភាពអាទិភាពចំនួន០៦ ដូចខាងក្រោម៖

### សកម្មភាពអាទិភាព ៣.២.១.៖ ការរៀបចំ និងការដាក់ឱ្យអនុវត្តមុខតំណែងវិជ្ជាជីវៈរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ

អនុក្រឹត្យលេខ៧៦ អនក្រ.បក ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៣ ស្តីពីការកំណត់មុខតំណែងវិជ្ជាជីវៈ និងការពិពណ៌នាមុខតំណែងនានានៃរចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវបានដាក់ចេញ ហើយសេចក្តីណែនាំអំពីនីតិវិធីរៀបចំមុខតំណែងវិជ្ជាជីវៈរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ក៏បានរៀបចំដាក់ចេញដោយ គ.ជ.អ.ប. ដើម្បីផ្តល់ការណែនាំដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌក្នុងការរៀបចំកំណត់អំពីតម្រូវការមុខតំណែងវិជ្ជាជីវៈ ការពិពណ៌នាមុខតំណែងវិជ្ជាជីវៈ និងតម្រូវការចំនួនបុគ្គលិក ព្រមទាំងការរៀបចំបុគ្គលិកទៅតាមមុខតំណែងវិជ្ជាជីវៈនីមួយៗស្របទៅតាមជំនាញវិជ្ជាជីវៈ និងបទពិសោធន៍ការងាររបស់បុគ្គលិកម្នាក់ៗ។

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពជាអាទិភាពនេះរួមមាន៖

- ផ្សព្វផ្សាយ និងផ្តល់ការបណ្តុះបណ្តាលដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌអំពីខ្លឹមសារនៃអនុក្រឹត្យ និងសេចក្តីណែនាំស្តីពីការកំណត់មុខតំណែងវិជ្ជាជីវៈ និងការពិពណ៌នាមុខតំណែងនានានៃរចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក ខណ្ឌ

- កំណត់មុខតំណែងវិជ្ជាជីវៈ និងចំនួនបុគ្គលិកដែលមានតម្រូវការជាក់ស្តែងនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗដោយផ្អែកទៅលើមុខងារ តួនាទី ភារកិច្ច និងសក្តានុពលសេដ្ឋកិច្ច-សង្គម និងតម្រូវការសេវាសាធារណៈ ព្រមទាំងរៀបចំការពិពណ៌នាមុខតំណែង
- រៀបចំបុគ្គលិកតាមមុខតំណែងវិជ្ជាជីវៈនីមួយៗស្របទៅតាមជំនាញ និងបទពិសោធន៍របស់បុគ្គលិកម្នាក់ៗ
- គាំទ្រ តាមដាន និងត្រួតពិនិត្យលើការរៀបចំ និងកំណត់មុខតំណែងវិជ្ជាជីវៈ និងការរៀបចំការពិពណ៌នាមុខតំណែងរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ លេខាធិការដ្ឋាន គ.ជ.អ.ប. ក្រសួងមុខងារសាធារណៈ ក្រសួងមហាផ្ទៃ និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ

**ស្ថាប័នចូលរួមអនុវត្ត** ៖ ក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍន៍

**តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ៣.២.១.**

| ល.រ. | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | ភាគរយរដ្ឋបាលក្រុង ស្រុក ខណ្ឌទទួលបានការបណ្តុះបណ្តាលអំពីការកំណត់មុខតំណែងវិជ្ជាជីវៈ និងការពិពណ៌នាមុខតំណែងវិជ្ជាជីវៈ | | ១០០% | | | | |
| ២ | ភាគរយរដ្ឋបាលក្រុង ស្រុក ខណ្ឌបានរៀបចំ និងកំណត់មុខតំណែងវិជ្ជាជីវៈ | | ៥០% | ១០០% | | | |
| ៣ | របាយការណ៍វាយតម្លៃអំពីតម្រូវការបុគ្គលិកនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ | | ១ | | | | |
| ៤ | ផែនការផ្តល់បុគ្គលិកបន្ថែមទៅឱ្យរដ្ឋបាល ក្រុង ស្រុក ខណ្ឌ | | | ១ | | | |

**សកម្មភាពអាទិភាព ៣.២.២.៖ ការរៀបចំ និងដាក់ឱ្យអនុវត្តមុខតំណែងវិជ្ជាជីវៈរបស់រដ្ឋបាលថ្នាក់រាជធានី ខេត្ត**

គោលបំណងសំខាន់នៃការកំណត់ឱ្យមានមុខតំណែងវិជ្ជាជីវៈ និងការរៀបចំឱ្យមានការពិពណ៌នាមុខតំណែង គឺដើម្បីធានាឱ្យរដ្ឋបាលរាជធានី ខេត្ត មានមូលដ្ឋានច្បាស់លាស់សម្រាប់ (១). រៀបចំបុគ្គលិកឱ្យចំតាមជំនាញ និង/ឬបទពិសោធន៍ការងារ (២). រៀបចំផែនការបុគ្គលិកផ្អែកលើតម្រូវការធនធានមនុស្សជាក់ស្តែង (ទាំងចំនួន និងជំនាញ) (៣). ជ្រើសរើសបុគ្គលិកឱ្យចំតាមជំនាញដែលរដ្ឋបាលរាជធានីខេត្តនីមួយៗត្រូវការចាំបាច់ (៤). រៀបចំលក្ខខណ្ឌការងារសម្រាប់បុគ្គលិកម្នាក់ៗឱ្យបានច្បាស់លាស់ (៥). រៀបចំផែនការបន្តវេនដែលធានាដល់ការត្រៀមធនធានមនុស្សដែលមានសមត្ថភាពខ្ពស់សមស្របសម្រាប់តែងតាំងជំនួសបុគ្គលិកដែលចូលនិវត្តន៍ ឬបាត់បង់ និង(៦). អភិវឌ្ឍសមត្ថភាពបុគ្គលិកឱ្យត្រូវទៅតាមជំនាញដែលត្រូវការជាក់ស្តែងរបស់រដ្ឋបាលរាជធានី ខេត្តនីមួយៗ។

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពជាអាទិភាពនេះរួមមាន៖

- រៀបចំអនុក្រឹត្យស្តីពីការកំណត់មុខតំណែងវិជ្ជាជីវៈ និងការពិពណ៌នាមុខតំណែងនានានៃរចនាសម្ព័ន្ធរដ្ឋបាលរាជធានី ខេត្ត
- រៀបចំ និងដាក់ចេញសេចក្តីណែនាំស្តីពីការកំណត់មុខតំណែងវិជ្ជាជីវៈ និងការពិពណ៌នាមុខតំណែងនីមួយៗ
- ផ្សព្វផ្សាយ និងផ្តល់ការបណ្តុះបណ្តាលដល់រដ្ឋបាលរាជធានី ខេត្ត ដើម្បីអនុវត្ត
- កំណត់មុខតំណែងវិជ្ជាជីវៈ និងចំនួនបុគ្គលិកដែលមានតម្រូវការជាក់ស្តែងនៅរដ្ឋបាលរាជធានី ខេត្តនីមួយៗដោយផ្អែកទៅលើមុខងារ តួនាទី ភារកិច្ច និងសក្តានុពលសេដ្ឋកិច្ច-សង្គម និងតម្រូវការសេវាសាធារណៈ ព្រមទាំងរៀបចំការពិពណ៌នាមុខតំណែង
- រៀបចំបុគ្គលិកតាមមុខតំណែងវិជ្ជាជីវៈនីមួយៗស្របទៅតាមជំនាញ និងបទពិសោធន៍របស់បុគ្គលិកម្នាក់ៗ
- គាំទ្រ តាមដាន និងត្រួតពិនិត្យលើការអនុវត្តរបស់រដ្ឋបាលរាជធានី ខេត្ត។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ លេខាធិការដ្ឋាន គ.ជ.អ.ប. ក្រសួងមុខងារសាធារណៈ ក្រសួងមហាផ្ទៃ និងរដ្ឋបាលរាជធានី ខេត្ត

**ស្ថាប័នចូលរួមអនុវត្ត** ៖ ក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍន៍

**តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ៣.២.២.**

| ល.រ | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | អនុក្រឹត្យស្តីពីការកំណត់មុខតំណែង និងការពិពណ៌នាមុខតំណែងនៅរដ្ឋបាលរាជធានី ខេត្ត | របាយការណ៍សិក្សា | ១ | | | | |
| ២ | សេចក្តីណែនាំស្តីពីការរៀបចំមុខតំណែង និងការពិពណ៌នាមុខតំណែងនៅរដ្ឋបាលរាជធានី ខេត្ត | | ១ | | | | |
| ៣ | ភាគរយរដ្ឋបាលរាជធានី ខេត្តបានរៀបចំ និងកំណត់មុខតំណែងវិជ្ជាជីវៈ និងការពិពណ៌នាមុខតំណែង | | | ១០០% | | | |
| ៤ | របាយការណ៍វាយតម្លៃអំពីតម្រូវការបុគ្គលិកនៅរដ្ឋបាលរាជធានី ខេត្ត | | | ១ | | | |

### សកម្មភាពអាទិភាព ៣.២.៣.៖ ការរៀបចំ និងការពង្រឹងការអនុវត្តក្រមសីលធម៌វិជ្ជាជីវៈសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ

ក្រមសីលធម៌វិជ្ជាជីវៈជាវិធាន ឬបទបញ្ញាផ្នែកសីលធម៌ដែលស្ថាប័ននីមួយៗបានកំណត់ឡើងសម្រាប់ដាក់ឱ្យបុគ្គលិកគ្រប់រូបប្រតិបត្តិដោយខ្ជាប់ខ្ជួន ដើម្បីធានារក្សាបាននូវគុណតម្លៃ កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់បុគ្គលិកម្នាក់ៗ និងរបស់ស្ថាប័ននីមួយៗ។ នាពេលបច្ចុប្បន្ននេះ ក្រមសីលធម៌វិជ្ជាជីវៈសម្រាប់អង្គវិជ្ជាជីវៈមួយចំនួនដូចជា អង្គគ្រូបង្រៀន អង្គសុខាភិបាល (គ្រូពេទ្យ) ត្រូវបានរៀបចំ និងកំពុងអនុវត្ត ក៏ប៉ុន្តែអង្គវិជ្ជាជីវៈមួយចំនួនទៀតដូចជាក្រមសីលធម៌វិជ្ជាជីវៈសម្រាប់អង្គរដ្ឋបាលទូទៅ និង

អង្គបច្ចេកទេសត្រូវបាននិងកំពុងរៀបចំ។

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពអាទិភាពនេះរួមមាន៖

- រៀបចំក្រមសីលធម៌វិជ្ជាជីវៈសម្រាប់អង្គរដ្ឋបាល អង្គបច្ចេកទេស និងអង្គដទៃទៀត
- ពង្រឹងការអនុវត្តនូវក្រមសីលធម៌វិជ្ជាជីវៈរបស់បុគ្គលិក ដើម្បីលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការបំពេញការងាររបស់បុគ្គលិក ជាពិសេសការធ្វើទំនាក់ទំនងសាធារណៈ និងការផ្តល់សេវាសាធារណៈ។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ ក្រសួងមុខងារសាធារណៈ ក្រសួងមហាផ្ទៃ លេខាធិការដ្ឋាន គ.ជ.អ.ប. និងក្រសួង ស្ថាប័នសាមី

**ស្ថាប័នចូលរួមអនុវត្ត** ៖ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ

**តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ៣.២.៣.**

| ល.រ. | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | ក្រមសីលធម៌វិជ្ជាជីវៈសម្រាប់អង្គរដ្ឋបាល និងអង្គបច្ចេកទេសដែលបានរៀបចំ | សេចក្តីព្រាង | ១ | ១ | | | |
| ២ | ភាគរយរដ្ឋបាលរាជធានី ខេត្តដែលបានដាក់ចេញក្រមសីលធម៌វិជ្ជាជីវៈសម្រាប់បុគ្គលិក | | | ១00% | | | |
| ៣ | ភាគរយរដ្ឋបាលក្រុង ស្រុក ខណ្ឌដែលបានដាក់ចេញក្រមសីលធម៌វិជ្ជាជីវៈសម្រាប់បុគ្គលិក | | | ១00% | | | |

## សកម្មភាពអាទិភាព ៣.២.៤.៖ ការពង្រឹង និងការកែលម្អការរៀបចំលក្ខខណ្ឌការងារប្រចាំឆ្នាំសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ

ក្រសួងមហាផ្ទៃបានដាក់ចេញសៀវភៅណែនាំស្តីពីការគ្រប់គ្រងកិច្ចការរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងនោះក៏មានការណែនាំក្នុងការគ្រប់គ្រងបុគ្គលិកផងដែរ ព្រមទាំងតម្រូវឱ្យរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌរៀបចំលក្ខខណ្ឌការងារប្រចាំឆ្នាំសម្រាប់បុគ្គលិករបស់ខ្លួន ដើម្បីធ្វើជាមូលដ្ឋានក្នុងការបំពេញការងារ និងការវាយតម្លៃការបំពេញការងាររបស់បុគ្គលិកប្រចាំឆ្នាំ។ ទោះជាយ៉ាងនេះក្តី បច្ចុប្បន្នការរៀបចំលក្ខខណ្ឌការងារសម្រាប់បុគ្គលិកនៅរដ្ឋបាលថ្នាក់ក្រោមជាតិពុំទាន់បានអនុវត្តឱ្យបានពេញលេញ និងមានប្រសិទ្ធភាពខ្ពស់នៅឡើយ។

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពអាទិភាពនេះរួមមាន៖

- រៀបចំផ្សព្វផ្សាយគោលការណ៍ណែនាំអំពីការរៀបចំលក្ខខណ្ឌការងារប្រចាំឆ្នាំរបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ
- ពង្រឹងការរៀបចំ និងការអនុវត្តលក្ខខណ្ឌការងារប្រចាំឆ្នាំសម្រាប់បុគ្គលិកដែលត្រូវធ្វើឡើងរវាងប្រធានអង្គភាព និងបុគ្គលិកម្នាក់ៗ ដើម្បីជាមូលដ្ឋានក្នុងការវាយតម្លៃលើលទ្ធផលនៃ

ការបំពេញការងាររបស់បុគ្គលិកម្នាក់ៗ។ លក្ខខណ្ឌការងារនេះ គឺជាឯកសារដែលរៀបរាប់លម្អិតអំពីការទទួលខុសត្រូវ និងលទ្ធផលរំពឹងទុក សូចនាករឬចំណុចដៅ និងក្របខ័ណ្ឌពេលវេលាច្បាស់លាស់។ ការរៀបចំលក្ខខណ្ឌការងារនេះ ផ្អែកជាសំខាន់ទៅលើផែនការសកម្មភាពប្រចាំឆ្នាំរបស់អង្គភាពនីមួយៗ និងការពិពណ៌នាមុខតំណែងរបស់បុគ្គលិកម្នាក់ៗ។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ លេខាធិការដ្ឋាន គ.ជ.អ.ប. ក្រសួងមហាផ្ទៃ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

**ស្ថាប័នគាំទ្រអនុវត្ត** ៖ ក្រសួងមុខងារសាធារណៈ និងក្រសួង ស្ថាប័ន

**តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ៣.២.៤.**

| ល.រ | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | ភាគរយរដ្ឋបាលរាជធានី ខេត្តបានរៀបចំលក្ខខណ្ឌការងារប្រចាំឆ្នាំសម្រាប់បុគ្គលិករបស់ខ្លួនស្របតាមការកំណត់ | | ១០០% | ១០០% | ១០០% | ១០០% | ១០០% |
| ២ | ភាគរយរដ្ឋបាលក្រុង ស្រុក ខណ្ឌបានរៀបចំលក្ខខណ្ឌការងារប្រចាំឆ្នាំសម្រាប់បុគ្គលិករបស់ខ្លួនស្របតាមការកំណត់ | | ១០០% | ១០០% | ១០០% | ១០០% | ១០០% |

**សកម្មភាពអាទិភាព ៣.២.៥.៖ ការពង្រឹងការគ្រប់គ្រងវត្តមានបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ**

រាជរដ្ឋាភិបាលបានដាក់ចេញអនុក្រឹត្យលេខ៥៦ អនក្រ.បក ចុះថ្ងៃទី១ ខែមេសា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងវត្តមានមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា។ ការបន្តពង្រឹងការគ្រប់គ្រងវត្តមានបុគ្គលិកនៃរដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាយន្តការមួយរួមចំណែកក្នុងការតាមដានការអនុវត្តការងាររបស់បុគ្គលិក ដើម្បីលើកកម្ពស់មនសិការវិជ្ជាជីវៈ និងជាផ្នែកមួយនៃការវាយតម្លៃផ្អែកលើសមិទ្ធកម្មរបស់បុគ្គលិក។ អ្នកគ្រប់គ្រងអាចកំណត់អំពីបែបផែននៃការគ្រប់គ្រងវត្តមានបុគ្គលិករបស់ខ្លួន ដោយកំណត់អំពីពេលវេលាបម្រើការងារ រយៈពេលបំពេញការងារក្នុងមួយថ្ងៃ និងទីកន្លែងបម្រើការងាររបស់បុគ្គលិកប្រកបដោយបរិយាបន្ន និងសមធម៌ និងមានលក្ខណៈបត់បែនតាមស្ថានភាពជាក់ស្តែងនៃការផ្តល់សេវាសាធារណៈ។

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពអាទិភាពនេះរួមមាន៖

- ពង្រឹងការចុះបញ្ជីវត្តមានជាប្រចាំថ្ងៃដោយមានការត្រួតពិនិត្យច្បាស់លាស់
- រៀបចំ និងដាក់ឱ្យអនុវត្តនូវប្រព័ន្ធគ្រប់គ្រងវត្តមានបុគ្គលិកនៃរដ្ឋបាលថ្នាក់ក្រោមជាតិតាមប្រព័ន្ធឌីជីថល។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ រដ្ឋបាលថ្នាក់ក្រោមជាតិ

**ស្ថាប័នគាំទ្រអនុវត្ត** ៖ ក្រសួងមុខងារសាធារណៈ និងក្រសួងមហាផ្ទៃ

**តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ៣.២.៥.**

| ល.រ. | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១ | ភាគរយរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌមានបញ្ជីវត្តមានប្រចាំថ្ងៃ | | ១០០% | ១០០% | ១០០% | ១០០% | ១០០% |
| ២ | ប្រព័ន្ធគ្រប់គ្រងវត្តមានបុគ្គលិកនៃរដ្ឋបាលថ្នាក់ក្រោមជាតិតាមប្រព័ន្ធឌីជីថល | | រៀបចំ | អនុវត្ត | | | |

### សកម្មភាពអាទិភាព ៣.២.៦.៖ ការវាយតម្លៃបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិផ្អែកលើសមិទ្ធកម្ម

នាពេលបច្ចុប្បន្ននេះ រដ្ឋបាលថ្នាក់ក្រោមជាតិពុំទាន់មានយន្តការ និងនីតិវិធីច្បាស់លាស់ក្នុងការវាយតម្លៃលើការបំពេញការងាររបស់បុគ្គលិកប្រចាំឆ្នាំប្រកបដោយប្រសិទ្ធភាព និងតម្លាភាពនៅឡើយ។ ការវាយតម្លៃលើការបំពេញការងាររបស់បុគ្គលិក គឺជាសមាសភាគដ៏សំខាន់មួយនៃប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម ព្រមទាំងផ្តល់ភាពយុត្តិធម៌ និងតម្លាភាពក្នុងការតែងតាំង ការតម្លើងថ្នាក់ ឋានន្តរស័ក្តិ ការលើកទឹកចិត្ត ឬការផ្តល់រង្វាន់ដល់បុគ្គលិកផងដែរ។

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពអាទិភាពនេះរួមមាន៖

- រៀបចំសេចក្តីណែនាំស្តីពីការវាយតម្លៃបុគ្គលិកផ្អែកលើសមិទ្ធកម្ម
- ផ្សព្វផ្សាយ និងបណ្តុះបណ្តាលដល់រដ្ឋបាលថ្នាក់ក្រោមជាតិអំពីសេចក្តីណែនាំស្តីពីការវាយតម្លៃបុគ្គលិកផ្អែកលើសមិទ្ធកម្ម
- អនុវត្តការវាយតម្លៃបុគ្គលិកផ្អែកលើសមិទ្ធកម្មដោយរដ្ឋបាលថ្នាក់ក្រោមជាតិ
- គាំទ្រ តាមដាន ត្រួតពិនិត្យរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តប្រព័ន្ធវាយតម្លៃលើការបំពេញការងាររបស់បុគ្គលិកប្រចាំឆ្នាំ។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ លេខាធិការដ្ឋាន គ.ជ.អ.ប. ក្រសួងមហាផ្ទៃ ក្រសួងមុខងារសាធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

**ស្ថាប័នគាំទ្រអនុវត្ត** ៖ ក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍន៍

**តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ៣.២.៦.**

| ល.រ. | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | សេចក្តីណែនាំស្តីពីការវាយតម្លៃផ្អែកលើសមិទ្ធកម្មរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | | | អនុម័ត | | | |
| ២ | ភាគរយរដ្ឋបាលរាជធានី ខេត្តដែលបានវាយតម្លៃផ្អែកលើសមិទ្ធកម្ម | | | | ១០០% | ១០០% | ១០០% |
| ៣ | ភាគរយរដ្ឋបាលក្រុង ស្រុក ខណ្ឌដែលបានវាយតម្លៃផ្អែកលើសមិទ្ធកម្ម | | | | ៥០% | ៧៥% | ១០០% |

### លទ្ធផលរំពឹងទុក ៣.៣.៖ សមត្ថភាពក្រុមប្រឹក្សា និងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានលើកកម្ពស់

ការអភិវឌ្ឍសមត្ថភាពក្រុមប្រឹក្សា និងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានផ្តល់ឱ្យជារៀងរាល់ឆ្នាំ តាមរយៈការបណ្តុះបណ្តាល និងសិក្ខាសាលានានាផ្អែកលើកម្មវិធីសិក្សាជាកាតព្វកិច្ច និងករណីចាំបាច់ដែលស្ថិតក្រោមការផ្តល់ និងការគាំទ្រពីសាលាជាតិរដ្ឋបាលមូលដ្ឋាននៃក្រសួងមហាផ្ទៃ គ្រឹះស្ថានបណ្តុះបណ្តាលសាធារណៈ លេខាធិការដ្ឋាន គ.ជ.អ.ប. ក្រសួង ស្ថាប័ន សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ គម្រោង/កម្មវិធីផ្សេងៗរបស់ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលនានា។ ទោះបីមានការបណ្តុះបណ្តាលជាបន្តបន្ទាប់យ៉ាងនេះក្តី ក៏ការបណ្តុះបណ្តាលពុំទាន់អាចឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅឡើយ ហើយឯកសារ និងកម្មវិធីបណ្តុះបណ្តាលមួយចំនួនដែលបានរៀបចំជាយូរឆ្នាំមកហើយ ក៏លែងសមស្របទៅនឹងស្ថានភាពបច្ចុប្បន្ននៃការវិវឌ្ឍ គោលនយោបាយថ្មីៗ បច្ចេកវិទ្យាឌីជីថល ការវិវឌ្ឍនៃសង្គម-សេដ្ឋកិច្ច មុខងារ និងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

អាស្រ័យហេតុនេះ ការអភិវឌ្ឍសមត្ថភាពក្រុមប្រឹក្សា និងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិត្រូវផ្តោតអាទិភាពលើ៖

- ការពិនិត្យ កែសម្រួល និងធ្វើបច្ចុប្បន្នភាពឯកសារបណ្តុះបណ្តាល និងកម្មវិធីសិក្សាដែលមានស្រាប់ និងការរៀបចំឯកសារ និងកម្មវិធីសិក្សាថ្មីៗប្រកបដោយនវានុវត្តន៍
- ការពិនិត្យកែលម្អវិធីសាស្ត្របណ្តុះបណ្តាលដោយបញ្ចូលនូវការប្រើប្រាស់ប្រព័ន្ធឌីជីថល និងបញ្ញាសិប្បនិម្មិត (AI)
- ការរៀបចំក្របខ័ណ្ឌស្តង់ដាសមត្ថភាពសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ និង
- ការសិក្សានិងការកំណត់អំពីតម្រូវការបណ្តុះបណ្តាល និងការពង្រឹងភាពជាម្ចាស់របស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗក្នុងការរៀបចំឱ្យមានការអភិវឌ្ឍសមត្ថភាពបុគ្គលិករបស់ខ្លួន។

ដើម្បីសម្រេចបាននូវលទ្ធផលរំពឹងទុកនេះ ផអ៥ទី២ បានគ្រោងឡើងនូវសកម្មភាពអាទិភាពចំនួន **០៥** ដូចខាងក្រោម៖

### សកម្មភាពអាទិភាព ៣.៣.១.៖ ការរៀបចំក្របខ័ណ្ឌស្តង់ដាសមត្ថភាពសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ

ការបង្កើតក្របខ័ណ្ឌស្តង់ដាសមត្ថភាពសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាមូលដ្ឋានសម្រាប់ការរៀបចំឯកសារ និងកម្មវិធីបណ្តុះបណ្តាលសម្រាប់ក្រុមគោលដៅជាក់លាក់នីមួយៗ។ ក្របខ័ណ្ឌស្តង់ដាសមត្ថភាពនេះ ត្រូវរៀបចំឡើងដោយផ្អែកលើមុខតំណែង (មុខតំណែងគ្រប់គ្រង និងមុខតំណែងវិជ្ជាជីវៈ) កម្រិតនៃមុខតំណែង/ក្របខ័ណ្ឌ ការពិពណ៌នាមុខតំណែង មុខងារនិងការទទួលខុសត្រូវរបស់ស្ថាប័ន ការវិវឌ្ឍនៃបច្ចេកវិទ្យាឌីជីថល និងតម្រូវការចាំបាច់នានា។

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពអាទិភាពនេះរួមមាន៖

- រៀបចំក្របខ័ណ្ឌស្តង់ដាសមត្ថភាពសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិដែលនឹងកំណត់យ៉ាងច្បាស់លាស់អំពីតម្រូវការបណ្តុះបណ្តាលជាមូលដ្ឋាន (កម្រិតអប្បរមា) និងរយៈពេលនៃការបណ្តុះបណ្តាលដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិនៅគ្រប់កម្រិត និងប្រភេទនៃមុខតំណែង
- ផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្តនូវក្របខ័ណ្ឌស្តង់ដាសមត្ថភាពសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ ក្រសួងមហាផ្ទៃ និងរដ្ឋបាលរាជធានី ខេត្ត

**ស្ថាប័នគាំទ្រអនុវត្ត** ៖ ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងដៃគូអភិវឌ្ឍន៍

**តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ៣.៣.១.**

| ល.រ. | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | ក្របខ័ណ្ឌស្តង់ដាសមត្ថភាពសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ | សេចក្តីព្រាង | អនុម័ត | | | | |

## សកម្មភាពអាទិភាព ៣.៣.២.៖ ការរៀបចំ និងកែសម្រួលឯកសារនិងកម្មវិធីសិក្សាតាមក្របខ័ណ្ឌស្តង់ដាសមត្ថភាព

កន្លងមក សាលាជាតិរដ្ឋបាលមូលដ្ឋានបានរៀបចំ និងបណ្តុះបណ្តាលដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិទៅតាមកម្មវិធីសិក្សាមួយចំនួន រួមមាន (១). វគ្គសិក្សាអំពីការគ្រប់គ្រងកម្រិតខ្ពស់ (២). វគ្គសិក្សាអំពីការគ្រប់គ្រងកម្រិត២ (៣). វគ្គសិក្សាអំពីការគ្រប់គ្រងកម្រិត១ (៤). វគ្គសិក្សាអំពីវិក្រឹត្យការជំនាញ (៥). វគ្គសិក្សាអំពីវិក្រឹត្យការមូលដ្ឋាន និង(៦). វគ្គសិក្សាអំពីលេខាធិការរដ្ឋបាល។ ទោះយ៉ាងនេះក្តី កម្មវិធីបណ្តុះបណ្តាលខាងលើនេះនៅមិនទាន់ឆ្លើយតបទៅនឹងស្តង់ដាសមត្ថភាពច្បាស់លាស់នៅឡើយ អាស្រ័យហេតុនេះ បន្ទាប់ពីក្របខ័ណ្ឌស្តង់ដាសមត្ថភាពត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្ត សាលាជាតិរដ្ឋបាលមូលដ្ឋានត្រូវពិនិត្យ កែសម្រួលឯកសារ និងកម្មវិធីសិក្សាដែលមានស្រាប់ខាងលើ និងរៀបចំឯកសារ និងកម្មវិធីសិក្សាថ្មីៗឱ្យស្របតាមការកំណត់នៅក្នុងក្របខ័ណ្ឌស្តង់ដាសមត្ថភាព។

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពអាទិភាពនេះរួមមាន៖

- ពិនិត្យ និងកែសម្រួលឯកសារ និងកម្មវិធីសិក្សាដែលមានស្រាប់ឱ្យស្របតាមក្របខ័ណ្ឌស្តង់ដាសមត្ថភាព
- រៀបចំឯកសារ និងកម្មវិធីសិក្សាថ្មីៗដែលជាតម្រូវការចាំបាច់របស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបានកំណត់នៅក្នុងក្របខ័ណ្ឌស្តង់ដាសមត្ថភាព។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត ៖** ក្រសួងមហាផ្ទៃ (សាលាជាតិរដ្ឋបាលមូលដ្ឋាន)
**ស្ថាប័នគាំទ្រអនុវត្ត ៖** រដ្ឋបាលថ្នាក់ក្រោមជាតិ លេខាធិការដ្ឋាន គ.ជ.អ.ប. និងក្រសួង ស្ថាប័ន

**តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ៣.៣.២.**

| ល.រ | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | កម្មវិធីសិក្សាដែលបានពិនិត្យ កែសម្រួល និងអនុម័តដោយក្រុមប្រឹក្សាភិបាលសាលា | | | ១ | | | |
| ២ | កម្មវិធីសិក្សាថ្មីៗដែលបានរៀបចំ និងអនុម័តដោយក្រុមប្រឹក្សាភិបាលសាលា | | | ១ | | ១ | |

**សកម្មភាពអាទិភាព ៣.៣.៣.៖ ការបណ្តុះបណ្តាលដល់រដ្ឋបាលថ្នាក់ក្រោមជាតិ**

ជារៀងរាល់ឆ្នាំ សាលាជាតិរដ្ឋបាលមូលដ្ឋានបានរៀបចំផែនការ និងថវិកា ដើម្បីផ្តល់ការបណ្តុះបណ្តាលទៅដល់ក្រុមប្រឹក្សា និងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិបានជាមធ្យមប្រមាណ **៧៥០នាក់**។ រដ្ឋបាលរាជធានី ខេត្តក៏បានរៀបចំផែនការ និងថវិកាផ្តល់ការបណ្តុះបណ្តាលដល់ក្រុមប្រឹក្សា និងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិជាច្រើនពាន់នាក់ក្នុងមួយឆ្នាំៗ **(៤៥.០០០នាក់ ក្នុងឆ្នាំ២០២៥)**។ សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិក៏បានអភិវឌ្ឍសមត្ថភាពដល់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ **(៩៥នាក់ ក្នុងឆ្នាំ២០២៥)**។ ទន្ទឹមនេះ ក្រសួង ស្ថាប័នពាក់ព័ន្ធមួយចំនួនក៏បានរៀបចំការបណ្តុះបណ្តាលជំនាញដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ។ បន្ថែមពីនេះ ដោយមានការគាំទ្រពីគម្រោង/កម្មវិធីនានារបស់ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលផ្សេងៗ សាលាជាតិរដ្ឋបាលមូលដ្ឋានបានសហការ និងផ្តល់ការបណ្តុះបណ្តាលទៅតាមកម្មវិធីសិក្សាជាក់លាក់មួយចំនួនដល់ក្រុមប្រឹក្សា និងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ។

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពអាទិភាពនេះរួមមាន៖

- រៀបចំផែនការ និងថវិកាសម្រាប់ការបណ្តុះបណ្តាលប្រចាំឆ្នាំដល់ក្រុមប្រឹក្សា និងបុគ្គលិក ដោយផ្អែកលើក្របខ័ណ្ឌស្តង់ដាសមត្ថភាព និងលទ្ធផលនៃការវាយតម្លៃប្រចាំឆ្នាំអំពីតម្រូវការអភិវឌ្ឍន៍សមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (ដោយសាលាជាតិរដ្ឋបាលមូលដ្ឋាន និងរដ្ឋបាលរាជធានី ខេត្តនីមួយៗ)
- រៀបចំការបណ្តុះបណ្តាលដល់ក្រុមប្រឹក្សា និងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិតាមកម្មវិធីបណ្តុះបណ្តាលដែលបានកំណត់ និងវិធីសាស្ត្របណ្តុះបណ្តាលថ្មីៗប្រកបដោយនវានុវត្តន៍ និងការប្រើប្រាស់ប្រព័ន្ធឌីជីថល ឬបញ្ញាសិប្បនិម្មិត ជាដើម។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត ៖** ក្រសួងមហាផ្ទៃ និងរដ្ឋបាលរាជធានី ខេត្ត
**ស្ថាប័នគាំទ្រអនុវត្ត ៖** ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ និងដៃគូអភិវឌ្ឍន៍

**តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ៣.៣.៣.**

| ល.រ. | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | ចំនួនសមាជិកក្រុមប្រឹក្សា និងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិទទួលបានការបណ្តុះបណ្តាលដោយសាលាជាតិរដ្ឋបាលមូលដ្ឋាន | ៧៥០ | ៨៥០ | ១.១០០ | ១.៥០០ | ២.០០០ | ២.៥០០ |
| ២ | ចំនួនសមាជិកក្រុមប្រឹក្សា និងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិទទួលបានការបណ្តុះបណ្តាលដោយរដ្ឋបាលរាជធានី ខេត្តកើនឡើង | ៦.៧០០ | ៧.០០០ | ៧.០០០ | ៧.០០០ | ៧.០០០ | ៧.០០០ |
| ៣ | ចំនួនសមាជិកក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិទទួលបានការអភិវឌ្ឍសមត្ថភាពដោយសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ | ៧.៥៧៥ | ៧.០០០ | ៦.០០០ | ៦.០០០ | ៦.០០០ | ៦.០០០ |

## សកម្មភាពអាទិភាព ៣.៣.៤.៖ ការវាយតម្លៃអំពីប្រសិទ្ធភាពនៃការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

ដើម្បីពង្រឹងសមត្ថភាពទីចាត់ការគ្រប់គ្រងធនធានមនុស្សរាជធានី ខេត្តឱ្យកាន់តែមានសមត្ថភាពខ្ពស់ក្នុងការគាំទ្រ និងការផ្តល់ការបណ្តុះបណ្តាលដល់ក្រុមប្រឹក្សា និងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ សាលាជាតិរដ្ឋបាលមូលដ្ឋានត្រូវធ្វើការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃអំពីប្រសិទ្ធភាពនៃការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលរាជធានី ខេត្តជាប្រចាំ។

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពអាទិភាពនេះរួមមាន៖

- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃអំពីប្រសិទ្ធភាពនៃការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលរាជធានី ខេត្ត
- រដ្ឋបាលរាជធានី ខេត្តរៀបចំរបាយការណ៍វឌ្ឍនភាពស្តីពីការបណ្តុះបណ្តាលប្រចាំឆ្នាំ។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ ក្រសួងមហាផ្ទៃ

**ស្ថាប័នគាំទ្រអនុវត្ត** ៖ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ

**តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ៣.៣.៤.**

| ល.រ | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | របាយការណ៍វាយតម្លៃអំពីប្រសិទ្ធភាពនៃការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលរាជធានី ខេត្ត | | | | ១ | | |
| ២ | ភាគរយរដ្ឋបាលរាជធានី ខេត្តរៀបចំរបាយការណ៍វឌ្ឍនភាពស្តីពីការបណ្តុះបណ្តាលប្រចាំឆ្នាំ | | ១០០% | ១០០% | ១០០% | ១០០% | ១០០% |

## សកម្មភាពអាទិភាព ៣.៣.៥.៖ ការចែករំលែកមេរៀនបទពិសោធន៍ក្នុងចំណោមរដ្ឋបាលថ្នាក់ក្រោមជាតិអំពីការអនុវត្តមុខងារណាមួយដែលទទួលបានជោគជ័យ

ការចែករំលែកមេរៀនបទពិសោធន៍ គឺជាវិធីសាស្ត្រដ៏មានប្រសិទ្ធភាពមួយក្នុងការអភិវឌ្ឍសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការដឹកនាំ ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗឱ្យកាន់តែមានប្រសិទ្ធភាព។ វិធីសាស្ត្រនេះ ធ្វើឱ្យអ្នកចូលរួមបានឃើញដោយផ្ទាល់ ងាយយល់ ងាយចងចាំ និងងាយយកទៅអនុវត្ត។

អាស្រ័យហេតុនេះ ផអ៥ទី២ ត្រូវបន្តពង្រឹងការគ្រប់គ្រង និងការអនុវត្តមុខងារជាកាតព្វកិច្ច និងមុខងារជាជម្រើសរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាដល់ការដោះស្រាយបញ្ហាប្រឈម និងឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងនានារបស់ប្រជាពលរដ្ឋតាមមូលដ្ឋាននីមួយៗ។

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពអាទិភាពនេះរួមមាន៖

- រៀបចំចងក្រងនូវមេរៀនបទពិសោធន៍ល្អៗក្នុងការអនុវត្តមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- រៀបចំការផ្លាស់ប្តូរបទពិសោធន៍ក្នុងចំណោមរដ្ឋបាលថ្នាក់ក្រោមជាតិអំពីបទពិសោធន៍ល្អៗក្នុងការអនុវត្តមុខងារណាមួយដែលអនុវត្តបានជោគជ័យ តាមរយៈការរៀបចំសិក្ខាសាលា ឬទស្សនកិច្ចសិក្សា។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ លេខាធិការដ្ឋាន គ.ជ.អ.ប. ក្រសួងមហាផ្ទៃ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
**ស្ថាប័នគាំទ្រអនុវត្ត** ៖ ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងដៃគូអភិវឌ្ឍន៍

**តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ៣.៣.៥.**

| ល.រ. | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | ចំនួនសិក្ខាសាលាផ្លាស់ប្តូរបទពិសោធន៍អំពីការអនុវត្តមុខងារ | | ២ | ២ | ២ | ២ | ២ |
| ២ | ចំនួនទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍អំពីការអនុវត្តមុខងារ | | ២ | ២ | ២ | ២ | ២ |

### លទ្ធផលរំពឹងទុក ៣.៤៖ ស្ថាប័ន/អង្គភាពអភិវឌ្ឍន៍សមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពង្រឹង

ការអភិវឌ្ឍសមត្ថភាពដល់ក្រុមប្រឹក្សា និងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាគោលបំណងដ៏ចម្បងនៃ កជទី២ ក្នុងការធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានបុគ្គលិកប្រកបដោយសមត្ថភាពជំនាញដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង និងការផ្តល់សេវាសាធារណៈនៅមូលដ្ឋាន។ ក្នុងគោលបំណងនេះ សាលាជាតិរដ្ឋបាលមូលដ្ឋាននៃក្រសួងមហាផ្ទៃត្រូវបានបង្កើតឡើងនៅឆ្នាំ២០១៦ និងទីចាត់ការគ្រប់គ្រងធនធានមនុស្សនៃរដ្ឋបាលរាជធានី ខេត្ត ក៏ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០១០ ដើម្បីផ្តល់សេវាអភិវឌ្ឍសមត្ថភាពជាប្រចាំដល់ក្រុមប្រឹក្សា និងបុគ្គលិករដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។ ទោះបីជាស្ថាប័នផ្តល់សេវាអភិវឌ្ឍសមត្ថភាពទាំងនេះបានខិតខំផ្តល់ការបណ្តុះបណ្តាលជារៀងរាល់ឆ្នាំដល់ក្រុមប្រឹក្សា និងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិជាច្រើនពាន់នាក់ក៏ដោយ ក៏ការបណ្តុះបណ្តាលទាំងនោះពុំទាន់បានឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍសមត្ថភាពជាក់ស្តែងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅឡើយ។ អាស្រ័យហេតុនេះ ផអ៥ទី២ នឹងបន្តផ្តោតលើការពង្រឹងសមត្ថភាពសាលា

ជាតិរដ្ឋបាលមូលដ្ឋាន និងទីចាត់ការគ្រប់គ្រងធនធានមនុស្សនៃរដ្ឋបាលរាជធានី ខេត្តឱ្យក្លាយជាស្ថាប័នស្នូលក្នុងការអភិវឌ្ឍសមត្ថភាពក្រុមប្រឹក្សា និងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយគុណភាព ប្រសិទ្ធភាព និងនិរន្តរភាព។ ទន្ទឹមនេះ ក៏ត្រូវសិក្សាអំពីលទ្ធភាពនៃការរៀបចំឱ្យមានសាលាបណ្តុះបណ្តាលថ្នាក់តំបន់ដែលត្រូវរៀបចំ និងអនុវត្តជាជំហានៗទៅតាមលទ្ធភាពដែលអាចធ្វើទៅបាន។

ដើម្បីសម្រេចបាននូវលទ្ធផលរំពឹងទុកនេះ ផ.អ.៥ទី២ បានគ្រោងឡើងនូវសកម្មភាពអាទិភាពចំនួន០៤ ដូចខាងក្រោម៖

**សកម្មភាពអាទិភាព ៣.៤.១៖ ការពង្រឹងសមត្ថភាពគ្រូបង្គោលសាលាជាតិរដ្ឋបាលមូលដ្ឋាន**

ដើម្បីពង្រឹងសាលាជាតិរដ្ឋបាលមូលដ្ឋានក្លាយជាសាលាដែលផ្តល់ការបណ្តុះបណ្តាលប្រកបដោយគុណភាពដែលត្រូវបានទទួលស្គាល់ទាំងកម្រិតជាតិ និងកម្រិតតំបន់ សាលាជាតិរដ្ឋបាលមូលដ្ឋានត្រូវមានគ្រូបង្គោលដែលមានសមត្ថភាពអាចផ្តល់ការបណ្តុះបណ្តាលប្រកបដោយគុណភាពដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពអាទិភាពនេះរួមមាន៖

- រៀបចំគ្រូបង្គោលរបស់សាលាជាតិរដ្ឋបាលមូលដ្ឋានឱ្យបានច្បាស់លាស់
- វាយតម្លៃអំពីតម្រូវការបណ្តុះបណ្តាលដល់គ្រូបង្គោលរបស់សាលាជាតិរដ្ឋបាលមូលដ្ឋាន
- រៀបចំផែនការ និងថវិកាបណ្តុះបណ្តាលប្រចាំឆ្នាំដល់បុគ្គលិកសាលាជាតិរដ្ឋបាលមូលដ្ឋានឱ្យក្លាយជាគ្រូបង្គោលប្រកបដោយសមត្ថភាពខ្ពស់
- ផ្តល់ការបណ្តុះបណ្តាលដល់គ្រូបង្គោលសាលាជាតិរដ្ឋបាលមូលដ្ឋានជាប្រចាំ ព្រមទាំងស្វែងរកគ្រឹះស្ថានបណ្តុះបណ្តាលសាធារណៈ និងឯកជនទាំងក្នុងប្រទេស និងគ្រឹះស្ថានបណ្តុះបណ្តាលក្រៅប្រទេស ដើម្បីផ្តល់ការបណ្តុះបណ្តាលដល់គ្រូបង្គោលសាលាជាតិរដ្ឋបាលមូលដ្ឋានក្លាយជាគ្រូបង្គោលប្រកបដោយគុណភាព និងមានវិជ្ជាជីវៈច្បាស់លាស់។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ ក្រសួងមហាផ្ទៃ
**ស្ថាប័នគាំទ្រអនុវត្ត** ៖ ក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍន៍

**តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ៣.៤.១.**

| ល.រ. | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | របាយការណ៍វាយតម្លៃអំពីតម្រូវការបណ្តុះបណ្តាលគ្រូបង្គោលរបស់សាលាជាតិរដ្ឋបាលមូលដ្ឋាន | | ១ | ១ | ១ | ១ | ១ |
| ២ | ផែនការ និងថវិកាបណ្តុះបណ្តាលប្រចាំឆ្នាំ | | ១ | ១ | ១ | ១ | ១ |
| ៣ | ចំនួនគ្រូបង្គោលទទួលបានការបណ្តុះបណ្តាលទាំងក្នុង និងក្រៅប្រទេស | | ២០ | ៣០ | ៤០ | ៥០ | ៦០ |

**សកម្មភាពអាទិភាព ៣.៤.២៖ ការលើកកម្ពស់ការគ្រប់គ្រងសាលាជាតិរដ្ឋបាលមូលដ្ឋាន**

សាលាជាតិរដ្ឋបាលមូលដ្ឋាននៃក្រសួងមហាផ្ទៃត្រូវបានបង្កើតឡើង និងដាក់ឱ្យដំណើរការនៅឆ្នាំ២០១៦។ រហូតមកដល់ពេលនេះ សាលាជាតិរដ្ឋបាលមូលដ្ឋានពុំទាន់មានហេដ្ឋារចនាសម្ព័ន្ធសាលាពេញលេញ និងពុំទាន់មានស្តង់ដានៃប្រតិបត្តិការការងារ (SOP) ដែលមានលក្ខណៈសមស្របជាស្ថាប័នបណ្តុះបណ្តាលប្រកបដោយជំនាញវិជ្ជាជីវៈនៅឡើយ និងខ្វះប្រព័ន្ធគ្រប់គ្រងបែបឌីជីថល។

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពអាទិភាពនេះរួមមាន៖

- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាលាជាតិរដ្ឋបាលមូលដ្ឋាន និងបំពាក់ឧបករណ៍ សម្ភារ ស័ក្តិសមជាស្ថាប័នបណ្តុះបណ្តាលប្រកបដោយជំនាញវិជ្ជាជីវៈ
- រៀបចំសៀវភៅប្រតិបត្តិការការងារនៃសាលាជាតិរដ្ឋបាលមូលដ្ឋានជាស្ថាប័នបណ្តុះបណ្តាលប្រកបដោយជំនាញវិជ្ជាជីវៈដែលគ្របដណ្តប់លើការងាររដ្ឋបាល ការងារគ្រប់គ្រងបុគ្គលិក និងគ្រូបង្រៀន ការងារហិរញ្ញវត្ថុ ការងារលទ្ធកម្ម ការគ្រប់គ្រងសិក្ខាកាម/សិស្ស ការគ្រប់គ្រងបណ្ណាល័យ ការគ្រប់គ្រងអន្តេវាសិកដ្ឋាន ការរៀបចំកម្មវិធីសិក្សា ការស្រាវជ្រាវ ការវាយតម្លៃលើការបណ្តុះបណ្តាល ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្នុងការរៀន និងការបង្រៀន
- ផ្តល់ការបណ្តុះបណ្តាលដល់បុគ្គលិកសាលាជាតិរដ្ឋបាលមូលដ្ឋានអំពីប្រតិបត្តិការការងាររបស់សាលា
- រៀបចំប្រព័ន្ធឌីជីថលសម្រាប់ការគ្រប់គ្រងបុគ្គលិក/គ្រូ ការគ្រប់គ្រងហិរញ្ញវត្ថុ ការគ្រប់គ្រងអន្តេវាសិកដ្ឋាន បណ្ណាល័យ ការគ្រប់គ្រងសិក្ខាកាម/សិស្ស។ ប្រព័ន្ធបណ្តុះបណ្តាលឌីជីថលដូចជាការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិច (E-Learning Center/Platform) ការបង្រៀននិងការសិក្សាអនឡាញនិងការរៀបចំមេរៀនឌីជីថល។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ ក្រសួងមហាផ្ទៃ
**ស្ថាប័នគាំទ្រអនុវត្ត** ៖ ក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍន៍

**តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ៣.៤.២.**

| ល.រ. | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | សៀវភៅប្រតិបត្តិការការងារសាលាជាតិរដ្ឋបាលមូលដ្ឋាន | | អនុម័ត | | | | |
| ២ | ការរៀបចំប្រព័ន្ធសិក្សាអេឡិចត្រូនិច (E-Learning Center/Platform) | | | សិក្សា រៀបចំ | អនុម័ត | | |
| ៣ | ភាគរយការបង្រៀននិងការសិក្សាអនឡាញ (Online Study) | | ៣០% | ៤០% | ៥០% | ៦០% | ៧០% |
| ៤ | ការរៀបចំមេរៀនឌីជីថល (Digital Courses) | | សិក្សា រៀបចំ | អនុម័ត | | | |

**សកម្មភាពអាទិភាព ៣.៤.៣៖ ការពង្រឹងកិច្ចសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័ន គ្រឹះស្ថានបណ្តុះបណ្តាលសាធារណៈនិងឯកជន និងវិទ្យាស្ថានឯកទេសទាំងក្នុងតំបន់និងពិភពលោក**

កន្លងមកសាលាជាតិរដ្ឋបាលមូលដ្ឋានបានសហការជាមួយក្រសួង ស្ថាប័ន គ្រឹះស្ថានបណ្តុះបណ្តាលសាធារណៈ ឯកជន ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលមួយចំនួន ដើម្បីជួយរៀបចំកម្មវិធីសិក្សា និងផ្តល់គ្រូឧទ្ទេសក្នុងការបណ្តុះបណ្តាលទៅដល់ក្រុមប្រឹក្សា និងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិលើប្រធានបទជាក់លាក់មួយចំនួន។ បច្ចុប្បន្នសាលាជាតិរដ្ឋបាលមូលដ្ឋានបានចុះអនុស្សារណៈ/កិច្ចព្រមព្រៀងជាមួយស្ថាប័នបណ្តុះបណ្តាលទាំងក្នុង និងក្រៅប្រទេសចំនួន១៦។ ក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការនេះបានធ្វើឱ្យសាលាជាតិរដ្ឋបាលមូលដ្ឋានមានសមត្ថភាព និងលទ្ធភាពក្នុងការផ្តល់សេវាអភិវឌ្ឍសមត្ថភាពកាន់តែមានគុណភាព និងសម្រេចបានជាបណ្តើរៗនូវកម្មវិធីបណ្តុះបណ្តាលស្របទៅតាមយុទ្ធសាស្ត្រអភិវឌ្ឍសមត្ថភាពរបស់សាលាជាតិរដ្ឋបាលមូលដ្ឋាន។ អាស្រ័យហេតុនេះ ផអ៥ទី២ នឹងត្រូវបន្តជំរុញពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការនេះបន្ថែមទៀត។

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពអាទិភាពនេះរួមមាន៖

- ពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័ន គ្រឹះស្ថានបណ្តុះបណ្តាលសាធារណៈ និងឯកជន ដើម្បីស្វែងរកការគាំទ្រការរៀបចំកម្មវិធីសិក្សា និងការបណ្តុះបណ្តាលដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិលើជំនាញនានា ដូចជាជំនាញច្បាប់ អភិបាលកិច្ច ការសម្រុះសម្រួលវិវាទ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការងាររដ្ឋបាល ការគ្រប់គ្រងបុគ្គលិក និងជំនាញបច្ចេកទេសតាមវិស័យនានា ។ល។
- បន្តពង្រឹងកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលនានា ដើម្បីកៀរគរធនធានក្នុងការរៀបចំឯកសារនិងកម្មវិធីបណ្តុះបណ្តាល និងការបណ្តុះបណ្តាល
- បង្កើតភាពជាដៃគូជាមួយវិទ្យាស្ថាននានាក្នុងតំបន់ និងពិភពលោកក្នុងការបណ្តុះបណ្តាលបុគ្គលិករដ្ឋបាលរដ្ឋបាលថ្នាក់ក្រោមជាតិ និងពង្រីកកិច្ចសហការ និងការផ្លាស់ប្តូរទស្សនកិច្ចសិក្សា/ចែករំលែកមេរៀនបទពិសោធន៍ពីគ្នាទៅវិញទៅមក ដើម្បីពង្រឹងសមត្ថភាពសាលាជាតិរដ្ឋបាលមូលដ្ឋាន។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ ក្រសួងមហាផ្ទៃ

**ស្ថាប័នគាំទ្រអនុវត្ត** ៖ ក្រសួង ស្ថាប័ន គ្រឹះស្ថានបណ្តុះបណ្តាលសាធារណៈ និងឯកជន ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល

**តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ៣.៤.៣.**

| ល.រ. | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១ | អនុស្សរណៈយោគយល់គ្នាជាមួយសកលវិទ្យាល័យ ឬវិទ្យាស្ថានឯកទេស ឬដៃគូអភិវឌ្ឍន៍ ឬអង្គការសង្គមស៊ីវិល | ១៥ | ២ | ២ | ២ | ២ | ២ |
| ២ | អនុស្សរណៈយោគយល់គ្នាជាមួយវិទ្យាស្ថានក្នុងតំបន់ ឬពិភពលោក | ១ | | | ១ | | |

## សកម្មភាពអាទិភាព ៣.៤.៤៖ ការពង្រឹងសមត្ថភាពអង្គភាពទទួលបន្ទុកអភិវឌ្ឍន៍សមត្ថភាពនៃរដ្ឋបាលរាជធានី ខេត្ត

បច្ចុប្បន្ន ទីចាត់ការគ្រប់គ្រងធនធានមនុស្សនៃរដ្ឋបាលរាជធានី ខេត្ត ដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសមត្ថភាពដល់ក្រុមប្រឹក្សា និងបុគ្គលិករដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ក្នុងការបំពេញតួនាទី ភារកិច្ចកន្លងមកនេះ ទីចាត់ការគ្រប់គ្រងធនធានមនុស្សនៃរដ្ឋបាលរាជធានី ខេត្តក៏នៅមានកម្រិតទាំងសមត្ថភាព និងលទ្ធភាពក្នុងការផ្តល់សេវាអភិវឌ្ឍសមត្ថភាពដល់ក្រុមប្រឹក្សា និងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។ អាស្រ័យហេតុនេះ ផអ៥ទី២ ក៏នឹងបន្តផ្តោតលើការពង្រឹងអង្គភាពទទួលបន្ទុកអភិវឌ្ឍន៍សមត្ថភាពនៃរដ្ឋបាលរាជធានី ខេត្តឱ្យក្លាយទៅជាអង្គភាពផ្តល់សេវាអភិវឌ្ឍសមត្ថភាពប្រកបដោយគុណភាព និងប្រសិទ្ធភាព។

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពអាទិភាពនេះរួមមាន៖

- រៀបចំសេចក្តីណែនាំអំពីការវាយតម្លៃតម្រូវការបណ្តុះបណ្តាល ការធ្វើផែនការ និងការគ្រោងថវិកាសម្រាប់បណ្តុះបណ្តាលរបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។ សាលាជាតិរដ្ឋបាលមូលដ្ឋានត្រូវរៀបចំសេចក្តីណែនាំនេះ ហើយផ្តល់ការបណ្តុះបណ្តាលដល់អង្គភាពទទួលបន្ទុកអភិវឌ្ឍន៍សមត្ថភាពនៃរដ្ឋបាលរាជធានី ខេត្តឱ្យមានចំណេះដឹងច្បាស់លាស់ក្នុងការវាយតម្លៃអំពីតម្រូវការបណ្តុះបណ្តាល ការរៀបចំផែនការនិងថវិកាបណ្តុះបណ្តាលប្រចាំឆ្នាំ
- សិក្សា និងវាយតម្លៃសមត្ថភាពនិងតម្រូវការបណ្តុះបណ្តាលរបស់អង្គភាពទទួលបន្ទុកអភិវឌ្ឍន៍សមត្ថភាពនៃរដ្ឋបាលរាជធានី ខេត្ត
- រៀបចំជ្រើសរើសបុគ្គលិកដែលមានសមត្ថភាព និងបទពិសោធន៍ការងារ ដើម្បីរៀបចំជាគ្រូបង្គោលតាមរដ្ឋបាលរាជធានី ខេត្តនីមួយៗ ដែលគ្រូបង្គោលទាំងនោះត្រូវទទួលស្គាល់ដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តាមរយៈសាលាជាតិរដ្ឋបាលមូលដ្ឋាន។ គ្រូបង្គោលទាំងនោះនឹងទទួលបានកម្រៃសេវាបង្រៀនតាមការកំណត់របស់រាជរដ្ឋាភិបាល។
- គាំទ្រ និងផ្តល់ការអភិវឌ្ឍសមត្ថភាពដល់បុគ្គលិក/គ្រូបង្គោលនៃអង្គភាពទទួលបន្ទុកអភិវឌ្ឍន៍សមត្ថភាពនៃរដ្ឋបាលរាជធានី ខេត្ត
- សិក្សា និងរៀបចំបង្កើតសាលាបណ្តុះបណ្តាលនៅតាមតំបន់មួយចំនួននៅថ្នាក់ក្រោមជាតិដែលមានវិសាលភាពផ្តល់សេវាអភិវឌ្ឍសមត្ថភាពដល់ក្រុមប្រឹក្សា និងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិតាមតំបន់នីមួយៗ (៤-៦ខេត្ត)។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ ក្រសួងមហាផ្ទៃ លេខាធិការដ្ឋាន គ.ជ.អ.ប. និងរដ្ឋបាលរាជធានី ខេត្ត
**ស្ថាប័នគាំទ្រអនុវត្ត** ៖ ក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍន៍

## តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ៣.៤.៤.

| ល.រ. | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | សេចក្តីណែនាំអំពីការវាយតម្លៃតម្រូវការបណ្តុះបណ្តាលដែលបានរៀបចំ និងផ្សព្វផ្សាយអនុវត្ត | | អនុម័ត | | | | |
| ២ | របាយការណ៍វាយតម្លៃអំពីតម្រូវការបណ្តុះបណ្តាលរបស់បុគ្គលិកទីចាត់ការគ្រប់គ្រងធនធានមនុស្ស | | អនុម័ត | | | | |
| ៣ | របាយការណ៍សិក្សាស្តីពីលទ្ធភាពនៃការបង្កើតសាលាបណ្តុះបណ្តាលតាមតំបន់ | | | សិក្សា | អនុម័ត | | |

## ៤. សមាសភាគទី៤៖ វិមជ្ឈការហិរញ្ញវត្ថុ និងប្រព័ន្ធផែនការនិងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

### ៤.១. សមិទ្ធផល

ផ្អែកតាមលទ្ធផលនៃការវាយតម្លៃពាក់កណ្តាលអាណត្តិនៃ កជទី២ ឬការវាយតម្លៃបញ្ចប់ ផអ៥ទី១ (២០២១-២០២៥) បានបង្ហាញថា ការអនុវត្តសមាសភាគទី៤ នៃ កជទី២ ដែលពាក់ព័ន្ធនឹងការងារវិមជ្ឈការហិរញ្ញវត្ថុ និងប្រព័ន្ធផែនការនិងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ សម្រេចបានលទ្ធផលសំខាន់ៗមួយចំនួន ដូចជា៖

- ការរៀបចំថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានអនុវត្តផ្អែកលើគម្រោងសកម្មភាពនៃកម្មវិធីវិនិយោគបីឆ្នាំរំកិល ស្របតាមប្រតិទិនការងារ និងនីតិវិធីកំណត់
- ការរៀបចំ និងអនុវត្តថវិកានៃរដ្ឋបាលថ្នាក់ក្រោមជាតិបានដំណើរការប្រកបដោយប្រសិទ្ធភាពតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន រួមមាន ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS)
- រដ្ឋបាលរាជធានី ខេត្តទាំង២៥ បាននិងកំពុងប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ (SARMIS) ដែលបានដាក់ឱ្យអនុវត្តចាប់ពីឆ្នាំ២០២១
- ការចូលរួមធនធានពីថវិការដ្ឋសម្រាប់មូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់មានការកើនឡើងគួរឱ្យកត់សម្គាល់
- មូលនិធិមានភ្ជាប់លក្ខខណ្ឌសម្រាប់មុខងារវិស័យសុខាភិបាលបានផ្ទេរទៅឱ្យរដ្ឋបាលរាជធានី ខេត្ត និងមូលនិធិមានភ្ជាប់លក្ខខណ្ឌសម្រាប់មុខងារវិស័យអប់រំបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ព្រមទាំងបានអនុវត្តប្រកបដោយប្រសិទ្ធភាព
- រដ្ឋបាលខេត្តបានចាត់ចែងថវិការបស់ខ្លួនយ៉ាងតិចចំនួន១០% នៃថវិកាគុណប្រយោជន៍សម្រាប់គាំទ្រការងារសេវាសង្គម និង
- រដ្ឋបាលក្រុង ស្រុក ខណ្ឌមួយចំនួនក៏ទទួលបានមូលនិធិមានភ្ជាប់លក្ខខណ្ឌសម្រាប់អនុវត្តមុខងារវិស័យផ្សេងទៀតផងដែរ (អនាម័យបរិស្ថាន អភិវឌ្ឍជនបទ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ)។

ទន្ទឹមនឹងសមិទ្ធផលខាងលើ ការវាយតម្លៃពាក់កណ្តាលអាណត្តិនៃ កជទី២ ក៏បានបង្ហាញឱ្យឃើញថា សកម្មភាពជាអាទិភាពមួយចំនួននៅក្នុង ផអ៥ទី១ មិនទាន់បានអនុវត្ត ដូចជា៖

- ការរៀបចំឯកសារជាយុទ្ធសាស្ត្រនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ការរៀបចំយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ឆ្នាំ២០២៦-២០៣០
- ការពង្រឹងប្រព័ន្ធគ្រប់គ្រងមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ

- ការលើកកម្ពស់សិទ្ធិអំណាចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ធនធានផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌសម្រាប់គម្រោងសេវាកម្មនានា
- ការពិនិត្យមើលឡើងវិញ និងការពង្រឹងការគ្រប់គ្រងមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ
- ការលើកកម្ពស់ក្របខ័ណ្ឌសម្រាប់ការគ្រប់គ្រងធនធានរបស់ដៃគូអភិវឌ្ឍន៍ដែលផ្តល់ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ
- ការពង្រឹងក្របខ័ណ្ឌគ្រប់គ្រងការវិនិយោគសាធារណៈដែលប្រើប្រាស់ថវិកាផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

បន្ថែមលើនេះ ក៏មានបញ្ហាប្រឈមមួយចំនួនដែលត្រូវដោះស្រាយក្នុងការអនុវត្ត ផអ៥ទី២ (២០២៦-២០៣០) ដូចជា៖

- រដ្ឋបាលរាជធានី ខេត្តមានប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុចំនួន២ គឺប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់រដ្ឋបាលរាជធានី ខេត្ត និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់វិស័យសុខាភិបាល
- មូលនិធិផ្នែកអភិវឌ្ឍន៍ក្រុង ស្រុកនៅមានទំហំតិចតួចធៀបនឹងការទទួលខុសត្រូវរបស់ខ្លួនលើសពីនេះ មូលនិធិនេះត្រូវបានបែងចែកសម្រាប់អនុវត្តមុខងារវិស័យមួយចំនួនទៀតដែលបានផ្ទេរពីក្រសួង ស្ថាប័ន និង
- ថវិកាសម្រាប់អនុវត្តមុខងារវិស័យនានាដែលបានផ្ទេរឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ មានទំហំតិចតួច លើកលែងវិស័យអប់រំ។

អាស្រ័យហេតុនេះ ការបន្តពង្រឹងការងារវិមជ្ឈការហិរញ្ញវត្ថុ និងការកែលម្អប្រព័ន្ធផែនការនិងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិគឺជាកិច្ចការចាំបាច់ ដើម្បីធានាដល់ការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ធនធានឱ្យមានប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព បរិយាបន្ន និងសមធម៌សង្គមស្របតាមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងស្របតាមការរៀបចំឡើងវិញនៃរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

ពាក់ព័ន្ធនឹងការបន្តពង្រឹងការងារវិមជ្ឈការហិរញ្ញវត្ថុ និងការកែលម្អប្រព័ន្ធផែនការនិងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ផអ៥ទី២ នឹងបន្តផ្តោតលើ (១). ការពង្រឹងភាពម្ចាស់ការ និងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ធនធានហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព បរិយាបន្ន និងសមធម៌សង្គម ដើម្បីធានាដល់ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានឆ្លើយតបទៅនឹងតម្រូវការអាទិភាពនានារបស់ប្រជាពលរដ្ឋ (២). ការពិនិត្យឡើងវិញនូវប្រព័ន្ធកសាងផែនការ និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យស្របតាមចរិតលក្ខណៈនៃទីក្រុងមេត្រូប៉ូលីតែន រដ្ឋបាលតំបន់ និងរដ្ឋបាលមូលដ្ឋាន (ទីប្រជុំជន និងជនបទ) និងស្របតាមក្របខ័ណ្ឌនៃការរៀបចំគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (៣). ការសិក្សាពីលទ្ធភាពនៃការបង្កើនធនធានហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការផ្ទេរ

ធនធានពីថ្នាក់ជាតិ មូលនិធិនានាដូចជា មូលនិធិភាតរភាព មូលនិធិសមធម៌ (ប្រព័ន្ធបែងចែកថវិកាប្រកបដោយសមធម៌) មូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ មូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ និងការបង្កើនប្រភពចំណូលផ្ទាល់ ដើម្បីធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានធនធានហិរញ្ញវត្ថុសមស្របទៅនឹងបន្ទុកការងារ និងការអភិវឌ្ឍមូលដ្ឋានឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ (៤). ការពង្រឹងការអនុវត្តថវិកាតាមកម្មវិធីនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិអាចចាត់ចែង និងប្រើប្រាស់ថវិកាប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព (៥). ការពង្រឹងក្របខ័ណ្ឌភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងវិស័យឯកជន (PPP) ដើម្បីធានាដល់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមប្រកបដោយចីរភាព និងពិពិធភាព និង (៦). កិច្ចការជាអាទិភាពផ្សេងៗទៀតផ្អែកទៅលើរបកគំហើញដែលបានមកពីការសិក្សាវាយតម្លៃ គោលនយោបាយ និងយុទ្ធសាស្ត្រថ្មីៗរបស់រាជរដ្ឋាភិបាល។

### ៩.២. សមិទ្ធផលរំពឹងទុក

សមិទ្ធផលរំពឹងទុកនៃសមាសភាគនេះគឺ **"រដ្ឋបាលថ្នាក់ក្រោមជាតិមានធនធានថវិកាដែលអាចព្យាករណ៍បាន និងមានទំហំសមស្របទៅនឹងមុខងារ និងអាទិភាពគោលនយោបាយជាតិ ហើយត្រូវបានវិភាជសម្រាប់ការប្រើប្រាស់ប្រកបដោយភាពបត់បែនក្នុងការឆ្លើយតបទៅនឹងតម្រូវការនានា ដូចមានកំណត់នៅក្នុងផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគ និងផែនការយុទ្ធសាស្ត្រថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ"**។

ដើម្បីសម្រេចបាននូវសមាសភាគនេះ ផអ៥ទី២ នឹងបន្តអនុវត្តសកម្មភាពអាទិភាពសំខាន់ៗមួយចំនួនដែលមិនបានអនុវត្ត និងបានអនុវត្តតែមិនបានបញ្ចប់ក្នុងអំឡុងពេលនៃការអនុវត្ត ផអ៥ទី១ ព្រមទាំងសកម្មភាពសំខាន់ៗមួយចំនួនទៀតសំដៅបន្តពង្រឹងការងារវិមជ្ឈការហិរញ្ញវត្ថុ និងការកែលម្អប្រព័ន្ធផែនការនិងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

### ៩.៣. លទ្ធផលរំពឹងទុក

ដើម្បីសម្រេចបាននូវសមិទ្ធផលរំពឹងទុកខាងលើ សមាសភាគទី៤ បានកំណត់នូវលទ្ធផលរំពឹងទុកចំនួន០៨ ដូចខាងក្រោម៖

- លទ្ធផលរំពឹងទុកទី១៖ កិច្ចដំណើរការកសាងផែនការត្រូវបានពង្រឹង កែលម្អ និងបន្សុីគ្នាជាមួយនឹងការរៀបចំគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- លទ្ធផលរំពឹងទុកទី២៖ ភាពជាម្ចាស់ និងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ធនធានហិរញ្ញវត្ថុត្រូវបានពង្រឹង
- លទ្ធផលរំពឹងទុកទី៣៖ ចំណូលមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានបង្កើន
- លទ្ធផលរំពឹងទុកទី៤៖ ទ្រព្យសម្បត្តិរដ្ឋត្រូវបានផ្ទេរ និងពង្រឹងការគ្រប់គ្រងដោយរដ្ឋបាលថ្នាក់ក្រោមជាតិ

លទ្ធផលរំពឹងទុកទី៥៖ មូលនិធិគ្មានភ្ជាប់លក្ខខណ្ឌត្រូវបានបង្កើន និងវិភាជទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិតាមរូបមន្ត និងលក្ខណៈវិនិច្ឆ័យប្រកបដោយសមធម៌

លទ្ធផលរំពឹងទុកទី៦៖ មូលនិធិមានភ្ជាប់លក្ខខណ្ឌត្រូវបានផ្ទេរ និងគ្រប់គ្រងដោយរដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព

លទ្ធផលរំពឹងទុកទី៧៖ ក្របខ័ណ្ឌសម្រាប់ផ្តល់ហិរញ្ញប្បទានការវិនិយោគសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពង្រឹង និងកែលម្អ

លទ្ធផលរំពឹងទុកទី៨៖ ក្របខ័ណ្ឌភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងវិស័យឯកជនត្រូវបានបង្កើត និងដាក់ឱ្យអនុវត្ត។

សកម្មភាពជាអាទិភាពដែលត្រូវអនុវត្ត ដើម្បីសម្រេចបានលទ្ធផលរំពឹងទុកនីមួយៗ រួមបញ្ចូលសូចនាករ និងចំណុចដៅសម្រាប់វាស់វែងការសម្រេចបាននូវសកម្មភាពជាអាទិភាពទាំងនេះ មានបរិយាយតាមលទ្ធផលរំពឹងទុកខាងក្រោម ៖

### លទ្ធផលរំពឹងទុក ៤.១.៖ កិច្ចដំណើរការកសាងផែនការត្រូវបានពង្រឹង កែលម្អ និងបន្សុីគ្នាជាមួយនឹងការរៀបចំគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

ប្រព័ន្ធ និងនីតិវិធីនៃការកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំធ្វើបច្ចុប្បន្នភាព និងដាក់ឱ្យអនុវត្តចុងក្រោយនៅឆ្នាំ២០១៧ ស្របទៅតាមប្រព័ន្ធអភិបាលកិច្ច និងការចូលរួមតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ កិច្ចដំណើរការ និងនិតិវិធីនៃការកសាងផែនការអភិវឌ្ឍន៍៥ឆ្នាំ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក៏ត្រូវបានពិនិត្យ វាយតម្លៃ និងកែលម្អជាបន្តបន្ទាប់ ដើម្បីធានាដល់គុណភាព ប្រសិទ្ធភាពនៃផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគទាំងនោះ ព្រមទាំងការបន្សុីគ្នាទៅនឹងដំណើរការរៀបចំគម្រោងថវិកាប្រចាំឆ្នាំ ដើម្បីធានាដល់ការប្រើប្រាស់ធនធានហិរញ្ញវត្ថុឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋ។

បើទោះបីជាមានការពង្រឹង និងការកែលម្អជាបន្តបន្ទាប់ក៏ដោយ ក៏ការវាយតម្លៃ ផអ៥ទី១ និងការអង្កេតអភិបាលកិច្ច បានផ្តល់ជាអនុសាសន៍ក្នុងការបន្តពង្រឹងការរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឱ្យស្របទៅតាមគោលការណ៍ ជំហាន នីតិវិធី ក្របខ័ណ្ឌពេលវេលាដែលបានកំណត់ ព្រមទាំងគិតគូរដល់វិធីសាស្ត្រ/មធ្យោបាយថ្មីៗបន្ថែមទៀត ដើម្បីបង្កើនការចូលរួមរបស់ប្រជាពលរដ្ឋ ក្រុមជនងាយរងគ្រោះ និងអ្នកពាក់ព័ន្ធនានា និងធានាឱ្យផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគនេះត្រូវបានរៀបចំឡើងប្រកបដោយគុណភាពឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែងនៃមូលដ្ឋាននីមួយៗ ភាពអាចវាស់វែងបាន និងភាពអាចសម្រេចទៅបានស្របតាមគោលនយោបាយរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ គោលនយោបាយ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ។

ជាមួយគ្នានេះ ប្រព័ន្ធកសាងផែនការ និងក្របខ័ណ្ឌនៃការរៀបចំគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិក៏ចាំបាច់ត្រូវពិនិត្យមើលឡើងវិញឱ្យស្របទៅជាមួយនឹងការកែសម្រួលរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលរាជធានីតាមបែបផែននៃរដ្ឋបាលទីក្រុងម៉េត្រូប៉ូលីតែន រដ្ឋបាលខេត្តតាមបែបផែនជារដ្ឋបាលតំបន់ និងរដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់តាមបែបផែនជារដ្ឋបាលមូលដ្ឋាន ដែលបានគ្រោងអនុវត្តក្នុង ផអ៥ទី២ នេះ។

អាស្រ័យហេតុនេះ ដើម្បីសម្រេចបាននូវលទ្ធផលរំពឹងទុកនេះ ផអ៥ទី២ បានគ្រោងឡើងនូវសកម្មភាពអាទិភាពចំនួន០៣ ដូចខាងក្រោម៖

## សកម្មភាពអាទិភាព ៤.១.១.៖ ការពង្រឹងកិច្ចដំណើរការកសាងផែនការ និងការរៀបចំគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

ពាក់ព័ន្ធនឹងសកម្មភាពអាទិភាពនេះ ក្នុងអំឡុងពេលនៃ ផអ៥ទី២ ចាំបាច់ត្រូវបន្តពង្រឹងកិច្ចដំណើរការកសាងផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគ យុទ្ធសាស្ត្រថវិកា និងការរៀបចំគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យបានពេញលេញ និងមានលក្ខណៈបន្សុីគ្នា។

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពអាទិភាពនេះរួមមាន៖

- ពង្រឹងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគស្របតាមគោលការណ៍ និងនិតិវិធីដែលបានកំណត់ តាមរយៈ (១). ការអភិវឌ្ឍសមត្ថភាព និងពង្រឹងការទទួលខុសត្រូវដល់ក្រុមការងារកសាងផែនការ (២). ការប្រើប្រាស់ទិន្នន័យមូលដ្ឋាននានា និងវិធីសាស្ត្រនានាក្នុងបង្កើនការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ (៣). ការពង្រឹងតួនាទីក្រុមប្រឹក្សាក្នុងការអនុម័ត និងការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃលើការអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ (៤). ការគាំទ្របច្ចេកទេស ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃពីថ្នាក់ជាតិ និងថ្នាក់រាជធានី ខេត្តស្របតាមគោលការណ៍កំណត់ និង (៥). ការពង្រឹងការទទួលខុសត្រូវលើការពិនិត្យ និងការផ្តល់អនុលោមភាពរបស់ក្រសួងមហាផ្ទៃ និងរាជធានី ខេត្តស្របតាមគោលការណ៍កំណត់
- ពង្រឹងការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដោយឆ្លើយតបទៅនឹងកម្មវិធីវិនិយោគ៣ឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ពង្រឹងរដ្ឋបាលរាជធានី ខេត្តក្នុងការរៀបចំ និងការអនុម័តគម្រោងថវិកាប្រចាំឆ្នាំនៅរដ្ឋបាលរាជធានី ខេត្តដោយភ្ជាប់ជាមួយនូវផែនការលទ្ធកម្ម និងផែនការរដ្ឋទេយ្យបុរេប្រទានសម្រាប់ការចរចាថវិកា និងការប្រើប្រាស់នូវចំណាត់ថ្នាក់ថវិកាផ្សេងៗបន្ថែមទៀតលើចំណាត់ថ្នាក់ថវិកាដែលមានស្រាប់
- ពង្រឹងរដ្ឋបាលក្រុង ស្រុក ខណ្ឌក្នុងការរៀបចំ និងការអនុម័តគម្រោងថវិកាប្រចាំឆ្នាំរបស់

រដ្ឋបាលក្រុង ស្រុក ខណ្ឌដោយភ្ជាប់ជាមួយនូវផែនការរដ្ឋទេយ្យបុរេប្រទានសម្រាប់ការពិនិត្យបញ្ជាក់អនុលោមភាព និងការប្រើប្រាស់នូវចំណាត់ថ្នាក់ថវិកាផ្សេងៗបន្ថែមទៀតលើចំណាត់ថ្នាក់ថវិកាដែលមានស្រាប់

- កែលម្អសារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត និងនីតិវិធីបច្ចេកទេសនៃការរៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បន្តធ្វើបច្ចុប្បន្នភាពលើក្របខ័ណ្ឌថវិការយៈពេលមធ្យមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត និងការរៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ពង្រឹង និងកែលម្អការរៀបចំផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្តដោយតម្រឹម និងធ្វើសមាហរណកម្មផែនការយុទ្ធសាស្ត្រថវិកាមន្ទីរជំនាញរាជធានី ខេត្ត និងផែនការសកម្មភាពរបស់រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ទៅក្នុងផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ ក្រសួងផែនការ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

**ស្ថាប័នចូលរួមអនុវត្ត** ៖ ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធ

**តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ៤.១.១.**

| ល.រ. | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | ចំនួនផែនការអភិវឌ្ឍន៍រដ្ឋបាលរាជធានី ខេត្តដែលបានផ្តល់អនុលោមភាពទាន់ពេលវេលា | | | | | | ២៥ |
| ២ | ចំនួនផែនការអភិវឌ្ឍន៍រដ្ឋបាលក្រុង ស្រុក ខណ្ឌដែលបានផ្តល់អនុលោមភាពទាន់ពេលវេលា | | | | | | ២១០ |
| ៣ | ចំនួនផែនការអភិវឌ្ឍន៍រដ្ឋបាលឃុំ សង្កាត់ដែលបានផ្តល់អនុលោមភាពទាន់ពេលវេលា | | | | ១.៦៥២ | | |
| ៤ | សារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត និងនីតិវិធីបច្ចេកទេសនៃការរៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | មានស្រាប់ | ១ | ១ | ១ | ១ | ១ |
| ៥ | ការធ្វើបច្ចុប្បន្នភាពលើក្របខ័ណ្ឌថវិការយៈពេលមធ្យមរបស់ថ្នាក់ក្រោមជាតិ (៣ឆ្នាំរំកិល) | មានស្រាប់ | ១ | ១ | ១ | ១ | ១ |
| ៦ | ចំនួនរដ្ឋបាលរាជធានី ខេត្តដែលបានធ្វើតម្រឹមផែនការយុទ្ធសាស្ត្រថវិកាមន្ទីរជំនាញរាជធានី ខេត្តទៅក្នុងផែនការយុទ្ធសាស្ត្រថវិការបស់ខ្លួន | | ២៥ | ២៥ | ២៥ | ២៥ | ២៥ |

## សកម្មភាពអាទិភាព ៤.១.២.៖ ការពិនិត្យ និងកែសម្រួលឡើងវិញប្រព័ន្ធកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

ក្នុងអំឡុងពេល ជអ៥ទី២ នឹងមានការពិនិត្យ និងកែសម្រួលរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរបស់

រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលក្រុង ស្រុកស្របតាមចរិតលក្ខណៈនៃប្រភេទរដ្ឋបាលនីមួយៗ (ទីក្រុងធំ ទីប្រជុំជន និងតំបន់ជនបទ។ល។)។ ប្រការនេះ ចាំបាច់ត្រូវពិនិត្យ និងកែសម្រួលឡើងវិញនូវប្រព័ន្ធកសាងផែនការឱ្យស្របទៅនឹងរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលត្រូវបានកែសម្រួលទាំងនេះ។

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពអាទិភាពនេះរួមមាន៖

– ពិនិត្យ និងកែសម្រួលប្រព័ន្ធកសាងផែនការរាជធានីឱ្យស្របតាមចរិតលក្ខណៈជារដ្ឋបាលទីក្រុងម៉េត្រូប៉ូលីតែន ប្រព័ន្ធកសាងផែនការរដ្ឋបាលខេត្តអាចមានចរិតលក្ខណៈជារដ្ឋបាលតំបន់ ហើយរដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់អាចមានចរិតលក្ខណៈជារដ្ឋបាលមូលដ្ឋានដោយធានានូវគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ
– ផ្សព្វផ្សាយ និងបណ្តុះបណ្តាលអំពីប្រព័ន្ធផែនការថ្មីដែលបានកែសម្រួលឱ្យបានទូលំទូលាយដើម្បីធានាដល់ការអនុវត្តប្រកបដោយប្រសិទ្ធភាព
– ពង្រឹងតួនាទីរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការទទួលខុសត្រូវលើការកំណត់អំពីទិសដៅយុទ្ធសាស្ត្រនៃផែនការអភិវឌ្ឍន៍៥ឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល និងការអនុម័តលើផែនការអភិវឌ្ឍន៍៥ឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
– កែសម្រួលនូវរចនាសម្ព័ន្ធ តួនាទី និងការទទួលខុសត្រូវនៃយន្តការនានារបស់ក្រុមប្រឹក្សាដែលពាក់ព័ន្ធនឹងការគាំទ្រការកសាងផែនការ ដូចជា ការពិនិត្យមើលឡើងវិញនូវរចនាសម្ព័ន្ធរបស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ការបង្កើតគណៈកម្មាធិការផ្សេងៗជាដើម
– ពិនិត្យមើលឡើងវិញអំពីការពិនិត្យបញ្ជាក់អនុលោមភាពលើផែនការអភិវឌ្ឍន៍៥ឆ្នាំរបស់រដ្ឋបាលរាជធានី ខេត្ត ដោយមានការចូលរួមពីក្រសួងផែនការ។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ ក្រសួងមហាផ្ទៃ ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងលេខាធិការដ្ឋាន គ.ជ.អ.ប.

**ស្ថាប័នចូលរួមអនុវត្ត** ៖ ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធ

**តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាពនៃលទ្ធផលរំពឹងទុក ៤.១.២.**

| ល.រ. | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | ប្រព័ន្ធកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលបានកែសម្រួល | | | | | សិក្សា | អនុម័ត |

## សកម្មភាពអាទិភាព ៤.១.៣.៖ ការរៀបចំ និងដាក់ឱ្យអនុវត្តនូវយន្តការត្រួតពិនិត្យ និងវាយតម្លៃផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗបានរៀបចំ និងអនុម័តនូវផែនការអភិវឌ្ឍន៍៥ឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរបស់ខ្លួនស្របតាមគោលការណ៍ និងសេចក្តីណែនាំបច្ចេកទេសស្តីពីការរៀបចំ និងការកសាងផែនការ

អភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំដែលបានដាក់ឱ្យប្រើប្រាស់តាមរយៈប្រកាសអន្តរក្រសួងរវាងក្រសួងមហាផ្ទៃ និងក្រសួងផែនការ។ ទន្ទឹមនេះ គោលការណ៍ និងសេចក្តីណែនាំបច្ចេកទេសស្តីពីការរៀបចំ និងការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក៏ត្រូវបានធ្វើការកែសម្រួលជាបន្តបន្ទាប់ ដើម្បីធានាឱ្យការរៀបចំកសាងផែនការអភិវឌ្ឍន៍៥ឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗមានភាពសមស្របទៅនឹងការកែសម្រួលរចនាសម្ព័ន្ធ និងការគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងមានភាពប្រទាក់ក្រឡាជាមួយនឹងដំណើរការនៃការរៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ។

យោងប្រកាសអន្តរក្រសួងដែលបានដាក់ចេញឆ្នាំ២០១០ និងឆ្នាំ២០១៧ រវាងក្រសួងមហាផ្ទៃ និងក្រសួងផែនការស្តីពីការដាក់ឱ្យប្រើប្រាស់សេចក្តីណែនាំបច្ចេកទេសស្តីពីការរៀបចំកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់បានតម្រូវឱ្យរដ្ឋបាលទាំងនេះ ធ្វើការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខ្លួន ក្នុងនោះរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ត្រូវ (១). វាយតម្លៃអំពីលទ្ធផល និងសមិទ្ធផលនៃការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំជារៀងរាល់ឆ្នាំ (២). វាយតម្លៃពាក់កណ្តាលអាណត្តិនៃការអនុវត្តផែនការអភិវឌ្ឍន៍ និង (៣). វាយតម្លៃអំពីផលប៉ះពាល់នៃការអនុវត្តផែនការអភិវឌ្ឍន៍ក្នុងរយៈពេល ០៦ខែចុងក្រោយនៃអាណត្តិរបស់ក្រុមប្រឹក្សា។

កន្លងមក រដ្ឋបាលថ្នាក់ក្រោមជាតិភាគច្រើនបានត្រឹមតែធ្វើការវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍របស់ខ្លួននៅ០៦ខែចុងក្រោយនៃអាណត្តិក្រុមប្រឹក្សារបស់ខ្លួន និងដោយបានបញ្ចូលលទ្ធផលនៃការវាយតម្លៃនេះទៅក្នុងរបាយការណ៍បញ្ចប់អាណត្តិរបស់ក្រុមប្រឹក្សាប៉ុណ្ណោះ។ ដោយឡែក ការវាយតម្លៃការអនុវត្តផែនអភិវឌ្ឍន៍ពាក់អាណត្តិរបស់ក្រុមប្រឹក្សា និងការវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគប្រចាំឆ្នាំរដ្ឋបាលថ្នាក់ក្រោមជាតិពុំដែលបានធ្វើនៅឡើយទេ ដោយសាររហូតដល់ពេលនេះ ថ្នាក់ជាតិពុំទាន់បានដាក់ចេញនូវសេចក្តីណែនាំ ឬនីតិវិធីនៃការវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ និងការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅឡើយ។

ដូច្នេះ ក្នុងអំឡុងពេលនៃ ផអ៥ទី២ ជាការចាំបាច់ត្រូវរៀបចំឱ្យមានសេចក្តីណែនាំ ឬនីតិវិធីសម្រាប់វាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ សំដៅធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិអាចកំណត់បាននូវលទ្ធផល សមិទ្ធផល និងផលប៉ះពាល់នៃការអនុវត្តផែនការអភិវឌ្ឍន៍របស់ខ្លួន និងកម្រិតនៃការសម្រេចបាននូវចក្ខុវិស័យ គោលបំណង និងគោលដៅដែលបានកំណត់ ព្រមទាំងផ្តល់លទ្ធភាពឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗអាចពិនិត្យ និងកែសម្រួលចក្ខុវិស័យ គោលដៅ គោលបំណង និងយុទ្ធសាស្ត្រតាមការចាំបាច់។

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពអាទិភាពនេះរួមមាន៖

- កំណត់នូវយន្តការ វិធីសាស្ត្រ និងឧបករណ៍សម្រាប់ការតាមដាន និងវាយតម្លៃលើការអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- កំណត់នូវប្រភេទ និងក្របខ័ណ្ឌពេលវេលានៃការតាមដាន និងវាយតម្លៃលើការអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បន្សីការបរិយាយសូចនាករគោលដៅអភិវឌ្ឍន៍ជាមួយនឹងប្រភេទទិន្នន័យនៃព័ត៌មានស្ថានភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗដែលបានរៀបចំធ្វើបច្ចុប្បន្នភាព និងដាក់ឱ្យអនុវត្តប្រចាំឆ្នាំ។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ ក្រសួងមហាផ្ទៃ ក្រសួងផែនការ និងលេខាធិការដ្ឋាន គ.ជ.អ.ប

**ស្ថាប័នចូលរួមអនុវត្ត** ៖ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ

**តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ៤.១.៣.**

| ល.រ. | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | នីតិវិធីនៃការតាមដាន និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | | អនុម័ត | | | | |
| ២ | ភាគរយរដ្ឋបាលរាជធានី ខេត្តដែលបានវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍នៅពាក់កណ្ដាលអាណត្តិក្រុមប្រឹក្សា | | | ១០០% | | | |
| ៣ | ភាគរយរដ្ឋបាលរាជធានី ខេត្តដែលបានវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍នៅ០៦ខែចុងក្រោយ នៃអាណត្តិក្រុមប្រឹក្សា | | | | | ១០០% | |
| ៤ | ភាគរយក្រុង ស្រុកដែលបានវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ពាក់កណ្ដាលអាណត្តិរបស់ក្រុមប្រឹក្សា | | | ១០០% | | | |
| ៥ | ភាគរយរដ្ឋបាលក្រុង ស្រុកដែលបានវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍នៅ០៦ខែចុងក្រោយនៃអាណត្តិក្រុមប្រឹក្សា | | | | | ១០០% | |

### លទ្ធផលរំពឹងទុក ៤.២.៖ ភាពជាម្ចាស់ និងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ធនធានហិរញ្ញវត្ថុត្រូវបានពង្រឹង

រដ្ឋបាលថ្នាក់ក្រោមជាតិបានគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ថវិការបស់ខ្លួនតាមគោលការណ៍នីតិវិធីដែលបានកំណត់ក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។ ពាក់ព័ន្ធនឹងកិច្ចការនេះ ក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន រដ្ឋបាលឃុំ សង្កាត់ដែលមានមេឃុំ ចៅសង្កាត់ជាអាណាប័កដើមខ្សែចំពោះថវិការបស់ខ្លួន រដ្ឋបាលក្រុង ស្រុក ដែលមានអភិបាលនៃគណៈអភិបាលក្រុង ស្រុកជាអាណាប័កដើមខ្សែចំពោះថវិការបស់ខ្លួន បានបំពេញតួនាទីជាអង្គភាពត្រួតពិនិត្យថវិកាចំពោះថវិការបស់ខ្លួន។ ក្នុងការអនុវត្តថវិការបស់ខ្លួន មេឃុំ ចៅសង្កាត់ និងអភិបាលក្រុង ស្រុក ជាអ្នកបោះផ្សាយអាណាបណ្ណ (អាណត្តិបើកប្រាក់ និងអាណត្តិនិយ័តកម្ម) និងបញ្ជូនត្រង់ទៅរតនាគាររាជធានី ខេត្ត ប៉ុន្តែរដ្ឋបាលក្រុង ស្រុកមានថវិកាចំនួន២ គឺថវិកាផ្ទាល់របស់រដ្ឋបាលក្រុង ស្រុក និងថវិកាសម្រាប់វិស័យអប់រំដែលថវិកាទាំង២នេះ

អនុវត្តតាមនីតិវិធី និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ២ដាច់ដោយឡែកពីគ្នា បើទោះបីជាកញ្ចប់ថវិកាសម្រាប់វិស័យអប់រំជាឧបសម្ព័ន្ធនៃថវិការដ្ឋបាលក្រុង ស្រុកក៏ដោយ។

ដោយឡែក ចំពោះរដ្ឋបាលរាជធានី ខេត្ត អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ជាអាណាប័កដើមខ្សែចំពោះថវិការបស់ខ្លួន ប៉ុន្តែការអនុវត្តថវិការបស់រដ្ឋបាលរាជធានី ខេត្តត្រូវស្ថិតក្រោមការត្រួតពិនិត្យពីអង្គភាពត្រួតពិនិត្យថវិកា ដែលមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្តត្រូវបានធ្វើប្រតិភូម្មពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យបំពេញមុខងារជាអង្គភាពត្រួតពិនិត្យថវិការាជធានី ខេត្ត ដោយរាល់អាណាបណ្ណ (អាណត្តិបើកប្រាក់ និងអាណត្តិនិយ័តកម្ម) ដែលបានបោះផ្សាយដោយអភិបាលរាជធានី ខេត្តត្រូវបញ្ជូនទៅអង្គភាពត្រួតពិនិត្យថវិកាដើម្បីពិនិត្យ និងផ្តល់ទិដ្ឋាការ មុននឹងបញ្ជូនទៅរតនាគាររាជធានី ខេត្ត ដើម្បីធ្វើការទូទាត់។ ម៉្យាងវិញទៀត រដ្ឋបាលរាជធានី ខេត្តមានថវិកា និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុចំនួន២ដាច់ដោយឡែកពីគ្នា គឺថវិកា និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់រដ្ឋបាលរាជធានី ខេត្ត និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់មន្ទីរសុខាភិបាល បើទោះបីជាកញ្ចប់ថវិការបស់សុខាភិបាលជាឧបសម្ព័ន្ធនៃថវិការដ្ឋបាលរាជធានី ខេត្តក៏ដោយ។

អាស្រ័យហេតុនេះ ក្នុងអំឡុងពេលនៃការអនុវត្ត ផអ៥ទី២ កិច្ចការចាំបាច់ដែលផ្តោតយកចិត្តទុកដាក់លើការផ្តល់សិទ្ធិអំណាចបន្ថែមទៀតទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិលើការគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ថវិការបស់ខ្លួនស្របតាមគោលការណ៍វិមជ្ឈការ គោលការណ៍រដ្ឋបាលឯកភាព និងស្របតាមចរិតលក្ខណៈនៃរដ្ឋបាលនីមួយៗ។

ដើម្បីសម្រេចបាននូវលទ្ធផលរំពឹងទុកនេះ ផអ៥ទី២ បានគ្រោងឡើងនូវសកម្មភាពអាទិភាពចំនួន **០៣** ដូចខាងក្រោម៖

### សកម្មភាពអាទិភាព ៤.២.១.៖ ការរៀបចំយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ឆ្នាំ ២០២៦-២០៣០

ទិសដៅជាយុទ្ធសាស្ត្រសម្រាប់ការកែលម្អបន្ថែមនូវប្រព័ន្ធកសាងផែនការ និងប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិនឹងត្រូវបានកំណត់តាមលទ្ធផល មេរៀននិងបទពិសោធន៍នៃការអនុវត្តយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ឆ្នាំ២០១៩-២០២៥ និងលទ្ធផលនៃការវាយតម្លៃពាក់កណ្តាលអាណត្តិនៃ កជទី២។ លទ្ធផល មេរៀននិងបទពិសោធន៍នេះ ត្រូវយកមកពិចារណា និងប្រើប្រាស់ជាធាតុចូលក្នុងការរៀបចំយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ឆ្នាំ២០២៦-២០៣០ ដោយមានសង្គតិភាពកម្រិតគោលការណ៍ និងអភិក្រមនៃការគ្រប់គ្រងថវិការដ្ឋស្របតាមយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិកាថ្នាក់ជាតិ និងគោលការណ៍វិមជ្ឈការ។

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពអាទិភាពនេះរួមមាន៖

– រៀបចំយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (២០២៦-២០៣០) ដោយផ្តោតលើ (១). ការឆ្លុះបញ្ចាំងអំពីមេរៀន និងបទពិសោធន៍ល្អៗដែលសម្រេចបានក្នុង

អំឡុងពេលនៃការអនុវត្តយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ ២០១៩-២០២៥ និងលទ្ធផលនៃការអនុវត្ត ផអ៥ទី១ នៃកជទី២ (២). ការផ្សារភ្ជាប់ជាមួយប្រព័ន្ធថវិកាជាតិទាំងមូល និងការបន្សុីគ្នារវាងការគ្រប់គ្រងថវិកាជាមួយនឹងការពង្រឹងភាពម្ចាស់ការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ (៣). ការរៀបចំឱ្យមានថវិកាឯកភាពនៅរដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលក្រុង ស្រុកដោយធ្វើសមាហរណកម្មធនធានហិរញ្ញវត្ថុផ្ទេរមានភ្ជាប់លក្ខខណ្ឌសម្រាប់អនុវត្តមុខងារដែលផ្ទេរទៅក្នុងកញ្ចប់ថវិការួមតែមួយរបស់រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលក្រុង ស្រុក (៤). ការពង្រឹងភាពម្ចាស់ការ និងការអនុវត្តថវិកានៅរដ្ឋបាលថ្នាក់ក្រោមជាតិក្រោមសិទ្ធិអំណាចរបស់ក្រុមប្រឹក្សា (៥). ការធ្វើប្រតិភូកម្មមុខងារទៅឱ្យរដ្ឋបាលក្រុង ស្រុកពិនិត្យបញ្ជាក់អនុលោមភាពលើគម្រោងថវិការបស់រដ្ឋបាលឃុំ សង្កាត់ (៦). ការធ្វើប្រតិភូកម្មមុខងារទៅឱ្យរដ្ឋបាលរាជធានីខេត្តជាអង្គភាពត្រួតពិនិត្យថវិកាលើការអនុវត្តថវិកាចំណាយរបស់ខ្លួនលើប្រភេទចំណាយជាក់លាក់មួយចំនួន និងក្នុងកម្រិតទំហំជាក់លាក់ (៧). ការរៀបចំឱ្យមានការអនុវត្តសាកល្បងនូវថវិកាកម្មវិធីនៅរដ្ឋបាលក្រុង ស្រុក និង (៨). ការរៀបចំឧបករណ៍ វិធីសាស្ត្រ និងនីតិវិធីរៀបចំថវិកា ដើម្បីលើកកម្ពស់បរិយាបន្ន និងសមធម៌សង្គមនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ

**ស្ថាប័នចូលរួមអនុវត្ត** ៖ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ

**តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ៤.២.១**

| ល.រ. | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | យុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ឆ្នាំ២០២៦-២០៣០ | | អនុម័ត | | | | |

**សកម្មភាពអាទិភាព៤.២.២៖ ការអនុវត្តយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (២០២៦-២០៣០)**

សកម្មភាពនេះ ត្រូវបន្ត និងពង្រឹងការអនុវត្តថវិកាស្របតាមផែនការសកម្មភាពដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (២០២៦-២០៣០)។

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពអាទិភាពនេះរួមមាន៖

- រៀបចំ ឬកែសម្រួលក្របខ័ណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- សិក្សា រៀបចំ និងដាក់ឱ្យអនុវត្តបែបផែនថ្មី ដើម្បីឱ្យមានថវិកាឯកភាពនៅរដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលក្រុង ស្រុកដោយធ្វើសមាហរណកម្មធនធានហិរញ្ញវត្ថុផ្ទេរមានភ្ជាប់លក្ខខណ្ឌសម្រាប់អនុវត្តមុខងារដែលផ្ទេរទៅក្នុងកញ្ចប់ថវិការួមតែមួយរបស់រដ្ឋបាលរាជធានី ខេត្ត និង

រដ្ឋបាលក្រុង ស្រុក ដោយត្រូវធានាដល់ការប្រើប្រាស់ធនធានផ្ទេរមានភ្ជាប់លក្ខខណ្ឌសម្រាប់អនុវត្តមុខងារជាកាតព្វកិច្ចដែលបានផ្ទេរ

- សិក្សា រៀបចំ និងដាក់ឱ្យអនុវត្តបែបផែនថ្មីពាក់ព័ន្ធនឹងមុខងារត្រួតពិនិត្យហិរញ្ញវត្ថុ និងការទូទាត់ថវិការបស់ថ្នាក់រាជធានី ខេត្តដោយធ្វើប្រតិភូកម្មមុខងារជូនរដ្ឋបាលរាជធានី ខេត្តជាអង្គភាពត្រួតពិនិត្យថវិកាលើការអនុវត្តថវិកាចំណាយរបស់ខ្លួនទៅលើប្រភេទចំណាយជាក់លាក់មួយចំនួន និងក្នុងកម្រិតទំហំជាក់លាក់
- ធ្វើប្រតិភូកម្មមុខងារទៅឱ្យរដ្ឋបាលក្រុង ស្រុកក្នុងការពិនិត្យបញ្ជាក់អនុលោមភាពគ្រោងថវិការបស់ឃុំ សង្កាត់
- រៀបចំគោលការណ៍ និងនីតិវិធីសម្រាប់ការអនុវត្តថវិកាកម្មវិធីរបស់រដ្ឋបាលក្រុង ស្រុក
- ធ្វើឱ្យមានលក្ខណៈសាមញ្ញ និងពន្លឿនកិច្ចដំណើរការអនុវត្តថវិកា តាមរយៈការបង្កើនការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការដោះស្រាយបញ្ហានានាដោយផ្អែកលើបច្ចេកវិទ្យាព័ត៌មាន ព្រមទាំងអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធជំនាន់ទី២ (NRMIS V2) ដែលបានកែលម្អ និងប្រព័ន្ធ E-Payment នៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- ពង្រឹងការគាំទ្រ ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃលើការរៀបចំ និងការអនុវត្តថវិការដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈយន្តការអន្តរក្រសួងរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ និងក្រសួង ស្ថាប័នពាក់ព័ន្ធ។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ

**ស្ថាប័នចូលរួមអនុវត្ត** ៖ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ

**តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ៤.២.២.**

| ល.រ. | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | ច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | សេចក្តីព្រាង | អនុម័ត | | | | |
| ២ | ភាគរយរដ្ឋបាលក្រុង ស្រុក ខណ្ឌដែលបានអនុវត្តប្រព័ន្ធ E-Payment | | ១០០% | | | | |
| ៣ | ភាគរយរដ្ឋបាលឃុំ សង្កាត់ដែលបានអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធជំនាន់ទី២ (NRMIS V2) | NRMIS V1 | | ១០០% | | | |
| ៤ | ភាគរយរដ្ឋបាលឃុំ សង្កាត់ដែលបានអនុវត្តប្រព័ន្ធ E-Payment | | | ១០០% | | | |

## សកម្មភាពអាទិភាព ៤.២.៣.៖ ការធ្វើវិមជ្ឈការ និងការពង្រឹងការអនុវត្តកិច្ចលទ្ធកម្មរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

ផ្អែកតាមយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ២០១៩-២០២៥ កិច្ចលទ្ធកម្មសាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានប្តូរជាបណ្តើរៗពីការអនុវត្តកិច្ចលទ្ធកម្មតាមបែបវិសហមជ្ឈការទៅវិមជ្ឈការកិច្ចលទ្ធកម្មសាធារណៈដោយបានផ្តល់សិទ្ធិអំណាច និងការទទួលខុសត្រូវច្រើនឡើងៗជូនរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗដែលជាស្ថាប័នអនុវត្តកិច្ចលទ្ធផ្ទាល់។ ការធ្វើវិមជ្ឈការកិច្ចលទ្ធកម្មសាធារណៈទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗក្នុងការអនុវត្តកិច្ចលទ្ធកម្មផ្ទាល់ ដោយការបង្កើនកម្រិតទឹកប្រាក់សិទ្ធិសម្រេចនៅរដ្ឋបាលថ្នាក់ក្រោមជាតិតាមរយៈប្រកាសលេខ៨៣២ សហវ.ប្រក.អលស ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការបង្កើនកម្រិតទឹកប្រាក់សិទ្ធិសម្រេចក្នុងកិច្ចលទ្ធកម្មសាធារណៈ។ សកម្មភាពនេះ ត្រូវបន្តជំរុញ និងគិតគូរអំពីការផ្តល់សិទ្ធិអំណាច និងការទទួលខុសត្រូវបន្ថែមទៀតទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ដើម្បីទទួលខុសត្រូវពេញលេញក្នុងភាពជាម្ចាស់លើការអនុវត្តកិច្ចលទ្ធកម្មសាធារណៈរបស់ខ្លួន សំដៅបង្កើនតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាពនៃការគ្រប់គ្រងលទ្ធកម្មសាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពអាទិភាពនេះរួមមាន៖

- ពង្រឹងការអនុវត្តកិច្ចលទ្ធកម្មគ្រប់ប្រភេទ (ទំនិញ សំណង់ និងសេវា) របស់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការពិនិត្យឡើងវិញនូវសៀវភៅណែនាំស្តីពីការសិក្សានិងការគ្រោងប្លង់គម្រោងរដ្ឋបាលថ្នាក់ក្រោមជាតិ កែលម្អការរៀបចំបញ្ជីអ្នកទទួលការ និងតារាងសម្រង់តម្លៃ ព្រមទាំងពង្រឹងសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសរដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ក្នុងការរៀបចំ ការអនុវត្ត និងការត្រួតពិនិត្យគម្រោងរបស់ខ្លួន
- ផ្តល់សិទ្ធិអំណាច និងការទទួលខុសត្រូវពេញលេញលើការអនុវត្តកិច្ចលទ្ធកម្មទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ
- បង្កើនកម្រិតទឹកប្រាក់សិទ្ធិសម្រេច លើកលែងតែមុខចំណាយមួយចំនួនដែលមានទំហំធំមិនមានគោលការណ៍/គោលរបបច្បាស់លាស់និង/ឬមានវេទយិតភាពខ្ពស់ ដែលចាំបាច់ត្រូវតែជាកម្មវត្ថុនៃការស្នើសុំការឯកភាពជាមុនពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ពង្រឹងការតាមដាន និងការត្រួតពិនិត្យពីថ្នាក់ជាតិទៅលើកិច្ចលទ្ធកម្មរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ
**ស្ថាប័នចូលរួមអនុវត្ត** ៖ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ

**តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ៤.២.៣.**

| ល.រ. | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | កម្រិតទឹកប្រាក់សិទ្ធិសម្រេចកិច្ចលទ្ធកម្មរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | - ១០០០លានរៀល (រាជធានី) | | កើនឡើង | | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | - ៧០០លានរៀល (ខេត្ត)<br>- ១៣០លានរៀល (ក្រុង ស្រុក) | | | | | | |
| ២ | ភាគរយនៃរដ្ឋបាលឃុំ សង្កាត់ដែលបានដេញថ្លៃគម្រោងនៅរដ្ឋបាលឃុំ សង្កាត់ | គ្មានទិន្នន័យ | ៣០% | ៤០% | ៥០% | ៦០% | ៧០% |
| ៣ | ភាគរយនៃគម្រោងក្រុង ស្រុកដែលបានដេញថ្លៃនៅមុនពាក់កណ្តាលឆ្នាំថវិកា | ២៨% | ៥០% | ៦០% | ៧០% | ៨០% | ៩០% |

### លទ្ធផលរំពឹងទុក ៤.៣.៖ ចំណូលមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានបង្កើន

ចំណូលមូលដ្ឋានដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ រួមមាន (១). រដ្ឋបាលរាជធានី ខេត្ត ទទួលបាននូវការផ្ទេរចំណូលពីប្រភពសារពើពន្ធ និងប្រភពមិនមែនសារពើពន្ធក្នុងនោះចំណូលពីប្រភពសារពើពន្ធត្រូវបានប្រមូលដោយសាខាពន្ធដារខេត្ត ខណ្ឌ ដោយឡែកចំណូលពីប្រភពមិនមែនសារពើពន្ធត្រូវបានប្រមូលដោយអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងមន្ទីរវិស័យនានា (២). រដ្ឋបាលក្រុង ស្រុកទទួលបានការផ្ទេរចំណូលពីប្រភពសារពើពន្ធ ដែលចំណូលពីប្រភពនេះត្រូវបានប្រមូលដោយការិយាល័យច្រកចេញចូលតែមួយរបស់រដ្ឋបាលក្រុង ស្រុក និង(៣). រដ្ឋបាលឃុំ សង្កាត់ទទួលបានការផ្ទេរចំណូលពីប្រភពសារពើពន្ធ ដែលចំណូលពីប្រភពនេះត្រូវបានប្រមូលតាមរយៈយន្តការច្រកចេញចូលតែមួយរបស់រដ្ឋបាលឃុំ សង្កាត់។

ការបង្កើនចំណូលមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានធ្វើឡើងតាមរយៈការបង្កើនប្រសិទ្ធភាពលើការប្រមូលចំណូលសារពើពន្ធ និងការប្រមូលចំណូលមិនមែនសារពើពន្ធរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងការបែងចែកនូវចំណូលសារពើពន្ធរវាងរដ្ឋបាលរាជធានី ខេត្តទៅឱ្យរដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ សំដៅកាត់បន្ថយវិសមភាពនៃចំណូលរវាងរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។ ក្នុងអំឡុងពេលនៃការអនុវត្ត ផអ៥ទី២ ជាការចាំបាច់ត្រូវពិចារណាបង្កើនប្រភេទចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ និងការបង្កើនអត្រាចែករំលែកចំណូលសារពើពន្ធរវាងរដ្ឋបាលរាជធានី ខេត្តទៅឱ្យរដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់។

ដើម្បីសម្រេចបាននូវលទ្ធផលរំពឹងទុកនេះ ផអ៥ទី២ បានគ្រោងឡើងនូវសកម្មភាពអាទិភាពចំនួន **០៥** ដូចខាងក្រោម៖

### សកម្មភាពអាទិភាព ៤.៣.១.៖ ការលើកកម្ពស់ប្រសិទ្ធភាពនៃការប្រមូល និងការគ្រប់គ្រងចំណូលសារពើពន្ធដែលមានស្រាប់

ក្នុងរយៈពេលកន្លងមក ថ្នាក់ជាតិបានប្រគល់ចំណូលពីប្រភេទពន្ធ និងអាករមួយចំនួនទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ដើម្បីបង្កើតបានជាចំណូលជាគុណប្រយោជន៍ថវិកា ដែលមកទល់បច្ចុប្បន្ននេះ ចំណូលទាំងនោះបានមកពីប្រភេទពន្ធចំនួន**០៩** គឺ (១). ពន្ធលើថ្លៃអចលនទ្រព្យ និងចលនទ្រព្យ (២). អាករសម្រាប់បំភ្លឺសាធារណៈ (៣). អាករលើការស្នាក់នៅ (៤). ពន្ធប៉ាតង់ (៥). ពន្ធលើមធ្យោបាយដឹកជញ្ជូន (៦). ពន្ធប្រថាប់ត្រា (៧). ពន្ធលើអចលនទ្រព្យ (៨). ពន្ធលើដីធ្លីមិនបានប្រើប្រាស់ និង (៩).

ពន្ធលើផ្ទាំងផ្សព្វផ្សាយ។ អាស្រ័យហេតុនេះ សកម្មភាពនេះនឹងបន្តលើកកម្ពស់ប្រសិទ្ធភាពនៃការប្រមូល និងការគ្រប់គ្រងចំណូលសារពើពន្ធទាំងនេះ។

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពអាទិភាពនេះរួមមាន៖

- លើកកម្ពស់ការព្យាករណ៍ ការគ្រប់គ្រង និងការត្រួតពិនិត្យតាមដានលើការប្រមូលចំណូលសារពើពន្ធពីប្រភេទពន្ធដែលមានស្រាប់ទាំងនេះ ជាពិសេសចំពោះប្រភេទពន្ធសំខាន់ៗ (ពន្ធលើអចលនទ្រព្យ ពន្ធលើដីធ្លីមិនបានប្រើប្រាស់ ។ល។) ដើម្បីធានាដល់ប្រសិទ្ធភាពនៃការរៀបចំថវិកា
- រៀបចំ និងអនុវត្តនូវរូបមន្ត និងលក្ខណៈវិនិច្ឆ័យច្បាស់លាស់ តម្លាភាព និងសមធម៌សម្រាប់ការបែងចែកឡើងវិញចំណូលដែលបានពីអតិរេកថវិការបស់រដ្ឋបាលរាជធានី ខេត្ត (អតិរេកពេលគ្រោង និងអតិរេកចុងឆ្នាំ) ទៅឱ្យរាជធានី ខេត្តនានា។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
**ស្ថាប័នចូលរួមអនុវត្ត** ៖ ក្រសួងមហាផ្ទៃ

**តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ៤.៣.១.**

| ល.រ. | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | ភាគរយនៃការប្រមូលចំណូលសារពើពន្ធប្រចាំឆ្នាំរបស់រដ្ឋបាលរាជធានី ខេត្តធៀបនឹងថវិកាគ្រោងប្រចាំឆ្នាំ | ៨២,៧៨% | ៩០% | ៩៥% | ៩៥% | ៩៥% | ៩៥% |

## សកម្មភាពអាទិភាព ៤.៣.២.៖ ការផ្ទេរចំណូលប្រភេទពន្ធថ្មីសម្រាប់ជាចំណូលជាគុណប្រយោជន៍ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

បើទោះបីជាបច្ចុប្បន្ន ថ្នាក់ជាតិបានប្រគល់ចំណូលពីប្រភេទពន្ធ និងអាករមួយចំនួនទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ដើម្បីបង្កើតបានជាចំណូលជាគុណប្រយោជន៍ថវិកាដែលមកទល់បច្ចុប្បន្ននេះចំណូលទាំងនោះបានមកពីប្រភេទពន្ធចំនួន៩ ដូចបានបញ្ជាក់នៅក្នុងសកម្មភាពអាទិភាព៤.៣.១. នៃ ផអ៥ទី២ ក៏រដ្ឋបាលថ្នាក់ក្រោមជាតិនៅមានតម្រូវការចំណូលបន្ថែមទៀតសម្រាប់ជាចំណូលគុណប្រយោជន៍ថវិការបស់ខ្លួន ដើម្បីលើកកម្ពស់ការអភិវឌ្ឍមូលដ្ឋាន និងការបង្កើនទាំងបរិមាណ គុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឱ្យស្របទៅនឹងការវិវឌ្ឍនៃស្ថានភាពសេដ្ឋកិច្ច-សង្គមប្រជាសាស្ត្រ និងតម្រូវការកាន់តែច្រើនឡើង។

អាស្រ័យហេតុនេះ សកម្មភាពនេះនឹងលើផ្តោតការពិនិត្យលើលទ្ធភាពនៃការផ្ទេរចំណូលពីប្រភេទពន្ធថ្មីៗបន្ថែមទៀតទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ជាចំណូលជាគុណប្រយោជន៍ថវិការបស់ខ្លួន។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
**ស្ថាប័នចូលរួមអនុវត្ត** ៖ ក្រសួងមហាផ្ទៃ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

**តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ៤.៣.២.**

| ល.រ. | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | ចំនួនប្រភេទពន្ធ និងអាករបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | ៩ប្រភេទ | | ១០ប្រភេទ | | | |

## សកម្មភាពអាទិភាព ៤.៣.៣.៖ ការបែងចែករំលែកចំណូលសារពើពន្ធពីរដ្ឋបាលរាជធានី ខេត្តទៅឱ្យរដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់

ការបែងចែករំលែកចំណូលសារពើពន្ធពីរដ្ឋបាលរាជធានី ខេត្តទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌនិងរដ្ឋបាលឃុំ សង្កាត់បានចាប់ផ្តើមអនុវត្តពីឆ្នាំ២០១៨។ ការបែងចែករំលែកចំណូលសារពើពន្ធពីរដ្ឋបាលរាជធានី ខេត្តទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌបានចាប់ផ្តើមពីឆ្នាំ២០១៨ក្នុងអត្រា៣% និងបានបង្កើនដល់អត្រា៤% ពីឆ្នាំ២០១៩-២០២៥។ រីឯការបែងចែករំលែកចំណូលសារពើពន្ធពីរដ្ឋបាលរាជធានី ខេត្តទៅឱ្យរដ្ឋបាលឃុំ សង្កាត់ បានចាប់ផ្តើមអនុវត្តពីឆ្នាំ២០១៨ ក្នុងអត្រា១% និងបានបង្កើនជាបន្តបន្ទាប់រហូតមកដល់អត្រា៦% ពីឆ្នាំ២០២៤-២០២៥។ ដូច្នេះ សកម្មភាពនេះនឹងបន្តផ្តោតលើការគ្រប់គ្រង និងការបង្កើនអត្រានៃការបែងចែកចំណូលពីចំណូលសារពើពន្ធរបស់រដ្ឋបាលរាជធានី ខេត្តទៅឱ្យរដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ស្របតាមការរីកចម្រើននៃសេដ្ឋកិច្ចជាតិ ព្រមទាំងពង្រឹងការប្រើប្រាស់ធនធានហិរញ្ញវត្ថុដែលបានពីការបែងចែករំលែកនេះសម្រាប់ការអភិវឌ្ឍមូលដ្ឋានឱ្យមានប្រសិទ្ធភាពស្របតាមគោលការណ៍កំណត់។

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពអាទិភាពនេះរួមមាន៖

- លើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង និងការបែងចែកចំណូលសារពើពន្ធរបស់រដ្ឋបាលរាជធានី ខេត្តទៅឱ្យរដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ តាមរយៈការជូនដំណឹងឱ្យបានទាន់ពេលវេលាអំពីទំហំធនធានបែងចែករំលែក ដើម្បីឱ្យរដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់នីមួយៗអាចដាក់បញ្ចូលធនធានបែងចែករំលែកទៅក្នុងគម្រោងថវិកាប្រចាំឆ្នាំរបស់ខ្លួន
- សិក្សាអំពីលទ្ធភាពនៃការបង្កើនអត្រាសម្រាប់បែងចែករំលែកចំណូលសារពើពន្ធរបស់រដ្ឋបាលរាជធានី ខេត្តទៅឱ្យរដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ ដើម្បីបង្កើនចំណូលមូលដ្ឋានសម្រាប់ការអភិវឌ្ឍរបស់រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់
- ពិនិត្យមើលឡើងវិញអំពីលក្ខណៈវិនិច្ឆ័យ និងរូបមន្តសម្រាប់បែងចែកចំណូលបែងចែករំលែកពីចំណូលសារពើពន្ធរបស់រដ្ឋបាលរាជធានី ខេត្តទៅឱ្យរដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ លេខាធិការដ្ឋាន គ.ជ.អ.ប. និងរដ្ឋបាលរាជធានី ខេត្ត

**ស្ថាប័នចូលរួមអនុវត្ត** ៖ រដ្ឋបាលថ្នាក់ក្រោមជាតិ

### តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ៤.៣.៣.

| ល.រ. | | ចំណុចដៅ |
|---|---|---|

| | សូចនាករ | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
|---|---|---|---|---|---|---|---|
| ១ | ភាគរយនៃអត្រាចំណូលចែករំលែកពីចំណូលសារពើពន្ធរបស់រដ្ឋបាលរាជធានី ខេត្តទៅឱ្យរដ្ឋបាលក្រុង ស្រុក | ៤% | ៤% | ៤,៥០% | ៤,៥០% | ៤,៥០% | ៤,៥០% |
| ២ | ភាគរយនៃអត្រាចំណូលចែករំលែកពីចំណូលសារពើពន្ធរបស់រដ្ឋបាលរាជធានី ខេត្តទៅឱ្យរដ្ឋបាលឃុំ សង្កាត់ | ៦% | ៦% | ៦,៥០% | ៦,៥០% | ៦,៥០% | ៦,៥០% |

## សកម្មភាពអាទិភាព ៤.៣.៤៖ ការលើកកម្ពស់ការប្រមូលចំណូលមិនមែនសារពើពន្ធ

សកម្មភាពនេះ ត្រូវបន្តផ្តោតលើការពង្រឹងការប្រមូលចំណូលមិនមែនសារពើពន្ធដែលរួមមានពីកម្រៃ ឬឈ្នួលសេវាពីយន្តការច្រកចេញចូលតែមួយ ចំណូលពីការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងកម្រៃពីសេវាផ្សេងៗទៀត។

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពអាទិភាពនេះរួមមាន៖

- ពង្រឹងសមត្ថភាព និងការទទួលខុសត្រូវរបស់យន្តការច្រកចេញចូលតែមួយ និងអង្គភាពទទួលខុសត្រូវលើការប្រមូលចំណូលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ពង្រឹងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធនៅថ្នាក់ក្រោមជាតិ និងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការប្រមូល និងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធនៅតាមយន្តការច្រកចេញចូលតែមួយដែលប្រព័ន្ធទាំង ២នេះ បានធ្វើសន្ទានកម្មទិន្នន័យនឹងគ្នារួចរាល់ហើយ។ ជាមួយគ្នានេះដែរ ក៏ត្រូវពិនិត្យលើការធ្វើសន្ទានកម្មទិន្នន័យរបស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធនៅថ្នាក់ក្រោមជាតិជាមួយនឹងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- ពិនិត្យ និងកំណត់មុខងារផ្តល់សេវាដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងកំណត់កម្រៃសេវាពីការអនុវត្តមុខងារនៃការផ្តល់សេវាទាំងនោះសម្រាប់ជាចំណូលថវិការបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ
- ផ្ទេរមុខងារផ្តល់សេវារដ្ឋបាល ឬសេវាសាធារណៈថ្មីៗបន្ថែមទៀតដែលអាចយកកម្រៃ ឬឈ្នួលសេវាបានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ បន្ថែមលើនេះ ត្រូវពិនិត្យលើការធ្វើប្រតិភូកម្មមុខងារផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលរាជធានីទៅឱ្យរដ្ឋបាលខណ្ឌ នៅពេលដែលមុខងារ និងរចនាសម្ព័ន្ធរបស់រដ្ឋបាលរាជធានី ត្រូវបានកែសម្រួលដែលមានចរិកលក្ខណៈជារដ្ឋបាលទីក្រុងម៉េត្រូប៉ូលីតែន ព្រមទាំងត្រូវពិនិត្យលើការផ្ទេរមុខងារផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលខេត្តទៅឱ្យរដ្ឋបាលក្រុង ស្រុក នៅពេលដែលមុខងារ និងរចនាសម្ព័ន្ធរបស់រដ្ឋបាលខេត្តត្រូវបានកែសម្រួលដែលមានចរិកលក្ខណៈជារដ្ឋបាលតំបន់
- សិក្សាអំពីជម្រើសនានានៃការប្រើប្រាស់ចំណូលដែលទទួលបានកម្រៃពីអ្នកប្រើប្រាស់សេវាសម្រាប់អនុវត្តមុខងារដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ (ឧទាហរណ៍ មុខងារ

គ្រប់គ្រងសំរាម សំណល់រឹង សេវាដឹកជញ្ជូនសាធារណៈ សេវាកម្សាន្ត និងសេវាសុខភាពនៅតាមមូលដ្ឋានជាដើម)

- ពង្រឹងការប្រមូលចំណូលពីការជួលទ្រព្យសម្បត្តិរដ្ឋដែលគ្រប់គ្រងដោយរដ្ឋបាលថ្នាក់ក្រោមជាតិ និងចែករំលែកចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋពីថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ លេខាធិការដ្ឋាន គ.ជ.អ.ប. និងរដ្ឋបាលថ្នាក់ក្រោមជាតិ

**ស្ថាប័នចូលរួមអនុវត្ត** ៖ ក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍន៍

**តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ៤.៣.៤.**

| ល.រ. | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | ចំណូលមិនមែនសារពើពន្ធប្រចាំឆ្នាំរបស់រដ្ឋបាលក្រុង ស្រុក | ១២.០១៩ លានរៀល | កើនឡើង | កើនឡើង | កើនឡើង | កើនឡើង | កើនឡើង |
| ២ | ចំណូលមិនមែនសារពើពន្ធប្រចាំឆ្នាំរបស់រដ្ឋបាលរាជធានី ខេត្ត | ២៨៨.៧១៦ លានរៀល | កើនឡើង | កើនឡើង | កើនឡើង | កើនឡើង | កើនឡើង |

## សកម្មភាពអាទិភាព ៤.៣.៥.៖ ការរៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីចំណូលមិនមែនសារពើពន្ធរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

យុទ្ធសាស្ត្រស្តីពីចំណូលមិនមែនសារពើពន្ធរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានគ្រោងជាសកម្មភាពអាទិភាពមួយនៅក្នុង កជទី២ ដែលត្រូវអនុវត្តនៅក្នុង ផអ៥ទី២។ ទោះបីយ៉ាងនេះក្តី ក្នុងអំឡុងពេលនៃការអនុវត្ត ផអ៥ទី១ លេខាធិការដ្ឋាន គ.ជ.អ.ប. ដោយមានការចូលរួមពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងមានការគាំទ្រពី ISD/GIZ; SDC; LUXAID យុទ្ធសាស្ត្រចំនួន២ ត្រូវបាននិងកំពុងសិក្សារួមមាន (១). យុទ្ធសាស្ត្រគ្រប់គ្រងចំណូលពីសេវារដ្ឋបាលនៅតាមយន្តការច្រកចេញចូលតែមួយ និង (២). យុទ្ធសាស្ត្រគ្រប់គ្រងចំណូលពីសេវាប្រមូលសំរាមសំណល់រឹងទីប្រជុំជន។ ផ្អែកលើមូលដ្ឋាននេះ ផអ៥ទី២ នឹងបន្តការសិក្សានិងរៀបចំនូវក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីចំណូលមិនមែនសារពើពន្ធរបស់រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យស្របតាមកែទម្រង់ប្រព័ន្ធថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (២០២៦-២០៣០)។

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពអាទិភាពនេះរួមមាន៖

- កំណត់ឱ្យបានច្បាស់លាស់នូវទស្សនទាន និងក្របខ័ណ្ឌគតិយុត្តជាមូលដ្ឋានស្តីពីកម្រៃ ឬឈ្នួលសេវាក្នុងគោលបំណងលើកកម្ពស់ការប្រមូលចំណូលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិបន្ថែមទៀតពីការផ្តល់សេវាសាធារណៈ
- ពិនិត្យឡើងវិញ ដើម្បីបង្កើនទំហំសេវា និង/ឬបន្ថែមសេវាថ្មីៗទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ និង/ឬផ្ទេរមុខងារផ្តល់សេវារវាងរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យស្របទៅតាមមុខងារ និងរចនា

សម្ព័ន្ធរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលបានកែសម្រួលស្របតាមចរិកលក្ខណៈនៃរដ្ឋបាលទីក្រុងម៉េត្រូប៉ូលីនតែន រដ្ឋបាលតំបន់ រដ្ឋបាលមូលដ្ឋាន រដ្ឋបាលទីប្រជុំជន និងរដ្ឋបាលតំបន់ជនបទ ព្រមទាំងស្របទៅនឹងមុខងារផ្តល់សេវាដែលបានផ្ទេរពីក្រសួង ស្ថាប័នថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ សំដៅបង្កើនប្រភេទចំណូលមិនមែនសារពើពន្ធថ្មីបន្ថែមទៀតដល់រដ្ឋបាលថ្នាក់ក្រោមជាតិ

- លើកកម្ពស់ការចែករំលែកចំណូលមិនមែនសារពើពន្ធរវាងថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ និង
- លើកកម្ពស់ការគ្រប់គ្រងចំណូលពីទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ លេខាធិការដ្ឋាន គ.ជ.អ.ប. និងរដ្ឋបាលថ្នាក់ក្រោមជាតិ

**ស្ថាប័នចូលរួមអនុវត្ត** ៖ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ

**តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ៤.៣.៥.**

| ល.រ. | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីចំណូលមិនមែនសារពើពន្ធរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | | | រៀបចំ | អនុវត្ត | | |

### លទ្ធផលរំពឹងទុក ៤.៤.៖ ទ្រព្យសម្បត្តិរដ្ឋត្រូវបានផ្ទេរ និងពង្រឹងការគ្រប់គ្រងដោយរដ្ឋបាលថ្នាក់ក្រោមជាតិ

ក្នុងក្របខ័ណ្ឌនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ លិខិតបទដ្ឋានគិតយុត្តនានាពាក់ព័ន្ធទៅនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ កែសម្រួល និងដាក់ឱ្យអនុវត្តជាបន្តបន្ទាប់ ដើម្បីផ្តល់សិទ្ធិអំណាច និងការទទួលខុសត្រូវដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ទ្រព្យសម្បតិរដ្ឋទាំងនេះឱ្យបានគង់វង្ស និងមានប្រសិទ្ធភាពដែលរួមមាន អនុក្រឹត្យលេខ៦៦ ស្តីពីវិធាន និងនីតិវិធីនៃការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ (ឆ្នាំ២០១៧) ច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ (ឆ្នាំ២០២០) និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាច្រើនទៀត។ បន្ថែមលើនេះ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងការចុះបញ្ជីទ្រព្យសម្បត្តិរដ្ឋ (SARMIS) ក៏ត្រូវបានដាក់ឱ្យអនុវត្តនៅរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ មន្ទីរ អង្គភាពជំនាញនៃក្រសួង ស្ថាប័ននានានៅថ្នាក់រាជធានី ខេត្ត ចាប់តាំងពីឆ្នាំ២០២១។ ដូច្នេះ ចាំបាច់ត្រូវបន្តពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិទាំងនេះឱ្យកាន់តែមានប្រសិទ្ធភាពបន្ថែមទៀត។

ជាមួយគ្នានេះដែរ មុខងារ ធនធានមនុស្ស និងធនធានហិរញ្ញវត្ថុក្នុងវិស័យមួយចំនួនក៏ត្រូវបានផ្ទេរទៅរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងកំឡុងពេលនៃការអនុវត្ត កជទី១ និង ផអ៥ទី១នៃ កជទី២ ក៏ប៉ុន្តែទ្រព្យ

សម្បត្តិរដ្ឋដែលត្រូវផ្ទេរភ្ជាប់ជាមួយមុខងារទាំងនោះនៅពុំទាន់បានផ្ទេរជាផ្លូវការនៅឡើយទេ។ អាស្រ័យហេតុនេះ ផអ៥ទី២ នឹងជំរុញការផ្ទេរទ្រព្យសម្បត្តិរដ្ឋទាំងនោះទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីផ្តល់ភាពម្ចាស់ការក្នុងការគ្រប់គ្រង និងប្រើប្រាស់សម្រាប់អនុវត្តមុខងារដែលបានផ្ទេរទាំងនោះឱ្យកាន់តែមានប្រសិទ្ធភាព។

ដើម្បីសម្រេចបាននូវលទ្ធផលរំពឹងទុកនេះ ផអ៥ទី២ បានគ្រោងឡើងនូវសកម្មភាពអាទិភាពចំនួន ០១ ដូចខាងក្រោម៖

**សកម្មភាពអាទិភាព ៤.៤.១.៖ ការពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការផ្ទេរទ្រព្យសម្បត្តិរដ្ឋទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ**

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពអាទិភាពនេះរួមមាន៖

- ពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈ (១). ការធ្វើបច្ចុប្បន្នភាពបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ (២). ការពង្រឹងការត្រួតពិនិត្យផ្ទៃក្នុង និងសវនកម្មផ្ទៃក្នុងរដ្ឋបាលថ្នាក់ក្រោមជាតិលើការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (៣). ការពង្រឹងសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ (៤). ការពង្រឹងការត្រួតពិនិត្យពីថ្នាក់ជាតិទៅលើការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋរបស់រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យស្របតាមតួនាទី និងការទទួលខុសត្រូវដែលបានកំណត់ជាធរមាន (អាជ្ញាធរគ្រប់គ្រង អាជ្ញាធរកាន់កាប់ និងអង្គភាពប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ)
- វាយតម្លៃ និងអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីដាក់ឱ្យដំណើរការប្រព័ន្ធបច្ចេកវិទ្យាព័ត៌សម្រាប់ការគ្រប់គ្រងនិងការចុះបញ្ជីទ្រព្យសម្បត្តិរដ្ឋរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ពិនិត្យ និងសម្រេចលើការផ្ទេរទ្រព្យសម្បត្តិដែលបម្រើឱ្យដល់ការអនុវត្តមុខងារតាមវិស័យនានាដែលបានផ្ទេរទៅឱ្យរដ្ឋបាលរដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ
- ពិនិត្យមើលឡើងវិញលើគោលការណ៍ និងនីតិវិធីជម្រះបញ្ជីទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងការពង្រឹងសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិលើការជម្រះទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ លេខាធិការដ្ឋាន គ.ជ.អ.ប. និងរដ្ឋបាលថ្នាក់ក្រោមជាតិ

**ស្ថាប័នចូលរួមអនុវត្ត** ៖ ក្រសួង ស្ថាប័ន

**តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ៤.៤.១.**

| ល.រ. | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១ | ភាគរយរដ្ឋបាលរាជធានី ខេត្តបានដំណើរការអនឡាញនូវប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ (SARMIS) | | ១០០% | | | | |
| ២ | ភាគរយរដ្ឋបាលក្រុង ស្រុកបានដំណើរការអនឡាញនូវប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ (SARMIS) | | | ១០០% | | | |
| ៣ | ភាគរយរដ្ឋបាលរាជឃុំ សង្កាត់បានដំណើរការអនឡាញនូវប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ (SARMIS) | | | | ១០០% | | |
| ៤ | ចំនួនក្រសួង ស្ថាប័នដែលបានផ្ទេរទ្រព្យសម្បត្តិរដ្ឋជាផ្លូវការទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ | | ៤ | ១៦ | | | |

### លទ្ធផលរំពឹងទុក ៤.៥៖ មូលនិធិគ្មានភ្ជាប់លក្ខខណ្ឌត្រូវបានបង្កើន និងវិភាជទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិតាមរូបមន្ត និងលក្ខណៈវិនិច្ឆ័យប្រកបដោយសមធម៌

មូលនិធិគ្មានភ្ជាប់លក្ខខណ្ឌត្រូវបានបង្កើតឡើង ដើម្បីផ្ទេរធនធានពីថវិកាជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីប្រើប្រាស់សម្រាប់ (១). បំពេញភារកិច្ចតាមផ្លូវច្បាប់ (២). បំពេញមុខងារភារកិច្ចក្នុងការបង្កើត ការជំរុញ និងការធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ (៣). ចំណាយផ្នែករដ្ឋបាលរបស់ខ្លួន និង (៤). ជ្រើសរើស គ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាជម្រើសនានា។

ចាប់ពីឆ្នាំ២០០២ ដល់បច្ចុប្បន្ននេះ មូលនិធិគ្មានភ្ជាប់លក្ខខណ្ឌដែលត្រូវបានបង្កើត និងបានផ្ទេរធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ រួមមាន៖ (១). មូលនិធិឃុំ សង្កាត់ត្រូវបានបង្កើតឡើងនៅឆ្នាំ២០០២ សម្រាប់វិភាជន៍ និងផ្ទេរធនធានពីថវិកាជាតិ និងធនធានពីប្រភពស្របច្បាប់ដទៃទៀតទៅឱ្យរដ្ឋបាលឃុំ សង្កាត់ (២). ការផ្ទេរធនធានបន្ថែមពីថវិកាជាតិក្នុងអត្រា១%ទៅឱ្យរដ្ឋបាលឃុំ សង្កាត់សម្រាប់ការអភិវឌ្ឍមូលដ្ឋានចាប់ពីឆ្នាំ២០២០ និង (៣). មូលនិធិក្រុង ស្រុក ត្រូវបានបង្កើតឡើងនៅឆ្នាំ២០១២ សម្រាប់វិភាជន៍ និងផ្ទេរធនធានពីថវិកាជាតិ និងធនធានពីប្រភពស្របច្បាប់ដទៃទៀតទៅឱ្យរដ្ឋបាលក្រុង ស្រុក។

ដើម្បីសម្រេចបាននូវលទ្ធផលរំពឹងទុកនេះ ផអ៥ទី២ បានគ្រោងឡើងនូវសកម្មភាពអាទិភាពចំនួន ០៣ ដូចខាងក្រោម៖

### សកម្មភាពអាទិភាព ៤.៥.១.៖ ការបង្កើនការផ្ទេរធនធានហិរញ្ញវត្ថុទៅឱ្យរដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់

សកម្មភាពអាទិភាពនេះ ផ្តោតទៅលើការបង្កើនធនធានហិរញ្ញវត្ថុគ្មានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ ដើម្បីផ្តល់លទ្ធភាពឱ្យរដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់មានធនធានកាន់តែសមស្របសម្រាប់អនុវត្តមុខងារជាអាណត្តិទូទៅរបស់ខ្លួន និងអាចចូលរួមបំពេញនូវកង្វះខាតនៃចំណាយប្រតិបត្តិការរដ្ឋបាល ព្រមទាំងការអនុវត្តមុខងារថ្មីៗ តាមរយៈ (១). ការបង្កើនអត្រាការផ្ទេរធនធានពីថវិការដ្ឋទៅឱ្យមូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់ និង (២). ការពិនិត្យ និងការកែសម្រួលឡើងវិញនូវរូបមន្ត និងលក្ខណៈវិនិច្ឆ័យសម្រាប់ការវិភាជធនធានពីមូលនិធិក្រុង ស្រុក និង

មូលនិធិឃុំ សង្កាត់ទៅឱ្យរដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់នីមួយៗប្រកបដោយសមធម៌ ដើម្បីកាត់បន្ថយគម្លាតនៃការអភិវឌ្ឍរវាងតំបន់ទីប្រជុំជន និងតំបន់ជនបទ និង(៣). ការបន្តរក្សាការបន្ថែមធនធានពីថវិការដ្ឋទៅឱ្យរដ្ឋបាលឃុំ សង្កាត់ក្នុងអត្រា១% ប្រចាំឆ្នាំសម្រាប់ការអភិវឌ្ឍមូលដ្ឋានក្នុងអំឡុងពេល ផអ៥ទី២។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃនិងលេខាធិការដ្ឋាន គ.ជ.អ.ប.
**ស្ថាប័នចូលរួមអនុវត្ត** ៖ ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងដៃគូអភិវឌ្ឍន៍

**តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ៤.៥.១.**

| ល.រ | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | អត្រាចូលរួមធនធានពីថវិការដ្ឋទៅឱ្យមូលនិធិក្រុង ស្រុក | ១,៦០% | ១,៦០% | ១,៦០% | ១,៦០% | កើនឡើង | កើនឡើង |
| ២ | អត្រាចូលរួមធនធានពីថវិការដ្ឋទៅឱ្យ មូលនិធិឃុំ សង្កាត់ | ៣,៥០% | ៣,៥០% | ៣,៥០% | ៣,៥០% | កើនឡើង | កើនឡើង |
| ៣ | អត្រាធនធានបន្ថែមពីថវិការដ្ឋទៅឱ្យរដ្ឋបាលឃុំ សង្កាត់ | ១% | ១% | ១% | ១% | ១% | ១% |

## សកម្មភាពអាទិភាព ៤.៥.២៖ ការពង្រឹងការគ្រប់គ្រងមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ

សកម្មភាពនេះ ផ្តោតទៅលើការរៀបចំឱ្យមាននូវគោលការណ៍ និងនីតិវិធីច្បាស់លាស់សម្រាប់ការគ្រប់គ្រង និងការបែងចែកមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗប្រកបដោយតម្លាភាព ប្រសិទ្ធភាព និងសមធម៌។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប.
**ស្ថាប័នចូលរួមអនុវត្ត** ៖ រដ្ឋបាលថ្នាក់ក្រោមជាតិ

**តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ៤.៥.២.**

| ល.រ | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | គោលការណ៍ និងនីតិវិធីសម្រាប់ការគ្រប់គ្រង និងការបែងចែកមូលមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ | | រៀបចំ | ដាក់ឱ្យអនុវត្ត | | | |

## សកម្មភាពអាទិភាព ៤.៥.៣៖ ការពង្រឹងការគ្រប់គ្រងធនធានផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌសម្រាប់អនុវត្តគម្រោងសេវាសង្គម និងអនាម័យបរិស្ថាន

សកម្មភាពនេះ ផ្តោតទៅលើការពង្រឹងការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ធនធានគ្មានភ្ជាប់លក្ខខណ្ឌសម្រាប់អនុវត្តគម្រោងសេវាសង្គម និងអនាម័យបរិស្ថានស្របតាមលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ដោយមានការគិតគូរដល់ការងារគាំពារសង្គម ការប្រែប្រួលអាកាសធាតុនិងគ្រោះមហន្តរាយ និងការលើកកម្ពស់បរិយាបន្ន និងសមធម៌សង្គម តាមរយៈ៖

- ពង្រឹងសមត្ថភាពរបស់រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់លើការរៀបចំគម្រោងថវិកាសម្រាប់គម្រោង/សកម្មភាពសេវាសង្គម និងអនាម័យបរិស្ថានតាមទំហំធនធានដែល

បានកំណត់ និងបញ្ចូលគម្រោងថវិកានេះទៅក្នុងគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់

- ពង្រឹងការអនុវត្តថវិកាសម្រាប់គម្រោង/សកម្មភាពសេវាសង្គម និងអនាម័យបរិស្ថានស្របតាមមុខសញ្ញាចំណាយ និងនីតិវិធីកំណត់ជាធរមាន ដើម្បីធានាថាគម្រោង/សកម្មភាពសេវាសង្គម និងអនាម័យបរិស្ថានដែលបានគ្រោងមានថវិកាគ្រប់គ្រាន់សម្រាប់អនុវត្តតាមផែនការដែលបានគ្រោង
- គាំទ្រ តាមដាន និងត្រួតពិនិត្យរដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់លើការប្រើប្រាស់ថវិកាសម្រាប់គម្រោង/សកម្មភាពសេវាសង្គម និងអនាម័យបរិស្ថាន
- ធ្វើបច្ចុប្បន្នភាពមុខសញ្ញាចំណាយ គម្រោង ឬសកម្មភាពសេវាសង្គម និងអនាម័យបរិស្ថានដើម្បីឆ្លើយតបទៅនឹងការវិវឌ្ឍនៃសេដ្ឋកិច្ច-សង្គម និងតម្រូវការជាក់ស្តែងរបស់មូលដ្ឋាន។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ
**ស្ថាប័នចូលរួមអនុវត្ត** ៖ រដ្ឋបាលថ្នាក់ក្រោមជាតិ

**តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ៤.៥.៣.**

| ល.រ | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | ភាគរយរដ្ឋបាលក្រុង ស្រុកដាក់បញ្ចូលគម្រោងថវិកាសម្រាប់គម្រោង/សកម្មភាពសេវាសង្គម និងអនាម័យបរិស្ថានក្នុងគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលក្រុង ស្រុក | | ១០០% | ១០០% | ១០០% | ១០០% | ១០០% |
| ២ | ភាគរយរដ្ឋបាលឃុំ សង្កាត់ដាក់បញ្ចូលគម្រោងថវិកាសម្រាប់គម្រោង/សកម្មភាពសេវាសង្គម និងអនាម័យបរិស្ថានក្នុងគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលឃុំ សង្កាត់ | | ១០០% | ១០០% | ១០០% | ១០០% | ១០០% |

### លទ្ធផលរំពឹងទុក ៤.៦.៖ មូលនិធិមានឆ្ពាប់លក្ខខណ្ឌត្រូវបានផ្ទេរ និងគ្រប់គ្រងដោយរដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព

គិតមកដល់ឆ្នាំ២០២៥ រដ្ឋបាលថ្នាក់ក្រោមជាតិបាននិងកំពុងអនុវត្តមុខងារមួយចំនួនដែលបានប្រគល់ពីក្រសួង ស្ថាប័នវិស័យមួយចំនួន ដូចជា មុខងារគ្រប់គ្រង និងការផ្តល់សេវាសុខាភិបាលដែលត្រូវបានប្រគល់ពីក្រសួងសុខាភិបាលទៅឱ្យរដ្ឋបាលរាជធានី ខេត្ត មុខងារចំនួន០៦ ដែលបានផ្ទេរពីក្រសួងអប់រំ យុវជន និងកីឡាទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្នុងនោះមុខងារចំនួន០៣ ត្រូវបានផ្ទេរតាមបែបផែន**ប្រគល់**ដែលរួមមាន មុខងារគ្រប់គ្រងការអប់រំកុមារតូច មុខងារគ្រប់គ្រងការអប់រំបឋមសិក្សា និងមុខងារគ្រប់គ្រងការអប់រំក្រៅប្រព័ន្ធ និងមុខងារចំនួន០៣ទៀត ត្រូវបានផ្ទេរតាមបែបផែនធ្វើ**ប្រតិភូកម្ម** ដែលរួមមាន មុខងារគាំទ្រផ្នែករដ្ឋបាលដល់គ្រឹះស្ថានមធ្យមសិក្សាចំណេះដឹងទូទៅ មុខងារគាំទ្រផ្នែករដ្ឋបាលដល់ការងារយុវជន និងមុខងារគាំទ្រផ្នែករដ្ឋបាលដល់ការងារអប់រំកាយនិងកីឡា។ ទន្ទឹមនឹងការ

ផ្ទេរមុខងារពីក្រសួងទាំង២នេះ ថ្នាក់ជាតិក៏បានផ្ទេរធនធានហិរញ្ញវត្ថុ និងបុគ្គលិកទៅឱ្យរដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីអនុវត្តមុខងារដែលបានផ្ទេរ។

ជាក់ស្តែង ក្នុងឆ្នាំ២០២៥ ថ្នាក់ជាតិបានផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌសម្រាប់អនុវត្តមុខងារវិស័យសុខាភិបាលមានទំហំ **៩២៦.៥៥៨លានរៀល** សមមូលនឹង **២២៦លានដុល្លារអាមេរិក** និងសម្រាប់អនុវត្តមុខងារវិស័យអប់រំនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌមានទំហំ **១.៨៤៥.៥២៦លានរៀល** សមមូលនឹង **៤៥០លានដុល្លារអាមេរិក**។

បន្ថែមលើនេះ នៅឆ្នាំ២០១៩ ក្រសួង ស្ថាប័នថ្នាក់ជាតិចំនួន១៩វិស័យ បានផ្ទេរមុខងារចំនួន៤៩ (មិនរាប់បញ្ចូលមុខងារអប់រំ យុវជន និងកីឡា) ជូនរដ្ឋបាលក្រុង ស្រុក ខណ្ឌ តាមរយៈអនុក្រឹត្យលេខ ១៨២ លេខ១៨៣ និងលេខ១៨៤ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក ខណ្ឌ។ ដោយឡែកថ្នាក់ជាតិបានផ្ទេរធនធានហិរញ្ញវត្ថុទៅឱ្យរដ្ឋបាលទាំងនោះ សម្រាប់រ៉ាប់រងតែទៅលើចំណាយបន្ទុកបុគ្គលិក និងចំណាយប្រតិបត្តិការរដ្ឋបាលប៉ុណ្ណោះ ហើយម្យ៉ាងវិញទៀត ធនធានហិរញ្ញវត្ថុនិងទ្រព្យសម្បត្តិពាក់ព័ន្ធនានាសម្រាប់អនុវត្តសកម្មភាពស្នូលនៃមុខងារដែលបានផ្ទេរទៅឱ្យនោះពុំទាន់បានផ្ទេរនៅឡើយ ដែលជាហេតុបណ្តាលឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌពុំមានលទ្ធភាពអនុវត្តមុខងារទាំងនោះបានពេញលេញនៅឡើយ។

ដើម្បីសម្រេចបាននូវលទ្ធផលរំពឹងទុកនេះ ផអ៥ទី២ បានគ្រោងឡើងនូវសកម្មភាពអាទិភាពចំនួន **០២** ដូចខាងក្រោម៖

**សកម្មភាពអាទិភាព ៤.៦.១.៖ ការពង្រឹងការគ្រប់គ្រងមូលនិធិមានភ្ជាប់លក្ខខណ្ឌក្នុងការអនុវត្តមុខងារជាកាតព្វកិច្ចដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ**

សកម្មភាពជាអាទិភាពនេះ នឹងផ្តោតទៅលើការពង្រឹងការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌឱ្យមានប្រសិទ្ធភាព តម្លាភាព គណនេយ្យភាពស្របតាមគោលការណ៍ និងនីតិវិធីហិរញ្ញវត្ថុជាធរមាន តាមរយៈ៖

- ពង្រឹងគណនេយ្យភាពរបស់មន្ទីរ/អង្គភាពដែលបានធ្វើសមាហរណកម្មទៅក្នុងរចនាសម្ព័ន្ធរបស់រដ្ឋបាលរាជធានី ខេត្ត (បច្ចុប្បន្នគឺមន្ទីរសុខាភិបាលរាជធានី ខេត្ត និងមណ្ឌលថែទាំកុមាររដ្ឋ) ចំពោះរដ្ឋបាលរាជធានី ខេត្ត តាមរយៈការដាក់ឆ្លងអភិបាល និងក្រុមប្រឹក្សានូវការពិនិត្យ និងអនុម័តលើគម្រោងថវិកាប្រចាំឆ្នាំ របាយការណ៍ហិរញ្ញវត្ថុ របាយការណ៍សមិទ្ធកម្មនៃការអនុវត្តមុខងារក្នុងក្របខ័ណ្ឌថវិកាកម្មវិធី និងកិច្ចការផ្សេងទៀតដែលកំណត់ដោយលិខិតបទដ្ឋានគតិយុត្ត
- ពង្រឹងគណនេយ្យភាពរបស់ការិយាល័យ/គ្រឹះស្ថានសិក្សាសាធារណៈដែលបានធ្វើសមាហរណកម្មទៅក្នុងរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ (បច្ចុប្បន្នគឺការិយាល័យជំនាញនានា និងគ្រឹះស្ថានសិក្សាសាធារណៈ) ចំពោះរដ្ឋបាលក្រុង ស្រុក ខណ្ឌ តាមរយៈការដាក់ឆ្លងអភិបាល

និងក្រុមប្រឹក្សានូវការពិនិត្យ និងអនុម័តលើគម្រោងថវិកាប្រចាំឆ្នាំ របាយការណ៍ហិរញ្ញវត្ថុ របាយការណ៍សមិទ្ធកម្មនៃការអនុវត្តមុខងារ និងកិច្ចការផ្សេងទៀតដែលកំណត់ដោយលិខិតបទដ្ឋានគតិយុត្ត

– ពង្រឹងការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់មូលនិធិមានភ្ជាប់លក្ខខណ្ឌឱ្យមានប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព តាមរយៈការធ្វើសវនកម្មផ្ទៃក្នុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ និងការធ្វើសវនកម្មពីខាងក្រៅ/អធិការកិច្ចហិរញ្ញវត្ថុតាមគោលការណ៍កំណត់ ព្រមទាំងពង្រឹងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះក្រសួង ស្ថាប័ន និងរាជរដ្ឋាភិបាល។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
**ស្ថាប័នចូលរួមអនុវត្ត** ៖ ក្រសួង ស្ថាប័ន

**តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ៤.៦.១.**

| ល.រ. | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | ភាគរយរដ្ឋបាលរាជធានី ខេត្តដែលបានអនុម័តលើគម្រោងថវិកាប្រចាំឆ្នាំក្នុងការអនុវត្តមូលនិធិមានភ្ជាប់លក្ខខណ្ឌ | | ១០០% | ១០០% | ១០០% | ១០០% | ១០០% |
| ២ | ភាគរយរដ្ឋបាលរាជធានី ខេត្តដែលបានអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំស្ដីពីការអនុវត្តមូលនិធិមានភ្ជាប់លក្ខខណ្ឌ | | ១០០% | ១០០% | ១០០% | ១០០% | ១០០% |
| ៣ | ភាគរយរដ្ឋបាលក្រុង ស្រុក ខណ្ឌដែលបានអនុម័តលើគម្រោងថវិកាប្រចាំឆ្នាំក្នុងការអនុវត្តមូលនិធិមានភ្ជាប់លក្ខខណ្ឌ | | ១០០% | ១០០% | ១០០% | ១០០% | ១០០% |
| ៤ | ភាគរយរដ្ឋបាលក្រុង ស្រុក ខណ្ឌដែលបានអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំស្ដីពីការអនុវត្តមូលនិធិមានភ្ជាប់លក្ខខណ្ឌ | | ១០០% | ១០០% | ១០០% | ១០០% | ១០០% |

**សកម្មភាពអាទិភាព ៤.៦.២.៖ ការកំណត់ទំហំ និងផ្ទេរធនធានមូលនិធិផ្ទេរមានភ្ជាប់លក្ខខណ្ឌសមស្របទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ**

សកម្មភាពជាអាទិភាពនេះ នឹងផ្ដោតទៅលើ៖

– រៀបចំបញ្ចប់របាយការណ៍សិក្សា និងការវិភាគស៊ីជម្រៅ ដើម្បីកំណត់ទំហំធនធានហិរញ្ញវត្ថុសមស្របសម្រាប់មុខងារជាកាតព្វកិច្ចមួយចំនួនដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ
– រៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់ផ្ទេរ និងសម្រាប់គ្រប់គ្រង ចាត់ចែង និងប្រើប្រាស់នូវធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌសម្រាប់អនុវត្តមុខងារជាកាតព្វកិច្ចមួយចំនួនដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ
– គាំទ្រ តាមដាន និងត្រួតពិនិត្យលើការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ លេខាធិការដ្ឋាន គ.ជ.អ.ប. និងក្រសួងផ្ទេរមុខងារ

**ស្ថាប័នចូលរួមអនុវត្ត** ៖ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ

**តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ៤.៦.២.**

| ល.រ. | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | របាយការណ៍សិក្សាមុខងារ និងធនធាននៃវិស័យជំនាញទាំង ១៩ ដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ | សេចក្ដីព្រាង | អនុម័ត | | | | |
| ២ | ក្របខ័ណ្ឌគតិយុត្តសម្រាប់ការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌសម្រាប់មុខងារជាកាតព្វកិច្ចសំខាន់ៗមួយចំនួនត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ | | អនុម័ត | | | | |
| ៣ | ការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌសម្រាប់មុខងារជាកាតព្វកិច្ចសំខាន់ៗមួយចំនួនត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ | | | អនុវត្ត | អនុវត្ត | អនុវត្ត | អនុវត្ត |

## លទ្ធផលរំពឹងទុក ៤.៧.៖ ក្របខ័ណ្ឌសម្រាប់ផ្ដល់ហិរញ្ញប្បទានការវិនិយោគសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានពង្រឹង និងកែលម្អ

ការគ្រប់គ្រងវិនិយោគសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ សំដៅដល់ការគ្រប់គ្រងគម្រោងវិនិយោគដែលរ៉ាប់រងដោយធនធានហិរញ្ញវត្ថុផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ធនធានហិរញ្ញវត្ថុដែលផ្ដល់ហិរញ្ញប្បទានដោយថ្នាក់ជាតិ ធនធានហិរញ្ញវត្ថុដែលផ្ដល់ហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ និងធនធានហិរញ្ញវត្ថុពីប្រភពស្របច្បាប់ផ្សេងៗទៀត។

ការគ្រប់គ្រងវិនិយោគសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានកំណត់ជាផ្នែកមួយនៃយុទ្ធសាស្ត្រស្ដីពីការកែទម្រង់ការគ្រប់គ្រងការវិនិយោគសាធារណៈ (២០១៩-២០២៥)។ យុទ្ធសាស្ត្រស្ដីពីការកែទម្រង់ការគ្រប់គ្រងការវិនិយោគសាធារណៈនេះ កំពុងស្ថិតក្នុងដំណាក់កាលនៃការធ្វើបច្ចុប្បន្នកម្មដោយរំកិលក្របខ័ណ្ឌពេលវេលាពីឆ្នាំ២០២៥ ដល់ឆ្នាំ២០២៨។ បច្ចុប្បន្នកម្មយុទ្ធសាស្ត្រស្ដីពីការកែទម្រង់ការគ្រប់គ្រងការវិនិយោគសាធារណៈ (២០២៥-២០២៨) សំដៅបង្កើតឱ្យបាននូវ "**ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈរួមមួយរបស់ថ្នាក់ជាតិ**" ដើម្បីធានាបាននូវភាពឆ្លើយតប ប្រសិទ្ធភាព ស័ក្តិសិទ្ធភាព តម្លាភាព គណនេយ្យភាព និងចីរភាពនៃការបែងចែក និងប្រើប្រាស់ធនធានសាធារណៈស្របតាមឧត្តមានុវត្តន៍ជាអន្តរជាតិ និងបរិការណ៍ជាក់ស្ដែងរបស់កម្ពុជា។

ដើម្បីចូលរួមអនុវត្តយុទ្ធសាស្ត្រខាងលើនេះឱ្យមានប្រសិទ្ធភាព ចាំបាច់ត្រូវពង្រឹងការគ្រប់គ្រងការវិនិយោគសាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងបង្កើត និងបន្តនូវយន្តការផ្ដល់មូលនិធិនានាដើម្បីបង្កើនល្បឿននៃការអភិវឌ្ឍនៅមូលដ្ឋាន និងការលើកកម្ពស់ប្រសិទ្ធភាពនៃការផ្ដល់សេវាសាធារណៈដែលរួមមានដូចជា (១). មូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ (២). មូលនិធិភាតរភាព និង (៣).

មូលនិធិពិសេស ជាដើម។ ដូចនេះ ដើម្បីសម្រេចបាននូវលទ្ធផលរំពឹងទុកនេះ ផអ៥ទី២ បានគ្រោងឡើងនូវសកម្មភាពអាទិភាពចំនួន០៤ ដូចខាងក្រោម៖

**សកម្មភាពអាទិភាព ៤.៧.១.៖ ការពង្រឹងការគ្រប់គ្រងការវិនិយោគសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

សកម្មភាពនេះ ផ្តោតលើការពង្រឹងការគ្រប់គ្រងវិនិយោគសាធារណៈដែលប្រើប្រាស់ថវិកាផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ថវិកាដែលកៀរគរបានពីដៃគូអភិវឌ្ឍន៍ និងប្រភពស្របច្បាប់ផ្សេងទៀត ស្របតាមយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ (២០២៥-២០២៨) ដែលបានធ្វើបច្ចុប្បន្នកម្ម តាមរយៈ (១). ការរៀបចំសំណើគម្រោងវិនិយោគសាធារណៈ (២). ការរៀបចំផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត ដើម្បីធ្វើសមាហរណកម្ម និងតម្រឹមថវិកានីយកម្មពីគ្រប់ប្រភព និងគ្រប់មុខសញ្ញាចំណាយ (៣). ការបង្កើតយន្តការបុរេថវិកានីយកម្មវិនិយោគសាធារណៈសម្រាប់បំពេញមុខងារទ្វារបាលកិច្ចនៃការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ (៤). ការអនុវត្តយន្តការគាំទ្រហិរញ្ញវត្ថុសម្រាប់សិក្សាលទ្ធភាព និងរៀបចំគម្រោង (៥). ការគ្រប់គ្រងប្រតិបត្តិការគម្រោងតាមប្រភពធនធាន (៦). ការអនុវត្តគោលការណ៍ និងនីតិវិធីគ្រប់គ្រងការប្រើប្រាស់ និងការថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ (៧). ការអនុវត្តនូវប្រព័ន្ធគ្រប់គ្រងទិន្នន័យគម្រោងវិនិយោគសាធារណៈ (៨). ការកសាង និងអភិវឌ្ឍន៍សមត្ថភាពមន្ត្រីរាជការលើជំនាញការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ និង (៩). ការតាមដានត្រួតពិនិត្យ និងវាយតម្លៃប្រព័ន្ធគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ។ ការធ្វើបច្ចុប្បន្នកម្មផែនការយុទ្ធសាស្ត្រនេះ ត្រូវបន្សុីគ្នាជាមួយនឹងការរៀបចំយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ (២០២៦-២០៣០) សំដៅធានាដល់ការផ្តល់សិទ្ធិអំណាចកាន់តែច្រើនឡើងដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង និងការអនុវត្តនូវគម្រោងវិនិយោគសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យកាន់តែមានប្រសិទ្ធភាព និងធានាដល់ការពង្រឹងនូវប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងសវនកម្មរបស់ថ្នាក់ជាតិ។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ

**ស្ថាប័នចូលរួមអនុវត្ត** ៖ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ

**តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ៤.៧.១.**

| ល.រ. | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | បច្ចុប្បន្នកម្មយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ (២០២៥-២០២៨) | បានរៀបចំ | អនុម័ត | | | | |

**សកម្មភាពអាទិភាព ៤.៧.២.៖ ការពង្រឹងការគ្រប់គ្រងមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ**

មូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានអនុវត្តចាប់ពីឆ្នាំ២០១៧ ហើយធនធាននៃមូលនិធិនេះត្រូវបានផ្តល់ហិរញ្ញប្បទានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការប្រកួតប្រជែងផ្អែកលើ

សមិទ្ធកម្មនៃការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗដែលអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។ មកដល់បច្ចុប្បន្ននេះ មានតែរដ្ឋបាលថ្នាក់ក្រុង ស្រុក ខណ្ឌប៉ុណ្ណោះត្រូវបានអនុញ្ញាតឱ្យចូលក្នុងការប្រកួតប្រជែង ដើម្បីទទួលបានធនធានពីមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ។

អាស្រ័យហេតុនេះ ផអ៥ទី២ នឹងផ្តោតទៅលើ៖

- ពិនិត្យលទ្ធភាពក្នុងការពង្រីកវិសាលភាពទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិផ្សេងទៀត ដើម្បីចូលរួមប្រកួតប្រជែងទទួលបានហិរញ្ញប្បទានពីមូលនិធិនេះ
- ពិនិត្យ និងកែលម្អគោលការណ៍វាយតម្លៃសមិទ្ធកម្មប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាឱ្យគោលការណ៍ទាំងនោះឆ្លើយតបទៅនឹងការវិវឌ្ឍជាក់ស្តែងនៃការរីកចម្រើនសង្គម-សេដ្ឋកិច្ច និងសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងលិខិតបទដ្ឋានគតិយុត្តថ្មីៗ
- រៀបចំគោលការណ៍វាយតម្លៃសមិទ្ធកម្មសម្រាប់រដ្ឋបាលថ្នាក់ផ្សេងៗទៅទៀត ជាពិសេសសម្រាប់រដ្ឋបាលឃុំ សង្កាត់
- ពិនិត្យ និងកំណត់ឡើងវិញអំពីប្រភពចំណូលរបស់មូលនិធិនេះសម្រាប់ពេលអនាគត
- ពិនិត្យ និងកែសម្រួលរូបមន្ត និងលក្ខណៈវិនិច្ឆ័យសម្រាប់វិភាជទៅឱ្យបាលថ្នាក់ក្រោមជាតិដែលអាចទទួលបានធនធានពីមូលនិធិនេះ
- សិក្សាពីលទ្ធភាពនៃការដាក់បញ្ចូលធនធានផ្តល់ពីមូលនិធិនេះទៅក្នុងគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត**៖ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប.
**ស្ថាប័នចូលរួមអនុវត្ត** ៖ រដ្ឋបាលថ្នាក់ក្រោមជាតិ

**តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ៤.៧.២.**

| ល.រ | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | គោលការណ៍វាយតម្លៃសមិទ្ធកម្មប្រចាំឆ្នាំរបស់រដ្ឋបាលក្រុង ស្រុក | | អនុម័ត | | | | |
| ២ | គោលការណ៍វាយតម្លៃសមិទ្ធកម្មប្រចាំឆ្នាំរបស់រដ្ឋបាលឃុំ សង្កាត់ | | | អនុម័ត | | | |

## សកម្មភាពអាទិភាព ៤.៧.៣.៖ ការបង្កើតមូលនិធិភាតរភាពសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ

ផ្អែកលើតម្រូវការនៃការអភិវឌ្ឍមូលដ្ឋាន និងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗកាន់មានការកើនឡើង ហើយធនធានថវិកាដែលរដ្ឋបាលថ្នាក់ក្រោមជាតិមានបច្ចុប្បន្ននៅពុំទាន់អាចឆ្លើយតបបានសមស្របនៅនឹងតម្រូវការទាំងនោះនៅឡើយ។ អាស្រ័យហេតុនេះ ផអ៥ទី២ ចាំបាច់ត្រូវគិតគូរលើការផ្តល់ធនធានបន្ថែមពីថ្នាក់ជាតិ តាមរយៈ ៖

- បង្កើត និងដាក់ឱ្យអនុវត្តមូលនិធិភារតភាពដែលមូលនិធិនេះអាចមានប្រភពចំណូលពីការចែករំលែកចំណូលពីប្រភេទចំណូលមិនមែនសារពើពន្ធមួយចំនួនរបស់រដ្ឋបាលថ្នាក់ជាតិ

- សិក្សា និងពិនិត្យមើលឡើងវិញនូវការអនុវត្តមូលនិធិភាតរភាពដែលមូលនិធិនេះអាចមានប្រភពចំណូលបន្ថែមពីការចែករំលែកចំណូលសារពើពន្ធរបស់រដ្ឋបាលរាជធានី ខេត្តក្នុងគោលដៅចែករំលែកចំណូលពន្ធមួយចំណែកពីបណ្តារដ្ឋបាលរាជធានី ខេត្តដែលមានសក្តានុពលចំណូលខ្ពស់ទៅឱ្យរដ្ឋបាលខេត្តដែលមានសក្តានុពលចំណូលទាប ដើម្បីរួមចំណែកកាត់បន្ថយគម្លាតនៃការអភិវឌ្ឍ និងការផ្តល់សេវាសាធារណៈរវាងរដ្ឋបាលថ្នាក់ក្រោមជាតិដែលស្ថិតក្នុងកម្រិតថ្នាក់រដ្ឋបាលដូចគ្នា
- កំណត់នូវវិធាន និងនីតិវិធីសម្រាប់គ្រប់គ្រង និងអនុវត្ត ព្រមទាំងការកំណត់នូវលក្ខណៈវិនិច្ឆ័យ និងរូបមន្តសម្រាប់ការវិភាជធនធានពីមូលនិធិនេះទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗប្រកបដោយតម្លាភាព និងសមធម៌។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប.
**ស្ថាប័នចូលរួមអនុវត្ត** ៖ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ

**តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ៤.៧.៣.**

| ល.រ | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | អនុក្រឹត្យស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃមូលនិធិភាតរភាព | សេចក្តីព្រាង | អនុម័ត | | | | |
| ២ | គោលការណ៍ វិធាន និងនីតិវិធីសម្រាប់ការគ្រប់គ្រង និងការអនុវត្តមូលនិធិភារតភាព | | | អនុម័ត | | | |
| ៣ | ការផ្ទេរធនធានមូលនិធិភាតរភាពទៅឱ្យរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ត្រូវបានអនុវត្ត | | | ១ | | | |

## សកម្មភាពអាទិភាព ៤.៧.៤.៖ ការសិក្សា និងការរៀបចំក្របខណ្ឌសម្រាប់បង្កើតមូលនិធិពិសេស

សកម្មភាពនេះ ផ្តោតលើការសិក្សា ដើម្បីកំណត់អំពីជម្រើសនានាក្នុងការផ្តល់លទ្ធភាពឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ អាចទទួលបានធនធានពីប្រភពនានាបន្ថែមទៀតសម្រាប់ការវិនិយោគដោយបង្កើតឱ្យមានមូលនិធិពិសេសនៃថវិកាជាតិសម្រាប់ជួយគាំទ្រដោយឡែកដល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលមានសក្តានុពលតិចតួច ក៏ដូចជាការអភិវឌ្ឍបន្ថែមនូវហេដ្ឋារចនាសម្ព័ន្ធរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនានាដែលជាតំបន់ប៉ូលសេដ្ឋកិច្ច សំខាន់ៗ តំបន់តាមព្រំដែន ឬតំបន់ដែលមានលក្ខណៈជាយុទ្ធសាស្ត្រ ដើម្បីធានាដល់ការកាត់បន្ថយគម្លាតនៃការអភិវឌ្ឍរវាងតំបន់នានា និងការចូលរួមចំណែកដ៏មានប្រសិទ្ធភាពក្នុងការជំរុញកំណើនសេដ្ឋកិច្ចជាតិ។

ក្នុងករណីដែលយន្តការទាំងនេះត្រូវបានបង្កើតឡើង ចាំបាច់ត្រូវពិចារណាអំពីជម្រើសនានានៃការគ្រប់គ្រងយន្តការទាំងនេះដែលអាចអនុវត្តតាមបែបផែនដោយឡែកពីគ្នា ឬត្រូវធ្វើសមាហរណកម្មទៅក្នុងយន្តការគ្រប់គ្រងមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ ឬមូលនិធិភាតរភាព។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ
**ស្ថាប័នចូលរួមអនុវត្ត** ៖ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ

**តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ៤.៧.៤.**

| ល.រ. | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | របាយការណ៍សិក្សាស្តីពីលទ្ធភាពបង្កើតមូលនិធិពិសេស | | | | | អនុម័ត | |

## លទ្ធផលរំពឹងទុក ៤.៨.៖ ក្របខ័ណ្ឌភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងវិស័យឯកជនត្រូវបានបង្កើត និងដាក់ឱ្យអនុវត្ត

ច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋ និងវិស័យឯកជនត្រូវបានដាក់ឱ្យប្រើប្រាស់ចាប់ពីឆ្នាំ២០២១។ ច្បាប់នេះ មានគោលបំណងលើកកម្ពស់ការគ្រប់គ្រងយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជនក្នុងការរៀបចំ និងអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងគម្រោងសេវាសាធារណៈប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព ចីរភាព តម្លាភាព គណនេយ្យភាព និងយុត្តិធម៌ ដើម្បីជាឧត្តមប្រយោជន៍ដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមនៅកម្ពុជា។ ការគ្រប់គ្រងយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជនក្នុងការរៀបចំ និងអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងគម្រោងសេវាសាធារណៈសម្រាប់វិស័យដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដូចខាងក្រោម៖

- ហេដ្ឋារចនាសម្ព័ន្ធ និងសេវាសាធារណៈបម្រើដល់វិស័យដឹកជញ្ជូន និងវិស័យភស្តុភារកម្ម មានជាអាទិ៍ ផ្លូវថ្នល់ ស្ពាន ផ្លូវដែក អាកាសយានដ្ឋាន កំពង់ផែ ចំណតសាធារណៈ និងព្រែកជីក
- ហេដ្ឋារចនាសម្ព័ន្ធប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាព័ត៌មាន និងបច្ចេកវិទ្យាឌីជីថល
- ការផលិត ការបញ្ជូន និងការចែកចាយថាមពលអគ្គិសនី បំពង់បង្ហូរប្រេងនិងឧស្ម័ន និងសេវាសាធារណៈផ្សេងទៀតក្នុងវិស័យរ៉ែ និងថាមពល
- ហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យ ប្រព័ន្ធលូ ប្រព័ន្ធបង្ហូរទឹក ប្រព័ន្ធបូមស្តារប្រព្រឹត្តកម្មទឹកកខ្វក់ ការគ្រប់គ្រងសំណល់ និងសេវាសាធារណៈផ្សេងទៀតបម្រើឱ្យកិច្ចគាំពារបរិស្ថាន
- ហេដ្ឋារចនាសម្ព័ន្ធ និងសេវាសាធារណៈពាក់ព័ន្ធនឹងវិស័យសុខាភិបាល វិស័យអប់រំ វិស័យការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ វិស័យទេសចរណ៍ វិស័យវប្បធម៌និងសិល្បៈ វិស័យកីឡា និងលំនៅឋានសង្គម
- ហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ មានជាអាទិ៍ តំបន់សេដ្ឋកិច្ចពិសេស សួនបណ្តុំឧស្សាហកម្មធុនតូចនិងមធ្យម និងសួនបច្ចេកវិទ្យា និងនវានុវត្តន៍។

កន្លងមក រាជរដ្ឋាភិបាលបានសម្រេចកំណត់វិស័យអាទិភាពចំនួន០៣ សម្រាប់គម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជនសម្រាប់រយៈពេល ១០ឆ្នាំ (២០២៥-២០៣៥) រួមមាន វិស័យដឹកជញ្ជូន និង

ភស្តុភារកម្ម វិស័យថាមពល និងវិស័យសាធារណការ។ យន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជនក្នុងការរៀបចំ និងអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងគម្រោងសេវាសាធារណៈត្រូវបានអនុវត្តតែនៅរដ្ឋបាលថ្នាក់ជាតិប៉ុណ្ណោះ។ អាស្រ័យហេតុនេះ អំឡុងពេលនៃការអនុវត្ត ផអ៥ទី២ ត្រូវផ្តួចផ្តើមឱ្យមានការសិក្សាអំពីការបង្កើតក្របខ័ណ្ឌភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងឯកជន ដើម្បីកំណត់នូវសក្តានុពលនៃគម្រោងក្នុងវិស័យនានាដែលមានលក្ខណៈសមស្រប។

ដើម្បីសម្រេចបាននូវលទ្ធផលរំពឹងទុកនេះ ផអ៥ទី២ បានគ្រោងឡើងនូវសកម្មភាពអាទិភាពចំនួន ០១ ដូចខាងក្រោម៖

**សកម្មភាពអាទិភាព ៤.៨.១.៖ ការរៀបចំ និងដាក់ឱ្យអនុវត្តនូវនីតិវិធីប្រតិបត្តិរួមសម្រាប់គម្រោងភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងវិស័យឯកជន**

សកម្មភាពនេះ ផ្តោតលើការរៀបចំការសិក្សាមួយអំពីវិសាលភាព និងវិស័យជាសក្តានុពលនានាសម្រាប់រៀបចំក្របខ័ណ្ឌភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងវិស័យឯកជន។

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពអាទិភាពនេះរួមមាន៖

- កំណត់នូវវិស័យនានាសម្រាប់ការវិនិយោគក្នុងក្របខ័ណ្ឌភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងវិស័យឯកជនដែលមានលទ្ធភាពបង្កើនចំណូលបានច្រើនជាងមុន មានការចំណាយតិច និង/ឬមានការលើកកម្ពស់ការផ្តល់សេវាបានល្អប្រសើរជាងមុន
- រៀបចំ និងដាក់ឱ្យអនុវត្តនីតិវិធីប្រតិបត្តិរួមសម្រាប់គម្រោងភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងវិស័យឯកជន។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប.

**ស្ថាប័នចូលរួមអនុវត្ត** ៖ ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងវិស័យឯកជន

**តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ៤.៨.១.**

| ល.រ. | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | នីតិវិធីប្រតិបត្តិរួមសម្រាប់គម្រោងភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងវិស័យឯកជន | | | | សិក្សា | អនុម័ត | |

## ៥ សមាសភាគទី៥៖ ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន

### ៥.១. សនិទានភាព

ការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន ដើម្បីបម្រើផលប្រយោជន៍ប្រជាពលរដ្ឋ គឺជាគោលបំណងដ៏ចម្បងរបស់រាជរដ្ឋាភិបាល។ ក្នុងការចូលរួមសម្រេចគោលបំណងនេះ កម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការបានផ្តោតលើ "**ការបង្វិតការធ្វើសេចក្តីសម្រេចចិត្តលើការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិដែលនៅកៀកជិតប្រជាពលរដ្ឋ**"។

ក្នុងអំឡុងពេលនៃការអនុវត្ត ផអ៥ទី១ ទោះបីរចនាសម្ព័ន្ធ និងប្រព័ន្ធអភិបាលកិច្ចនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានកែលម្អជាបណ្តើរៗ ព្រមទាំងមុខងារ ធនធានមនុស្ស និងធនធានហិរញ្ញវត្ថុកាន់តែច្រើនត្រូវបានផ្ទេរជាបន្តបន្ទាប់ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិក៏ដោយ ក៏ផ្អែកតាមការកើនឡើងនូវតម្រូវការថ្មីៗរបស់ប្រជាពលរដ្ឋ ដោយសារការរីកចម្រើនផ្នែកសេដ្ឋកិច្ច នគរូបនីយកម្ម បច្ចេកវិទ្យាឌីជីថល ការផ្លាស់ប្តូររបៀបរស់នៅតាមបែបទំនើប ការប្រែប្រួលអាកាសធាតុ គ្រោះមហន្តរាយ ជំងឺឆ្លងកាចសាហាវ និងវិបត្តិសាកលនានាបានតម្រូវឱ្យ ផអ៥ទី២ នៅតែបន្តផ្តោតលើការពង្រឹងរចនាសម្ព័ន្ធ ប្រព័ន្ធអភិបាលកិច្ចនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ការផ្ទេរមុខងារ ធនធានមនុស្ស និងធនធានហិរញ្ញវត្ថុទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិក្លាយជាស្ថាប័នដែលកាន់តែមានភាពធន់មាំ មានសមត្ថភាព លទ្ធភាព ស្អាតស្អំ និងម្ចាស់ការក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានក្នុងការឆ្លើយតបទៅនឹងតម្រូវការ ដោះស្រាយបញ្ហានៅតាមមូលដ្ឋាន និងបម្រើផលប្រយោជន៍របស់ប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព បរិយាបន្ន និងសមធម៌សង្គម។

សមាសភាគទាំង៤ខាងលើបានផ្តោតទៅលើការជំរុញ និងពង្រឹងការគ្រប់គ្រងការងារកំណែទម្រង់ ការកែលម្អរចនាសម្ព័ន្ធ មុខងារ ប្រព័ន្ធអភិបាលកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងនិងការអភិវឌ្ឍធនធានមនុស្ស និងការលើកកម្ពស់ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពនៃការប្រើប្រាស់ធនធានហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ដោយឡែក ចំពោះសមាសភាគទី៥នេះ ផ្អែកលើមូលដ្ឋានដែលរៀបចំ និងអនុវត្តតាមសមាសភាគទាំង៤ខាងលើ នឹងផ្តោតលើការលើកកម្ពស់ទាំងបរិមាណ និងគុណភាពនៃការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ ដោះស្រាយបញ្ហាប្រឈមជាអាទិភាពនានានៅតាមមូលដ្ឋានឱ្យកាន់តែចំទិសដៅ ឆាប់រហ័ស មានប្រសិទ្ធភាព មានតម្លាភាព គណនេយ្យភាព បរិយាបន្ន និងសមធម៌សង្គម។

### ៥.២. សមិទ្ធផលរំពឹងទុក

សមិទ្ធផលរំពឹងនៃសមាសភាគទី៥នេះ គឺ "**រដ្ឋបាលថ្នាក់ក្រោមជាតិមានយន្តការ នីតិវិធី និងស្តង់ដាសម្រាប់ផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋឱ្យកាន់តែមានប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព បរិយាបន្ន និងសមធម៌សង្គម**"។

ដើម្បីជានាសម្រេចសមិទ្ធផលរំពឹងទុកនេះ ក្នុងរយៈពេល៥ឆ្នាំបន្ទាប់ (២០២៦-២០៣០) ត្រូវផ្តោតលើកិច្ចការចាំបាច់មួយចំនួនដូចខាងក្រោម៖

- ការកំណត់ច្បាស់លាស់នូវមុខងារជាកាតព្វកិច្ច ដែលរដ្ឋបាលថ្នាក់ក្រោមជាតិតាមប្រភេទ និងតាមកម្រិតថ្នាក់នីមួយៗមានកាតព្វកិច្ចត្រូវអនុវត្តមុខងារជាកាតព្វកិច្ចទាំងនោះ ស្របតាមលក្ខខណ្ឌ និងស្តង់ដាជាតិដែលបានកំណត់
- ការជំរុញ ការសម្របសម្រួល និងការគាំទ្រដល់ក្រសួង ស្ថាប័នពាក់ព័ន្ធការរៀបចំសេចក្តីណែនាំបច្ចេកទេសសម្រាប់អនុវត្តមុខងារជាកាតព្វកិច្ច និងមុខងារជាជម្រើសនានា ព្រមទាំងរៀបចំការផ្សព្វផ្សាយ និងការបណ្តុះបណ្តាលជូនដល់ក្រុមប្រឹក្សា និងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិឱ្យមានការយល់ដឹងច្បាស់អំពីលក្ខខណ្ឌនៃការប្រើប្រាស់ធនធានមានភ្ជាប់លក្ខខណ្ឌសម្រាប់អនុវត្តមុខងារជាកាតព្វកិច្ច និងធនធានឆន្ទានុសិទ្ធិសម្រាប់អនុវត្តមុខងារជាជម្រើស។ សេចក្តីណែនាំបច្ចេកទេសនេះ ត្រូវកំណត់ឱ្យបានច្បាស់លាស់អំពីគោលការណ៍ នីតិវិធី និងស្តង់ដាសម្រាប់អនុវត្តមុខងារជាកាតព្វកិច្ច និងមុខងារជាជម្រើសក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិសាមីនីមួយៗឱ្យបានត្រឹមត្រូវ កាន់តែមានប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព បរិយាបន្ន និងសមធម៌សង្គម
- ការបន្តជំរុញ ពង្រឹង និងពង្រីកការធ្វើទំនើបកម្មប្រព័ន្ធ និងនីតិវិធីផ្តល់សេវារដ្ឋបាលតាមយន្តការច្រកចេញចូលតែមួយនៅរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវារដ្ឋបាល និងការទូទាត់កម្រៃសេវាតាមប្រព័ន្ធអនឡាញដែលមានលក្ខណៈងាយស្រួល ឆាប់រហ័ស តម្លាភាព និងទទួលការជឿជាក់ពីប្រជាពលរដ្ឋ។ ទន្ទឹមគ្នានេះ ក៏ត្រូវផ្តោតលើការរៀបចំបង្រួញនីតិវិធីនៃការផ្តល់សេវារដ្ឋបាលជាកញ្ចប់ ចំពោះការចេញលិខិតអនុញ្ញាតទាំងឡាយណាដែលតម្រូវឱ្យមានការពិនិត្យបច្ចេកទេស និងការសម្រេចពីអង្គភាព/ស្ថាប័នមានសមត្ថកិច្ចតាមជំនាញផ្សេងៗគ្នាច្រើនវិស័យ។ ក្នុងរយៈពេល៥ឆ្នាំបន្ទាប់នេះ ក៏ចាំបាច់ត្រូវសិក្សាពីលទ្ធភាព និងជម្រើសសមស្របនានាសម្រាប់ការបង្កើត និងដាក់ឱ្យដំណើរការមជ្ឈមណ្ឌលផ្តល់សេវារដ្ឋបាល (Public Service Mall) នៅតាមតំបន់ទីប្រជុំជនធំៗ ដើម្បីប្រមូលផ្តុំការផ្តល់សេវារដ្ឋបាលដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ក្រសួង ស្ថាប័នថ្នាក់ជាតិផង និងស្ថិតក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិផងនៅកន្លែងតែមួយ ដើម្បីបង្កលក្ខណៈងាយស្រួលជូនប្រជាពលរដ្ឋ ជាពិសេសប្រជាពលរដ្ឋដែលមកស្វែងរកការងារធ្វើ និងមករស់នៅនៅតាមទីប្រជុំជនធំៗក្នុងការទទួលបានសេវារដ្ឋបាលចាំបាច់នានាកាន់តែងាយស្រួល និងឆាប់រហ័ស
- ការជំរុញរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានប្រកបដោយនិរន្តរភាព ដើម្បីបង្កើតការងារ និងបង្កើនប្រាក់ចំណូលរបស់ប្រជាពលរដ្ឋតាមសហគមន៍នានា។ ការងារនេះ ត្រូវផ្តោតទាំងទៅលើការជំរុញ និងលើកកម្ពស់ប្រសិទ្ធភាពនៃការទាក់ទាញការចុះបញ្ជីគម្រោងវិនិយោគដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលរាជធានី ខេត្ត និងទាំង

ការគាំទ្រ និងលើកកម្ពស់អាជីវកម្ម សហគ្រាសខ្នាតតូច-មធ្យម សហគមន៍កសិករ និងសិប្បកម្មកែច្នៃផលិតផលក្នុងស្រុកនៅក្នុងក្របខ័ណ្ឌនៃដែនសមត្ថកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។ ក្រៅពីនេះ ការអភិវឌ្ឍតាមតំបន់ព្រំដែនក៏ត្រូវផ្តោតការយកចិត្តទុកដាក់ដើម្បីធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិដែលនៅជាប់ព្រំដែនទទួលបានការអភិវឌ្ឍទាំងហេដ្ឋារចនាសម្ព័ន្ធ សកម្មភាពសេដ្ឋកិច្ច កិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសជិតខាងប្រកបដោយចីរភាព និងសន្តិភាព

- ការបន្តជំរុញ និងបង្កើនកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធក្នុងចំណោមរដ្ឋបាលថ្នាក់ក្រោមជាតិ និងកិច្ចសហប្រតិបត្តិការក្នុងភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយអង្គការសង្គមស៊ីវិល និងវិស័យឯកជនក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិសាមីនីមួយៗប្រកបដោយភាពជឿជាក់ និងឈរលើស្មារតីបម្រើផលប្រយោជន៍ប្រជាពលរដ្ឋជាធំ និងដោយភាពស្មោះត្រង់
- ការបញ្ជ្រាបភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ ការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានាទៅក្នុងនីតិវិធីអនុវត្តការងារ នីតិវិធីការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ក៏ជាកិច្ចការចាំបាច់ដែលត្រូវផ្តោតការយកចិត្តទុកដាក់ពង្រឹង និងលើកកម្ពស់ការអនុវត្តនៅក្នុង៥ឆ្នាំបន្ទាប់នេះផងដែរ
- ការលើកកម្ពស់តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការចូលរួមអនុវត្តប្រព័ន្ធគាំពារសង្គម រួមមានដូចជាកម្មវិធីរបបសន្តិសុខសង្គម កម្មវិធីជាតិជំនួយសង្គម និងក្របខ័ណ្ឌច្បាប់នានាដែលត្រូវបានបង្កើតឡើង ដើម្បីពង្រឹងសន្តិសុខប្រាក់ចំណូល និងផ្តល់ការគាំពារទល់នឹងហានិភ័យ និងភាពងាយរងគ្រោះនានាដែលប្រជាពលរដ្ឋអាចនឹងជួបប្រទះ
- ការជំរុញ ពង្រឹង និងពង្រីកចលនាប្រឡងប្រណាំងក្នុងចំណោមរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ តាមរយៈការរៀបចំបង្កើតយន្តការ/ប្រព័ន្ធវាយតម្លៃលើលទ្ធផលនៃការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់ និងប្រព័ន្ធស្ទង់មតិលើភាពពេញចិត្តរបស់ប្រជាពលរដ្ឋចំពោះគុណភាព និងប្រសិទ្ធភាពនៃការអភិវឌ្ឍមូលដ្ឋាន និងការផ្តល់សេវារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

### ៥.៣. លទ្ធផលរំពឹងទុក

ដើម្បីសម្រេចបាននូវសមិទ្ធផលរំពឹងទុកខាងលើ សមាសភាគទី៥ បានកំណត់នូវលទ្ធផលរំពឹងទុកចំនួន០៤ ដូចខាងក្រោម៖

លទ្ធផលរំពឹងទុកទី១៖ ការគ្រប់គ្រង និងការអនុវត្តមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវាសាធារណៈត្រូវបានពង្រឹងឱ្យកាន់តែមានប្រសិទ្ធភាព

លទ្ធផលរំពឹងទុកទី២៖ យន្តការច្រកចេញចូលតែមួយនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានធ្វើទំនើបកម្ម ពង្រឹង និងពង្រីកការអនុវត្ត

លទ្ធផលរំពឹងទុកទី៣៖ ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានប្រកបដោយចីរភាពនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងការអភិវឌ្ឍតាមតំបន់ជាប់ព្រំដែនត្រូវបានជំរុញ និងលើកកម្ពស់

លទ្ធផលរំពឹងទុកទី៤៖ ភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រងហានិភ័យពីគ្រោះមហន្តរាយ ជំងឺឆ្លងកាចសាហាវនានា និងកិច្ចគាំពារសង្គមត្រូវបានបញ្ជ្រាបទៅក្នុងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

សកម្មភាពជាអាទិភាពដែលត្រូវអនុវត្ត ដើម្បីសម្រេចបានលទ្ធផលរំពឹងទុកនីមួយៗ រួមបញ្ចូលសូចនាករ និងចំណុចដៅសម្រាប់វាស់វែងការសម្រេចបាននូវសកម្មភាពជាអាទិភាពទាំងនេះ មានបរិយាយតាមលទ្ធផលរំពឹងទុកខាងក្រោម ៖

### លទ្ធផលរំពឹងទុក ៥.១.៖ ការគ្រប់គ្រង និងការអនុវត្តមុខងារនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវាសាធារណៈត្រូវបានពង្រឹងឱ្យកាន់តែមានប្រសិទ្ធភាព

គិតដល់ឆ្នាំ២០២៥ រាជរដ្ឋាភិបាល និងក្រសួង ស្ថាប័នពាក់ព័ន្ធបានផ្ទេរមុខងារតាមវិស័យនានាទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីគ្រប់គ្រង ចាត់ចែង និងអនុវត្តការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានស្របតាមគោលនយោបាយជាតិ និងឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាននីមួយៗ។ ទោះយ៉ាងនេះក្តី មុខងារដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិទាំងនោះពុំទាន់បានកំណត់ច្បាស់លាស់នូវមុខងារជាកាតព្វកិច្ចដែលរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗត្រូវអនុវត្តដោយខានពុំបាន និងមុខងារជាជម្រើសដែលរដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិជ្រើសរើសយកមកអនុវត្តដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងដែលមានលក្ខណៈផ្សេងៗគ្នានៅតាមមូលដ្ឋាននីមួយៗ។

ទន្ទឹមគ្នានេះ មុខងារមួយចំនួនដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិក៏ពុំទាន់មានសេចក្តីណែនាំបច្ចេកទេស និងការបណ្តុះបណ្តាលជូនដល់ក្រុមប្រឹក្សា និងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិឱ្យមានការយល់ដឹងច្បាស់លាស់ក្នុងការដឹកនាំ ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារទាំងនោះឱ្យមានប្រសិទ្ធភាពល្អនៅឡើយ។

ដើម្បីសម្រេចបាននូវលទ្ធផលរំពឹងទុកនេះ ផអ៥ទី២ បានគ្រោងឡើងនូវសកម្មភាពអាទិភាពចំនួន ០២ ដូចខាងក្រោម៖

### សកម្មភាពអាទិភាព ៥.១.១.៖ ការលើកកម្ពស់ការគ្រប់គ្រង និងការអនុវត្តមុខងារជាកាតព្វកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

មុខងារជាកាតព្វកិច្ច គឺជាមុខងារទាំងឡាយណាដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិតាមរយៈច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវតែអនុវត្តមុខងារជា

កាតព្វកិច្ចដែលបានផ្ទេរឱ្យទាំងនោះដោយខានមិនបាន។ ក្នុងការអនុវត្តមុខងារជាកាតព្វកិច្ច រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋ និងត្រូវទទួលខុសត្រូវចំពោះក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលដោយអនុលោមតាមលក្ខខណ្ឌ និងស្តង់ដាដែលបានកំណត់ជាធរមាន។

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពអាទិភាពនេះរួមមាន៖

- កំណត់ឱ្យបានច្បាស់លាស់នូវមុខងារជាកាតព្វកិច្ច ដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិតាមរយៈការដាក់ចេញនូវអនុក្រឹត្យ ដើម្បីឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗដឹងច្បាស់អំពីមុខងារទាំងឡាយណាដែលខ្លួនត្រូវអនុវត្តដោយខានពុំបាន និងត្រូវដឹកនាំ គ្រប់គ្រង ចាត់ចែងការអនុវត្តមុខងារជាកាតូកិច្ចទាំងនោះឱ្យមានប្រសិទ្ធភាពស្របតាមលក្ខខណ្ឌ នីតិវិធី និងស្តង់ដាដែលបានកំណត់
- សម្របសម្រួល ជំរុញ និងគាំទ្រដល់ក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការរៀបចំ ពិនិត្យ និងកែលម្អសេចក្តីណែនាំបច្ចេកទេសសម្រាប់អនុវត្តមុខងារជាកាតព្វកិច្ច ព្រមទាំងរៀបចំការផ្សព្វផ្សាយ និងការបណ្តុះបណ្តាលអំពីសេចក្តីណែនាំបច្ចេកទេសទាំងនោះជូនដល់ក្រុមប្រឹក្សា និងបុគ្គលិក រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យមានការយល់ដឹងច្បាស់លាស់អំពីការដឹកនាំ ការគ្រប់គ្រង និងការអនុវត្តមុខងារជាកាតព្វកិច្ចទាំងនោះប្រកបដោយប្រសិទ្ធភាព
- ជំរុញ និងពង្រឹងការតាមដាន ត្រួតពិនិត្យ និងផ្តល់ការគាំទ្រផ្នែកបច្ចេកទេសជាប្រចាំដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការដឹកនាំ ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារជាកាតព្វកិច្ចដែលបានផ្ទេរទៅឱ្យ ដើម្បីធានាឱ្យបានថារដ្ឋបាលថ្នាក់ក្រោមជាតិអាចអនុវត្តមុខងារជាកាតូកិច្ចនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព និងស្របតាមលក្ខខណ្ឌ និងស្តង់ដាកំណត់
- វាយតម្លៃលើការដឹកនាំ ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារជាកាតព្វកិច្ចដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីមានមូលដ្ឋានសម្រាប់កែលម្អ។ ការវាយតម្លៃនេះគួរផ្តោតលើការអនុវត្តមុខងារសុខាភិបាលដែលបានផ្ទេរទៅឱ្យរដ្ឋបាលរាជធានី ខេត្ត មុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងមុខងារអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ លេខាធិការដ្ឋាន គ.ជ.អ.ប. និងក្រសួងមហាផ្ទៃ

**ស្ថាប័នចូលរួមអនុវត្ត** ៖ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ

**តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ៥.១.១.**

| ល.រ. | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | អនុក្រឹត្យស្តីពីការកំណត់មុខងារជាកាតព្វកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | | អនុម័ត | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ២ | ភាគរយនៃមុខងារកាតព្វកិច្ចដែលមានសេចក្តីណែនាំបច្ចេកទេស និងបានបណ្តុះបណ្តាលជូនរដ្ឋបាលថ្នាក់ក្រោមជាតិ | | | ៥០% | ៨០% | ៩០% | ១០០% |
| ៣ | របាយការណ៍វាយតម្លៃការអនុវត្តមុខងារសុខាភិបាល | | អនុម័ត | | | | |
| ៤ | របាយការណ៍វាយតម្លៃការអនុវត្តមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន | | | អនុម័ត | | | |
| ៥ | របាយការណ៍វាយតម្លៃការអនុវត្តមុខងារអប់រំ យុវជន និងកីឡា | | | | | អនុម័ត | |

## សកម្មភាពអាទិភាព ៥.១.២.៖ ការលើកកម្ពស់ការគ្រប់គ្រង និងការអនុវត្តមុខងារជាជម្រើសរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

មុខងារជាជម្រើសសំដៅដល់មុខងារទាំងឡាយណាដែលមិនត្រូវបានកំណត់ថា ជាមុខងារជាកាតព្វកិច្ច។ រដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិជ្រើសរើសមុខងារជាជម្រើសមកអនុវត្ត ដើម្បីឆ្លើយតបនឹងតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋដែលបានកំណត់ជាតម្រូវការអាទិភាពក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។ រដ្ឋបាលថ្នាក់ក្រោមជាតិអាចជ្រើសរើសមុខងារជាជម្រើសមកអនុវត្តក្នុងករណីដែលគ្មានការជំទាស់ពីក្រសួង ស្ថាប័នពាក់ព័ន្ធនានា។

នាពេលកន្លងមក ផ្អែកតាមអនុក្រឹត្យលេខ២៨៥ អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការជ្រើសរើស ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារជាជម្រើសដោយក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិបានជ្រើសរើសមុខងារជាជម្រើសជាច្រើនមកអនុវត្ត ដើម្បីឆ្លើយតប និងដោះស្រាយបញ្ហាប្រឈមនានារបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋានដែលបានកំណត់ក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិសាមីនីមួយៗដូចជា គម្រោងសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ផ្លូវ សាលារៀន ស្ពាន ប្រព័ន្ធធារាសាស្ត្រ ប្រព័ន្ធលូ និងគម្រោងផ្តល់សេវាសង្គម និងអនាម័យបរិស្ថានជាដើម។

ការរៀបចំ និងការអនុវត្តមុខងារជាជម្រើសទាំងនេះ ត្រូវបានរៀបចំតាមគោលការណ៍ និងនីតិវិធីដែលបានដាក់ឱ្យអនុវត្តជាយូរឆ្នាំមកហើយ ដូចជា សៀវភៅណែនាំស្តីពីការរៀបចំនិងការអនុវត្តគម្រោងឃុំ សង្កាត់ (PIM) សៀវភៅណែនាំស្តីពីការរៀបចំគម្រោងក្រុង ស្រុក (DIM) សៀវភៅណែនាំស្តីពីការរៀបចំគម្រោងរាជធានី ខេត្តជាដើម។ ទន្ទឹមគ្នានេះ សៀវភៅណែនាំទាំងនេះក៏ពុំបានគ្រប់ដណ្តប់លើគ្រប់ទិដ្ឋភាពបច្ចេកទេសសម្រាប់ការរៀបចំ និងការអនុវត្តគម្រោងមួយចំនួននៅឡើយ ដូចជា គម្រោងផ្តល់សេវាសង្គម និងអនាម័យបរិស្ថាន និងគម្រោងដែលត្រូវការឱ្យមានលក្ខណៈបច្ចេកទេសជាក់លាក់ដោយឡែកៗជាដើម។

អាស្រ័យហេតុនេះ ក្នុងរយៈពេល៥ឆ្នាំបន្ទាប់នេះ ចាំបាច់ត្រូវពិនិត្យ ធ្វើបច្ចុប្បន្នភាព កែលម្អសៀវភៅណែនាំទាំងនេះ ព្រមទាំងត្រូវផ្សព្វផ្សាយ និងបណ្តុះបណ្តាលជូនដល់ក្រុមប្រឹក្សា និងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានការយល់ដឹងច្បាស់លាស់ក្នុងការរៀបចំ និងអនុវត្តមុខងារជាជម្រើសដែលជាតម្រូវការនៅតាមមូលដ្ឋាននីមួយៗឱ្យកាន់តែមានប្រសិទ្ធភាព។

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពអាទិភាពនេះរួមមាន៖

- ពិនិត្យ ធ្វើបច្ចុប្បន្នភាព និងកែលម្អសៀវភៅណែនាំស្តីពីការរៀបចំគម្រោងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងក្របខ័ណ្ឌនៃការអនុវត្តមុខងារជាជម្រើស រួមមាន សៀវភៅណែនាំស្តីពីការរៀបចំ និងការអនុវត្តគម្រោងឃុំ សង្កាត់ (PIM) សៀវភៅណែនាំស្តីពីការរៀបចំគម្រោងក្រុង ស្រុក (DIM) សៀវភៅណែនាំស្តីពីការរៀបចំគម្រោងរាជធានី ខេត្ត ដោយត្រូវបញ្ចូលនីតិវិធីសម្រាប់រៀបចំគម្រោងផ្តល់សេវាសង្គម និងអនាម័យបរិស្ថានផងដែរ។ ការធ្វើបច្ចុប្បន្នភាព និងកែលម្អសៀវភៅណែនាំទាំងនេះ ត្រូវគិតគូរដល់ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យា និងត្រូវធានាដល់ការបញ្ជ្រាបភាពធន់ទៅនឹងហានិភ័យនៃគ្រោះមហន្តរាយអាកាសធាតុ ការកាត់បន្ថយផលប៉ះពាល់បរិស្ថាន និងសង្គម កិច្ចគាំពារសង្គម ព្រមទាំងការលើកកម្ពស់សមភាពយេនឌ័របរិយាបន្ន និងសមធម៌សង្គម
- រៀបចំផ្សព្វផ្សាយ និងបណ្តុះបណ្តាលដល់ក្រុមប្រឹក្សា និងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិអំពីសៀវភៅណែនាំដែលបានកែលម្អ និងធ្វើបច្ចុប្បន្នភាពទាំងនេះជូនដល់ក្រុមប្រឹក្សា និងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ
- តាមដាន ត្រួតពិនិត្យ និងគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការរៀបចំ និងការអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធ និងគម្រោងសេវាសង្គម និងអនាម័យបរិស្ថានក្នុងក្របខ័ណ្ឌនៃការអនុវត្តមុខងារជាជម្រើស។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ ក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប.

**ស្ថាប័នចូលរួមអនុវត្ត** ៖ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ

**តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ៥.១.២.**

| ល.រ. | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | សៀវភៅណែនាំស្តីពីការរៀបចំ និងការអនុវត្តគម្រោងឃុំ សង្កាត់ដែលបានកែលម្អ និងបានបញ្ចូលនីតិវិធីរៀបចំ និងអនុវត្តគម្រោងផ្តល់សេវាសង្គម និងអនាម័យបរិស្ថាន | | អនុម័ត | | | | |
| ២ | សៀវភៅណែនាំស្តីពីការរៀបចំគម្រោងក្រុង ស្រុកដែលបានកែលម្អ និងបានបញ្ចូលនីតិវិធីរៀបចំគម្រោងផ្តល់សេវាសង្គម និងអនាម័យបរិស្ថាន | | អនុម័ត | | | | |
| ៣ | សៀវភៅណែនាំស្តីពីការរៀបចំគម្រោងរាជធានី ខេត្តដែលបានកែលម្អ និងបានបញ្ចូលនីតិវិធីរៀបចំគម្រោងផ្តល់សេវាសង្គម | | អនុម័ត | | | | |
| ៤ | ភាគរយឃុំ សង្កាត់ទទួលបានការបណ្តុះបណ្តាលអំពីសៀវភៅណែនាំការរៀបចំ និងការអនុវត្តគម្រោងឃុំ សង្កាត់ | | | ១០០% | | | |
| ៥ | ភាគរយក្រុង ស្រុកទទួលបានការបណ្តុះបណ្តាលអំពីសៀវភៅណែនាំការរៀបចំ និងការអនុវត្តគម្រោងក្រុង ស្រុក | | | ១០០% | | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ៦ | ភាគរយរាជធានី ខេត្តទទួលបានការបណ្តុះបណ្តាលអំពីសៀវភៅណែនាំការរៀបចំ និងការអនុវត្តគម្រោងរាជធានី ខេត្ត | | | ១០០% | | | |

**លទ្ធផលរំពឹងទុក ៥.២.៖ យន្តការច្រកចេញចូលតែមួយនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានធ្វើទំនើបកម្ម និងពង្រឹងការអនុវត្ត**

ការផ្តល់សេវារដ្ឋបាលតាមយន្តការច្រកចេញចូលតែមួយនៅរដ្ឋបាលថ្នាក់ក្រោមជាតិ បានចាប់ផ្តើមអនុវត្តពីឆ្នាំ២០០៥ ដោយបានពិនិត្យ វាយតម្លៃ និងកែលម្អជាបណ្តើរៗ។ នៅឆ្នាំ២០១៧ យន្តការនេះត្រូវបានពង្រីក និងដាក់ឱ្យដំណើរការនៅតាមរដ្ឋបាលថ្នាក់ក្រោមជាតិទូទាំងប្រទេស។

ជារួម យន្តការផ្តល់សេវារដ្ឋបាលតាមច្រកចេញចូលតែមួយនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានទទួលស្គាល់ថាជាយន្តការដ៏មានប្រសិទ្ធភាពមួយ ដែលទទួលបានការពេញចិត្តពីប្រជាពលរដ្ឋគួរឱ្យកត់សម្គាល់។ ក្នុងអំឡុងពេលនៃការអនុវត្ត ផអ៥ទី១ យន្តការនេះត្រូវបានជំរុញ ពង្រឹង និងកែលម្អជាបន្តបន្ទាប់តាមរយៈ ការធ្វើទំនើបកម្មដាក់ឱ្យអនុវត្តនីតិវិធីផ្តល់សេវារដ្ឋបាល និងការទូទាត់កម្រៃសេវាតាមប្រព័ន្ធអនឡាញនៅតាមរដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលក្រុង ស្រុកគោលដៅមួយចំនួន។

ទោះយ៉ាងនេះក្តី ផ្អែកតាមការប្រែប្រួលស្ថានភាពនយោបាយ សេដ្ឋកិច្ច នគរូបនីយកម្ម បច្ចេកវិទ្យាឌីជីថល ការកើនឡើងនូវតម្រូវការសេវាសង្គម និងការវិវឌ្ឍនៃរចនាសម្ព័ន្ធ ប្រព័ន្ធអភិបាលកិច្ច មុខងារ និងសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលបានកែលម្អជាបណ្តើរៗនាពេលកន្លងមក បានតម្រូវឱ្យមានការពិនិត្យឡើងវិញនូវទំហំ ប្រភេទ ស្តង់ដា និងនីតិវិធីផ្តល់សេវារដ្ឋបាលតាមយន្តការច្រកចេញចូលតែមួយនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ ជាមួយគ្នានេះ ការរៀបចំផ្តល់សេវារដ្ឋបាលចល័តជូនប្រជាពលរដ្ឋជាពិសេសក្រុមជនដែលងាយរងគ្រោះ និងជួបការលំបាកតាមសហគមន៍ដែលស្ថិតនៅតាមតំបន់ឆ្ងាយពីទីតាំងផ្តល់សេវាក៏ចាំបាច់ត្រូវការគិតគូរពង្រឹង និងពង្រីកផងដែរ។

ដើម្បីសម្រេចបាននូវលទ្ធផលរំពឹងទុកនេះ ផអ៥ទី២ បានគ្រោងឡើងនូវសកម្មភាពអាទិភាពចំនួន០៥ ដូចខាងក្រោម៖

## សកម្មភាពអាទិភាព ៥.២.១.៖ ការធ្វើទំនើបកម្មប្រព័ន្ធ និងកែលម្អនីតិវិធីផ្តល់សេវារដ្ឋបាលតាមយន្តការច្រកចេញចូលតែមួយនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពអាទិភាពនេះរួមមាន៖

- ពិនិត្យ កែលម្អ និងពង្រីកការអនុវត្តប្រព័ន្ធ/នីតិវិធីការផ្តល់សេវារដ្ឋបាល និងការទូទាត់កម្រៃសេវាតាមប្រព័ន្ធអនឡាញ/ឌីជីថលតាមយន្តការច្រកចេញចូលតែមួយនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសនៅតាមរដ្ឋបាលខេត្ត និងរដ្ឋបាលក្រុង ស្រុក ខណ្ឌទូទាំងប្រទេស
- រៀបចំ និងដាក់ឱ្យដំណើរការយន្តការ/ប្រព័ន្ធវាយតម្លៃ ឬស្ទង់មតិអំពីភាពពេញចិត្តរបស់ប្រជាពលរដ្ឋចំពោះគុណភាពសេវារដ្ឋបាលដែលបានផ្តល់តាមយន្តការច្រកចេញចូលតែមួយ

ដោយរដ្ឋបាលថ្នាក់ក្រោមជាតិសាមីនីមួយៗ។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ ក្រសួងមហាផ្ទៃ
**ស្ថាប័នចូលរួមអនុវត្ត** ៖ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ

**តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ៥.២.១.**

| ល.រ | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | ភាគរយរដ្ឋបាលខេត្តដែលដំណើរការផ្តល់សេវារដ្ឋបាលតាមប្រព័ន្ធអនឡាញ/ឌីជីថល | ៤៨% | ១០០% | | | | |
| ២ | ភាគរយរដ្ឋបាលក្រុង ស្រុកដែលដំណើរការផ្តល់សេវារដ្ឋបាលតាមប្រព័ន្ធអនឡាញ/ឌីជីថល | ៤% | ៥០% | ១០០% | | | |
| ៣ | ភាគរយរាជធានី ខេត្តដែលមានយន្តការស្ទង់មតិអំពីភាពពេញចិត្តរបស់ប្រជាពលរដ្ឋលើគុណភាពសេវា | | | ១០០% | | | |
| ៤ | ភាគរយក្រុង ស្រុក ខណ្ឌដែលមានយន្តការស្ទង់មតិអំពីភាពពេញចិត្តរបស់ប្រជាពលរដ្ឋលើគុណភាពសេវា | | | ១០០% | | | |

## សកម្មភាពអាទិភាព ៥.២.២.៖ ការជំរុញការផ្តល់សេវារដ្ឋបាលចល័ត

បច្ចុប្បន្ន រដ្ឋបាលថ្នាក់ក្រោមជាតិមួយចំនួនបាននិងកំពុងផ្តល់សេវារដ្ឋបាលចល័តជូនប្រជាពលរដ្ឋរស់នៅក្នុងសហគមន៍ដែលស្ថិតនៅក្នុងតំបន់ឆ្ងាយពីទីតាំងកន្លែងផ្តល់សេវារដ្ឋបាលក្នុងបំណងជួយឱ្យប្រជាពលរដ្ឋដែលរស់នៅតំបន់ឆ្ងាយជួបការលំបាកបានទទួលសេវារដ្ឋបាល/ឯកសារស្របច្បាប់សម្រាប់ប្រើប្រាស់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់ខ្លួន ការស្វែងរកការងារធ្វើ ការប្រកបមុខរបរ ការធ្វើអាជីវកម្មស្របច្បាប់ និងការទទួលបានសេវាជាមូលដ្ឋាននិងចាំបាច់នានា។

ករណីនេះ បង្ហាញឱ្យឃើញពីការយកចិត្តទុកដាក់របស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវាបម្រើផលប្រយោជន៍ប្រជាពលរដ្ឋប្រកបដោយបរិយាបន្ន។ គំនិតផ្តួចផ្តើមល្អនេះ គួរត្រូវបានជំរុញ និងពង្រីកការអនុវត្តដល់រដ្ឋបាលថ្នាក់ក្រោមជាតិផ្សេងទៀតឱ្យបានទូលំទូលាយ។

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពអាទិភាពនេះរួមមាន៖

- ចងក្រង ផ្សព្វផ្សាយ និងចែករំលែកមេរៀនបទពិសោធន៍ល្អៗពាក់ព័ន្ធនឹងការផ្តល់សេវារដ្ឋបាលចល័តជូនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ជំរុញ និងគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការរៀបចំផ្តល់សេវារដ្ឋបាលចល័តស្របតាមស្ថានភាពជាក់ស្តែង និងលទ្ធភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិសាមីនីមួយៗ។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ ក្រសួងមហាផ្ទៃ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
**ស្ថាប័នចូលរួមអនុវត្ត** ៖ រដ្ឋបាលថ្នាក់ក្រោមជាតិ

### តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ៥.២.២.

| ល.រ. | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | ចំនួនរដ្ឋបាលថ្នាក់ក្រោមជាតិដែលបានផ្តល់សេវារដ្ឋបាលចល័ត | ២ | ៤ | ១០ | ២០ | ៣០ | ៥០ |

## សកម្មភាពអាទិភាព ៥.២.៣.៖ ការពិនិត្យ និងការកែសម្រួលឡើងវិញនូវទំហំ ប្រភេទ ស្តង់ដា និងនីតិវិធីផ្តល់សេវារដ្ឋបាលនៅតាមកម្រិត និងប្រភេទនៃរដ្ឋបាលថ្នាក់ក្រោមជាតិ

សកម្មភាពនេះ ផ្តោតលើការសិក្សា និងកែសម្រួលទំហំ ប្រភេទ និងស្តង់ដាសេវារដ្ឋបាលដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗនាពេលបច្ចុប្បន្នឱ្យកាន់តែមានភាពសមស្របទៅនឹងរចនាសម្ព័ន្ធ ប្រព័ន្ធអភិបាលកិច្ច តួនាទី មុខងារ និងសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិតាមកម្រិតថ្នាក់នីមួយៗក្នុងការផ្តល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋឱ្យកាន់តែឆាប់រហ័ស មានប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងកាន់តែមានភាពពេញចិត្តពីប្រជាពលរដ្ឋ។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ ក្រសួងមហាផ្ទៃ

**ស្ថាប័នចូលរួមអនុវត្ត** ៖ ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ

### តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ៥.២.៣.

| ល.រ. | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | បញ្ជីប្រភេទសេវារដ្ឋបាលរបស់រដ្ឋបាល ក្រុង ស្រុក ខណ្ឌដែលបានធ្វើបច្ចុប្បន្នភាព | | ១ | | ១ | | ១ |
| ២ | បញ្ជីប្រភេទសេវារដ្ឋបាលរបស់រដ្ឋបាលរាជធានី ខេត្តដែលបានធ្វើបច្ចុប្បន្នភាព | | ១ | | ១ | | ១ |

## សកម្មភាពអាទិភាព ៥.២.៤.៖ ការរៀបចំនីតិវិធីផ្តល់សេវារដ្ឋបាលជាកញ្ចប់តាមយន្តការច្រកចេញចូលតែមួយនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

នាពេលបច្ចុប្បន្ននេះ ការផ្តល់សេវារដ្ឋបាលតាមយន្តការច្រកចេញចូលតែមួយនៅរដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាការប្រមូលផ្តុំសេវារដ្ឋបាលតាមវិស័យនីមួយៗមកផ្តល់នៅកន្លែងតែមួយដោយពុំទាន់បានបង្រួញនីតិវិធី និងកាត់បន្ថយបែបបទនានា ឈានទៅរៀបចំការផ្តល់សេវារដ្ឋបាលជាកញ្ចប់ចំពោះការចេញលិខិតអនុញ្ញាត/អាជ្ញាបណ្ណទាំងឡាយដែលមានការពាក់ព័ន្ធទៅនឹងសមត្ថកិច្ចតាមវិស័យច្រើនផ្សេងៗគ្នានៅឡើយ។ ការបង្រួញនីតិវិធីសម្រាប់ការផ្តល់សេវារដ្ឋបាលជាកញ្ចប់នេះនឹងកាត់បន្ថយសំណុំបែបបទនានាជាច្រើនដែលបង្កលក្ខណៈកាន់តែងាយស្រួលជូនដល់ប្រជាពលរដ្ឋ ជាពិសេសជូនអាជីវករដែលត្រូវការលិខិតអនុញ្ញាតធ្វើអាជីវកម្មពីរដ្ឋបាលថ្នាក់ក្រោមជាតិ។

អាស្រ័យហេតុនេះ ក្នុងការរៀបចំនីតិវិធីការផ្តល់សេវារដ្ឋបាលជាកញ្ចប់នេះ កិច្ចការសំខាន់ៗដែលត្រូវអនុវត្តរួមមាន៖

- ពិនិត្យលើប្រភេទសេវារដ្ឋបាលដែលកំពុងផ្តល់តាមយន្តការច្រកចេញចូលតែមួយនៅរដ្ឋបាលថ្នាក់ក្រោមជាតិនាពេលបច្ចុប្បន្ន ដើម្បីកំណត់សេវារដ្ឋបាលទាំងឡាយណាដែលអាចរៀបចំផ្តល់ជាកញ្ចប់ជូនប្រជាពលរដ្ឋ
- រៀបចំនីតិវិធីសម្រាប់ការផ្តល់សេវារដ្ឋបាលជាកញ្ចប់ដោយត្រូវបង្រួញនីតិវិធី និងកាត់បន្ថយបែបបទដែលពុំចាំបាច់នានា
- ផ្សព្វផ្សាយ និងបណ្តុះបណ្តាលដល់រដ្ឋបាលថ្នាក់ក្រោមជាតិអំពីនីតិវិធីផ្តល់សេវារដ្ឋបាលជាកញ្ចប់តាមយន្តការច្រកចេញចូលតែមួយនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ ក្រសួងមហាផ្ទៃ

**ស្ថាប័នចូលរួមអនុវត្ត** ៖ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ

**តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ៥.២.៤.**

| ល.រ. | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | នីតិវិធីផ្តល់សេវារដ្ឋបាលជាកញ្ចប់ | | សិក្សា | អនុម័ត | អនុវត្ត | | |

## សកម្មភាពអាទិភាព ៥.២.៥.៖ ការសិក្សាលទ្ធភាពបង្កើតមជ្ឈមណ្ឌលផ្តល់សេវារដ្ឋបាល

នាពេលបច្ចុប្បន្ននេះ ទោះបីសេវារដ្ឋបាលមួយចំនួនត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីផ្តល់ជូនប្រជាពលរដ្ឋតាមយន្តការច្រកចេញចូលតែមួយក៏ដោយ ក៏មានសេវារដ្ឋបាលមួយចំនួនផ្សេងទៀតបាននិងកំពុងផ្តល់ជូនប្រជាពលរដ្ឋដោយក្រសួង ស្ថាប័នមានសមត្ថកិច្ចនៅតាមទីកន្លែងផ្សេងៗគ្នា។ ស្ថានភាពបែបនេះនៅមិនទាន់បង្កលក្ខណៈភាពងាយស្រួលជូនប្រជាពលរដ្ឋក្នុងការស្វែងរក និងទទួលបានសេវាទាំងនោះនៅឡើយ។ អាស្រ័យហេតុនេះ ផ្អែកលើមេរៀន និងបទពិសោធន៍នៃការរៀបចំយន្តការផ្តល់សេវារដ្ឋបាលតាមច្រកចេញចូលតែមួយនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងបទពិសោធន៍ល្អៗនៅតាមបណ្តាប្រទេសនានា គួរគប្បីរៀបចំបង្កើតមជ្ឈមណ្ឌលប្រមូលផ្តុំការផ្តល់សេវានានាដែលស្ថិតក្រោមដែនសមត្ថកិច្ចរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិនៅកន្លែងតែមួយ (public service mall) ជាពិសេសនៅតំបន់ទីប្រជុំជនធំៗមួយចំនួន ដូចជារាជធានីភ្នំពេញ ក្រុងកំពង់សោម ក្រុងសៀមរាប ក្រុងបាត់ដំបង ក្រុងកំពង់ចាមជាដើម។ ការរៀបចំបែបនេះនឹងបង្កើននូវប្រសិទ្ធភាពនៃការផ្តល់សេវាជូនប្រជាពលរដ្ឋ ហើយប្រជាពលរដ្ឋនឹងកាន់តែមានភាពងាយស្រួលក្នុងការស្វែងរក និងទទួលបានសេវានានាដែលខ្លួនត្រូវការនៅកន្លែងតែមួយ។

ពាក់ព័ន្ធនឹងកិច្ចការនេះ សកម្មភាពដែលត្រូវរៀបចំ និងអនុវត្ត គឺការសិក្សាលទ្ធភាព និងជម្រើសសមស្របសម្រាប់រៀបចំបង្កើត និងដាក់ឱ្យដំណើរការមជ្ឈមណ្ឌលផ្តល់សេវារដ្ឋបាល (Public Service

Mall) នៅតំបន់ទីប្រជុំជនដែលប្រមូលផ្តុំការផ្តល់សេវាលើគ្រប់វិស័យ ទាំងសេវារដ្ឋបាលដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ក្រសួង ស្ថាប័នថ្នាក់ជាតិ និងសេវារដ្ឋបាលដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅកន្លែងតែមួយ ដើម្បីធ្វើឱ្យប្រជាពលរដ្ឋកាន់តែមានភាពងាយស្រួលក្នុងការស្វែងរក និងទទួលបានសេវារដ្ឋបាលគ្រប់ប្រភេទ និងគ្រប់វិស័យនៅកន្លែងតែមួយ។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ លេខាធិការដ្ឋាន គ.ជ.អ.ប. និងក្រសួងមហាផ្ទៃ

**ស្ថាប័នចូលរួមអនុវត្ត** ៖ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ

**តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ៥.២.៥.**

| ល.រ. | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | របាយការណ៍សិក្សាអំពីលទ្ធភាពបង្កើតមជ្ឈមណ្ឌលផ្តល់សេវាតាមទីប្រជុំជន | | | សិក្សា | អនុម័ត | អនុវត្ត | |

## លទ្ធផលរំពឹងទុក ៥.៣.៖ ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានប្រកបដោយចីរភាពនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងការអភិវឌ្ឍតំបន់ជាប់ព្រំដែនត្រូវបានជំរុញ និងលើកកម្ពស់

ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានក្នុងក្របខ័ណ្ឌនៃ ផអ៥ទី២នេះ សំដៅដល់ដំណើរការនៃកិច្ចសហការរវាងរដ្ឋបាលមូលដ្ឋាន វិស័យឯកជន អង្គការសហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធនានាក្នុងការជំរុញ និងលើកកម្ពស់សកម្មភាពសេដ្ឋកិច្ចមូលដ្ឋានឱ្យមានការរីកចម្រើនក្នុងគោលបំណងការបង្កើតឱកាសការងារ ការបង្កើនប្រាក់ចំណូលរបស់ប្រជាពលរដ្ឋដោយប្រើប្រាស់សក្តានុពលនានាដែលមាននៅតាមរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយឱ្យមានប្រសិទ្ធភាព និងនិរន្តរភាព។

សេដ្ឋកិច្ចមូលដ្ឋាន គឺជាគ្រឹះសំខាន់នៃសេដ្ឋកិច្ចជាតិ។ អាស្រ័យហេតុនេះ ការជំរុញ និងការលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន គឺជាកិច្ចការដ៏មានសារៈសំខាន់ក្នុងចូលរួមអនុវត្តឱ្យសម្រេចបាននូវគោលដៅនៃយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល នោះគឺ (១). ការធានាឱ្យបាននូវកំណើនសេដ្ឋកិច្ច (២). ការបង្កើតឱកាសការងារឱ្យបានកាន់តែច្រើន (៣). ការសម្រេចបាននូវគោលដៅកាត់បន្ថយភាពក្រីក្រ (៤). ការពង្រឹងសមត្ថភាពអភិបាលកិច្ច និងលើកកម្ពស់គុណភាពស្ថាប័ន និង(៥). ការធានាបាននូវចីរភាពនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច។

ផ្អែកតាមការវិវឌ្ឍនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ តាមរយៈការរៀបចំ និងអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិតាមដំណាក់កាលនីមួយៗ បានពង្រឹងឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិកាន់តែមានស្វ័យភាព លទ្ធភាព និងសមត្ថភាពក្នុងការដឹកនាំ ការគ្រប់គ្រង និងការចាត់ចែងមិនត្រឹមតែលើការងាររដ្ឋបាល សុវត្ថិភាពសង្គម និងសណ្តាប់ធ្នាប់សាធារណៈនោះឡើយ

ថែមទាំងការផ្ដល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាននីមួយៗ។

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ មុខងារក្នុងវិស័យនានាជាច្រើនត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ រួមមាន មុខងារផ្ដល់សេវារដ្ឋបាល សេវាចុះបញ្ជីគម្រោងវិនិយោគ និងមុខងារផ្ដល់សេវាសាធារណៈតាមវិស័យនានា ដូចជា មុខងារក្នុងវិស័យសេដ្ឋកិច្ច និងសង្គមកិច្ច (ពាណិជ្ជកម្ម ឧស្សាហកម្ម សិប្បកម្ម ទេសចរណ៍ កសិកម្ម ធនធានទឹក បរិស្ថាន ធនធានធម្មជាតិ សាធារណការនិងដឹកជញ្ជូន រ៉ែ និងថាមពល វប្បធម៌ អប់រំ សុខាភិបាល នគរូបនីយកម្ម ដែនដីនិងសំណង់ វិស័យការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈជាដើម)។

ការផ្ទេរមុខងារតាមវិស័យនានាកាន់តែច្រើនទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ គឺមិនត្រឹមតែបានផ្ដល់សិទ្ធិអំណាច ការទទួលខុសត្រូវកាន់ច្រើនទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនោះឡើយ ថែមទាំងជាការផ្ដល់ឱកាសដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្ដួចផ្ដើមគំនិតថ្មីៗសម្រាប់ជំរុញ និងលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន តាមរយៈការបង្កលក្ខណៈអំណោយផល ការលើកទឹកចិត្ត និងការគាំទ្រដល់ការបង្កើត និងការពង្រីកអាជីវកម្ម សិប្បកម្ម សហគ្រាសខ្នាតតូច មធ្យម សហគមន៍កសិករ ឬសហគមន៍ផលិតផលក្នុងមូលដ្ឋាន ផ្អែកលើសក្ដានុពលដែលមានស្រាប់នៅតាមរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ សំដៅបង្កើតឱកាសការងារ បង្កើតមុខរបរ និងបង្កើនប្រាក់ចំណូលរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាននីមួយៗ។ ក្រៅពីនេះ ការអភិវឌ្ឍតាមតំបន់ព្រំដែនក៏ត្រូវផ្ដោតការយកចិត្តទុកដាក់ ដើម្បីធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិដែលនៅជាប់ព្រំដែនទទួលបានការអភិវឌ្ឍទាំងហេដ្ឋារចនាសម្ព័ន្ធ សកម្មភាពសេដ្ឋកិច្ច និងកិច្ចសហប្រតិបត្តិការជាមួយបណ្ដាប្រទេសជិតខាងប្រកបដោយចីរភាព និងសន្តិភាព។

ដើម្បីសម្រេចបាននូវលទ្ធផលរំពឹងទុកនេះ ផអ៥ទី២ បានគ្រោងឡើងនូវសកម្មភាពអាទិភាពចំនួន **០៦** ដូចខាងក្រោម៖

### សកម្មភាពអាទិភាព ៥.៣.១.៖ ការជំរុញ និងលើកកម្ពស់ការចុះបញ្ជីគម្រោងវិនិយោគដែលមានទុនសមមូល៥លានដុល្លារអាមេរិកចុះ

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពអាទិភាពនេះរួមមាន៖

- ជំរុញការរៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់ការធ្វើប្រតិភូកម្ម និងការរៀបចំសេចក្ដីណែនាំបច្ចេកទេសពីក្រសួង ស្ថាប័នពាក់ព័ន្ធ
- រៀបចំ ផ្សព្វផ្សាយ និងបណ្ដុះបណ្ដាលអំពីគោលការណ៍ និងនីតិវិធីចុះបញ្ជីគម្រោងវិនិយោគដែលមានទុនសមមូល៥លានដុល្លារអាមេរិកចុះជូនដល់អនុគណៈកម្មការវិនិយោគរាជធានី ខេត្ត និងអង្គភាពពាក់ព័ន្ធ និងជំរុញការចុះបញ្ជីតាមប្រព័ន្ធឌីជីថល
- សិក្សា រៀបចំ និងធ្វើបច្ចុប្បន្នភាពព័ត៌មានអំពីសក្ដានុពលសំខាន់ៗដែលមាននៅតាមរដ្ឋបាលរាជធានី ខេត្តសម្រាប់ការផ្សព្វផ្សាយ និងការទាក់ទាញអ្នកវិនិយោគទាំងនៅក្នុងស្រុក និងនៅ

ក្រៅស្រុក

- តាមដាន ត្រួតពិនិត្យ និងគាំទ្រដល់រដ្ឋបាលរាជធានី ខេត្តលើការចុះបញ្ជីគម្រោងវិនិយោគដែលមានទុនសមមូល ៥លានដុល្លារចុះ
- សិក្សាអំពីលទ្ធភាពនៃការធ្វើប្រតិភូកម្មសិទ្ធិអំណាចទៅឱ្យរដ្ឋបាលរាជធានី ខេត្តលើការចុះបញ្ជី និងការចេញវិញ្ញាបណ្ណបត្រដំណើរការក្រុមហ៊ុន សហគ្រាស និងសិប្បកម្មស្របតាមទំហំនៃការចុះបញ្ជីគម្រោងវិនិយោគដែលមានទុនសមមូល៥លានដុល្លារអាមេរិកចុះ។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ ក្រសួងមហាផ្ទៃ លេខាធិការដ្ឋាន គ.ជ.អ.ប. និងរដ្ឋបាលរាជធានី ខេត្ត
**ស្ថាប័នចូលរួមអនុវត្ត** ៖ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងក្រសួង ស្ថាប័ន

**តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ៥.៣.១.**

| ល.រ. | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | សេចក្តីណែនាំស្តីពីគោលការណ៍ និងនីតិវិធីនៃការចុះបញ្ជីគម្រោងវិនិយោគ | សេចក្តីព្រាង | អនុម័ត | | | | |
| ២ | ចំនួនរដ្ឋបាលរាជធានី ខេត្តដែលបានទទួលការបណ្តុះបណ្តាលអំពីគោលការណ៍ និងនីតិវិធីចុះបញ្ជីគម្រោងវិនិយោគ | | ២៥ | | | | |
| ៣ | ប្រព័ន្ធឌីជីថលសម្រាប់ការចុះបញ្ជីគម្រោងវិនិយោគ | សិក្សា | រៀបចំ | | | | |

## សកម្មភាពអាទិភាព ៥.៣.២.៖ ការរៀបចំផែនការយុទ្ធសាស្ត្រស្តីពីការលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានប្រកបដោយចីរភាពនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

នាពេលកន្លងមក រដ្ឋបាលថ្នាក់ក្រោមជាតិបានចូលរួមយ៉ាងសកម្មក្នុងការជំរុញការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន តាមរយៈការប្រើប្រាស់ធនធានឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការសាងសង់គម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច និងមធ្យមនានាដូចជា ការសាងសង់ផ្លូវ ថ្នល់ ស្ពានដើម្បីជួយសម្រួលដល់ការធ្វើដំណើរ និងការដឹកជញ្ជូនផលិតផលរបស់សហគមន៍មកកាន់ទីផ្សារ និងការសាងសង់ប្រព័ន្ធធារាសាស្ត្រសម្រាប់ជួយសម្រួលដល់ការបង្កើនផលិតផលកសិកម្មរបស់ប្រជាកសិករនៅតាមមូលដ្ឋាននានាជាដើម។

ទន្ទឹមគ្នានេះ រដ្ឋបាលថ្នាក់ក្រោមជាតិមួយចំនួនក៏បានចូលរួមអនុវត្តសកម្មភាព/គម្រោងបង្កើនប្រាក់ចំណូល ដូចជាការរៀបចំបង្កើតក្រុមចិញ្ចឹមមាន់ ក្រុមចិញ្ចឹមត្រី ក្រុមដាំបន្លែ ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋដែលបានរៀបចំ និងដាក់ឱ្យអនុវត្តក្នុងក្របខ័ណ្ឌជាគម្រោង ឬកម្មវិធីដាច់ដោយឡែកៗដោយក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធនានា។

ទោះយ៉ាងនេះក្តី ដើម្បីធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានផែនទីបង្ហាញផ្លូវច្បាស់លាស់ក្នុងការជំរុញ និងលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានប្រកបដោយចីរភាព ជាពិសេសការបង្កើតឱកាសការងារ

និងការបង្កើនប្រាក់ចំណូលរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋានក្នុងរយៈពេល៥ឆ្នាំបន្ទាប់នេះត្រូវផ្តោតលើការរៀបចំ និងការអនុវត្តសកម្មភាពសំខាន់ៗមួយចំនួន។

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពអាទិភាពនេះរួមមាន៖

- រៀបចំផែនការយុទ្ធសាស្ត្រស្តីពីការលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានប្រកបដោយចីរភាពនៅរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ជាផែនទីបង្ហាញផ្លូវដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការជំរុញ និងលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ផែនការយុទ្ធសាស្ត្រនេះ ត្រូវផ្តោតលើចំណុចសំខាន់ៗពាក់ព័ន្ធ៖
  - ទស្សនទាននៃការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានប្រកបដោយចីរភាព
  - តួនាទី ភារកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានប្រកបដោយចីរភាព
  - ការប្រើប្រាស់សក្តានុពលដែលមានស្រាប់នៅតាមមូលដ្ឋានសម្រាប់ជំរុញការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានប្រកបចីរភាព
  - ការបង្កើតលក្ខខណ្ឌអំណោយផលដល់វិស័យឯកជនក្នុងការបង្កើត ពង្រឹង និងពង្រីកអាជីវកម្ម សហគ្រាស សិប្បកម្មខ្នាតតូច និងមធ្យមនៅតាមមូលដ្ឋាន
  - ការគាំទ្រគំនិតផ្តួចផ្តើមពាក់ព័ន្ធនឹងការបង្កើតសហគមន៍កសិកម្មទំនើប សហគមន៍ផលិតផលនៅមូលដ្ឋាន និងការផ្លាស់ប្តូរពីការអភិវឌ្ឍសេដ្ឋកិច្ចគ្រួសារទៅជាសេដ្ឋកិច្ចបែបពាណិជ្ជកម្ម
  - តម្រូវការបណ្តុះបណ្តាលយុវជន និងស្ត្រីអំពីជំនាញវិជ្ជាជីវៈ ការគ្រប់គ្រងសហគ្រាស និងអាជីវកម្មខ្នាតតូច និងមធ្យមនៅតាមមូលដ្ឋាន
  - ការរៀបចំវេទិកាពិគ្រោះយោបល់រវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយវិស័យឯកជន អង្គការសង្គមស៊ីវិល សហគមន៍មូលដ្ឋានស្តីពីការលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន
  - ការរៀបចំគោលនយោបាយលើកទឹកចិត្ត និងទាក់ទាញអ្នកវិនិយោគទាំងក្នុង និងក្រៅស្រុក
  - យុទ្ធសាស្ត្រស្វែងរកទីផ្សារ និងការបង្កើតបណ្តាញទីផ្សារសម្រាប់ផលិតផលក្នុងស្រុក។
- ពិនិត្យ និងកែលម្អឯកសារបច្ចេកទេសស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានសម្រាប់ក្រុមប្រឹក្សាក្រុង ស្រុកដែលបានដាក់ចេញកន្លងមកឱ្យស្របតាមផែនការយុទ្ធសាស្ត្រស្តីពីការលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានប្រកបដោយចីរភាព។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ លេខាធិការដ្ឋាន គ.ជ.អ.ប. និងក្រសួងមហាផ្ទៃ

**ស្ថាប័នចូលរួមអនុវត្ត** ៖ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ

**តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ៥.៣.២.**

| ល.រ. | សូចនាករ | ចំណុចដៅ |
|---|---|---|

| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
|---|---|---|---|---|---|---|---|
| ១ | ផែនការយុទ្ធសាស្ត្រស្តីពីការលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចនៅរដ្ឋបាលថ្នាក់ក្រោមជាតិ | | សិក្សា | អនុម័ត | | | |
| ២ | ឯកសារណែនាំបច្ចេកទេសស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចដែលបានកែលម្អ | | | អនុម័ត | | | |

## សកម្មភាពអាទិភាព ៥.៣.៣.៖ ការលើកកម្ពស់ការយល់ដឹងរបស់ក្រុមប្រឹក្សា និងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិអំពីការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានប្រកបដោយចីរភាពនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

បន្ទាប់ពីការរៀបចំ និងដាក់ចេញផែនការយុទ្ធសាស្ត្រស្តីពីការលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានប្រកបដោយចីរភាពនៅរដ្ឋបាលថ្នាក់ក្រោមជាតិ (សកម្មភាព៥.៣.២) ចាំបាច់ត្រូវរៀបចំការផ្សព្វផ្សាយឱ្យបានទូលំទូលាយ ដើម្បីបង្កើនការយល់ដឹងដល់ក្រុមប្រឹក្សា និងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិអំពីទស្សនទាននៃការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន និងតួនាទីសំខាន់របស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការជំរុញការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានប្រកបដោយចីរភាពនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពអាទិភាពនេះរួមមាន៖

- ផ្សព្វផ្សាយដល់ក្រុមប្រឹក្សា និងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិអំពីយុទ្ធសាស្ត្រស្តីពីការលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានប្រកបដោយចីរភាពនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងឯកសារបច្ចេកទេសស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិដែលបានកែសម្រួល
- ជំរុញ និងគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តួចផ្តើមគំនិត ការរៀបចំ និងការអនុវត្តសកម្មភាព ឬគម្រោងនានាពាក់ព័ន្ធនឹងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានប្រកបដោយចីរភាពក្នុងដែនសមត្ថកិច្ចរបស់ខ្លួនស្របតាមផែនការយុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានប្រកបដោយចីរភាព
- សិក្សា ចងក្រង ផ្សព្វផ្សាយ និងចែករំលែកមេរៀន និងបទពិសោធន៍ល្អៗពាក់ព័ន្ធនឹងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានក្នុងចំណោមរដ្ឋបាលថ្នាក់ក្រោមជាតិ។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ លេខាធិការដ្ឋាន គ.ជ.អ.ប. និងក្រសួងមហាផ្ទៃ

**ស្ថាប័នចូលរួមអនុវត្ត** ៖ រដ្ឋបាលថ្នាក់ក្រោមជាតិ វិស័យឯកជន និងអង្គការសង្គមស៊ីវិល

### តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ៥.៣.៣.

| ល.រ. | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | ភាគរយរដ្ឋបាលក្រុង ស្រុកដែលបានអនុវត្តគម្រោងអភិវឌ្ឍន៍សេដ្ឋកិច្ចមូលដ្ឋាន | | | ៥% | ១០% | ២៥% | ៥០% |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ២ | ចំនួនសិក្ខាសាលាចែករំលែកមេរៀន និងបទពិសោធន៍ស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានក្នុងចំណោមរដ្ឋបាល ក្រុង ស្រុក | | | | ១ | ១ | ១ |

## សកម្មភាពអាទិភាព ៥.៣.៤៖ ការសម្របសម្រួល ការកៀរគរដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិលក្នុងការគាំទ្រ និងចូលរួមអនុវត្តផែនការយុទ្ធសាស្ត្រលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន

នាពេលកន្លងមកនេះ រាជរដ្ឋាភិបាល ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលបានសហការគ្នារៀបចំ និងអនុវត្តគម្រោង/កម្មវិធីជាច្រើនដើម្បីគាំទ្រដល់សកម្មភាពអភិវឌ្ឍន៍សេដ្ឋកិច្ចមូលដ្ឋានពាក់ព័ន្ធនឹងការបង្កើតមុខរបរ ការបង្កើនប្រាក់ចំណូល និងការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅតាមសហគមន៍មូលដ្ឋាននានា។ ទោះយ៉ាងនេះក្តី គម្រោង/កម្មវិធីទាំងនេះត្រូវបានរៀបចំ និងអនុវត្តដាច់ដោយឡែកៗពីគ្នា ពុំទាន់មានលក្ខណៈជាប្រព័ន្ធដែលធានាដល់ការលើកកម្ពស់ការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅឡើយ។ ក្នុងន័យនេះ ដើម្បីធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានលទ្ធភាព សមត្ថភាព និងមានការទទួលខុសត្រូវខ្ពស់ក្នុងការជំរុញការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានប្រកបដោយចីរភាពក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ចាំបាច់ត្រូវមានការសម្រួលសម្រួល ការកៀរគរ ការគាំទ្រ និងការចូលរួមពីដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រស្តីពីការលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានប្រកបដោយនិរន្តរភាពនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពអាទិភាពនេះរួមមាន៖

- ផ្សព្វផ្សាយដល់ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិលពាក់ព័ន្ធនានាអំពីយុទ្ធសាស្ត្រស្តីពីការលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានប្រកបដោយចីរភាពនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីកៀរគរការចូលរួម និងគាំទ្រពីដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលក្នុងការជំរុញ និងគាំទ្រការអនុវត្តផែនការយុទ្ធសាស្ត្រនេះ
- សម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលក្នុងការកៀរគរការចូលរួម និងការគាំទ្រដល់ការអនុវត្តផែនការយុទ្ធសាស្ត្រពីការលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានប្រកបដោយចីរភាពនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានធនធាន និងមានភាពម្ចាស់ការក្នុងការជំរុញការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានប្រកបដោយចីរភាព។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ លេខាធិការដ្ឋាន គ.ជ.អ.ប. ក្រសួងមហាផ្ទៃ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

**ស្ថាប័នចូលរួមអនុវត្ត** ៖ ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល

### តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ៥.៣.៤.

| ល.រ. | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | ចំនួនស្ថាប័នដៃគូអភិវឌ្ឍន៍ដែលបានគាំទ្រដល់ការអនុវត្តផែនការយុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន | | | | ២ | ៤ | ៥ |

### សកម្មភាពអាទិភាព ៥.៣.៥៖ ការជំរុញ និងការលើកទឹកចិត្តវិស័យឯកជនក្នុងការលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន

វិស័យឯកជន គឺជាតួអង្គដ៏សំខាន់ដែលមិនអាចខ្វះបានក្នុងការចូលរួមចំណែកជំរុញការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន។ ការវិនិយោគរបស់ផ្នែកឯកជនក្នុងវិស័យផលិតកម្ម កសិកម្ម សេវាកម្ម ទេសចរណ៍ ការបង្កើតមូលដ្ឋានអាជីវកម្ម និងសហគ្រាសនានា គឺជាការបង្កើតការងារសម្រាប់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន។ ទន្ទឹមគ្នានេះ តាមរយៈការវិនិយោគរបស់ផ្នែកឯកជនក៏នឹងនាំមកនូវបច្ចេកវិទ្យា និងចំណេះដឹងថ្មីៗប្រកបដោយនវានុវត្តន៍សម្រាប់ការជំរុញការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានឱ្យមានការរីកចម្រើនឆាប់រហ័ស។

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពអាទិភាពនេះរួមមាន៖

- ជំរុញឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរៀបចំចងក្រង និងធ្វើបច្ចុប្បន្នភាពជាប្រចាំនូវទិន្នន័យមូលដ្ឋានអាជីវកម្ម សិប្បកម្ម កសិកម្ម សេវាកម្ម និងសហគមន៍ផលិតនានាដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីប្រើប្រាស់ក្នុងបំណងផ្តល់ការគាំទ្រដល់ផ្នែកឯកជនក្នុងការជំរុញ និងពង្រីកការវិនិយោគលើអាជីវកម្មរបស់ខ្លួនឱ្យកាន់តែមានភាពរីកចម្រើន និងបង្កើតការងារនៅមូលដ្ឋាន
- ជំរុញរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការរៀបចំ និងអនុវត្តគោលនយោបាយលើកទឹកចិត្ត បង្កើនភាពជឿជាក់ និងបង្កបរិយាកាសអំណោយផល ដើម្បីទាក់ទាញអ្នកវិនិយោគផ្នែកឯកជនឱ្យមកវិនិយោគលើអាជីវកម្មតាមវិស័យនានាដែលមានសក្តានុពលនៅតាមមូលដ្ឋាន និងផ្តល់សេវាសាធារណៈក្នុងភាពជាដៃគូជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ (PPP)។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ លេខាធិការដ្ឋាន គ.ជ.អ.ប. ក្រសួងមហាផ្ទៃ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
**ស្ថាប័នចូលរួមអនុវត្ត** ៖ ក្រសួង ស្ថាប័ន និងវិស័យឯកជន

**តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ៥.៣.៥.**

| ល.រ. | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | ភាគរយរដ្ឋបាលក្រុង ស្រុកដែលបានធ្វើបច្ចុប្បន្នភាពទិន្នន័យមូលដ្ឋានអាជីវកម្មប្រចាំឆ្នាំ | | ៥០% | ៧០% | ១០០% | ១០០% | ១០០% |

### សកម្មភាពអាទិភាព ៥.៣.៦៖ ការរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍតាមតំបន់ជាប់ព្រំដែន

ការអភិវឌ្ឍតាមតំបន់ជាប់ព្រំដែន គឺជាកិច្ចការជាយុទ្ធសាស្ត្រដ៏មានសារៈសំខាន់មួយដែលចាំបាច់ត្រូវរៀបចំឱ្យមានផែនការយុទ្ធសាស្ត្រច្បាស់លាស់សម្រាប់ធ្វើជាមូលដ្ឋានក្នុងការរៀបចំ និងកសាងតំបន់ព្រំដែនជាប់ជាមួយបណ្តាប្រទេសជិតខាងដែលធានាបាននូវសុខសន្តិភាព កិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍប្រកបដោយចីរភាព។

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពអាទិភាពនេះរួមមាន៖

- សិក្សា និងរៀបចំផែនការយុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍតំបន់ជាប់ព្រំដែនសម្រាប់ធ្វើជាផែនទី

បង្ហាញផ្លូវដល់ការរៀបចំ និងកសាងតំបន់ជាប់ព្រំដែនដែលធានាដល់ការរក្សាសុខសន្តិភាព កិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍប្រកបដោយចីរភាព។ ការរៀបចំផែនការយុទ្ធសាស្ត្រនេះ ត្រូវមានការពិគ្រោះយោបល់ជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ ក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធនានា

- រៀបចំផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្តផែនការយុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍតំបន់ជាប់ព្រំដែនឱ្យបានទូលំទូលាយដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធ
- កៀរគរការគាំទ្រ ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃ ដើម្បីធានាឱ្យផែនការយុទ្ធសាស្ត្រនេះមានការចូលរួមគាំទ្រ និងអនុវត្តដោយក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ លេខាធិការដ្ឋាន គ.ជ.អ.ប. និងក្រសួងមហាផ្ទៃ

**ស្ថាប័នចូលរួមអនុវត្ត** ៖ ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងដៃគូអភិវឌ្ឍន៍

**តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ៥.៣.៦.**

| ល.រ. | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | ផែនការយុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍតំបន់ជាប់ព្រំដែន | | | សិក្សា | អនុម័ត | | |
| ២ | សិក្ខាសាលាផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍតំបន់ជាប់ព្រំដែន | | | | ១ | | |
| ៣ | របាយការណ៍វាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍតំបន់ជាប់ព្រំដែន | | | | | | អនុម័ត |

### លទ្ធផលរំពឹងទុក ៥.៤.៖ ភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រងហានិភ័យពីគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា និងកិច្ចគាំពារសង្គម ត្រូវបានបញ្ជ្រាបទៅក្នុងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

ទោះបីការបញ្ជ្រាបភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងហានិភ័យពីគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានាទៅក្នុងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានអនុវត្តនៅក្នុងអំឡុងពេល ជអ៥ទី១ ក៏ដោយ ក៏កិច្ចការដ៏មានសារៈសំខាន់នេះនៅពុំទាន់បានរៀបចំ និងដាក់ឱ្យអនុវត្តក្នុងលក្ខណៈជាប្រព័ន្ធនៅក្នុងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យបានទូលំទូលាយនៅឡើយ ដែលប្រការនេះចាំបាច់ត្រូវបន្តជំរុញ និងរៀបចំអនុវត្តឱ្យបានពេញលេញនៅក្នុងអំឡុងពេលនៃជអ៥ទី២បន្តទៀត។

ទន្ទឹមគ្នានេះ ផែនការយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១របស់រាជរដ្ឋាភិបាលអាណត្តិទី៧ បានផ្តោតលើការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមឱ្យកាន់តែមានភាពធន់ និងរក្សាភាពទន់ភ្លន់ក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ គ្រោះអាសន្ន និងវិបត្តិនានា ព្រមទាំងឆ្លើយតបទៅនឹងការវិវឌ្ឍនៃកត្តា

សេដ្ឋកិច្ច កត្តាសង្គម និងកត្តាប្រជាសាស្ត្រ សំដៅផ្តល់ផលប្រយោជន៍ជូនប្រជាពលរដ្ឋដោយឈរលើស្មារតី "**មិនបោះបង់ពលរដ្ឋណាម្នាក់**"។ ក្នុងមុខងារអភិបាលកិច្ចនៃប្រព័ន្ធគាំពារសង្គម រដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាស្ថាប័នប្រតិបត្តិករដ៏សំខាន់មួយក្នុងចំណោមស្ថាប័នពាក់ព័ន្ធនានា។ ក្នុងន័យនេះ ការពង្រឹងតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការចូលរួមអនុវត្តប្រព័ន្ធគាំពារសង្គម គឺជាកិច្ចការដែលត្រូវផ្តោតការយកចិត្តទុកដាក់នៅក្នុងអំឡុងពេលនៃ ផអ៥ទី២ នេះផងដែរ។

ដើម្បីសម្រេចបាននូវលទ្ធផលរំពឹងទុកនេះ ផអ៥ទី២ បានគ្រោងឡើងនូវសកម្មភាពអាទិភាពចំនួន ០២ ដូចខាងក្រោម៖

**សកម្មភាពអាទិភាព ៥.៤.១.៖ ការរៀបចំផែនការយុទ្ធសាស្ត្រស្តីពីការបញ្ជ្រាបភាពធន់នឹងការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងហានិភ័យពីគ្រោះមហន្តរាយ និងជំងឺកាចសាហាវនានានៅរដ្ឋបាលថ្នាក់ក្រោមជាតិ**

ទោះបីបញ្ហាប្រឈមដែលកើតឡើងដោយសារការប្រែប្រួលអាកាសធាតុ ត្រូវបានទទួលស្គាល់ថាជាបញ្ហាប្រឈមដែលត្រូវមានការយកចិត្តទុកដាក់ដោះស្រាយក៏ដោយ ក៏បច្ចុប្បន្ននេះ រដ្ឋបាលថ្នាក់ក្រោមជាតិពុំទាន់មានការណែនាំដែលមានលក្ខណៈជាប្រព័ន្ធសម្រាប់ដោះស្រាយ និងកាត់បន្ថយហានិភ័យនានាដែលកើតឡើងដោយការប្រែប្រួលអាកាសធាតុនៅក្នុងប្រព័ន្ធគ្រប់គ្រងការងារ ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗឡើយ។ អាស្រ័យហេតុនេះ ក្នុងរយៈពេល៥ឆ្នាំបន្ទាប់ ចាំបាច់ត្រូវរៀបចំ និងដាក់ឱ្យអនុវត្តនូវផែនការយុទ្ធសាស្ត្រស្តីពីការបញ្ជ្រាបភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រងហានិភ័យពីគ្រោះមហន្តរាយ និងជំងឺកាចសាហាវនានា ដើម្បីផ្តល់ផែនទីបង្ហាញផ្លូវដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពអាទិភាពនេះរួមមាន៖

- សិក្សា និងរៀបចំផែនការយុទ្ធសាស្ត្រស្តីពីការបញ្ជ្រាបភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រងហានិភ័យពីគ្រោះមហន្តរាយ និងជំងឺកាចសាហាវនានាទៅក្នុងប្រព័ន្ធគ្រប់គ្រងការងារ ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្តផែនការយុទ្ធសាស្ត្រស្តីពីការបញ្ជ្រាបភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រងហានិភ័យពីគ្រោះមហន្តរាយ និងជំងឺកាចសាហាវនានាទៅក្នុងប្រព័ន្ធគ្រប់គ្រងការងារ ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- តាមដាន ត្រួតពិនិត្យ និងការគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រស្តីពីការបញ្ជ្រាបភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រងហានិភ័យពីគ្រោះមហន្តរាយ និងជំងឺកាចសាហាវនានាទៅក្នុងប្រព័ន្ធគ្រប់គ្រងការងារ ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ លេខាធិការដ្ឋាន គ.ជ.អ.ប.

**ស្ថាប័នចូលរួមអនុវត្ត** ៖ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ

**តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ៥.៤.១.**

| ល.រ. | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | ផែនការយុទ្ធសាស្ត្រស្តីពីការបញ្ជ្រាបភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ | | អនុម័ត | | | | |

## សកម្មភាពអាទិភាព ៥.៤.២.៖ ការពង្រឹង និងការជំរុញការអនុវត្តបទដ្ឋានបច្ចេកទេសសម្រាប់ការផ្តល់សេវាដែលមានភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ

ក្នុងអំឡុងនៃ ផអ៥ទី១ បទដ្ឋានបច្ចេកទេសសម្រាប់ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធដែលធានាឱ្យមានភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ និងបទដ្ឋានបច្ចេកទេសស្តីពីការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុក្នុងសកម្មភាពកសិកម្មត្រូវបានពិនិត្យ កែលម្អ និងដាក់ឱ្យអនុវត្តនៅតាមរដ្ឋបាលថ្នាក់ក្រោមជាតិ។

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពអាទិភាពនេះរួមមាន៖

- គាំទ្រ និងជំរុញរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការរៀបចំ និងអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធ និងសកម្មភាពក្នុងវិស័យនានាស្របតាមបទដ្ឋានបច្ចេកទេសពាក់ព័ន្ធនឹងភាពធន់ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ
- កៀរគរធនធានហិរញ្ញវត្ថុ និងបច្ចេកទេសពីដៃគូអភិវឌ្ឍន៍ និងស្ថាប័នពាក់ព័ន្ធនានា ដើម្បីគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការរៀបចំ និងអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធ និងសកម្មភាពក្នុងវិស័យនានាដែលធានាឱ្យមានភាពធន់ និងការបន្សាំនៅនឹងការប្រែប្រួលអាកាសធាតុ។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ លេខាធិការដ្ឋាន គ.ជ.អ.ប. ក្រសួងមហាផ្ទៃ និងក្រសួង ស្ថាប័ន

**ស្ថាប័នចូលរួមអនុវត្ត** ៖ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ

**តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ៥.៤.២.**

| ល.រ | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | ភាគរយរដ្ឋបាលក្រុង ស្រុកដែលបានរៀបចំ និងអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធដែលមានភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ | | | ៣០% | ៥០% | ៧០% | ៧០% |

## សកម្មភាពអាទិភាព ៥.៤.៣.៖ ការពង្រឹងតួនាទី និងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការចូលរួមអនុវត្តប្រព័ន្ធគាំពារសង្គម

នាពេលកន្លងមក រដ្ឋបាលថ្នាក់ក្រោមជាតិបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងដំណើរការគ្រប់គ្រងចាត់ចែងប្រព័ន្ធគាំពារសង្គម ជាពិសេសកម្មវិធីជំនួយសង្គម ដូចជាចូលរួមកំណត់អត្តសញ្ញាណក្រុមពលរដ្ឋ

គោលដៅនៃប្រព័ន្ធគាំពារសង្គម រួមមានគ្រួសារក្រីក្រ គ្រួសាររងហានិភ័យ ជនងាយរងគ្រោះ បុគ្គលបម្រើការក្នុងសេវាកំសាន្តទេសចរណ៍នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ ការបើកផ្តល់សាច់ប្រាក់ ការផ្សព្វផ្សាយ និងការបញ្ជ្រាបចំណេះដឹងអំពីប្រព័ន្ធគាំពារសង្គម ជាដើម។

ទោះយ៉ាងនេះក្តី ភាពសកម្មនៃការចូលរួមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងដំណើរការគ្រប់គ្រងចាត់ចែងប្រព័ន្ធគាំពារសង្គមនៅមានភាពខុសៗគ្នាពីតំបន់មួយទៅតំបន់មួយទៀតដោយអាស្រ័យលើកត្តាធនធានមនុស្ស ធនធានហិរញ្ញវត្ថុ និងភាពច្បាស់លាស់នៃទំនាក់ទំនងការងាររវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គភាពមានសមត្ថកិច្ចពាក់ព័ន្ធនានា។

ផ្អែកលើស្ថានភាពនេះ ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម (២០២៤-២០៣៥) បានផ្តល់ការតម្រង់ទិសដល់ការពង្រឹងតួនាទី និងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការចូលរួមអនុវត្តប្រព័ន្ធគាំពារសង្គមដោយផ្តោតលើ (១). ការអភិវឌ្ឍសមត្ថភាព (២). ការបែងចែកតួនាទី ការទទួលខុសត្រូវ និងទំនាក់ទំនងការងារឱ្យច្បាស់លាស់ក្នុងចំណោមរដ្ឋបាលថ្នាក់ក្រោមជាតិ និង (៣). ការលើកកម្ពស់ឌីជីថលូបនីយកម្មនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាដល់ការអនុវត្តកម្មវិធីកិច្ចគាំពារសង្គមនៅតាមមូលដ្ឋាននីមួយៗប្រកបដោយប្រសិទ្ធភាព។

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពអាទិភាពនេះ រួមមាន៖

- សិក្សាពិនិត្យមើលឡើងវិញនូវក្របខ័ណ្ឌច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដើម្បីកំណត់តួនាទី ការទទួលខុសត្រូវ និងទំនាក់ទំនងការងាររវាងរដ្ឋបាលថ្នាក់ក្រោមជាតិតាមកម្រិតថ្នាក់នីមួយៗ (ថ្នាក់រាជធានី ខេត្ត ថ្នាក់ក្រុង ស្រុក ខណ្ឌ និងថ្នាក់ឃុំ សង្កាត់) ក្នុងការចូលរួមអនុវត្តប្រព័ន្ធ/កម្មវិធីគាំពារសង្គម
- រៀបចំ ផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្តលិខិតបទដ្ឋានគតិយុត្ត ដើម្បីកំណត់តួនាទី ការទទួលខុសត្រូវ និងទំនាក់ទំនងការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តប្រព័ន្ធ/កម្មវិធីគាំពារសង្គម
- គាំទ្របច្ចេកទេស ការអភិវឌ្ឍសមត្ថភាព និងធនធានហិរញ្ញវត្ថុ ដើម្បីធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានទាំងសមត្ថភាព និងលទ្ធភាពគ្រប់គ្រាន់ក្នុងការអនុវត្តប្រព័ន្ធ/កម្មវិធីគាំពារសង្គម
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃឱ្យបានទៀងទាត់ ដើម្បីធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិអនុវត្តតួនាទី និងការទទួលខុសត្រូវរបស់ខ្លួនលើការអនុវត្តប្រព័ន្ធ/កម្មវិធីគាំពារសង្គមបានត្រឹមត្រូវតាមគោលការណ៍ បែបបទ និងនីតិវិធីដែលបានកំណត់ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។

**ស្ថាប័នទទួលខុសត្រូវអនុវត្ត** ៖ ក្រសួងមហាផ្ទៃ លេខាធិការដ្ឋាន គ.ជ.អ.ប. និងក្រុមប្រឹក្សាជាតិគាំពារសង្គម
**ស្ថាប័នចូលរួមអនុវត្ត** ៖ ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងដៃគូអភិវឌ្ឍន៍

**តារាងសូចនាករ និងចំណុចដៅនៃសកម្មភាពជាអាទិភាព ៥.៤.៤.**

| ល.រ. | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| ១ | របាយការណ៍សិក្សាអំពីតួនាទី និងការទទួលខុសត្រូវរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការចូលរួមអនុវត្តប្រព័ន្ធគាំពារសង្គម | | សិក្សា | អនុម័ត | | | |
| ២ | លិខិតបទដ្ឋានគតិយុត្តស្តីពីការកំណត់តួនាទី ការទទួលខុសត្រូវ និងទំនាក់ទំនងការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការចូលរួមអនុវត្តប្រព័ន្ធគាំពារសង្គម | | | អនុម័ត | | | |

# ជំពូកទី៣

# ការគ្រប់គ្រង និងការអនុវត្ត ផអ៥ទី២

## ១. ក្របខ័ណ្ឌសម្រាប់ការគ្រប់គ្រង និងការអនុវត្ត

ការគ្រប់គ្រង និងការអនុវត្ត ផអ៥ទី២ ស្ថិតក្រោមការដឹកនាំ និងសម្របសម្រួលរបស់ គ.ជ.អ.ប. ដោយមានលេខាធិការដ្ឋាន គ.ជ.អ.ប. ជាសេនាធិការ។

ការអនុវត្ត ផអ៥ទី២ ត្រូវធ្វើឡើងតាមរយៈផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ (ផ.ស.ថ.) របស់ គ.ជ.អ.ប. ដែលត្រូវបានរៀបចំដោយមានការចូលរួមពីស្ថាប័នអនុវត្ត និងភាគីពាក់ព័ន្ធនានា។

លេខាធិការដ្ឋាន គ.ជ.អ.ប. ទទួលខុសត្រូវជួយ គ.ជ.អ.ប. ក្នុងការគ្រប់គ្រង ការសម្របសម្រួល និងការតាមដានត្រួតពិនិត្យជាប្រចាំលើការអនុវត្ត ផអ៥ទី២ រួមបញ្ចូលទាំងការរៀបចំ ផ.ស.ថ. និងការរៀបចំរបាយការណ៍ស្តីពីការអនុវត្ត ផអ៥ទី២។ លេខាធិការដ្ឋាន គ.ជ.អ.ប. ក៏មានតួនាទីសម្របសម្រួល និងផ្តល់ការគាំទ្រដល់ស្ថាប័នអនុវត្ត និងភាគីពាក់ព័ន្ធនានាក្នុងការអនុវត្ត ផអ៥ទី២ និងការអនុវត្ត ផ.ស.ថ. ផងដែរ។

ស្ថាប័នអនុវត្តនៃ ផអ៥ទី២ រួមមាន លេខាធិការដ្ឋាន គ.ជ.អ.ប. ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងដៃគូពាក់ព័ន្ធនានា។ ស្ថាប័នអនុវត្តនីមួយៗត្រូវរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ខ្លួនដោយផ្អែកតាមលទ្ធផលរំពឹងទុក សកម្មភាពជាអាទិភាព និងក្របខ័ណ្ឌលទ្ធផលនៃ ផអ៥ទី២ និងគម្រោង កម្មវិធីពាក់ព័ន្ធនានា។ លេខាធិការដ្ឋាន គ.ជ.អ.ប. ត្រូវបូកសរុប និងដាក់បញ្ចូលនូវផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ស្ថាប័នអនុវត្តនានា ដើម្បីបង្កើតជាផែនការសកម្មភាព និងថវិការួមមួយរបស់ គ.ជ.អ.ប.។

ស្ថាប័នអនុវត្តនីមួយៗ ត្រូវវិភាជថវិកាសម្រាប់អនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ខ្លួនដោយប្រើប្រាស់ថវិការបស់រដ្ឋ និងថវិកាដែលអាចមានការគាំទ្រពីដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលនានាសម្រាប់សកម្មភាពជាក់លាក់នានា ដែលពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់ស្ថាប័នអនុវត្តដូចបានកំណត់ក្នុង ផអ៥ទី២។ ដូច្នេះ លេខាធិការដ្ឋាន គ.ជ.អ.ប. ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវធ្វើការបញ្ចូលសកម្មភាពនានានៃ ផអ៥ទី២ ដែលជាការទទួលខុសត្រូវរបស់ខ្លួនទៅក្នុងផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងថវិកាប្រចាំឆ្នាំរបស់ខ្លួន។

ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ស្ថាប័នអនុវត្តត្រូវរៀបចំដោយផ្អែកលើគម្រោងថវិកាប្រចាំឆ្នាំរបស់ស្ថាប័នអនុវត្ត និងធនធាននានាដែលអាចទទួលបានការគាំទ្រពីដៃគូអភិវឌ្ឍន៍ដោយមានការកំណត់ជាក់លាក់ និងបរិយាយលម្អិតអំពីលទ្ធផលរំពឹងទុក សកម្មភាពជាអាទិភាព សូចនាករ និងចំណុចដៅ ផែនការចំណាយ និងក្របខ័ណ្ឌពេលវេលា។

លេខាធិការដ្ឋាន គ.ជ.អ.ប. ត្រូវកៀរគរធនធានពីដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល វិស័យឯកជន និងភាគីពាក់ព័ន្ធនានាសម្រាប់អនុវត្តសកម្មភាពអាទិភាពនានានៃ ផអ៥ទី២។ ធនធានទាំងនេះ ត្រូវប្រើប្រាស់សម្រាប់គាំទ្រសកម្មភាពជាអាទិភាពមួយចំនួន មានដូចជា ៖

- ជំនួយបច្ចេកទេស ដើម្បីជួយលេខាធិការដ្ឋាន គ.ជ.អ.ប. និងស្ថាប័នអនុវត្តនានា
- សកម្មភាពនានានៃការអភិវឌ្ឍសមត្ថភាព
- ការរៀបចំគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត និងសេចក្តីណែនាំបច្ចេកទេសនានាដែលពាក់ព័ន្ធនឹងការអនុវត្តមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ការពិនិត្យ ការវាយតម្លៃ និងការអង្កេតនានាស្តីពីការអនុវត្ត ផអ៥ទី២
- ការគាំទ្រគម្រោងវិនិយោគនានាផ្នែកហេដ្ឋារចនាសម្ព័ន្ធ និងសេវាសង្គមនៅមូលដ្ឋាន
- ការអនុវត្តសកម្មភាពនានារបស់ស្ថាប័នមិនមែនរដ្ឋាភិបាល (ឧទាហរណ៍ សមាគមក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ...)
- សកម្មភាពជាអាទិភាពផ្សេងទៀត។

លេខាធិការដ្ឋាន គ.ជ.អ.ប. ត្រូវប្រើប្រាស់ធនធានទាំងនេះ ស្របតាមអនុស្សារណៈយោគយល់ ឬកិច្ចព្រមព្រៀងរវាងលេខាធិការដ្ឋាន គ.ជ.អ.ប. ជាមួយដៃគូអភិវឌ្ឍន៍ទាំងនោះ។

គម្រោង/កម្មវិធីដែលទទួលបានហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍គឺជា ៖

- គម្រោងនៃ ផអ៥ទី២ ដូចជា គម្រោងដែលផ្តល់ហិរញ្ញប្បទានសម្រាប់គាំទ្រលទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាពនានាដែលបានកំណត់ក្នុង ផអ៥ទី២ ឬ
- គម្រោង ឬកម្មវិធីដាច់ដោយឡែកនានាដែលផ្តល់ហិរញ្ញប្បទានសម្រាប់គាំទ្រលទ្ធផលរំពឹងទុក និងសកម្មភាពជាក់លាក់ផ្សេងទៀតដែលស្ថិតនៅក្រៅ ផអ៥ទី២ ប៉ុន្តែលទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាពជាក់លាក់ទាំងនោះរួមចំណែកក្នុងការសម្រេចបានសមិទ្ធផល និងគោលដៅនៃ ផអ៥ទី២។

## ២. ការត្រួតពិនិត្យ និងការវាយតម្លៃ ផអ៥ទី២

លេខាធិការដ្ឋាន គ.ជ.អ.ប. ទទួលខុសត្រូវក្នុងការត្រួតពិនិត្យ និងវាយតម្លៃ ផអ៥ទី២ ដោយត្រូវវាស់វែងលើវឌ្ឍនភាពនៃការអនុវត្តធៀបជាមួយនឹងលទ្ធផលនានាដែលកំណត់ក្នុង ផអ៥ទី២ ព្រមទាំងត្រួតពិនិត្យលើសមត្ថភាព ប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព គណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងផលប៉ះពាល់លើសុខុមាលភាពរបស់ប្រជាពលរដ្ឋ។

### ២.១. ការត្រួតពិនិត្យ និងការរៀបចំរបាយការណ៍អនុវត្ត ផអ៥ទី២

ដើម្បីជាមូលដ្ឋានក្នុងការវាស់វែងវឌ្ឍនភាពនៃ ផអ៥ទី២ ការអនុវត្ត ផ.ស.ថ. ត្រូវត្រួតពិនិត្យ និងរាយការណ៍ជាប្រចាំ។ ស្ថាប័នអនុវត្តទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិទទួលខុសត្រូវក្នុងការតាមដានត្រួតពិនិត្យ និងរាយការណ៍អំពីស្ថានភាពនៃការអនុវត្ត ផ.ស.ថ. ជាប្រចាំជូនលេខាធិការដ្ឋាន គ.ជ.អ.ប.

តាមរយៈប្រព័ន្ធទិន្នន័យមូលដ្ឋាននៃ ផ.ស.ថ. និងតាមរយៈមធ្យោបាយផ្សេងៗទៀត ដើម្បីផ្តល់លទ្ធភាពដល់លេខាធិការដ្ឋាន គ.ជ.អ.ប. ក្នុងការបូកសរុប និងរៀបចំរបាយការណ៍ជូន គ.ជ.អ.ប.។ លេខាធិការដ្ឋាន គ.ជ.អ.ប. ត្រូវរៀបចំកិច្ចប្រជុំជាទៀងទាត់ជាមួយស្ថាប័នអនុវត្តនានា ដើម្បីពិនិត្យមើលលើវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្ត ផ.ស.ថ. ប្រចាំឆ្នាំ និងរៀបចំកិច្ចប្រជុំជាមួយដៃគូអភិវឌ្ឍន៍នានា ដើម្បីធ្វើបច្ចុប្បន្នភាព និងពិភាក្សាដោះស្រាយបញ្ហាប្រឈមនានានៃការអនុវត្ត ផ.ស.ថ. ប្រចាំឆ្នាំផងដែរ។

គ.ជ.អ.ប. ត្រូវរៀបចំរបាយការណ៍ស្តីពីការអនុវត្តកម្មវិធីជាតិ ដើម្បីដាក់ជូនរាជរដ្ឋាភិបាលយ៉ាងតិចរៀងរាល់ ៦ខែម្តង។

នៅចុង ផអ៥ទី២ លេខាធិការដ្ឋាន គ.ជ.អ.ប. ត្រូវរៀបចំរបាយការណ៍ស្តីពីការអនុវត្ត ផអ៥ទី២ ជូន គ.ជ.អ.ប. និងផ្សព្វផ្សាយរបាយការណ៍នេះឱ្យបានទូលំទូលាយតាមរយៈមធ្យោបាយនានា ដូចជា គេហទំព័រ និងបណ្តាញព័ត៌មានសង្គម គ.ជ.អ.ប. ឬមធ្យោបាយផ្សេងៗទៀត។

## ២.២. ការវាយតម្លៃនៃការអនុវត្ត ផអ៥ទី២

ទន្ទឹមនេះ ដើម្បីធានាដល់ការត្រួតពិនិត្យ និងការវាយតម្លៃ ផអ៥ទី២ ឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ លេខាធិការដ្ឋាន គ.ជ.អ.ប. ត្រូវសម្របសម្រួល និងសហការជាមួយស្ថាប័នពាក់ព័ន្ធនានាក្នុងការរៀបចំ និងអនុវត្តការអង្កេត ការវាយតម្លៃ និងការសិក្សាស្រាវជ្រាវមួយចំនួនបន្ថែមទៀត ដូចជាការវាយតម្លៃប្រចាំឆ្នាំ ការវាយតម្លៃបញ្ចប់ ផអ៥ទី២ ការវាយតម្លៃបញ្ចប់ កជទី២ និងការវាយតម្លៃផលប៉ះពាល់មានដូចជា ការអង្កេតអភិបាលកិច្ច ការអង្កេតសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ការវាយតម្លៃគោលនយោបាយ ព្រមទាំងការសិក្សាដែលមានលក្ខណៈជាការវាយតម្លៃ និងការស្រាវជ្រាវនានា។ លើសពីនេះ របាយការណ៍នៃការអង្កេត ការវាយតម្លៃ ការសិក្សា និងការស្រាវជ្រាវត្រូវរៀបចំ និងផ្សព្វផ្សាយយ៉ាងទូលំទូលាយស្របតាមគោលនយោបាយ និងលិខិតបទដ្ឋាននានាស្តីពីការផ្សព្វផ្សាយព័ត៌មានរបស់ គ.ជ.អ.ប.។

### ក. ការវាយតម្លៃ ផអ៥ទី២ ប្រចាំឆ្នាំ

ផ្អែកតាមរបាយការណ៍របស់ស្ថាប័នអនុវត្តស្តីពីការអនុវត្ត ផ.ស.ថ. លេខាធិការដ្ឋាន គ.ជ.អ.ប. ត្រូវរៀបចំការវាយតម្លៃអំពីវឌ្ឍនភាពនៃការអនុវត្ត ផអ៥ទី២ ធៀបនឹងលទ្ធផលរំពឹងទុក និងសកម្មភាពរួមទាំងសូចនាករ និងចំណុចដៅដែលបានកំណត់ ព្រមទាំងទិន្នន័យដើមគ្រានានានៃ កជទី២។ បន្ទាប់មកត្រូវធ្វើបច្ចុប្បន្នភាពនៃការអនុវត្ត ផអ៥ទី២ តាមការចាំបាច់។

### ខ. ការវាយតម្លៃបញ្ចប់ កជទី២

ការវាយតម្លៃបញ្ចប់ កជទី២ ឬផអ៥ទី២ ត្រូវអនុវត្តនៅក្នុងអំឡុងឆ្នាំទី៥នៃ ផអ៥ទី២ ក្នុងគោលបំណងវាយតម្លៃអំពីសមិទ្ធផល បញ្ហាប្រឈម និងមេរៀនបទពិសោធន៍នៃក្នុងការអនុវត្ត កជទី២ ធៀបនឹងក្របខ័ណ្ឌលទ្ធផលដែលបានកំណត់។

គ. ការវាយតម្លៃផលប៉ះពាល់សំខាន់ៗ

នៅក្នុងអំឡុងពេលនៃ ផអ៥ទី២ ការវាយតម្លៃផលប៉ះពាល់សំខាន់ៗមួយចំនួនត្រូវអនុវត្ត ដើម្បីវាស់វែងលទ្ធផលសំខាន់ៗដែលបានកំណត់នៅក្នុង ផអ៥ទី២ រួមមាន ៖

**ការអង្កេតអភិបាលកិច្ច**

ការអង្កេតអភិបាលកិច្ច គឺជាការសិក្សាតាមដានអំពីការផ្លាស់ប្តូរនៃសន្ទស្សន៍គន្លឹះៗមួយចំនួនពាក់ព័ន្ធនឹងអភិបាលកិច្ចដូចជា ការផ្តល់សេវា ការឆ្លើយតប ការចូលរួមរបស់ប្រជាពលរដ្ឋ តម្លាភាព និងគណនេយ្យភាពធៀបនឹងទិន្នន័យដើមគ្រានៃអភិបាលកិច្ចដែលបានកំណត់ក្នុងឆ្នាំ២០២៤។ ផ្អែកតាមផែនការ ការអង្កេតនេះនឹងត្រូវអនុវត្តក្នុងឆ្នាំ២០២៨។

**ការអង្កេតសមត្ថភាព**

ការវាយតម្លៃការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិមានគោលបំណងសិក្សា តាមដានអំពីការផ្លាស់ប្តូរឥរិយាបថរបស់បុគ្គលិក និងប្រព័ន្ធនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិធៀបនឹងទិន្នន័យដើមគ្រានៃសមត្ថភាពដែលបានកំណត់ក្នុងឆ្នាំ២០២៥។ ផ្អែកតាមផែនការ ការអង្កេតនេះនឹងត្រូវអនុវត្តក្នុងឆ្នាំ២០២៩។

**ការវាយតម្លៃគោលនយោបាយ**

លេខាធិការដ្ឋាន គ.ជ.អ.ប. ដែលជាសេនាធិការជូន គ.ជ.អ.ប. មានតួនាទីក្នុងការវាយតម្លៃគោលនយោបាយនានាដែលរួមបញ្ចូលច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងនីតិវិធីនានាក្នុងក្របខ័ណ្ឌកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីជាមូលដ្ឋានក្នុងការលើកកម្ពស់ប្រសិទ្ធភាពនៃការរៀបចំ និងការអនុវត្តគោលនយោបាយទាំងនោះ ព្រមទាំងធានាការសម្រេចបាននូវគោលបំណង និងលទ្ធផលនានាដែលបានកំណត់។ ការវាយតម្លៃនេះ ផ្តោតលើផ្នែកសំខាន់ៗមួយចំនួន ដូចជាកិច្ចដំណើរការរៀបចំតាក់តែងគោលនយោបាយ លទ្ធផលនៃការរៀបចំតាក់តែងគោលនយោបាយ គុណភាពនៃគោលនយោបាយដែលបានដាក់ចេញ ការអនុវត្តគោលនយោបាយ និងប្រសិទ្ធភាពនៃគោលនយោបាយ។ ការវាយតម្លៃគោលនយោបាយត្រូវអនុវត្តឱ្យបានទៀងទាត់ជារៀងរាល់ឆ្នាំ។

ឃ. ការសិក្សាដែលមានលក្ខណៈជាការវាយតម្លៃ និងការស្រាវជ្រាវ

ដើម្បីលើកកម្ពស់ការយល់ដឹងអំពីវឌ្ឍនភាព និងផលប៉ះពាល់នៃ កជទី២ ការសិក្សាដែលមានលក្ខណៈជាការវាយតម្លៃ និងការស្រាវជ្រាវមួយចំនួនត្រូវផ្តួចផ្តើមរៀបចំ និងអនុវត្តបន្ថែមលើការវាយតម្លៃដែលបានកំណត់ខាងលើ។ លេខាធិការដ្ឋាន គ.ជ.អ.ប. ត្រូវរៀបចំអភិវឌ្ឍជំនាញស្តីពីការរៀបចំតាក់តែងការសិក្សា និងការស្រាវជ្រាវដល់មន្ត្រីជំនាញរបស់ខ្លួន ព្រមទាំងត្រូវសម្របសម្រួល និងអនុវត្តការសិក្សា និងស្រាវជ្រាវដោយផ្ទាល់ ឬដោយមានជំនួយបច្ចេកទេសពីខាងក្រៅ ផ្អែកលើគោលបំណង វិសាលភាព និងកម្រិតជំនាញដែលត្រូវការសម្រាប់កិច្ចការនេះ។

### ២.៧. ផែនការសកម្មភាព និងថវិកាសម្រាប់ការត្រួតពិនិត្យ និងការវាយតម្លៃ

នៅក្នុងអំឡុងពេលចាប់ផ្តើមអនុវត្ត ផអ៥ទី២ លេខាធិការដ្ឋាន គ.ជ.អ.ប. ត្រូវរៀបចំ និងអនុម័ត ផ.ស.ថ. ស្តីពីការត្រួតពិនិត្យ និងការវាយតម្លៃរយៈពេល០៥ឆ្នាំ និងប្រចាំឆ្នាំនៃ ផអ៥ទី២ ដោយកំណត់អំពីសកម្មភាព ក្របខ័ណ្ឌពេលវេលា និងថវិកាសម្រាប់អនុវត្តការត្រួតពិនិត្យ និងការវាយតម្លៃនីមួយៗ រួមបញ្ចូលទាំងការពិនិត្យកែសម្រួល និងរៀបចំសៀវភៅណែនាំ និងសេចក្តីណែនាំនានាស្តីពីការត្រួតពិនិត្យ និងការវាយតម្លៃរបស់ គ.ជ.អ.ប. ជំហាន វិធីសាស្រ្ត និងឧបករណ៍សម្រាប់ការត្រួតពិនិត្យ និងការវាយតម្លៃ ស្ថាប័នទទួលខុសត្រូវ និងស្ថាប័នចូលរួមអនុវត្តការត្រួតពិនិត្យ និងការវាយតម្លៃ ព្រមទាំងតម្រូវការនានានៃការអភិវឌ្ឍសមត្ថភាព ឬការជ្រើសរើសបុគ្គលិកដែលមានជំនាញច្បាស់លាស់ក្នុងការត្រួតពិនិត្យ និងការវាយតម្លៃជាដើម។

## ៣. ការគ្រប់គ្រងហានិភ័យ

លទ្ធផលរំពឹងទុកនានានៃ ផអ៥ទី២ មានទំនាក់ទំនង និងពឹងអាស្រ័យគ្នាទៅវិញទៅមក និងត្រូវអនុវត្តដោយក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិដោយមានការចូលរួមពីអង្គការសង្គមស៊ីវិល វិស័យឯកជន និងភាគីពាក់ព័ន្ធនានាដែលមានតួនាទី ភារកិច្ច និងការទទួលខុសត្រូវផ្សេងៗគ្នា។ ដើម្បីជានាការសម្រេចបានលទ្ធផលរំពឹងទុកទាំងនេះ ផអ៥ទី២ បានកំណត់នូវហានិភ័យសំខាន់ៗមួយចំនួន និងវិធានការសម្រាប់កាត់បន្ថយហានិភ័យទាំងនេះ ដូចមានបរិយាយតាមសមាសភាគក្នុងតារាងខាងក្រោម ៖

## តារាង÷ការគ្រប់គ្រងហានិភ័យ

| ល.រ. | ហានិភ័យ | ផលប៉ះពាល់ | លទ្ធភាពកើតមាន | វិធានការកាត់បន្ថយ |
|---|---|---|---|---|
| **សមាសភាគទី១៖ ការដឹកនាំ និងការសម្របសម្រួលការងារកំណែទម្រង់** | | | | |
| ១ | ការបន្តបង្កសង្គ្រាមដោយភាគីថៃនៅតាមតំបន់ព្រំដែនរវាងកម្ពុជា-ថៃដែលប៉ះពាល់ជាអវិជ្ជមានដល់ការអនុវត្តគោលនយោបាយកំណែទម្រង់នៅក្នុងតំបន់ទាំងនោះ ជាពិសេសការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានជូនប្រជាពលរដ្ឋ | ខ្ពស់ | មធ្យម | - ពិនិត្យ និងកែសម្រួលថវិកាប្រចាំឆ្នាំសម្រាប់អនុវត្ត ផអ៥ទី២ នៃរដ្ឋបាលថ្នាក់ក្រោមជាតិជាប់ព្រំដែន ដើម្បីគាំទ្រជនភៀសសឹក<br>- ពិនិត្យ និងកែសម្រួលថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលទទួលផលប៉ះពាល់ដោយសារសង្គ្រាមដោយផ្តោតលើការផ្តល់សេវា ការអភិវឌ្ឍមូលដ្ឋាន និងការងារសង្គ្រោះបន្ទាន់ ដើម្បីគាំទ្រជនភៀសសឹក<br>- កៀរគរធនធានពីដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងសប្បុរសជននានា ដើម្បីគាំទ្រការងារសង្គ្រោះបន្ទាន់ |
| ២ | វិបត្តិសេដ្ឋកិច្ចសកលបង្កឡើងដោយសង្គ្រាម និងគោលនយោបាយពន្ធ នាំឱ្យថយចុះកំណើនសេដ្ឋកិច្ចកម្ពុជា និងជាលទ្ធផលនាំឱ្យខ្វះថវិកាសម្រាប់អនុវត្តការងារកំណែទម្រង់ | ខ្ពស់ | ទាប | - ពិនិត្យ និងកែសម្រួលថវិកាប្រចាំឆ្នាំសម្រាប់អនុវត្ត ផអ៥ទី២ ដោយផ្តោតលើសកម្មភាពជាអាទិភាព និងមានភាពចាំបាច់បំផុត<br>- ផ្អាក ឬពន្យារពេលការអនុវត្តសកម្មភាពតាមការចាំបាច់ |
| ៣ | ធនធានថវិកាមិនត្រូវបានផ្តល់គ្រប់គ្រាន់សម្រាប់អនុវត្តនូវសកម្មភាពស្នូលនៃការងារកំណែទម្រង់ | ខ្ពស់ | ទាប | - លេខាធិការដ្ឋាន គ.ជ.អ.ប. សហការជិតស្និទ្ធជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីត្រួតពិនិត្យ និងគាំទ្រក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការរៀបចំ និងអនុវត្ត ផ.ស.ថ. របស់ស្ថាប័នអនុវត្តនីមួយៗ<br>- បន្តកៀរគរធនធានពីដៃគូអភិវឌ្ឍន៍សម្រាប់គាំទ្រដល់កិច្ចការ ឬគម្រោងដែលមានការលំបាកក្នុងការប្រើប្រាស់ថវិការដ្ឋ |
| ៤ | ការសម្របសម្រួល និងសហការគ្នាមិនបានល្អ និងជិតស្និទ្ធនៃកម្មវិធីកំណែទម្រង់អភិបាលកិច្ច និងកំណែទម្រង់វិស័យនានានាំឱ្យការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការពុំមានប្រសិទ្ធភាព | ខ្ពស់ | ទាប | - ពង្រឹងការសម្របសម្រួល និងសហការរវាងកម្មវិធីកំណែទម្រង់អភិបាលកិច្ច និងកំណែទម្រង់វិស័យនានា តាមរយៈការពង្រឹងកិច្ចប្រជុំប្តូរវេនរវាងលេខាធិការដ្ឋាននៃកម្មវិធីកំណែទម្រង់នានា |

| ល.រ. | ហានិភ័យ | ផលប៉ះពាល់ | លទ្ធភាពកើតមាន | វិធានការកាត់បន្ថយ |
|---|---|---|---|---|
| | | | | - ពង្រឹងការចុះតាមដានរួមគ្នានៅមូលដ្ឋាន ដើម្បីពិនិត្យវឌ្ឍនភាព និងបញ្ហាប្រឈមជាក់ស្តែងនៃការអនុវត្តគោលនយោបាយ និងលិខិតបទដ្ឋាននានាដែលបានដាក់ចេញ |
| **សមាសភាគទី២៖ រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ** | | | | |
| ១ | ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុកពុំមានសិទ្ធិអំណាច និងស្វ័យភាពពេញលេញក្នុងការអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួន នឹងនាំឲយចុះនូវប្រសិទ្ធភាព និងតម្លាភាពនៃការអនុវត្តប្រព័ន្ធអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ ព្រមទាំងកាត់បន្ថយប្រសិទ្ធភាពនៃបំពេញការងារ ការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋានរបស់<br>រដ្ឋបាលថ្នាក់ក្រោមជាតិ | មធ្យម | ខ្ពស់ | - តាមដាន និងពង្រឹងការអនុវត្តលិខិតបទដ្ឋាននានាស្តីពីការបំពេញតួនាទី ភារកិច្ច ទំនាក់ទំនងការងារ និងគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>- រៀបចំវគ្គរំលឹកឡើងវិញអំពីលិខិតបទដ្ឋាននានាដែលពាក់ព័ន្ធនឹងការបំពេញតួនាទី ភារកិច្ចទំនាក់ទំនងការងារ និងគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>- រៀបចំ និងកំណត់កញ្ចប់ថវិកាច្បាស់លាស់របស់ក្រុមប្រឹក្សានៅក្នុងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ |
| ២ | ភាពមិនជោគជ័យនៃយុទ្ធសាស្ត្រឌីជីថលដោយសារការកំណត់នីតិវិធីរដ្ឋបាលមិនច្បាស់លាស់ និងការខ្វះធនធាន និងបុគ្គលិកដែលមានសមត្ថភាពសមស្របរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | មធ្យម | មធ្យម | - ពិនិត្យ និងកែសម្រួលនីតិវិធីរដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យបានច្បាស់លាស់<br>- រៀបចំការបណ្តុះបណ្តាលដែលមានលក្ខណៈជាប្រព័ន្ធដល់មន្ត្រីនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការបញ្ជ្រាបចំណេះដឹងអំពីបច្ចេកវិទ្យាព័ត៌មាន និងអភិបាលកិច្ចឌីជីថលទៅក្នុងការបណ្តុះបណ្តាលដំបូងចំពោះបុគ្គលិកដែលចូលបម្រើការងារថ្មី<br>- ពិនិត្យ និងកំណត់ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីកែលម្អឧបករណ៍ និងហេដ្ឋារចនាសម្ព័ន្ធនៃប្រព័ន្ធព័ត៌មានវិទ្យានៅរដ្ឋបាលថ្នាក់ក្រោមជាតិ |
| ៣ | យន្តការ និងប្រព័ន្ធអធិការកិច្ច និងសវនកម្មនៃរដ្ឋបាលថ្នាក់ក្រោមជាតិមិនត្រូវបានបង្កើត និងអនុវត្តជាប្រព័ន្ធនាំឱ្យកាត់បន្ថយប្រសិទ្ធភាពគុណភាព និងតម្លាភាពនៃការបំពេញការងារ ការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | មធ្យម | មធ្យម | - គ.ជ.អ.ប. ដឹកនាំ សម្របសម្រួល និងពិភាក្សាអំពីជម្រើសសមស្របសម្រាប់ការរៀបចំ និងការដាក់ចេញនូវយន្តការ និងប្រព័ន្ធអធិការកិច្ច និងសវនកម្មទៅលើរដ្ឋបាលថ្នាក់ក្រោមជាតិ។ |

| ល.រ. | ហានិភ័យ | ផលប៉ះពាល់ | លទ្ធភាពកើតមាន | វិធានការកាត់បន្ថយ |
|---|---|---|---|---|
| **សមាសភាគទី៣៖ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស** | | | | |
| ១ | បញ្ហាកង្វះបុគ្គលិករបស់រដ្ឋបាលក្រុង ស្រុកសម្រាប់អនុវត្តមុខងារដែលបានផ្ទេរពីថ្នាក់ជាតិមិនត្រូវបានដោះស្រាយនាំឱ្យគេមើលឃើញថា ការបង្កើតរដ្ឋបាលក្រុង ស្រុកជារដ្ឋបាលមូលដ្ឋាននៅក្រោមគោលការណ៍រដ្ឋបាលឯកភាពមិនដំណើរការ និងមិនមានសារសំខាន់ | ខ្ពស់ | ខ្ពស់ | - គ.ជ.អ.ប. និងក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវផ្តោតការយកចិត្តទុកដាក់ និងផ្តល់អាទិភាពក្នុងការដោះស្រាយបញ្ហាកង្វះបុគ្គលិក និងធនធាននៅថ្នាក់ក្រុង ស្រុកឱ្យបានឆាប់ |
| ២ | សិទ្ធិអំណាចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រងបុគ្គលិកមិនអាចអនុវត្តបានតាមគោលការណ៍ និងលិខិតបទដ្ឋានដែលបានកំណត់ | មធ្យម | មធ្យម | - ពង្រឹងការអនុវត្តគោលការណ៍ និងបទបញ្ញត្តិដែលបានកំណត់<br>- ពង្រឹងការតាមដាន និងការអនុវត្តរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការជ្រើសរើស និងរៀបចំបុគ្គលិក |
| ៣ | ថ្នាក់ដឹកនាំរដ្ឋបាលថ្នាក់ក្រោមជាតិយកចិត្តទុកដាក់មិនបានពេញលេញក្នុងការបង្កើនចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រង និងតុល្យភាពស្ត្រីក្នុងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ | ខ្ពស់ | មធ្យម | - រៀបចំវគ្គបណ្តុះបណ្តាលដោយឡែកសម្រាប់បុគ្គលិកជាស្ត្រី និងក្រុមជនងាយរងគ្រោះដែលមានសក្តានុពលសម្រាប់បំពេញមុខតំណែងគ្រប់គ្រង<br>- ពង្រឹងលក្ខខណ្ឌនៃការជ្រើសរើស និងការតែងតាំងបំពេញមុខតំណែងទំនេរ និងមុខតំណែងថ្មីដោយផ្តល់អាទិភាពដល់ស្ត្រី និងក្រុមជនងាយរងគ្រោះ<br>- បញ្ចូលសមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គមក្នុងវគ្គបណ្តុះបណ្តាលអំពីភាពជាអ្នកដឹកនាំ<br>- ពង្រឹងការអនុវត្តផែនការយុទ្ធសាស្ត្រស្តីពីការបង្កើនចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ (២០២៤-២០២៨) |
| ៤ | ខ្វះការអភិវឌ្ឍសមត្ថភាព និងការគាំទ្រពីក្រសួង ស្ថាប័ន និងមន្ទីរ អង្គភាពជំនាញដល់បុគ្គលិកវិស័យនានាដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក នាំឱ្យការអនុវត្តមុខងារនានាដែលបានផ្ទេរពុំមានប្រសិទ្ធភាព | ខ្ពស់ | មធ្យម | - ក្រសួង ស្ថាប័នដែលបានផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រុង ស្រុក ត្រូវណែនាំឱ្យមន្ទីរ អង្គភាពជំនាញដែលជាខ្សែបណ្តោយរបស់ខ្លួនពង្រឹងការត្រួតពិនិត្យ ការអភិវឌ្ឍសមត្ថភាព និងការគាំទ្របុគ្គលិកវិស័យនៃរដ្ឋបាលក្រុង ស្រុក |

| ល.រ. | ហានិភ័យ | ផលប៉ះពាល់ | លទ្ធភាពកើតមាន | វិធានការកាត់បន្ថយ |
|---|---|---|---|---|
| | | | | - ក្រសួង ស្ថាប័ន និងមន្ទីរ អង្គភាពជំនាញពង្រឹងការអភិវឌ្ឍសមត្ថភាព និងការគាំទ្ររដ្ឋបាលក្រុង ស្រុកក្នុងការអនុវត្តមុខងារដែលបានផ្ទេរ<br>- វិភាជ និងបញ្ចូលសកម្មភាព និងថវិការបស់មន្ទីរ អង្គភាពជំនាញនានាពាក់ព័ន្ធនឹងការអភិវឌ្ឍសមត្ថភាព និងការគាំទ្ររដ្ឋបាលក្រុង ស្រុកក្នុង ផ.ស.ថ. របស់រាជធានី ខេត្ត |
| ៥ | រដ្ឋបាលថ្នាក់ក្រោមជាតិមិនសូវយកចិត្តទុកដាក់ និងផ្តល់អាទិភាពក្នុងការអភិវឌ្ឍសមត្ថភាពបុគ្គលិករបស់ខ្លួនជាប្រចាំ | ខ្ពស់ | ទាប | - ពង្រឹង និងរៀបចំក្រុមអភិវឌ្ឍន៍សមត្ថភាពតាមរាជធានី ខេត្តនីមួយៗ ដើម្បីអភិវឌ្ឍសមត្ថភាពដល់មន្ត្រីរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់<br>- ពង្រឹងការរៀបចំ និងអនុវត្តផែនការអន្តរាគមន៍អភិវឌ្ឍសមត្ថភាពនៅថ្នាក់រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ<br>- ណែនាំរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យវិភាជថវិកាជាក់លាក់ និងក្នុងចំនួនសមស្រប ដើម្បីអភិវឌ្ឍសមត្ថភាពបុគ្គលិករបស់ខ្លួន<br>- ត្រួតពិនិត្យ និងវាយតម្លៃជាប្រចាំលើការអនុវត្តសកម្មភាពអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ |
| ៦ | សាលាជាតិរដ្ឋបាលមូលដ្ឋានពុំមានជំនាញគ្រប់គ្រាន់ក្នុងការរៀបចំ និងអនុវត្តកម្មវិធីបណ្តុះបណ្តាលអំពីជំនាញបច្ចេកទេសនៃវិស័យនានាដែលបានផ្ទេរមុខងារទៅឱ្យរដ្ឋបាលក្រុង ស្រុក | ខ្ពស់ | មធ្យម | - ពង្រឹងកិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានាក្នុងការរៀបចំ និងអនុវត្តវគ្គបណ្តុះបណ្តាលនានាដល់រដ្ឋបាលក្រុង ស្រុក<br>- ពង្រឹងសមត្ថភាពគ្រូនៃសាលាជាតិរដ្ឋបាលមូលដ្ឋានលើជំនាញវិស័យនានា។ |
| **សមាសភាគទី៤៖ វិមជ្ឈការហិរញ្ញវត្ថុ និងប្រព័ន្ធផែនការនិងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ** | | | | |
| ១ | រដ្ឋបាលក្រុង ស្រុក ខណ្ឌមិនត្រូវបានផ្តល់ថវិកាគ្រប់គ្រាន់សម្រាប់អនុវត្តមុខងារថ្មីៗនានាដែលបានផ្ទេរពីក្រសួង ស្ថាប័នប្រកបដោយប្រសិទ្ធភាព | ខ្ពស់ | មធ្យម | - លេខាធិការដ្ឋាន គ.ជ.អ.ប. និងក្រសួងមហាផ្ទៃត្រូវបន្តធ្វើការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីស្វែងយល់រួមគ្នាពីផលប៉ះពាល់អវិជ្ជមានដោយសារហានិភ័យនេះ<br>- ការកំណត់ឱ្យបានច្បាស់លាស់នូវមុខងារជាកាតព្វកិច្ច និងមុខងារជាជម្រើសនៅក្នុងចំណោមមុខងារដែលបានផ្ទេររួចហើយទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ |

| ល.រ. | ហានិភ័យ | ផលប៉ះពាល់ | លទ្ធភាពកើតមាន | វិធានការកាត់បន្ថយ |
|---|---|---|---|---|
| ២ | ការបង្កើតយន្តការ និងប្រព័ន្ធផ្សេងៗគ្នាជាច្រើន ដើម្បីផ្ទេរធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិដែលបង្កឱ្យមានការចំណាយបន្ថែមច្រើន និងពុំមានសង្គតិភាពជាមួយនឹងគោលការណ៍នៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ | ខ្ពស់ | ខ្ពស់ | - កាត់បន្ថយឱ្យបានជាអតិប្បរមានូវការប្រើប្រាស់យន្តការចំពោះកិច្ចនានាពាក់ព័ន្ធនឹងការផ្ទេរធនធាន<br>- ធានាថាគោលបំណងជាទូទៅមួយនៃការបង្កើតប្រព័ន្ធផ្ទេរធនធានអន្តររដ្ឋបាលមួយត្រូវបានកំណត់ឱ្យបានច្បាស់លាស់ និងមានលក្ខណៈសាមញ្ញ |
| ៣ | ការរៀបចំ និងដាក់ចេញនូវលិខិតបទដ្ឋាននានាពាក់ព័ន្ធនឹងការកែទម្រង់ហិរញ្ញវត្ថុសាធារណៈមិនមានសង្គតិភាពជាមួយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងកម្មវិធីកំណែទម្រង់ផ្សេងទៀត | ខ្ពស់ | មធ្យម | - ពង្រឹងការសម្របសម្រួល និងសហការជាប្រចាំរវាងកម្មវិធីកំណែទម្រង់អភិបាលកិច្ច និងកំណែទម្រង់វិស័យនានា តាមរយៈលេខាធិការដ្ឋានរបស់កម្មវិធីកំណែទម្រង់នីមួយៗ<br>- ពិនិត្យ និងកំណត់បញ្ហាប្រឈមជាអាទិភាព ដើម្បីពិភាក្សា និងដោះស្រាយក្នុងកិច្ចប្រជុំ គ.ជ.អ.ប.។ |
| **សមាសភាគទី៥៖ ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន** | | | | |
| ១ | រដ្ឋបាលក្រុង ស្រុក ខណ្ឌមិនមានថវិកាគ្រប់គ្រាន់សម្រាប់អនុវត្តមុខងារថ្មីៗនានាដែលបានផ្ទេរពីក្រសួង ស្ថាប័ន ប្រកបដោយប្រសិទ្ធភាព | ខ្ពស់ | មធ្យម | - លេខាធិការដ្ឋាន គ.ជ.អ.ប. ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងស្ថាប័នពាក់ព័ន្ធនានា ដើម្បីដោះស្រាយបញ្ហាកង្វះថវិកាសម្រាប់អនុវត្តមុខងារវិស័យនានា (លើកលែងវិស័យអប់រំ និងសុខាភិបាល)<br>- កំណត់ឱ្យបានច្បាស់លាស់នូវមុខងារជាកាតព្វកិច្ច និងមុខងារជាជម្រើសនៅក្នុងចំណោមមុខងារដែលបានផ្ទេររួចហើយទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ |
| ២ | រដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌខ្វះមន្ត្រីបច្ចេកទេសសម្រាប់ជួយគាំទ្រក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ក្នុងការរៀបចំ និងអនុវត្តគម្រោងប្រកបដោយប្រសិទ្ធភាព និងគុណភាព រួមបញ្ចូលការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងគម្រោងទាំងនោះ | មធ្យម | មធ្យម | - លេខាធិការដ្ឋាន គ.ជ.អ.ប. ត្រូវសហការជាមួយក្រសួងមហាផ្ទៃ និងក្រសួងមុខងារសាធារណៈ ដើម្បីដោះស្រាយបញ្ហាខ្វះមន្ត្រីបច្ចេកទេសឱ្យបានឆាប់<br>- លេខាធិការដ្ឋាន គ.ជ.អ.ប. រៀបចំ និងអនុវត្តកម្មវិធីបណ្តុះបណ្តាលដល់មន្ត្រីបច្ចេកទេសថ្នាក់រាជធានី ខេត្តជាប្រចាំដោយសហការជិតស្និទ្ធជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា<br>- សិក្សាអំពីលទ្ធភាពក្នុងការប្រើប្រាស់វិស័យឯកជន ដើម្បីសិក្សា និងរៀបចំគម្រោងមូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់ ដើម្បីដាក់ជូន គ.ជ.អ.ប. ពិនិត្យ និងអនុម័ត |

| ល.រ. | ហានិភ័យ | ផលប៉ះពាល់ | លទ្ធភាពកើតមាន | វិធានការកាត់បន្ថយ |
|---|---|---|---|---|
| ៣ | ខ្វះការត្រួតពិនិត្យ និងគាំទ្រជាប្រចាំដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ក្នុងការរៀបចំ និងអនុវត្តគម្រោងមូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់នាំឱ្យកាត់បន្ថយប្រសិទ្ធភាព គុណភាព និងតម្លាភាពនៃការអនុវត្តគម្រោង | ខ្ពស់ | ខ្ពស់ | - ក្រសួងមហាផ្ទៃត្រូវពង្រឹងការតាមដាន ត្រួតពិនិត្យ និងផ្តល់ការគាំទ្រជាប្រចាំដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ក្នុងការរៀបចំ និងអនុវត្តគម្រោងរបស់ខ្លួន<br>- ពង្រឹងការពិនិត្យឡើងវិញប្រចាំអំពីគម្រោងក្រោយពេលអនុវត្ត និងដោះស្រាយបញ្ហាប្រឈមនានាដែលកើតមានឡើង ដើម្បីពង្រឹងប្រសិទ្ធភាព និងគុណភាពនៃគម្រោង។ |

# ជំពូកទី៤

# ផែនការចំណាយនៃផែនការអនុវត្តរយៈពេលប្រាំឆ្នាំ ដំណាក់កាលទី២

## ៤.១. ការប៉ាន់ស្មានចំណាយសម្រាប់ ផអ៥ទី២

ការប៉ាន់ស្មានចំណាយសរុបនៃ ផអ៥ទី២ ត្រូវបានគណនាដោយផ្អែកលើកិច្ចការនានា សកម្មភាពជាអាទិភាពដែលបានកំណត់នៅក្នុងលទ្ធផលរំពឹងទុកនីមួយៗនៃ ផអ៥ទី២។ ចំណាយប៉ាន់ស្មានទាំងនេះត្រូវពិនិត្យ និងធ្វើបច្ចុប្បន្នភាពប្រចាំឆ្នាំសម្រាប់ជាមូលដ្ឋានក្នុងការរៀបចំ ផ.ស.ថ. ស្តីពីការអនុវត្ត ផអ៥ទី២។

ការប៉ាន់ស្មានចំណាយសម្រាប់ ផអ៥ទី២ រួមមានការចំណាយសម្រាប់ ៖

- ការអនុវត្តសកម្មភាពមានដូចជា ការរៀបចំគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្ត ការអភិវឌ្ឍសមត្ថភាព ការរៀបចំកិច្ចប្រជុំនិងសិក្ខាសាលាផ្សព្វផ្សាយ ការសិក្សាវាយតម្លៃនិងការអង្កេត ការរៀបចំនិងដាក់ឱ្យអនុវត្តនូវរចនាសម្ព័ន្ធនិងប្រព័ន្ធនានា និងចំណាយសម្រាប់ការត្រួតពិនិត្យ និងការវាយតម្លៃ ។ល។
- ការផ្ទេរធនធានហិរញ្ញវត្ថុពីថ្នាក់ជាតិ ដូចជាថវិការាជធានី ខេត្ត មូលនិធិក្រុង ស្រុក មូលនិធិឃុំ សង្កាត់ មូលនិធិមានភ្ជាប់លក្ខខណ្ឌ ថវិកាឧបត្ថម្ភធន ចំណូលចែករំលែកពន្ធរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ។ល។

ចំណាយប៉ាន់ស្មានសរុបរបស់ ផអ៥ទី២ មានចំនួន **៤៣.៦០០.៩៩៦លានរៀល** សមមូលនឹង **១០.៩០០លានដុល្លារអាមេរិក** សម្រាប់រយៈពេល០៥ឆ្នាំចាប់ពីឆ្នាំ២០២៦ ដល់ឆ្នាំ២០៣០ ក្នុងនោះធនធានហិរញ្ញវត្ថុផ្ទេរពីថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានចំនួនជាង៩៧% ដូចបង្ហាញតាមឆ្នាំនៃសមាសភាគនីមួយៗក្នុងតារាងខាងក្រោម។ ជាមធ្យម ការអនុវត្ត ផអ៥ទី២ ត្រូវការថវិកាចំនួន **៨.៧២០.១៩៩លានរៀល** សមមូលនឹង **២.១៨០លានដុល្លារអាមេរិក**ក្នុងមួយឆ្នាំ។

**តារាងប៉ាន់ស្មានចំណាយតាមសមាសភាគ និងតាមឆ្នាំនីមួយៗ (គិតជាលានរៀល)**

| ល.រ. | សមាសភាគ | ថវិកាប៉ាន់ស្មានតាមឆ្នាំ | | | | | |
|---|---|---|---|---|---|---|---|
| | | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | សរុប |
| ១ | ការដឹកនាំ និងការសម្របសម្រួលការងារកំណែទម្រង់ | ១១៨.៦៥២ | ១២២.០៣៨ | ១២៣.១៨៨ | ១២២.៥៣៨ | ១១៩.០៣២ | **៦០៥.៤៤៨** |
| ២ | រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ | ៣.៧៥៥ | ២.៥០៤ | ២.៦៣៣ | ៣.០២៩ | ៣.២៨៨ | **១៥.២០៨** |
| ៣ | ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស | ៤.៩៣០ | ៤.៥១០ | ៤.២៧០ | ៤.៣២០ | ៤.៧៧០ | **២២.៨០០** |
| ៤ | វិមជ្ឈការហិរញ្ញវត្ថុ និងប្រព័ន្ធផែនការនិងថវិកាថ្នាក់ក្រោមជាតិ | ៧.៦៩១.៧៥២ | ៨.១០៩.៧៨៤ | ៨.៥៥៨.១០៥ | ៩.០៣៧.៧០៥ | ៩.៥៥១.៨១០ | ៤២.៩៤៩.១៥៦ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៥ | ការផ្តល់សេវាសាធារណៈ និង ការអភិវឌ្ឍមូលដ្ឋាន | ១.៦៦៤ | ២.១២០ | ១.៧២០ | ១.៥៤០ | ១.៣៤០ | ៨.៣៨៤ |
| សរុប | | ៧.៨២០.៧៥៣ | ៨.២៤០.៩៥៦ | ៨.៦៨៩.៩១៦ | ៩.១៦៩.១៣២ | ៩.៦៨០.២៤០ | ៤៣.៦០០.៩៩៦ |

## ៤.២. ការផ្តល់ហិរញ្ញប្បទានសម្រាប់ ផអ៥ទី២

ភាគច្រើននៃថវិកាប៉ាន់ស្មានសរុបសម្រាប់ការអនុវត្ត ផអ៥ទី២ ដូចបានបង្ហាញនៅក្នុងផ្នែកខាងលើទទួលបានការគាំទ្រពីរាជរដ្ឋាភិបាលដែលបានវិភាជទៅឱ្យស្ថាប័នអនុវត្តនានា រួមមានក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់អនុវត្តសកម្មភាពជាអាទិភាពនានាដែលបានកំណត់ក្នុង ផអ៥ទី២ ស្របតាមតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ខ្លួន។

លេខាធិការដ្ឋាន គ.ជ.អ.ប. ត្រូវសម្របសម្រួល និងសហការជិតស្និទ្ធជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងការណែនាំ និងគាំទ្រស្ថាប័នអនុវត្តនានា ដើម្បីវិភាជថវិកាសម្រាប់ការអនុវត្តសកម្មភាពនានានៃ ផអ៥ទី២ និងដាក់បញ្ចូលថវិកានេះទៅក្នុងផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងថវិកាប្រចាំឆ្នាំរបស់ស្ថាប័នអនុវត្តនីមួយៗ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវធានាថា ថវិកាដែលបានវិភាជដោយក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗសម្រាប់ការអនុវត្តសកម្មភាពនានានៃ ផអ៥ទី២ ត្រូវបានគាំទ្រ និងអនុវត្តប្រកបដោយប្រសិទ្ធភាព។

ក្រៅពីថវិកាដែលគាំទ្រដោយរាជរដ្ឋាភិបាល លេខាធិការដ្ឋាន គ.ជ.អ.ប. នឹងកៀរគរធនធាននានាពីដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងវិស័យឯកជននានា ដើម្បីអនុវត្ត ផអ៥ទី២។ បច្ចុប្បន្ននេះ មានដៃគូអភិវឌ្ឍន៍សំខាន់ៗចំនួន**១២** បានផ្តល់និងគ្រោងថវិកា ដើម្បីគាំទ្រការអនុវត្ត ផអ៥ទី២ តាមរយៈគម្រោង/កម្មវិធីនានាដែលមានថវិកាប៉ាន់ស្មានសរុបចំនួន **៦៦៧.០១៤លានរៀល** សមមូលនឹង **១៦៦,៧៥លានដុល្លារអាមេរិក** ប៉ុន្តែថវិកាទាំងនេះ មិនបានបញ្ចូលក្នុងថវិកាប៉ាន់ស្មានសរុបរបស់ ផអ៥ទី២ ឡើយ ដោយសារគម្រោង/កម្មវិធីមួយចំនួនពុំទាន់មានព័ត៌មានច្បាស់លាស់អំពីថវិការបស់ខ្លួន។

គម្រោង/កម្មវិធីសំខាន់ៗដែលបាននិងគ្រោងគាំទ្រ ផអ៥ទី២ រួមមាន ៖

- គម្រោងរដ្ឋបាលមូលដ្ឋាន និងការប្រែប្រួលអាកាសធាតុដំណាក់កាលទី៣ គាំទ្រថវិកាដោយមូលនិធិអាកាសធាតុបៃតង (GCF)
- គម្រោងលើកកម្ពស់ការផ្តល់សេវានៅថ្នាក់ក្រោមជាតិគាំទ្រមូលនិធិដោយជា GIZ/ISD-II
- គម្រោងលើកកម្ពស់ការងារគណនេយ្យភាពសង្គមគាំទ្រថវិកាដោយថវិកាកញ្ចប់រួម (Trust Fund) តាមរយៈធនាគារពិភពលោក
- គម្រោងបន្សាំនឹងការប្រែប្រួលអាកាសធាតុនៅថ្នាក់មូលដ្ឋានគាំទ្រមូលនិធិដោយ UNCDF
- គម្រោងលើកកម្ពស់វិស័យសេវាសង្គមគាំទ្រមូលនិធិដោយ UNICEF
- គម្រោងលើកកម្ពស់អាហារូបត្ថម្ភនៅកម្ពុជាគាំទ្រមូលនិធិដោយធនាគារពិភពលោក

- គម្រោងអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានដែលធន់នឹងការប្រែប្រួលអាកាសធាតុគាំទ្រមូលនិធិដោយធនាគារពិភពលោក
- គម្រោងការអភិវឌ្ឍធារាសាស្ត្រ និងកសិកម្មដែលធន់នឹងការប្រែប្រួលអាកាសធាតុគាំទ្រមូលនិធិដោយ IFAD
- ការអភិវឌ្ឍសេដ្ឋកិច្ចកសិករខ្នាតតូចដែលធន់នឹងការប្រែប្រួលអាកាសធាតុគាំទ្រមូលនិធិដោយ ADB
- គម្រោងពង្រឹងភាពអង់អាចដល់ស្ត្រីដើម្បីសង្គមធន់ទៅនឹងការប្រែប្រួលអាកាសធាតុគាំទ្រមូលនិធិដោយ UNEP។ល។

**តារាងថវិកាប៉ាន់ស្មាននៃគម្រោង/កម្មវិធី និងតាមឆ្នាំនីមួយៗ (គិតជាលានរៀល)**

| ល.រ. | ឈ្មោះគម្រោង កម្មវិធី | ថវិកាប៉ាន់ស្មានតាមឆ្នាំ | | | | | |
|---|---|---|---|---|---|---|---|
| | | ថ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | សរុប |
| ១ | ការបន្សាំនឹងការប្រែប្រួលអាកាសធាតុនៅថ្នាក់មូលដ្ឋាន | ៥៣៤ | 0 | 0 | 0 | 0 | **៥៣៤** |
| ២ | រដ្ឋបាលមូលដ្ឋាន និងការប្រែប្រួលអាកាសធាតុ ដំណាក់កាលទី៣ | ៥.៥៩៧ | ៨.១១៣ | ៩.៥៩៧ | ៨.១១០ | ៧.៧១៨ | **៣៩.១៣៤** |
| ៣ | អភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានដែលធន់នឹងការប្រែប្រួលអាកាសធាតុ | 0 | ៦៤.000 | ៦៤.000 | ៦៤.000 | ៦៤.000 | **២៥៦.000** |
| ៤ | ការងារគណនេយ្យភាពសង្គមផ្នែកផ្គត់ផ្គង់ | ៣.៦៣៣ | 0 | 0 | 0 | 0 | **៣.៦៣៣** |
| ៥ | ការងារគណនេយ្យភាពសង្គមផ្នែកតម្រូវការ | ១.៩២០ | ៦.៤00 | ៦.៤00 | ៦.៤00 | ៦.៤00 | **២៧.៥២0** |
| ៦ | ការលើកកម្ពស់សេវាសង្គម | ៤.៣៩៩ | 0 | 0 | 0 | 0 | **៤.៣៩៩** |
| ៧ | ការសាងសង់សាលាជាតិរដ្ឋបាលមូលដ្ឋាន | ៧.៥0៩ | 0 | 0 | 0 | 0 | **៧.៥0៩** |
| ៨ | អាហារូបត្ថម្ភនៅកម្ពុជា | ១២.៣៦២ | 0 | 0 | 0 | 0 | **១២.៣៦២** |
| ៩ | ការពង្រឹងភាពអង់អាចដល់ស្ត្រីដើម្បីសង្គមធន់ទៅនឹងការប្រែប្រួលអាកាសធាតុ ដំណាក់កាលទី២ | ១៩២ | 0 | 0 | 0 | 0 | **១៩២** |
| ១០ | ការអភិវឌ្ឍសេដ្ឋកិច្ចកសិករខ្នាតតូចដែលធន់នឹងការប្រែប្រួលអាកាសធាតុ | 0 | ៤៦.៦៦៧ | ៤៦.៦៦៧ | ៤៦.៦៦៧ | ៤៦.៦៦៧ | **១៨៦.៦៦៨** |
| ១១ | ការអភិវឌ្ឍធារាសាស្ត្រ និងកសិកម្មដែលធន់នឹងការប្រែប្រួលអាកាសធាតុ | ៨.៦0២ | ២១.៨១៥ | ២២.៣៨៤ | ២៤.0៤៤ | ៣៤.២១៨ | **១១១.0៦៤** |
| ១២ | ការធ្វើឱ្យប្រសើរឡើងដល់ការផ្តល់សេវាជូនប្រជាពលរដ្ឋ ដំណាក់កាលទី២ | ១៨.000 | 0 | 0 | 0 | 0 | **១៨.000** |
| **សរុប** | | **៦២.៧៤៨** | **១៤៦.៩៩៥** | **១៤៩.0៤៧** | **១៤៩.២២១** | **១៥៩.00៣** | **៦៦៧.0១៤** |

# ជំពូកទី ៥
# សេចក្តីសន្និដ្ឋាន

ផអ៥ទី២ ជាផែនទីបង្ហាញផ្លូវរយៈពេលមធ្យមដ៏សំខាន់បំផុតសម្រាប់ការណែនាំតម្រង់ទិសដល់ការរៀបចំ និងការអនុវត្ត កជទី២ ឱ្យសម្រេចបានគោលដៅ និងគោលបំណងដែលបានកំណត់ ដើម្បីឈានទៅសម្រេចបានចក្ខុវិស័យដែលប្រាថ្នាចង់ឱ្យប្រជាពលរដ្ឋទទួលបានផលប្រយោជន៍ពីសេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានដែលផ្តល់ដោយរដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយបរិយាបន្ន និងសមធម៌សង្គម សំដៅរួមចំណែកសម្រេចគោលបំណងក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមជាតិ និងប្រែក្លាយប្រទេសកម្ពុជាឱ្យទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០។

ដើម្បីធានាការសម្រេចបាននូវគោលដៅ និងគោលបំណងខាងលើ ផអ៥ទី២ បានកំណត់នូវលទ្ធផលរំពឹងទុកជាយុទ្ធសាស្ត្រសំខាន់ៗមួយចំនួនដែលចាត់ទុកជាកត្តាកំណត់នូវភាពជោគជ័យនៃការអនុវត្ត កជទី២ រួមមាន ៖ (១). រដ្ឋបាលក្រុង ស្រុកមានបុគ្គលិកគ្រប់គ្រាន់ និងសមត្ថភាពសម្រាប់បំពេញតួនាទី ភារកិច្ចរបស់ខ្លួន ព្រមទាំងមានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់សម្រាប់អនុវត្តមុខងារវិស័យនានាដែលបានផ្ទេរពីថ្នាក់ជាតិ (២). រដ្ឋបាលខេត្តក្លាយជារដ្ឋបាលមានលក្ខណៈជារដ្ឋបាលតំបន់ និងរដ្ឋបាលរាជធានីក្លាយជារដ្ឋបាលមានលក្ខណៈជាទីក្រុងម៉េត្រូប៉ូលីតែន (៣). ស្ថាប័ននៅថ្នាក់ជាតិជាក់លាក់ត្រូវបានកែលម្អតួនាទី និងការទទួលខុសត្រូវលើការសម្របសម្រួលការគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យកាន់តែមានប្រសិទ្ធភាព (៤). រដ្ឋបាលថ្នាក់ក្រោមជាតិមានផែនការរៀបចំដែនដី ប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីយ៉ាងច្បាស់លាស់សម្រាប់ការរៀបចំនគរូបនីយកម្មប្រកបដោយនិរន្តរភាព (៥). រដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិអំណាចពេញលេញក្នុងការគ្រប់គ្រងបុគ្គលិករបស់ខ្លួនប្រកបដោយប្រសិទ្ធភាព គណនេយ្យភាពផ្អែកតាមផែនការច្បាស់លាស់ និងទាំងចំនួន និងតុល្យភាពនៃបុគ្គលិកស្ត្រីនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានបង្កើន (៦). រដ្ឋបាលថ្នាក់ក្រោមជាតិ ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានាមានសមត្ថភាព និងការយល់ដឹងយ៉ាងទូលំទូលាយអំពី កជទី២ (៧). ចំណូលពន្ធ និងមិនមែនពន្ធសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានបង្កើន (៨). ការផ្តល់សេវារដ្ឋបាលតាមយន្តការច្រកចេញចូលតែមួយត្រូវបានធ្វើទំនើបកម្ម ដើម្បីធានាដល់ការផ្តល់សេវារដ្ឋបាលកាន់តែមានប្រសិទ្ធភាព និង(៩). ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានត្រូវបានលើកកម្ពស់ ដើម្បីផ្តល់ផលប្រយោជន៍ជូនប្រជាពលរដ្ឋកាន់តែមានប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព បរិយាបន្ន និងសមធម៌សង្គមដោយផ្តោតការយកចិត្តទុកដាក់ខ្ពស់លើការពង្រឹងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ ហានិភ័យនៃគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា។

ជាការពិត ដើម្បីធានាការសម្រេចបាននូវលទ្ធផលរំពឹងទុកជាយុទ្ធសាស្ត្រខាងលើ ផអ៥ទី២ ត្រូវអនុវត្តដោយមានកិច្ចសហការ និងការសម្របសម្រួលយ៉ាងជិតស្និទ្ធជាមួយកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ កម្មវិធីកំណែទម្រង់ច្បាប់ កម្មវិធីកំណែទម្រង់

ប្រព័ន្ធយុត្តិធម៌ និងកម្មវិធីកំណែទម្រង់តាមវិស័យនានា ព្រមទាំងការពង្រឹងការចូលរួមក្នុងភាពជាដៃគូជាមួយដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងវិស័យឯកជននានាក្នុងការបង្កើតនូវប្រព័ន្ធអភិបាលកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលមានលក្ខណៈទំនើប ស្វ័យភាព តម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងមានការឆ្លើយតប។

មេរៀនបទពិសោធន៍នៃការអនុវត្ត កជទី១ បានបង្ហាញយ៉ាងច្បាស់ថា កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការត្រូវអនុវត្តជាជំហានៗប្រកបដោយការប្រុងប្រយ័ត្នដោយមានការពិភាក្សា ការពិគ្រោះយោបល់ និងការស្រុះស្រួលគ្នា មានភាពច្បាស់លាស់ និងមានការតាំងចិត្តយ៉ាងមោះមុតពីថ្នាក់ដឹកនាំនៃក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងត្រូវអនុវត្តដោយមានកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយកម្មវិធីកំណែទម្រង់អភិបាលកិច្ចដទៃទៀត។ អាស្រ័យហេតុនេះ ផអ៥ទី២ នឹងបន្តយកចិត្តទុកដាក់លើការពង្រឹងការដឹកនាំ និងការសម្របសម្រួលការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការជាមួយកម្មវិធីកំណែទម្រង់ផ្សេងទៀត ដើម្បីធានាដល់ការសម្រេចបាននូវសមិទ្ធផល និងលទ្ធផលរំពឹងទុកនានាដែលបានកំណត់ក្នុង ផអ៥ទី២ ជាពិសេសការដោះស្រាយបញ្ហាធនធានមនុស្ស ការបង្កើនសមត្ថភាព និងធនធានហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុកឱ្យបានគ្រប់គ្រាន់សម្រាប់អនុវត្តមុខងារនានាដែលបានផ្ទេរពីថ្នាក់ជាតិប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។

ជាមួយគ្នានេះដែរ ផអ៥ទី២ បានកំណត់នូវលទ្ធផលរំពឹងទុកដោយមានសូចនាករ ចំណុចដៅ និងស្ថាប័នទទួលខុសត្រូវជាក់លាក់ និងថវិកាប៉ាន់ស្មានដែលត្រូវការសម្រាប់លទ្ធផលរំពឹងទុកនីមួយៗ។ អាស្រ័យហេតុនេះ ស្ថាប័នទទួលខុសត្រូវទាំងអស់ត្រូវមានថវិកាគ្រប់គ្រាន់ ដើម្បីអនុវត្តសកម្មភាពជាអាទិភាពនានាដែលស្ថាប័នទទួលខុសត្រូវដូចបានកំណត់ក្នុង ផអ៥ទី២ សំដៅសម្រេចបាននូវលទ្ធផលរំពឹងទុកនានា និងគោលដៅដែលបានកំណត់។

គ.ជ.អ.ប. មានជំនឿជឿជាក់ថា ផអ៥ទី២ នឹងនាំមកនូវសមិទ្ធផលជាច្រើនបន្ថែមទៀតសម្រាប់កំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិសំដៅសម្រេចបានចក្ខុវិស័យរបស់ កជទី២ គឺ "**ប្រជាពលរដ្ឋទទួលបានផលប្រយោជន៍ពីសេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានដែលផ្តល់ដោយរដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយបរិយាបន្ន និងសមធម៌សង្គម**"។




រៀបចំដោយ៖

សហការបោះពុម្ពដោយ៖

កិច្ចសហប្រតិបត្តិការ អាល្លឺម៉ង់
DEUTSCHE ZUSAMMENARBEIT
Schweizerische Eidgenossenschaft
Confédération suisse
Confederazione Svizzera
Confederaziun svizra
Swiss Agency for Development and Cooperation SDC
LUXEMBOURG AID & DEVELOPMENT
អនុវត្តដោយ giz

ទាញយកឯកសារ